ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សេចក្តីណែនាំប្រតិបត្តិ
# យុទ្ធសាស្ត្រ
# សហគមន៍សាលារៀន

ឧសភា ២០២១

# មាតិកា


សេចក្តីផ្តើម ..... 1
៣ឆ្នាំនៃការឆ្លងកំណាត់ផ្លូវធ្វើដំណើរដែលគ្មានផ្លូវ ..... 1
ទិដ្ឋភាពទូទៅនៃការអនុវត្តវិមជ្ឈការអប់រំ ..... 2
*កត្តានាំមកនូវភាពជោគជ័យក្នុងដំណើរការសាលារៀន* ..... 3
*សហគមន៍ដឹងថាអ្វីប្រាកដចង់បានតែនៅមិនទាន់បាន* ..... 4
*សហគមន៍និងមន្ត្រីអប់រំកំណត់អត្តចរិតថា «ការលំបាកដែលមិនបាច់ដោះស្រាយ»* ..... 4
*សហគមន៍ជឿជាក់ថាគេត្រូវការនូវវប្បធម៌សាលារៀនសព្វគ្រប់ដូចខាងក្រោម* ..... 5
*ភាពជាក់ស្តែងនិងទ្រឹស្តីនៃអំណាចរដ្ឋបាលនិងហិរញ្ញវត្ថុ* ..... 5
*សាលារៀនយល់ឃើញថាសក្តានុពលសហគមន៍ដែលមាននៅមិនទាន់បានប្រើអស់លទ្ធភាព* ..... 5
ទិដ្ឋភាពទូទៅក្របខណ្ឌយុទ្ធសាស្ត្រសហគមន៍សាលារៀន ..... 8
ការចាប់ផ្តើមនូវរបត់ថ្មីនៃការកសាងសង្គមមួយដែលគ្រប់គ្នាចង់បាន ..... 8
ចក្ខុវិស័យសហគមន៍សាលារៀន ..... 8
១ បេសកកម្ម ..... 8
២ គោលបំណង ..... 8
៣ យុទ្ធសាស្ត្រនិងការផ្លាស់ប្តូរ ..... 8
៤ វប្បធម៌សហគមន៍សាលារៀន ..... 9
៥ គុណតម្លៃសហគមន៍សាលារៀន ..... 10
ប្រព័ន្ធផ្តល់លទ្ធភាពអនុវត្ត ..... 10
១ រចនាសម្ព័ន្ធ ..... 10
២ តួនាទី និងយុទ្ធសាស្ត្រ ..... 11
៣ តួនាទី និងស្តង់ដាសហគមន៍សាលារៀន ..... 11
៤ ស្តង់ដាសហគមន៍សាលារៀន និងការវាយតម្លៃ ..... 17
៥ ការគ្រប់គ្រងហិរញ្ញវត្ថុ និងលទ្ធកម្ម (ត្រូវបញ្ចូលខ្លឹមបន្ថែមពីក្រុមការងារហិរញ្ញវត្ថុ) ..... 23
៦ កម្មវិធីធានារ៉ាប់រងសង្គម និងអភិវឌ្ឍសមត្ថភាព ..... 27
ប្រព័ន្ធផ្តល់អំណាច ..... 31
១ ក្របខ័ណ្ឌផលសម្រេចរយៈពេល៦ឆ្នាំ ..... 31
២ ការគ្រប់គ្រងនិងការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀនជាដំណាក់កាល ..... 33
ឆ្នាំទី១ ការធ្វើឱ្យសាលារៀន និងថ្នាក់រៀនមានដំណើរការសម្រាប់ផលសម្រេចអប់រំ និងការសិក្សារៀនសូត្រ ..... 33
១- វត្ថុបំណង ..... 33

២- ការធានាសិស្សថ្នាក់ទី៦ទាំងអស់ចូលរៀន ..... 33
៣- អនុវត្តការធ្វើផែនការសាលារៀនសម្រាប់ការសិក្សារៀនសូត្រ ..... 34
៤- ការសាងសង់ការទាមទារដើម្បីកសាងកិច្ចសន្យាសង្គម ..... 76
៥- ការពិនិត្យតាមដាន ការបង្រៀននិងការសិក្សារៀនសូត្រ ..... 80
៦- ការពិនិត្យឡើងវិញចុងឆ្នាំនិងត្រៀមសម្រាប់ការធ្វើផែនការឆ្នាំបន្ទាប់ ..... 97
ឆ្នាំទី២៖ ការធ្វើឱ្យសាលារៀនបំពេញបានស្តង់ដាអប្បបរមាយុទ្ធសាស្ត្រសហគមន៍សាលារៀន ..... 115
១- វត្ថុបំណង ..... 115
២- ការធ្វើផែនការសាលារៀនបំពេញស្តង់ដាអប្បបរមា ..... 116
៣- ការអនុវត្តការគ្រប់គ្រងការអនុវត្តការងារគ្រូបង្រៀននិងនាយកសាលា ..... 130
៤- ពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តរបស់សាលារៀនផ្អែកតាមទិន្នន័យជឿជាក់បាន ..... 142
៥- រំលែកព័ត៌មានពីលទ្ធផលសម្រេចបានសម្រាប់កសាងគណនេយ្យភាព ..... 143
ឆ្នាំទី៣ ឆ្ពោះទៅរកការរក្សានិរន្តរភាពសាលារៀនជាមួយកម្មវិធីបំណិនរកចំណូល ..... 144
១- វត្ថុបំណង ..... 144
២- ការកំណត់ក្រុមគោលដៅឆ្នាំទី៣បំពេញបាននូវក្រុមគោលដៅគ្រោងឆ្នាំទី៣ ..... 144
៣- ការធ្វើផែនការបំពេញស្តង់ដាសាលារៀនមានប្រសិទ្ធភាព ..... 153
៤ អនុវត្តកម្មវិធីបំណិនរកចំណូលនៅសាលារៀន ..... 158
៥- កសាងនូវការទទួលខុសត្រូវសង្គមរបស់សាលារៀនក្នុងសហគមន៍ ..... 167
៦- ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តរបស់សាលារៀនផ្អែកលើទិន្នន័យជឿជាក់បាន ..... 169
ឆ្នាំទី៤៖ សាលារៀនមានដំណើរការប្រកបដោយនិរន្តរភាព និងច្រើនជាងនេះ ..... 170
១- វត្ថុបំណង ..... 170
២- ធ្វើផែនការសាលារៀនបំពេញបាននូវស្តង់ដាសាលារៀនមានប្រសិទ្ធភាព និងលើសពីនេះ (ឆ្ពោះទៅស្តង់ដាសាលារៀននៃប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់) ..... 170
៣- ការបន្តការសិក្សាទៅមុខទៀតរបស់សិស្ស ..... 172
៤- ការកសាងធនធានមនុស្ស ..... 173
៥- និរន្តរភាពសហគមន៍សាលារៀន ..... 174
ឧបសម្ព័ន្ធ ..... 179

# សេចក្តីថ្លែងអំណរគុណ

ក្នុងនាម ក្រសួងអប់រំ យុវជន និងកីឡា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមការងារអនុវិស័យអប់រំមធ្យមសិក្សាចំណេះទូទៅ ដែលបានចងក្រង **យុទ្ធសាស្ត្រសហគមន៍សាលារៀន** នេះឡើង។ ខ្ញុំសូមថ្លែងអំណរគុណ ឯកឧត្តមបណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន រដ្ឋលេខាធិការ និងជានាយកគម្រោងកែលម្អការអប់រំមធ្យមសិក្សា រួមជាមួយ ឯកឧត្តម កែវ សាក់ ទីប្រឹក្សាក្រសួងអប់រំ យុវជន និងកីឡា, ឯកឧត្តម ឡោ ឆវណ្ណា អគ្គនាយករងអប់រំ និងជាប្រធានគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា, លោកបណ្ឌិត សំអោ អង្គារតន៍ អគ្គនាយករងគោលនយោបាយ និងផែនការ, លោក ព្រីង មរកត ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ, លោក អ៊ិត ជេដ្ឋា អនុប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ, លោកបណ្ឌិត សុខ សូត្រ ព្រឹទ្ធបុរសមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលបានដឹកនាំ និងចូលរួមរៀបចំសៀវភៅប្រតិបត្តិស្តីពី យុទ្ធសាស្ត្រសហគមន៍សាលារៀននេះ។

ការកសាងសៀវភៅនេះក៏មានការចូលរួមផងដែរពីថ្នាក់ដឹកនាំ ថ្នាក់គ្រប់គ្រង មន្ត្រីនៃមហាវិទ្យាល័យអប់រំ និងគណៈគ្រប់គ្រងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មន្ត្រីអប់រំថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងនាយកគ្រឹះស្ថានមធ្យមសិក្សា។ ខ្លឹមសារក្នុងសៀវភៅប្រតិបត្តិនេះ គឺជាលទ្ធផលនៃការខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ជាមួយសាលាមធ្យមសិក្សានានា ក្នុងរយៈពេល៣ឆ្នាំកន្លងមក តាមរយៈការអនុវត្តវិមជ្ឈការអប់រំនៅសាលាមធ្យមសិក្សាគោលដៅទាំង១០០។ មេរៀនពិសោធន៍ដែលមានផលជះវិជ្ជមាន ពីការអនុវត្តជាក់ស្តែង ត្រូវបានយកមកចងក្រងសម្រាប់ជាការឆ្លើយតបទៅនឹងតម្រូវការប្រទេសជាតិនាឆ្នាំ២០៣០ និងឈានឆ្ពោះទៅ២០៥០។

ជាមួយគ្នានេះដែរ ខ្ញុំសូមថ្លែងអំណរគុណចំពោះធនាគារពិភពលោក ក្រោមការដឹកនាំដោយលោក បេង ស៊ីមេត មន្ត្រីជាន់ខ្ពស់ឯកទេសអប់រំ និងសហការី ព្រមទាំងដៃគូអភិវឌ្ឍន៍ដទៃទៀត ដែលបានរួមចំណែកកសាងមេរៀនពិសោធន៍ពីការអនុវត្តវិមជ្ឈការអប់រំ តាមរយៈការគ្រប់គ្រងតាមសាលារៀន រហូតប្រែក្លាយជា យុទ្ធសាស្ត្រសហគមន៍សាលារៀន នេះឡើង។

ថ្ងៃសុក្រ ២រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

## សេចក្តីផ្តើម

យុទ្ធសាស្រ្តស្នូល នៃយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ បានបញ្ជាក់ថា «**ការបង្កើនល្បឿនអភិបាលកិច្ចតាមរយៈការធ្វើវិមជ្ឈការអំណាចទៅមូលដ្ឋាន ក្នុងគោលបំណងធ្វើឱ្យសេវាសាធារណៈអាចបម្រើផលប្រយោជន៍ប្រសើរបំផុតសម្រាប់ប្រជាជន និងការកសាងជាតិ**» ដែលត្រូវបានយកជាក្របខណ្ឌសម្រាប់រៀបចំសៀវភៅប្រតិបត្តិស្តីពី «**យុទ្ធសាស្រ្តសហគមន៍សាលារៀន**» នេះ។ សៀវភៅប្រតិបត្តិនេះជាចំណែកមួយយ៉ាងសំខាន់ក្នុងការអនុវត្តផែនការយុទ្ធសាស្រ្តវិស័យអប់រំឆ្នាំ២០១៩-២០២៣ ជាពិសេសវត្ថុបំណងគោលនយោបាយ ការកែលម្អគុណភាពអប់រំ និងការកសាងសមត្ថភាពដឹកនាំ និងគ្រប់គ្រងអប់រំ។

របាយការណ៍អភិវឌ្ឍសាកលលោកឆ្នាំ២០០៤ ស្តីពីសេវាសាធារណៈ របស់ធនាគារពិភពលោក បានបង្ហាញថា ការឆ្លើយតបនឹងតម្រូវការអប់រំតាមរយៈការសម្រេចចិត្តពីថ្នាក់កណ្តាលតែឯងគឺមិនអាចឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរៀនសូត្ររបស់សិស្សបានឡើយ ដូចនេះវិស័យអប់រំត្រូវផ្ទេរអំណាចទៅសាលារៀននិងសហគមន៍ក្នុងការអនុវត្តសេចក្តីសម្រេចចិត្ត ដើម្បីដោះស្រាយតម្រូវការសិក្សារៀនសូត្រឱ្យបានទាន់ពេលវេលា។ បន្ថែមពីលើនេះទៀត ធនាគារពិភពលោក បានបោះផ្សាយនូវសៀវភៅស្តីពី "ដំណោះស្រាយជាប្រព័ន្ធសម្រាប់វាស់វែងលទ្ធផលអប់រំ" សៀវភៅស្តីពី "ការធ្វើឱ្យសាលារៀនមានដំណើរការ" និង របាយការណ៍អភិវឌ្ឍន៍សាកលលោកឆ្នាំ២០១៨ ស្តីពី "ការសិក្សារៀនសូត្ររបស់សិស្ស" ដែលត្រូវបានយកជាឯកសារសម្អាងក្នុងការ កសាងសៀវភៅណែនាំប្រតិបត្តិ។ ការសិក្សារៀនសូត្រពីស្ថានភាពជាក់ស្តែងកើតឡើងនៅថ្នាក់រៀន និងសាលារៀនក្នុងរយៈពេល៣ឆ្នាំកន្លងមក រួមជាមួយការឆ្លុះបញ្ចាំងទៅនឹងអនុសាសន៍នៃសៀវភៅខាងលើនេះ ក្រុមការងារអនុវិស័យមធ្យមសិក្សា ដោយមានការចង្អុលបង្ហាញផ្លូវពីឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី និងឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋលេខាធិការ បានចងក្រងសៀវភៅប្រតិបត្តិនេះឡើង។ មេរៀនពិសោធន៍ជាក់ស្តែងទាំងនេះមានរៀបរាប់ដូចខាងក្រោម៖

## ៣ឆ្នាំនៃការឆ្លងកំណាត់ផ្លូវធ្វើដំណើរដែលគ្មានផ្លូវ

មុនការអនុវត្តគម្រោងរហូតដល់ឆ្នាំ២០១៩ ពុំមាននរណាម្នាក់ដឹងប្រាកដថាត្រូវអនុវត្តកិច្ចការអ្វីខ្លះក្នុងការគ្រប់គ្រងសាលារៀនឱ្យក្លាយជាសាលារៀនសម្រេចបាននូវស្តង់ដាសាលារៀនមានប្រសិទ្ធភាព។ ដើម្បីសិក្សារៀនសូត្រស្វែងយល់ពីកិច្ចការនេះ នៅចន្លោះឆ្នាំ២០១៧-២០២០ ក្រសួងអប់រំ យុវជន និងកីឡា តាំងពីថ្នាក់ដឹកនាំគោលនយោបាយ មន្ត្រីថ្នាក់ក្រសួង រួមជាមួយទីប្រឹក្សាក្រសួង និងមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ គណៈគ្រប់គ្រងសាលារៀន សហគមន៍ សិស្ស មាតាបិតាបិតាសិស្ស និងអាជ្ញាធរមូលដ្ឋាន បានផ្តោតថាមពលក្នុងការអនុវត្តឱ្យសម្រេចស្តង់ដាសាលារៀនមានប្រសិទ្ធភាព និងបានអនុវត្តកិច្ចការដែលបានព្រមព្រៀងគ្នា នៅក្នុងសេចក្តីណែនាំស្តីពីការគ្រប់គ្រងតាមសាលារៀន ក៏ដូចជារក្សានូវការផ្លាស់ប្តូរ ព្រមទាំងភាពបត់បែនរបៀបធ្វើការងារជារៀងរាល់ឆ្នាំ ដើម្បីសម្រេចបានវត្ថុបំណងខាងលើ។

ជាលទ្ធផលនៅឆ្នាំ២០១៩ ក្រសួងរកឃើញប្រាកដថា កិច្ចការអ្វីដែលត្រូវធ្វើ ធ្វើយ៉ាងដូចម្តេច និងមានជម្រើសអ្វីខ្លះដែលល្អប្រសើរបំផុតសម្រាប់សម្រេចវត្ថុបំណងកិច្ចការនេះ។ រាល់អនុសាសន៍របស់ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី និងឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋលេខាធិការ ត្រូវបានក្រុមការងារយកធ្វើជាគោលការណ៍សម្រាប់អនុវត្តការងារ។

ជាលទ្ធផល បីឆ្នាំនៃការអនុវត្តការងារក្នុងក្របខណ្ឌយុទ្ធសាស្រ្តស្នូលនៃយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ៤ "ដើម្បីពន្លឿនអភិបាលកិច្ចតាមរយៈវិមជ្ឈការអំណាចពីថ្នាក់កណ្តាលទៅសាលារៀន និងសហគមន៍ក្នុងគោល

បំណងផ្តល់សេវាសាធារណៈដែលបម្រើប្រយោជន៍ប្រសើរបំផុតដល់សិស្សនិងសហគមន៍” ក្នុងបរិបទវិស័យអប់រំទទួលបានលទ្ធផលគួរជាទីមោទនៈ។

## និដ្ឋភាពទូទៅនៃការអនុវត្តវិមជ្ឈការអប់រំ

ក្រសួងបានសិក្សាពីការធ្វើវិមជ្ឈការអប់រំនៅក្នុងសកលលោក ហើយយល់ឃើញថាការរក្សាគណនេយ្យភាពប្រព័ន្ធដោយរក្សាអំណាចសម្រេចចិត្តនៅថ្នាក់កណ្តាលគឺ មិនអាចឆ្លើយតបទៅនឹងតម្រូវការសេវាសាធារណៈទាន់ពេលនោះឡើយ។ ដូច្នេះនៅឆ្នាំ២០១៧ ក្រសួងបានសម្រេចចិត្តថាត្រូវផ្តល់អំណាចសម្រេចចិត្តទៅសាលារៀននិងសហគមន៍សម្រាប់ដោះស្រាយអាទិភាពដែលជាតម្រូវការនៃការសិក្សារៀនសូត្ររបស់សិស្ស។ ពិសោធន៍ពីអតីតកាលទាក់ទងដល់ការអនុវត្តការសម្រេចចិត្តរបស់សាលារៀន និងសហគមន៍ដើម្បីជួយការសិក្សារបស់សិស្ស បង្ហាញថាអត្តចរិតនិងចរិយាកន្លងមក មិនអាចជួយសាលារៀននិងសហគមន៍បានទេ។ តាមការសង្កេតជារួមបង្ហាញថា អត្រាសិស្សចូលរៀននៅមធ្យមសិក្សាមានចំនួនតិច សមត្ថភាពសិស្សនៅទាប ទាំងការអាននិងគិតលេខ ការបោះបង់ការសិក្សាខ្ពស់ សមត្ថភាពចិញ្ចឹមខ្លួននិងគ្រួសារមិនបានសមរម្យ គ្រូបង្រៀនមួយចំនួនអវត្តមាន ឬមានវត្តមាននៅសាលារៀនតែមិនបានបង្រៀនឱ្យបានពេញលេញ ឬបន្តបង្រៀនតាមវិធីដែលពុំអាចជួយសិស្សឱ្យរៀនចេះ ហើយសិស្សដែលរៀនមិនចេះក៏ឱ្យឡើងថ្នាក់ដែរ។ល។

ផ្តើមចេញពីការទទួលស្គាល់ចំណុចខ្វះខាតខាងលើ រួមជាមួយនឹងការខិតខំប្រឹងប្រែងជួយសិស្ស ឱ្យ សម្រេចបានលទ្ធផលសិក្សា អ្នកពាក់ព័ន្ធទាំងអស់ចាប់ផ្តើមទទួលស្គាល់ការពិតនៃការងារនិងជីវិតៈ គុណផលសិក្សាសិស្សថ្នាក់ទី៦កើនឡើងនៅមុនពេលចូលរៀនថ្នាក់ទី៧ តាមរយៈកិច្ចការសហការរវាងសាលាមធ្យមសិក្សានិងបឋមសិក្សា ការភ្ញាក់ដឹងរបស់មាតាបិតាពីការខិតខំរៀននិងសមត្ថភាពសិក្សារបស់កូន ការជួយពីក្រសួងដល់គ្រូបង្រៀនបឋមសិក្សាក្នុងការប្រើវិធីសាស្ត្រនិងល្បិចកែលម្អការបង្រៀនភាសាខ្មែរនិងគណិតវិទ្យា សហគមន៍យល់ពីភាពច្បាស់លាស់ពីការខិតខំ និងការកែប្រែរបស់គ្រូបង្រៀនពីការប្រើវិធីបង្រៀនសិស្សមិនចេះមកជាការបង្រៀនដែលល្អ ពីពេលមុនគ្រូបង្រៀនគឺខ្វះរហូត ដល់ឥឡូវមានដំណោះស្រាយដែលនឹងឈានទៅរកភាពគ្រប់គ្រាន់ កែប្រែការយល់ឃើញពីការលំបាកទាំងអស់គឺសុទ្ធតែបណ្តាលមកពីអ្នកដទៃ មកជាការផ្តោតលើកិច្ចការរបស់ខ្លួនវិញ។ គ្រូបង្រៀននិងគណៈគ្រប់គ្រងសាលារៀនធ្វើកិច្ចការប្រាកដ ដោយសារបានមករៀនក្នុងវគ្គលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន នៅមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

សាលារៀន សហគមន៍ និងថ្នាក់ក្រោមជាតិដោះស្រាយការខ្វះគ្រូ តាមរយៈ (១)ការខ្ចីគ្រូពីសាលានៅក្បែរមកបង្រៀននៅសាលារៀនដែលខ្វះគ្រូ (២)ការបញ្ជូនគ្រូឧសុងឯកទេសដើមដែលមានបទពិសោធន៍បង្រៀនច្រើនឆ្នាំឱ្យចូលរៀនក្នុងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន (៣)ជ្រើសរើសសិស្សពូកែលើមុខវិជ្ជាផ្សេងៗមកបណ្តុះបណ្តាលនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន រួចវិលត្រឡប់ទៅជួយបង្រៀននៅសាលាវិញដោយមានការគាំទ្របន្ថែមពីសហគមន៍ និង(៤)ក្នុងករណីនៅតែខ្វះគ្រូត្រូវស្រង់គ្រូមុខវិជ្ជាដែលខ្វះពិភាក្សាជាមួយថ្នាក់ជាតិដើម្បីដោះស្រាយ។

សាលារៀន និងសហគមន៍ ឈានមកដល់ការទទួលអារម្មណ៍ថាយើងមិនគប្បីរស់ជាមួយអតីតកាលទៀតទេ។ សហគមន៍ដែលពីមុនមិនខ្វីរវល់ជាមួយសាលារៀនមកចូលរួមរាល់សកម្មភាពរបស់សាលារៀន សិស្សចុះឈ្មោះចូលរៀនទាំងអស់តែ១ថ្ងៃ តេស្តសិស្សថ្នាក់ទី៦កើនសមត្ថភាពដល់៦៥% សាលារៀនរៀបចំថ្ងៃដឹងគុណគ្រូថ្នាក់ទី៦។

ការធ្វើតេស្តដែលពីមុនមិនអើពើដឹង មកជាការធ្វើតេស្តដោយហ្មត់ចត់លើមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យាសម្រាប់សិស្សថ្នាក់ទី៦ចូលទី៧។ សាលាបឋមសិក្សាក្នុងកម្រង សហការធ្វើកិច្ចការជាមួយសាលាមធ្យមសិក្សាលើកិច្ចការសំខាន់ៗនៃកម្មវិធីការគ្រប់គ្រងសាលារៀន។ គណៈកម្មការគ្រប់គ្រងសាលារៀននិងគណៈគ្រប់គ្រងសាលារៀនសហការគ្នាបានល្អ។ ជាក់ស្តែងសាលានៅជើងភ្នំជិតព្រំដែនប្រទេសថៃបានធ្វើតេស្ត សិស្សប្រឹងប្រែងរៀនសូត្រលទ្ធផលតេស្តថ្នាក់ទី៦ល្អជាងឆ្នាំមុន សិស្សជាប់ភាសាខ្មែរ៩០% និងគណិតវិទ្យា៥៥%។ គ្រូខិតខំបង្រៀនមិនប្រកាន់កម្រិតថ្នាក់ ជួយគ្នាអនុវត្តការបង្រៀនដោយប្រើប្រាស់ចំណេះដឹងនិងបទពិសោធន៍ដែលបានមកពីមហាវិទ្យាល័យអប់រំ។ សិស្សមិនត្រឹមតែរៀននៅក្នុងថ្នាក់រៀននោះទេ តែរៀនគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ សហគមន៍ចូលរួមសកម្មភាពអភិវឌ្ឍន៍សាលារៀនដូចជាការធ្វើតេស្ត ការសាងសង់អគារសិក្សា និងការកែលម្អបរិស្ថានសាលារៀនជាដើម។

គ្រប់ភាគីពាក់ព័ន្ធបានសម្រេចចិត្តនិងបានអនុវត្តនូវអ្វីដែលថ្មី អ្វីដែលជាប្រយោជន៍ដល់សិស្ស សហគមន៍ និងសង្គម ដូចជា នាយកសាលា គ្រូបង្រៀន សិស្ស និងសហគមន៍សហការធ្វើការជាមួយគ្នា គ្រូខិតខំបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន(បង្រៀនពេញម៉ោងនិងអនុវត្តតេស្តបានប្រសើរ) សហគមន៍ចូលរួមជួយឧបត្ថម្ភដល់គ្រូ ដែលបង្រៀនលើសម៉ោង ឬ ម៉ោងបន្ថែម អាជ្ញាធរមូលដ្ឋានចូលរួមជួយសាលារៀន សហគមន៍រីករាយដោយឃើញកូនចៅខិតខំរៀនសូត្រ។ ការអនុវត្តការគ្រប់គ្រងតាមសាលារៀនរយៈពេលបីឆ្នាំកន្លងមកនេះបានធ្វើឱ្យមានការផ្លាស់ប្តូរឥរិយាបទធ្វើការងាររបស់មន្ត្រី ការចែករំលែកចំណេះដឹងរវាងគ្រូបង្រៀននិងគ្រូបង្រៀន ដែលប្រការនេះធ្វើឱ្យគុណផលសិក្សារបស់សិស្សមានការប្រែប្រួលជាវិជ្ជមាន គួរឱ្យកត់សម្គាល់។

## *កត្តានាំមកនូវភាពជោគជ័យក្នុងដំណើរការសាលារៀន*

ថ្នាក់ដឹកនាំគោលនយោបាយ មន្ត្រីអប់រំថ្នាក់ជាតិនិងក្រោមជាតិ នាយកសាលា និងគ្រូបង្រៀន បានបណ្តុះនូវសុជីវធម៌បុគ្គល ធ្វើតែអំពើល្អដើម្បីប្រយោជន៍សិស្សនិងសហគមន៍ រួមសាមគ្គីគ្នាដើម្បីបុព្វហេតុតែមួយគឺផលប្រយោជន៍សិស្សនិងសហគមន៍។ ការខិតខំអនុវត្តនូវអំពើល្អទាំងនេះ ក្នុងរយៈពេលបីឆ្នាំកន្លងមក បាននាំមកនូវការកសាងគុណតម្លៃដោយចាប់ផ្តើមដំបូងពីបុគ្គលម្នាក់ៗ ហើយបច្ចុប្បន្នបានក្លាយទៅជាគុណតម្លៃរួមដែលទាំងអស់គ្នាទទួលស្គាល់។ គុណតម្លៃទាំងនេះនឹងត្រូវបានយកមកបញ្ចូលក្នុងសេចក្តីណែនាំប្រតិបត្តិយុទ្ធសាស្ត្រសហគមន៍សាលារៀន។

សិស្សទទួលបាននូវយុត្តិធម៌ពីការខិតខំប្រឹងប្រែងរៀនសូត្រ នេះជាអ្វីដែលលើកឡើងដោយសិស្សមួយចំនួននាពេលឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីបានជួបពួកគេនៅសាលារៀន។ សិស្សពោលថា «បើអ្នកណាប្រឹងប្រែងរៀនសូត្រ អ្នកនោះនឹងបានធ្វើតេស្តស្តង់ដាប្រចាំខែជាប់ តែបើអ្នកណាមិនរៀនអ្នកនោះនឹងធ្លាក់»។ ជាមួយគ្នានោះ សិស្សបានសំណូមពរដល់ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី ឱ្យក្រសួងអនុវត្តការងារកំណែទម្រង់នេះនៅគ្រប់សាលារៀនទាំងអស់នៅក្នុងប្រទេស។

ភាពពិតនៃសមធម៌អប់រំគឺការកើនឡើងទាំងបរិមាណ និងគុណភាពរៀនសូត្រ។ មាតាបិតាទាំងក្នុងនិងក្រៅសហគមន៍របស់សាលារៀនបាននាំសិស្សមកចុះឈ្មោះចូលរៀននៅសាលារៀនដែលអនុវត្តកម្មវិធីការគ្រប់គ្រង តាមសាលារៀន។ បរិមាណសិស្សធ្លាក់នៃសាលារៀនគោលដៅភាគច្រើនបានថយចុះស្ទើរទាំងអស់។ បរិមាណសិស្សរៀនបានមធ្យមភាគកើនឡើងខ្ពស់។ តែនៅមានចំណោទក្នុងការបង្កើនបរិមាណសិស្សរៀនមានសមត្ថភាពល្អ និងល្អប្រសើរ ហើយសហគមន៍ដឹងថានេះជាកិច្ចការត្រូវធ្វើបន្ទាប់។

កាលពីអតីតកាល សហគមន៍ គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងមន្ត្រីអប់រំតែងតែលើកឡើងពីការលំបាក ហើយការលំបាកដែលលើកឡើងសុទ្ធតែជាការលំបាកដែលបណ្ដាលមកពីអ្នកដទៃ។ ប្រការនេះធ្វើឱ្យការលំបាកទាំងនោះមិនត្រូវបានដោះស្រាយឡើយ ព្រោះគ្មានម្ចាស់។ តែបច្ចុប្បន្ន ដោយផ្ដោតលើបច្ចុប្បន្នភាពសម្រាប់អនាគត និងប្រើអតីតកាលជាមេរៀន គ្រប់សមាសធាតុដែលជាកោសិការបស់សហគមន៍ បានស្វែងយល់ថា ការចំណាយពេលគិតពីរឿង ឬបញ្ហារបស់អ្នកដទៃវាមិនបាននាំមកនូវប្រយោជន៍ដល់សហគមន៍នោះទេ។ ដូច្នេះទាំងអស់គ្នាសម្រេចចិត្ត ប្រើពេលវេលាបច្ចុប្បន្នទាំងអស់ផ្ដោតលើកិច្ចការដែលម្នាក់ៗត្រូវធ្វើដោយតម្កល់ប្រយោជន៍របស់សិស្ស និងសហគមន៍ជាធំ។

## សហគមន៍ដឹងថាអ្វីប្រាកដចង់បានតែនៅមិនទាន់បាន

ខាងក្រោមនេះជាបំណងរបស់សហគមន៍ដែលបានថ្លែងប្រាប់មន្ត្រីបម្រើសេវាសាធារណៈពាក់ព័ន្ធនឹងអ្វីដែលពួកគេត្រូវការ៖ (១)សិស្ស គ្រួសារសិស្ស និងសហគមន៍ទាំងមូលត្រូវការនូវសមត្ថភាពរស់នៅជាមួយជីវិតរីករាយ (២) សមត្ថភាពចាកចេញពីភាពក្រីក្រដោយសារការបង្កើតនិងប្រើគំនិតមួយ (៣)គុណភាពសិក្សានិងលទ្ធផលសិក្សាសិស្សត្រូវតែមានកម្រិតល្អនិងល្អប្រសើរ (៤)រៀនចប់និងត្រូវមានសមត្ថភាពឆ្លើយតបតម្រូវការទីផ្សារការងារ (៥) យុវជនត្រូវក្លាយខ្លួនជាពលរដ្ឋពេញលេញ ឬ ពលរដ្ឋសាកល (៦)គ្រូទាំងអស់ត្រូវបាននូវការបណ្ដុះបណ្ដាលពេញមួយជីវិត (កម្មវិធីលើកកម្ពស់គុណវុឌ្ឍិ និងកម្មវិធីបណ្ដុះបណ្ដាលរយៈពេលខ្លី មធ្យម និងរយៈពេលវែង) (៧)សហគមន៍ត្រូវទទួលបាននូវគ្រូបង្រៀនមានគុណភាព ដែលអាចប្រើយុទ្ធសាស្ត្របង្រៀនដោយប្រាកដថាអាចជួយសិស្សបាន (៨) សាលាសម្ព័ន្ធត្រូវរឹងមាំ ដោយគ្រូពីសាលាមានស្តង់ដាត្រូវជួយគ្រូនៅសាលាមិនទាន់មានស្តង់ដា (៩)គុណភាពសិស្សត្រូវមានកម្រិតដូចគ្នាទៅនឹងសិស្សនៅក្នុងតំបន់អាស៊ី (១០) ធនធានដែលជាធាតុចូលត្រូវមានលក្ខណៈដូចគ្នា និង(១១)ការជួយសិស្សរៀនយឺតត្រូវតែផ្ដោតលើសិស្សម្នាក់ៗ និងជួយឱ្យបានគ្រប់គ្នាដើម្បីរក្សានូវការសន្យានៃពាក្យសមធម៌ បរិយាប័ន្ន និងយុត្តិធម៌សម្រាប់សិស្ស។

## សហគមន៍និងមន្ត្រីអប់រំកំណត់អត្តចរិតថា «ការលំបាកដែលមិនបាច់ដោះស្រាយ»

ផ្ដើមពីការរៀនសូត្រតាមការអនុវត្តជាក់ស្ដែងក្នុងរយៈពេលពេញបីឆ្នាំ រួមជាមួយការទទួលរងឥទ្ធិពលនៃជំងឺកូវីដ-១៩ ថ្នាក់ដឹកនាំគោលនយោបាយ មន្ត្រីអប់រំ នាយកសាលា គ្រូបង្រៀន និងសហគមន៍យល់ប្រាកដក្នុងចិត្តថា ការលំបាកជាជីវិត ការលំបាកធ្វើឱ្យជីវិតមានន័យ ព្រោះវាជាឱកាសនៃជីវិត។ កិច្ចការរបស់យើងទាំងអស់គ្នា គប្បីផ្ដោតលើគោលបំណង ឬ អ្វីដែលចង់បានពីការលំបាកមួយ ដោយអនុវត្តសកម្មភាពសម្រាប់ដំណោះស្រាយកិច្ចការនោះ ព្រោះថាការបារម្ភវាគ្រាន់តែបង្អាក់មនុស្សតែប៉ុណ្ណោះ។ ថ្នាក់ដឹកនាំគោលនយោបាយ និង មន្ត្រីអប់រំបានប្រើប្រាស់ភាពឆ្លាតវៃដោយគ្រោងឡើងនូវកិច្ចការជាក់លាក់នៅក្នុងសេចក្ដីណែនាំស្ដីពីការគ្រប់គ្រងតាមសាលារៀន ដោយបង្រៀនដល់សាលារៀននិងសហគមន៍ឱ្យអនុវត្តកិច្ចការតាមរបៀបថ្មី នាំមកនូវជោគជ័យក្នុងការងារ ឆ្លើយតបទៅនឹងតម្រូវការប្រាកដ ដែលសហគមន៍ចង់បាន បើទោះជាបែបនេះក្ដី អ្វីប្រាកដដែលសហគមន៍ចង់បានគឺភាពឆ្លាតវៃបន្ថែមទៀតសម្រាប់ឆ្លើយតបទៅនឹងសហគមន៍វិញ (រៀនមានសមត្ថភាពល្អនិងល្អប្រសើរ មានសមត្ថភាពរកចំណូលចាកផុតពីភាពក្រីក្រ និងសមត្ថភាពរស់ជាមនុស្សពេញលេញ)។ ដូច្នេះអតីតកាលបានបង្រៀនទាំងអស់គ្នា ឱ្យប្រើបច្ចុប្បន្នកាលអនុវត្តកិច្ចការដោយប្រាកដប្រជានិងច្បាស់លាស់ នោះនឹងនាំមកនូវអ្វីដែលទាំងអស់គ្នាចង់បាន។

### *សហគមន៍ជឿជាក់ថាគេត្រូវការវប្បធម៌សាលារៀនសព្វគ្រប់ដូចខាងក្រោម*

វប្បធម៌សាលារៀនគឺជាអ្វីដែលមនុស្សទាំងអស់ត្រូវអនុវត្តនូវកិច្ចការប្រាកដរបស់ខ្លួន ដើម្បីបង្ហាញនូវគណនេយ្យភាពសេវាសាធារណៈ។ មន្ត្រីម្នាក់ៗ ទាំងនៅកម្រិតសាលារៀន ថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិត្រូវរៀននិងទទួលឱ្យបាននូវៈ (១)សមត្ថភាពគេចចេញផុតពីការប៉ះទង្គិចអារម្មណ៍ (២)ញាណថែរក្សាខ្លួនដោយខ្លួនឯង (៣)ញាណថាត្រូវមានចំណែកទទួលខុសត្រូវសង្គម និង (៤)ញាណប្រាកដថាមិនគប្បីរស់នៅដើម្បីតែខ្លួនឯងនោះទេ។ ដូច្នេះត្រូវបណ្ដុះនូវអត្តចរិតយល់ឃើញថាបើបណ្ដុះបាននូវញាណទាំងអស់នេះនឹងនាំឱ្យបុគ្គលខ្លួនឯងមានក្ដីសុខ ហើយការអនុវត្តនូវកិច្ចការរបស់ខ្លួនប្រាកដជាវិធីដែលនាំឱ្យកសាងបាននូវញាណទាំងអស់នេះហើយ។

### *ភាពជាក់ស្ដែងនិងទ្រឹស្ដីនៃអំណាចរដ្ឋបាលនិងហិរញ្ញវត្ថុ*

ដើម្បីឈានដល់ដំណាក់កាលអភិវឌ្ឍ សាលារៀននិងសហគមន៍ត្រូវអនុវត្តកិច្ចកាតាមរបៀបថ្មី នោះគំនិតថ្មីនឹងកើតមានឡើងរហូត ដូចនេះមិនគប្បីរង់ចាំក្រដាសជាសេចក្ដីណែនាំទើបអនុវត្តនោះទេ។ អនុវត្តគំនិតថ្មីដើម្បីកសាងបទពិសោធន៍ នៅពេលនោះសាលារៀននិងសហគមន៍នឹងកាន់តែមានអំណាច ដោយសារវាជាអំណាចនៃចំណេះដឹងដែលកសាងបានពីភាពជាក់ស្ដែង ហើយនេះវាមិនមែនជារឿងថ្មីទេ ព្រោះសាលានិងសហគមន៍ មន្ត្រីអប់រំ និងថ្នាក់ដឹកនាំគោលនយោបាយបានអនុវត្តរួចហើយ។ ពីពិសោធន៍ទទួលបានពីភាពជាក់ស្ដែងនាំទៅរកការបង្កើតច្បាប់ ឬ សេចក្ដីណែនាំដែលទាក់ទងនឹងអំណាចរដ្ឋបាលនិងហិរញ្ញវត្ថុ បន្តអនុវត្តច្បាប់ក្នុងវិសាលភាពទូលាយនិងក្នុងបរិបទសង្គមដែលនឹងនាំទៅរកការកសាងបាននូវសង្គមមួយដែលមានសុជីវធម៌ សមធម៌ យុត្តិធម៌ និងគោរពសិទ្ធិមនុស្ស។

### *សាលារៀនយល់ឃើញថាសក្ដានុពលសហគមន៍ដែលមាននៅមិនទាន់បានប្រើអស់លទ្ធភាព*

តាមការសង្កេតក្នុងរយៈពេលបីឆ្នាំកន្លងមកនេះ សហគមន៍បានដើរតួយ៉ាងសំខាន់ និងមានសក្ដានុពលសម្រាប់អនុវត្តកម្មវិធីកំណែទម្រង់វិស័យអប់រំ។ សក្ដានុពលទាំងនោះមានដូចជា សហគមន៍ជាមន្ត្រីដែលមិនទាមទារប្រាក់ខែ សហគមន៍ជាមន្ត្រីដែលសម្បូរដោយទ្រព្យសម្បត្តិ មានចំណេះដឹង និងមានការប្ដេជ្ញាចិត្តដើម្បីសហគមន៍របស់គេ ហើយអ្វីដែលគេត្រូវការ គឺក្រមប្រតិបត្តិដែលឯកភាពគ្នាក្នុងសហគមន៍ ដើម្បីគេអាចប្រើប្រាស់សក្ដានុពលរបស់គេបានក្នុងការជួយសហគមន៍សាលារៀន។ ពិសោធន៍ទាំងនេះនឹងត្រូវបានយកមកចងក្រងក្នុងយុទ្ធសាស្ត្រសហគមន៍សាលារៀននេះ។

## បំណងប្រាថ្នានិងការប្ដេជ្ញាចិត្តរបស់សហគមន៍

### សហគមន៍កសាងសមត្ថភាពដើម្បីសហគមន៍

ការអនុវត្តកម្មវិធីកំណែទម្រង់នេះបាននាំឱ្យសហគមន៍និងសាលារៀន ប្រើសក្ដានុពលរបស់ខ្លួនធ្វើឱ្យ មនុស្សទាំងអស់ ធ្វើកិច្ចការដើម្បីមនុស្សគ្រប់គ្នាក្នុងសហគមន៍ ហើយបុគ្គលម្នាក់ៗប្រឹងប្រែងដើម្បីសហគមន៍ទាំងមូល។ សហគមន៍បានបណ្ដុះនូវអត្តចរិតចៀសវាងនូវវប្បធម៌ (១)មនុស្សទាំងអស់ដើម្បីបុគ្គលម្នាក់ និង(២)បុគ្គលម្នាក់ដើម្បីមនុស្សមួយក្រុមតូច។

## សហគមន៍នឹងប្រើសក្ដានុពលនៃភាពវិជ្ជមានក្នុងចិត្ត សម្រាប់ការអភិវឌ្ឍសហគមន៍សាលារៀន

ឆ្លងតាមបទពិសោធន៍ជាច្រើនទសវត្សរ៍នៃការរស់នៅជាមួយការប៉ះទង្គិចអារម្មណ៍ សាលារៀន សហគមន៍ និងមន្ត្រីអប់រំ យល់ច្បាស់ក្នុងចិត្តថា នៅក្នុងលោកនេះមិនមានអត្តចរិត ឬ ចរិយាអវិជ្ជមានណាមួយដែលនាំឱ្យមនុស្សមានសេចក្ដីសុខឡើយ ហើយវាក៏មិនអាចដោះស្រាយបញ្ហាអ្វីមួយបានដែរ។ ផ្ទុយទៅវិញដោយមានការគាំទ្រពីថ្នាក់ដឹកនាំ

គោលនយោបាយ រួមជាមួយ (១)ការប្រកាន់អត្តចរិតនិងចរិយាវិជ្ជមានគ្រប់ពេលវេលា ប្រាកដណាស់ថានឹងមិនមាននរណាម្នាក់ក្នុងលោកអាចបំពានអ្នកបានឡើយ បើអ្នកមិនអនុញ្ញាតឱ្យគេបំពាន (២)ការបណ្តុះនូវសេចក្តីមេត្តាអាណិត និងសណ្តោសប្រណីដល់គ្រប់ប្រភេទបុគ្គល នឹងជួយដល់គ្រប់បុគ្គលដែលត្រូវការអ្នកជួយ ហើយ (៣)អ្នកនឹងមិនទាមទារអ្វីទាំងអស់ពីគ្រប់មនុស្ស ព្រោះអ្នកមានទាំងអស់នូវអ្វីដែលអ្នកត្រូវការ ដោយសារអ្នកជាមនុស្សពេញលេញ។

## សហគមន៍នឹងប្រើថាមពលនៃភាពប្រឆាំងសម្រាប់ការអភិវឌ្ឍ

នៅគ្រប់ទីកន្លែងបើកាលណាមានកំណែទម្រង់ នោះនឹងមានការប្រឆាំងតប ហើយត្រូវចាត់ទុកថានេះជារឿងធម្មតា។ បើអ្នកប្រឆាំងខ្សោយ ទោះអ្នកនៅស្ងៀម ក៏អ្នកនៅតែខ្លាំង តែបើអ្នកប្រឆាំងខ្សោយខំស្រែក អ្នកគ្រាន់តែសម្លឹងមុខគេ ហើយនៅស្ងៀមទៅ ក៏អ្នកនៅតែខ្លាំង ឬថាបើអ្នកប្រឆាំងខ្លាំង អ្នករៀនពីគេ អនុវត្តគំនិតគេតាមរបៀបថ្មី នោះអ្នកកាន់តែខ្លាំង ហើយបើអ្នកប្រឆាំងដែលកាន់តែខ្លាំងបំផុត អនុញ្ញាតឱ្យគេមកធ្វើការជាមួយអ្នកទៅ ដូចនេះអ្នកនៅតែខ្លាំងបំផុតដដែល។

## សហគមន៍យល់ថាត្រូវតែអភិវឌ្ឍការដឹកនាំឈានឱ្យដល់កម្រិតនៃការដឹកនាំដោយមិនបាច់ដឹកនាំ

ជាការហត់នឿយណាស់ បើអង្គភាពមួយមានបញ្ហារាប់រយដែលត្រូវចំណាយពេលសម្រាប់ដោះស្រាយវា ហើយមិនមានពេលវេលាធ្វើកិច្ចការដើម្បីអភិវឌ្ឍ។ អ្នកដឹកនាំគោលនយោបាយ មន្ត្រីអប់រំ សាលារៀន និងសហគមន៍មានភាពប្រាកដក្នុងចិត្តថា ត្រូវតែរៀនរស់ក្រោមច្បាប់ ព្រោះនេះជាអភិបាលកិច្ច ប្រការនេះនឹងបញ្ចៀសនូវបញ្ហារាប់រយដែលមិនបានការ ប្រើពេលវេលាគិតនិងជួយមនុស្សនិងសង្គម ហើយដែលពេលខ្លះការពិតនៃជីវិតដែលវាលើសពីច្បាប់/គោលការណ៍ដែលបានណែនាំ ដែលទាមទារឱ្យមានការធ្វើបច្ចុប្បន្នកម្មច្បាប់/សេចក្តីណែនាំជាប្រចាំដើម្បីជួយសង្គម និងមនុស្សជាច្រើនឱ្យទាន់ពេលវេលា ជួយមនុស្សម្នាក់ៗនិងមនុស្សគ្រប់រូបឱ្យក្លាយជាអ្នកដឹកនាំ បើបុគ្គលគ្រប់រូបជាអ្នកដឹកនាំ នោះមិនត្រូវការការដឹកនាំឡើយ តែអ្វីមួយគត់ដែលមនុស្សត្រូវការគឺការកំណត់ទិស។

## សហគមន៍យល់ថាគប្បីរៀនរស់ជាមួយភាពស្ងប់សុខនៃជីវិតរីករាយ

មិនមានអ្នកណាម្នាក់ចង់រស់ជាមួយភាពទុក្ខសោកនិងភាពក្រីក្រនោះទេ ជាការសំខាន់ដែលគប្បីយល់ថាព្រះកំណត់រង្វាស់នៃផ្លូវជីវិត(វាសនា)អ្នក ពោលគឺពេលដែលអ្នកទទួលបាននូវកិច្ចការមួយ អ្នកត្រូវធ្វើឱ្យបានប្រាកដ ព្រោះថាអ្នកជាអ្នកធ្វើឱ្យវាសនារបស់អ្នកក្លាយជាការពិត។ ដោយសារអ្នកទទួលបាននូវភាពជោគជ័យពីការអនុវត្តកិច្ចការនោះ រាប់តាំងពីការជួយខ្លួនឯងជាបុគ្គលម្នាក់ ជួយគ្រួសារបាន ជួយអង្គភាពបាន រហូតដល់ជួយសង្គមទាំងមូល។ កិច្ចការទាំងនោះបាននាំមនុស្សនៅជុំវិញខ្លួនអ្នកបានសុខ ហើយចំពោះអ្នកវិញពេលដែលអ្នកនៅទោលតែម្នាក់ឯងក៏អ្នកបានសុខដែរ។ លើសពីនេះ ទោះអ្នកនៅកន្លែងណាក៏ដោយ ក៏អ្នកមានមនុស្សដែលចង់ជជែកលេងជាមួយអ្នក ព្រោះថាការជជែកគ្នានាំឱ្យគេមាននូវសេចក្តីសុខ ពេលនោះភាពឯកោនឹងត្រូវបាត់បង់ ហើយមនុស្សបែបនេះនឹងរស់នៅជាមួយជីវិតស្ងប់សុខនិងរីករាយ។

## សហគមន៍ប្ដេជ្ញាថាសហគមន៍សាលារៀនត្រូវឈានឆ្ពោះដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព

គ្រប់ចំណុចដែលបានរៀបរាប់ខាងលើនឹងនាំមកនូវការអភិវឌ្ឍប្រកបដោយនិរន្តរភាព មានន័យថា «គ្រប់គ្រាន់ហើយ» (sustainble development means enough)។ គប្បីរៀនរស់ជាមួយជីវិតធម្មតា ហើយប្រាកដក្នុងចិត្តថា មានជីវិតធម្មតាគប្បីគ្រប់គ្រាន់ហើយ។ សំណួរមួយសួរថា តើអ្វីដែលបានរៀបរាប់ខាងលើ អាចនាំឱ្យយើងកែប្រែក្រម ប្រតិបត្តិពីការគ្រប់គ្រងតាមសាលារៀនឬទេ? ចម្លើយគឺ យើងត្រូវតាក់តែង «យុទ្ធសាស្រ្តសហគមន៍សាលារៀន» «School community strategy»។ សំណួរចុងក្រោយសួរថា ហេតុអ្វីយើងត្រូវតាក់តែងយុទ្ធសាស្រ្តសហគមន៍សាលារៀន? ចម្លើយអាចរកបានក្នុងសំណួរត្រឡប់វិញថា៖ តើសាលារៀនមួយអាចផ្ដល់ការអប់រំដល់សហគមន៍បានទេ បើមិនសហការជាមួយសាលារៀនទាំងអស់? តើសាលារៀនទាំងអស់អាចផ្ដល់ការអប់រំបានទេ បើគ្រួសារនីមួយៗនៃគ្រួសារទាំងអស់មិនមែនជាកន្លែងផ្ដល់ការអប់រំ? តើសាលារៀនទាំងអស់ និងគ្រួសារទាំងអស់អាចផ្ដល់ការអប់រំសម្រាប់ទាំងអស់គ្នាបានទេ បើទីផ្សារទាំងអស់មិនមែនជាកន្លែងអប់រំ តែជាកន្លែងបោកបញ្ឆោតនិងកេងប្រវ័ញ្ច? រាល់សំណួរខាងលើនេះនឹងត្រូវបានបកស្រាយនៅក្នុងខ្លឹមសារនៃយុទ្ធសាស្រ្តសហគមន៍សាលារៀនខាងក្រោមនេះ៖

## និដ្ឋភាពទូទៅក្របខណ្ឌយុទ្ធសាស្ត្រសហគមន៍សាលារៀន

### ការចាប់ផ្តើមនូវវប្បធម៌ថ្មីនៃការកសាងសង្គមមួយដែលគ្រប់គ្នាចង់បាន

| ចក្ខុវិស័យ៖ កិច្ចការត្រូវធ្វើ សម្រេចគោលនយោបាយ | | ផ្តល់លទ្ធភាពអនុវត្ត៖ កំណត់ព្រំដែនអំណាច | | ផ្តល់អំណាច៖ សម្រេចផលសម្រេច | | រក្សាថាមពលការងារ៖ កសាងគុណតម្លៃ | |
|---|---|---|---|---|---|---|---|
| បេសកកម្ម | គោលបំណង | រចនាសម្ព័ន្ធនិងតួនាទី | ស្តង់ដានិងការវាយតម្លៃ | ផែនការសមិទ្ធកម្ម ៦ឆ្នាំ | ផែនការអនុវត្តឆ្នាំទី១ ដល់ទី៤ | ប្រព័ន្ធគ្រប់គ្រងការអនុវត្តការងារ | ការអភិវឌ្ឍគន្លងអាជីព |
| យុទ្ធសាស្ត្រនិងការផ្លាស់ប្តូរ | វប្បធម៌និងគុណតម្លៃ | ការបែងចែកភារៈកិច្ចនិងការងារ | ការគ្រប់គ្រងហិរញ្ញវត្ថុ | ការកសាងធនធានមនុស្ស | ការពិនិត្យតាមដាននិងវាយតម្លៃ | ការដឹកនាំផ្តោតលើលទ្ធផល | និរន្តរភាពសាលារៀន |

### ចក្ខុវិស័យសហគមន៍សាលារៀន

### ១ បេសកកម្ម

*(១) បណ្តុះសិស្សឱ្យមានបំណិនខ្ពស់សម្រាប់ជីវិតនិងការងារ និងត្រៀមរួចជាស្រេចដើម្បីចូលរៀននៅគ្រឹះស្ថានឧត្តមសិក្សា ឬ ចូលរួមក្នុងទីផ្សារការងារ និង*

*(២) កែលម្អការអនុវត្តរបស់សាលារៀនឱ្យបំពេញបានស្តង់ដាសាលារៀនមានប្រសិទ្ធភាព។ សាលារៀននឹងជួយដល់សិស្សទាំងអស់ដោយគ្មានការរើសអើងលើភាពក្រីក្រ យេនឌ័រ ពិការភាព ឬជនជាតិភាគតិច (បរិយាប័ន្ន សមធម៌)។*

### ២ គោលបំណង

*(១) សិស្ស៨០ទៅ៨៥% មានបំណិនខ្ពស់សម្រាប់ជីវិតនិងការងារ និងត្រៀមរួចជាស្រេចដើម្បីចូលរៀននៅគ្រឹះស្ថានឧត្តមសិក្សា ឬ ចូលរួមក្នុងទីផ្សារការងារ នៅមុនឆ្នាំ២០៣០*

*(២) សាលារៀនបំពេញបាននូវស្តង់ដាយុទ្ធសាស្ត្រសហគមន៍សាលារៀននៅ៦ឆ្នាំក្រោយ។ សាលារៀននឹងជួយដល់សិស្សទាំងអស់ដោយគ្មានការរើសអើងលើភាពក្រីក្រ យេនឌ័រ ពិការភាព ឬជនជាតិភាគតិច (បរិយាប័ន្ន សមធម៌)។*

### ៣ យុទ្ធសាស្ត្រនិងការផ្លាស់ប្តូរ



*ការអនុវត្តយុទ្ធសាស្ត្រនាំឱ្យមានការផ្លាស់ប្តូរ*

(១) ការធ្វើតេស្តស្តង់ដាវាស់សមត្ថភាពសិស្ស និងបិទផ្សាយលទ្ធផលជាសាធារណៈ នាំឱ្យមានការទាមទារពីអតិថិជននូវសេវាសាធារណៈនិងការបង្រៀនមានគុណភាព

(២) សហគមន៍ប្រើអំណាចសម្រេចចិត្តលើផែនការ ថវិកា និងកិច្ចការសាលារៀន នាំឱ្យសហគមន៍ក្លាយជាម្ចាស់សាលារៀន និងជួយដល់សាលារៀន

(៣) នាយកសាលាប្រើសិទ្ធិប្រតិបត្តិជានាកិច្ចការរដ្ឋបាលសាលារៀន និងបង្ហាញលទ្ធផលសិក្សា ចំណូលចំណាយ និងការរីកចម្រើនស្តង់ដាសាលារៀនជាសាធារណៈ ដែលនាំឱ្យសហគមន៍ជឿជាក់លើសាលារៀន គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន

(៤) យកចិត្តទុកដាក់ថែរក្សាគ្រូបង្រៀន ទាំងសមត្ថភាពនិងការស់នៅ ដែលជាគន្លឹះក្នុងការកសាងកិច្ចសន្យាសង្គមរវាងគ្រូបង្រៀន មាតាបិតាសិស្សនិងសិស្ស និងសហគមន៍ ហើយវានាំឱ្យមនុស្សទាំងអស់ធ្វើកិច្ចការរបស់ខ្លួនដើម្បីគាំទ្រការសិក្សារបស់សិស្ស

(៥) ការអនុវត្តវប្បធម៌គឺ នាំឱ្យបុគ្គលិកអប់រំទាំងអស់ក្នុងសាលារៀន គោរពគ្នាដោយប្រើអំណាចសម្រាប់ធ្វើតែកិច្ចការត្រូវធ្វើ មិនប្រើអំណាចខុសគោលដៅ ឬ ប្រើធនធានសាលារៀនសម្រាប់ប្រយោជន៍បុគ្គល ចំណែកឯការអនុវត្តគុណតម្លៃគឺ ជាកត្តានាំឱ្យមនុស្សម្នាក់ៗ ក្លាយជាមនុស្សល្អ ដោយសារបុគ្គល ម្នាក់ៗធ្វើតែអ្វីដែលត្រូវ និងជួយមនុស្សទាំងអស់ក្នុងសហគមន៍

(៦) ការយកចិត្តទុកដាក់លើការអប់រំថែទាំកុមារតូចគឺ ជាកត្តាគន្លឹះនាំឱ្យកុមារមានសមត្ថភាពគ្រឹះ រួមមានសមត្ថភាពទំនាក់ទំនង អាហារូបត្ថម្ភល្អ និងខួរក្បាលពេញលេញ អក្ខរកម្ម និងចិត្តសង្គម ហើយសមត្ថភាពទាំងនេះនឹងនាំឱ្យកុមារម្នាក់ៗក្លាយជាធនធានមនុស្សសំខាន់សម្រាប់អនាគត។

*គ្រប់ការផ្លាស់ប្តូរគឺចាប់ផ្តើមពីមួយ ពោលគឺអ្នកហ្នឹងហើយដែលត្រូវចាប់ផ្តើម*

(១) ការផ្លាស់ប្តូរគឺដោយសារវាមានគ្រឹះមួយដែលរឹងមាំ គ្រឹះនោះគឺ ពុំមានអ្នកណាម្នាក់ចង់ក្រទេ ហើយមនុស្សម្នាក់ៗចង់ក្លាយជាមនុស្សល្អ

(២) ពីនាំសិស្សម្នាក់ផ្លាស់ប្តូរ នឹងនាំសិស្សទាំងអស់ក្នុងថ្នាក់ផ្លាស់ប្តូរ

(៣) ពីថ្នាក់រៀនមួយផ្លាស់ប្តូរ ទៅថ្នាក់រៀនទាំងអស់ក្នុងសាលារៀនមួយផ្លាស់ប្តូរ

(៤) ពីសាលារៀនមួយផ្លាស់ប្តូរ ទៅសាលារៀនទាំងអស់ក្នុងក្រុង ស្រុក ខណ្ឌផ្លាស់ប្តូរ

(៥) ពីក្រុង ស្រុក ខណ្ឌមួយផ្លាស់ប្តូរ ទៅក្រុង ស្រុក ខណ្ឌទាំងអស់ក្នុងរាជធានី ខេត្តផ្លាស់ប្តូរ

(៦) ពីរាជធានី ខេត្តមួយផ្លាស់ប្តូរ ទៅរាជធានី ខេត្តទាំងអស់ក្នុងប្រទេសផ្លាស់ប្តូរ

## ៤ វប្បធម៌សហគមន៍សាលារៀន

ជារបៀបធ្វើកិច្ចការតាមបែបវិមជ្ឈការអំណាចទៅសហគមន៍និងសាលារៀន ដែលនាំឱ្យគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន សិស្ស និងសហគមន៍ មានកិច្ចការច្បាស់លាស់ និងទទួលខុសត្រូវជាមួយនឹងកិច្ចការរបស់ខ្លួន។ សៀវភៅណែនាំប្រតិបត្តិនេះនឹងរៀបរាប់ និងអធិប្បាយកិច្ចការទាំងនេះ។

### ៨ គុណតម្លៃសហគមន៍សាលារៀន

ជាការអនុវត្តគំនិតល្អដែលព្រមព្រៀងគ្នាក្នុងរយៈពេលមួយកំណត់ គំនិតល្អនោះនឹងក្លាយជាគុណតម្លៃ។ សាលារៀននិងសហគមន៍៖

(១) នឹងបម្រើប្រយោជន៍រួមនិងប្រសើរបំផុតសម្រាប់ប្រជាជននិងសិស្ស
(២) គោរពនិងថែទាំគ្នាទៅវិញទៅមក
(៣) រៀនសូត្រនិងធ្វើការជាក្រុមជាប់ជាប្រចាំ
(៤) ផ្តួចផ្តើមគំនិតថ្មីសម្រាប់អភិវឌ្ឍសាលារៀននិងសហគមន៍
(៥) ធ្វើឱ្យមាននិរន្តរភាពដំណើរការសាលារៀននិងរៀបចំសិស្សរបស់យើងសម្រាប់រស់ជាមួយជីវិតនិងការងារដែលប្រសើរ។

## ប្រព័ន្ធផ្តល់លទ្ធភាពអនុវត្ត

*ក្របខណ្ឌនិងលំដាប់អនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន*

### ១ រចនាសម្ព័ន្ធ



## ២ តួនាទី និងយុទ្ធសាស្ត្រ

| តួនាទី | យុទ្ធសាស្ត្រ (៦អា) |
|---|---|
| នាយកសាលា | (១) ការធ្វើតេស្តស្តង់ដា |
| គណៈកម្មការគ្រប់គ្រងសាលារៀន | (២) ការប្រើអំណាចសម្រេចចិត្ត |
| នាយកសាលា | (៣) ការបង្ហាញគណនេយ្យភាព |
| គណៈកម្មការគ្រប់គ្រងសាលារៀន | (៤) ការយកចិត្តទុកដល់គ្រូបង្រៀន |
| នាយកសាលា | (៥) ការយកចិត្តទុកដាក់ដល់វប្បធម៌និងគុណតម្លៃ |
| គណៈកម្មការគ្រប់គ្រងសាលារៀន | (៦) ការយកចិត្តទុកដាក់ដល់កុមារតូច |

| ដំណាក់កាលអភិវឌ្ឍសហគមន៍សាលារៀនជាការទទួលខុសត្រូវរួមគ្នារវាងនាយកសាលា គណៈកម្មការគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន |
|---|
| ឆ្នាំទី១ ការធ្វើឱ្យសាលារៀននិងថ្នាក់រៀនមានដំណើរការសម្រាប់ការសិក្សារៀនសូត្រ |
| ឆ្នាំទី២ ការធ្វើឱ្យសាលារៀនបំពេញបានស្តង់ដាអប្បបរមាសាលារៀនមានប្រសិទ្ធភាព |
| ឆ្នាំទី៣ ឆ្ពោះទៅរកការរក្សានិរន្តរភាពសាលារៀនជាមួយកម្មវិធីបំណិនរកចំណូល |
| ឆ្នាំទី៤ សាលារៀនមានដំណើរការប្រកបដោយនិរន្តរភាព និងឈានឆ្ពោះទៅដូចសាលារៀននៃប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ |

## ៣ តួនាទី និងស្តង់ដាសហគមន៍សាលារៀន

| តួនាទី | ស្តង់ដាសហគមន៍សាលារៀន |
|---|---|
| គណៈគ្រប់គ្រងសាលារៀន | ស្តង់ដាទី១៖ សាលារៀនមានដំណើរការសម្រាប់ផលសម្រេចការអប់រំនិងការសិក្សាសិស្ស |
| គ្រូបង្រៀន | ស្តង់ដាទី២៖ ថ្នាក់រៀនមានដំណើរការសម្រាប់ការបង្រៀននិងការសិក្សារបស់សិស្សម្នាក់ៗ |
| គណៈកម្មការគ្រប់គ្រងសាលារៀន | ស្តង់ដាទី៣៖ ភាពជាម្ចាស់សហគមន៍សាលារៀន |
| គណៈគ្រប់គ្រងសាលារៀន | ស្តង់ដាទី៤៖ ដំណើរការរដ្ឋបាលនិងប្រតិបត្តិការសហគមន៍សាលារៀន |
| ថ្នាក់ជាតិនិងក្រោមជាតិ | ស្តង់ដាទី៥៖ គណនេយ្យភាពថ្នាក់ជាតិនិងក្រោមជាតិ |

*ការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន (គ.គ.ស.)*

គ.គ.ស. ជារចនាសម្ព័ន្ធផ្លូវការមានតួនាទីទទួលខុសត្រូវរួម និងគ្រប់គ្រងការអនុវត្តការគ្រប់គ្រងតាមសាលារៀនប្រចាំថ្ងៃ និងអភិវឌ្ឍសាលារៀន។ ចំនួនសមាជិកគ.គ.ស.គឺមានភាពបត់បែនអាស្រ័យទៅលើទំហំសាលារៀនធំ មធ្យម ឬតូច។ សម្រាប់សាលារៀនតូច គ.គ.ស.ត្រូវមានចំនួនសមាជិកយ៉ាងតិច៦នាក់ (លើកទឹកចិត្តឱ្យមានសមាជិកលើសពីនេះ) ជាអ្នកដែលត្រូវបានជ្រើសរើសពីសហគមន៍ ដែលមានគ្រួសារក្រីក្រនិងយ៉ាប់យ៉ឺន គ្រួសារអ្នកមានឬមធ្យម ប្រធានភូមិ ប្រជាជនដែលមានការគោរពពីសហគមន៍ សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ រដ្ឋអំណាចក្រុង ស្រុក ខណ្ឌ មន្ត្រីឃុំ ឬ មន្ត្រីមន្ទីរពេទ្យ ឬ សុខាភិបាល មន្ត្រីរាជការ សហគមន៍មានបំណិនវិជ្ជាជីវៈ និង សិស្ស ឬ សមាជិកក្រុមប្រឹក្សាយុវជនជាដើម។ ការជ្រើសរើស គ.គ.ស. ត្រូវតែអនុវត្តឱ្យបានត្រឹមត្រូវទៅតាមសេចក្ដីណែនាំដូចខាងក្រោម ដើម្បីចៀសវាងភាពគ្មានប្រសិទ្ធភាពនៅក្នុងការអនុវត្តមុខងារ ដែលបណ្ដាលមកពីការបង្កើតគ.គ.ស.មានទំនោរទៅការបំពេញចិត្តឱ្យបុគ្គលមានអំណាចគ្របដណ្ដប់ការជ្រើសរើស៖

**សមាសភាពសមាជិក គ.គ.ស. មាន៖**

(១) ប្រធាន ១រូប ទទួលខុសត្រូវរួមលើដំណើរការគ្រប់គ្រងសាលារៀន
(២) អនុប្រធាន ១រូប ទទួលខុសត្រូវលើការធ្វើផែនការនិងថវិកា
(៣) អនុប្រធាន ១រូប ទទួលខុសត្រូវលើការគ្រប់គ្រងការអនុវត្តការងារមន្ត្រី
(៤) សមាជិក ១រូប ទទួលខុសត្រូវលើការធ្វើតេស្តវាយតម្លៃសមត្ថភាពសិស្សនិងការបង្រៀន
(៥) សមាជិក ១រូប ទទួលខុសត្រូវលើការរកមូលនិធិនៅសាលារៀន និងពីសហគមន៍ និងកម្មវិធីបំណិនរកចំណូល
(៦) សមាជិក ១រូប ទទួលខុសត្រូវលើការពិនិត្យតាមដាននិងវាយតម្លៃ និងការចែករំលែកទិន្នន័យទៅសាធារណៈ

គ.គ.ស. ដែលបានរៀបចំបង្កើតឡើងត្រូវបានអនុម័តយល់ព្រមដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាម រយៈការិយាល័យអប់រំ យុវជន និងកីឡា ក្នុងរយៈពេលប្រាំពីរថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីសាលារៀនដាក់ស្នើសុំការឯកភាព។ ផ្ទុយទៅវិញបើមានការលំបាកលើនីតិវិធីរដ្ឋបាល គ.គ.ស.អាចអនុម័តតាមរយៈការព្រមព្រៀងគ្នាត្រឹមកម្រិតសហគមន៍របស់ខ្លួន។

នៅឆ្នាំទី១នៃការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន នាយកសាលាត្រូវអញ្ជើញសហគមន៍មកចូលរួមប្រជុំដើម្បីរៀបចំជ្រើសរើសសមាសភាពបង្កើតគ.គ.ស.។ លិខិតអញ្ជើញត្រូវផ្ញើទៅសមាជិកគ្រប់គ្រួសារ ក្នុងសហគមន៍តាមរយៈសិស្ស ឬ គ្រូបង្រៀន ឬ បុគ្គលិកអប់រំ ឬ ប្រធានភូមិ។ នាយកសាលាត្រូវធានាថាគ្រួសារក្រីក្រនិងយ៉ាប់យ៉ឺនត្រូវបានអញ្ជើញមកចូលរួមក្នុងការប្រជុំនេះ។ ក្នុងករណីចាំបាច់ ក្រសួង ឬ មន្ទីរអ.យ.ក. ឬ ការិយាល័យអ.យ.ក. ឬ សាលារៀននៅក្នុងឃុំ សង្កាត់ ឬ នៅក្នុងក្រុង ស្រុក ខណ្ឌជាមួយ ដែលមានបទពិសោធន៍អនុវត្តការងារនេះ ត្រូវបានអញ្ជើញមកឱ្យជួយរៀបចំការងារនេះផងដែរ។

ការប្រជុំត្រូវមានដំណើរការដូចខាងក្រោម៖

- នាយកសាលាបង្ហាញនូវសារតារដែលនាំមកនូវការប្រជុំនេះដែលមានខ្លឹមសារដូចតទៅ៖ យកខ្លឹមសារនៃសារតារសេចក្តីណែនាំនេះមកអានបញ្ជាក់ពី វត្ថុបំណងនៃការប្រជុំគឺ ការបង្កើតគ.គ.ស. សមាសភាពដែលអាចឈរឈ្មោះសម្រាប់ការបោះឆ្នោតគ.គ.ស. តួនាទីក្នុងគ.គ.ស. និងជំហាននៃការជ្រើសរើសគ.គ.ស.។
- ជំហាននៃការជ្រើសរើសគ.គ.ស.
  - ទី១៖ ស្នើដល់សមាជិកអង្គប្រជុំសរសេរលើក្រដាសតូចនូវឈ្មោះយ៉ាងតិច៣នាក់ ជាអ្នកដែលខ្លួនជឿទុកចិត្តជាតំណាងសហគមន៍ ដើម្បីឈរឈ្មោះជាអ្នកដែលអង្គប្រជុំបោះឆ្នោតរើសជាសមាជិកគ.គ.ស.
  - ទី២៖ មន្ត្រីសាលារៀន ឬគ្រូបង្រៀនសរសេរឈ្មោះទាំងអស់លើក្តារខៀនឬក្រដាសផ្ទាំងស រួចហើយដាល់លេខរៀនពី១ រហូតដល់ឈ្មោះចុងក្រោយ
  - ទី៣៖ ស្នើដល់សមាជិកអង្គប្រជុំម្នាក់ៗជ្រើសយកឈ្មោះដែលមានស្រាប់ចំនួន៣ ពីក្តារខៀនឬក្រដាសផ្ទាំងស ដោយគ្រាន់តែសរសេរលេខរៀងដែលខ្លួនពេញចិត្ត មកដាក់លើក្រដាសតូចមួយរបស់ខ្លួន រួចប្រគល់ជូនទៅអ្នកសម្របសម្រួលដើម្បីធ្វើកិច្ចការបន្ត
  - ទី៤៖ មន្ត្រីសាលារៀនឬគ្រូបង្រៀនម្នាក់អានលេខនៅក្នុងក្រដាសម្តងមួយៗ។ មន្ត្រីសាលារៀនឬគ្រូបង្រៀនម្នាក់ទៀតគូសសញ្ញាសម្គាល់សំឡេងឆ្នោត លើក្តារខៀនឬក្រដាសផ្ទាំងស នៅខាងក្រោយលេខ ឬ ឈ្មោះ ដែលបានទទួលសំឡេងឆ្នោត រួចហើយរាប់ចំនួនលេខនៅក្រោយឈ្មោះ និងកត់ត្រាចំនួនសំឡេងឆ្នោតសរុបនៅខាងចុងឈ្មោះម្នាក់ៗ
  - ទី៥៖ ការសម្រេចបញ្ជីឈ្មោះ និងតួនាទីគ.គ.ស.
    - ឈ្មោះណាមួយដែលទទួលបានសំឡេងឆ្នោតច្រើនជាងគេគឺ ត្រូវទទួលបានការទុកចិត្តជាងពីសហគមន៍ខ្លាំងជាងគេ នឹងត្រូវធ្វើជាប្រធាន គ.គ.ស.
    - ឈ្មោះដែលទទួលបានសំឡេងឆ្នោតបន្ទាប់ នឹងត្រូវទទួលជាអនុប្រធានទទួលបន្ទុកការធ្វើផែនការនិងថវិកា
    - ឈ្មោះដែលទទួលបានសំឡេងឆ្នោតបន្ទាប់ នឹងត្រូវទទួលជាអនុប្រធានទទួលបន្ទុកការគ្រប់គ្រងមន្ត្រី
    - ឈ្មោះដែលទទួលបានសំឡេងឆ្នោតបន្តបន្ទាប់ចំនួនបីនាក់ទៀត ឬ ច្រើនជាងនេះ នឹងត្រូវទទួលបន្ទុកជាសមាជិកគ.គ.ស. (សម្រាប់សាលារៀន មធ្យម ឬ ធំ អាចមានអនុប្រធាន បួននាក់ និងសមាជិកចាប់ពីប្រាំនាក់ឡើងទៅ)
    - នាយកសាលាសម្របសម្រួលជាមួយអ្នកមានឈ្មោះជាប់ជាគ.គ.ស. ថាតើគាត់ព្រមទទួលយកតួនាទីដែលសហគមន៍បានផ្តល់ការទុកចិត្តឬទេ
    - ប្រសិនបើមាននរណាម្នាក់ចង់ផ្លាស់ប្តូរតួនាទីរបស់ខ្លួន នោះនាយកសាលាត្រូវពិភាក្សាក្នុងអង្គប្រជុំ ដើម្បីសម្រេច
    - សម្រេចបញ្ជីឈ្មោះអ្នកជាប់ឆ្នោតជាស្ថាពរ និងតួនាទី
    - នាយកសាលាប្រកាសជាសាធារណៈឈ្មោះនិងតួនាទីអ្នកជាប់ឆ្នោតស្ថាពរឱ្យបានលឺៗក្នុងអង្គប្រជុំ រួចស្នើឱ្យសមាជិកទាំងអស់នៃអង្គប្រជុំលើកដៃបញ្ជាក់ការព្រមព្រៀងចុងក្រោយ

- ទី៦៖ សមាសភាព គ.គ.ស.ម្នាក់ៗ ដែលទើបនឹងជាប់ឆ្នោត ត្រូវចុះហត្ថលេខាលើបញ្ជីឈ្មោះ
- ទី៧៖ នាយកសាលាដាក់ស្នើបញ្ជីឈ្មោះគ.គ.ស.ទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរយៈការិយាល័យ អប់រំ យុវជន និងកីឡា ដើម្បីសូមការអនុម័ត ក្នុងរយៈពេលប្រមាណប្រាំពីរនៃថ្ងៃធ្វើការ។

- បញ្ជាក់៖ អាណត្តិរបស់ គ.គ.ស. មានសុពលភាពរយៈពេលមួយឆ្នាំ ដោយគិតចាប់តាំងពីការទទួលបានការអនុម័ត។ ប្រសិនបើគ.គ.ស.មានដំណើរល្អ គ.គ.ស.អាចបន្តសុពលភាពរបស់ខ្លួន ដោយមានការព្រមព្រៀងពីរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬ ស្មារតីអង្គប្រជុំប្រចាំឆ្នាំរបស់សហគមន៍។ ផ្ទុយទៅវិញប្រសិនបើ គ.គ.ស. ដំណើរការមិនល្អ នោះសាលារៀនត្រូវចាប់ផ្តើមធ្វើការជ្រើសរើស គ.គ.ស. ថ្មីតាមជំហានខាងលើនៅឆ្នាំបន្ទាប់។

សម្រាប់សាលារៀនដែលបានអនុវត្តការគ្រប់គ្រងតាមសាលារៀនច្រើនឆ្នាំហើយ និងបានបំពេញស្តង់ដាសាលារៀនមានប្រសិទ្ធភាពហើយនោះ គ.គ.ស. និងនាយកសាលាអាចពិភាក្សាដើម្បីផ្លាស់ប្តូរពីឈ្មោះ គ.គ.ស. មកជា ក្រុមប្រឹក្សាសាលារៀន (ក.ប.ស.) វិញ។ ក.ប.ស. មានស្វ័យភាពច្រើនជាងគ.គ.ស. ជាពិសេសលើការងាររដ្ឋបាលនិងហិរញ្ញវត្ថុ។ ក.ប.ស.អាចមានចំនួនសមាជិកច្រើន ជាពិសេសមកពីគ្រួសារអ្នកមានសេដ្ឋកិច្ចធូរធារដែលមានការប្តេជ្ញាចិត្តជួយអភិវឌ្ឍសាលារៀន។

ដូចដែលបានរៀបរាប់ខាងដើម នាយកសាលានិងគ.គ.ស. ត្រូវធានាការប្រើប្រាស់ស្វ័យភាពសម្រាប់គណនេយ្យភាពតាមរយៈការអនុវត្តប្រព័ន្ធ៦អាបិទជិត។

**ភារកិច្ចចម្បងរបស់នាយកសាលា និងគ.គ.ស. ឬ ក.ប.ស.**

នាយកសាលាដែលបានអភិវឌ្ឍសាលារៀន បំពេញបាននូវស្តង់ដាសាលារៀនមានប្រសិទ្ធភាពជានាយកសាលាល្អ ហើយគាត់នឹងត្រូវបន្តការងាររបស់គាត់ជានាយកសាលា។ នាយកសាលា មានតួនាទីជា ប្រធានប្រតិបត្តិ ហើយគាត់ និងគ.គ.ស. មានភារកិច្ចធំៗដូចខាងក្រោម៖

(១) កែលម្អការសិក្សារៀនសូត្ររបស់សិស្សពីថ្នាក់ទី៧ ដល់ ទី១២ នាំឱ្យសិស្សអាចរៀនទទួលបាននូវកម្រិតល្អនិងល្អប្រសើរលើមុខវិជ្ជាគោល
(២) ផ្តោតការសិក្សារបស់សិស្សលើមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យា ជាអាទិភាព ពិសេសនៅកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា
(៣) អនុវត្តអនុសាសន៍របាយការណ៍ការគ្រប់គ្រងហិរញ្ញវត្ថុ និងសវនកម្ម
(៤) ធ្វើឱ្យការសិក្សាមានភាពបន្សុីគ្នារវាងសាលាមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា ដើម្បីឈានឆ្ពោះទៅឧត្តមសិក្សា
(៥) បង្កើនប្រសិទ្ធផល និង កំណត់មុខសញ្ញាប្រើប្រាស់ធនធាន ដោយផ្តោតលើអាទិភាពរបស់សាលារៀនដែលមានមូលដ្ឋានលើយុទ្ធសាស្ត្រ វប្បធម៌ និងគុណតម្លៃ។

ក.ប.ស. មានស្វ័យតាពច្រើនលើការងាររដ្ឋបាលនិងហិរញ្ញវត្ថុ - កិច្ចការចម្បងនៃក.ប.ស. គឺ៖

(១) ផ្តល់មូលនិធិដល់សាលារៀន និងគ្រប់គ្រងចំណូលនិងចំណាយទាំងអស់

(២) សម្រេចលើគម្រោងវិនិយោគរបស់សាលារៀន

(៣) សម្រេចលើផែនការនិងថវិកាសាលារៀន

(៤) ពិនិត្យតាមដានការអនុវត្តការងាររបស់សាលារៀនក្នុងបរិបទផ្លាស់ប្តូរ

(៥) សម្រេចចិត្តលើការជ្រើសរើសនិងបញ្ឈប់បុគ្គលិក

(៦) បង្កើតទំនាក់ទំនងសាធារណៈសម្រាប់អភិវឌ្ឍសាលារៀន។

តួនាទីសិស្សនិងយុវជន

(១) នៅឆ្នាំទី១៖ សិស្សម្នាក់ៗត្រូវទទួលខុសត្រូវលើការរៀនសូត្ររបស់ខ្លួន តាមរយៈការធ្វើផែនការនិងពិនិត្យតាមដានការសិក្សារបស់ខ្លួន។ សម្រាប់ថ្នាក់រៀន សិស្សត្រូវជួយគ្រូបង្រៀនក្នុងការគ្រប់គ្រងរដ្ឋបាលថ្នាក់រៀន តាមរយៈការរៀបជាក្រុមប្រឹក្សាកុមារ យុវជនតាមថ្នាក់រៀន និងចូលរួមប្រជុំពិនិត្យ តាមដាននៅកម្រិតថ្នាក់រៀន។

(២) នៅឆ្នាំទី២៖ សិស្សម្នាក់ៗបន្តកិច្ចការឆ្នាំទី១ និងឈានដល់ការជួយគណៈគ្រប់គ្រងសាលារៀនក្នុងដំណើរប្រតិបត្តិការសាលារៀន។ សិស្សអាចបង្កើតជាក្រុមប្រឹក្សាកុមារ យុវជនកម្រិតសាលារៀន និងចូលរួមក្នុងការប្រជុំពិនិត្យតាមដាននៅកម្រិតសាលារៀន។

(៣) នៅឆ្នាំទី៣៖ សិស្សបន្តកិច្ចការឆ្នាំទី១និងទី២ និងឈានដល់ការជ្រើសរើសតំណាងចូលរួមជាសមាជិកក្នុងគណៈកម្មការគ្រប់គ្រងសាលារៀន និងកិច្ចការគណៈកម្មការគ្រប់គ្រងសាលារៀន។

(៤) នៅឆ្នាំទី៤៖ សិស្សបន្តការងារពីឆ្នាំមុនៗ និងតំណាងក្រុមប្រឹក្សាកុមារ យុវជនចូលជាសមាជិកក្នុងក្រុមប្រឹក្សាសាលារៀន ប្រសិនបើសាលារៀនប្រែក្លាយពីគណៈកម្មការគ្រប់គ្រងសាលារៀនមកជាក.ប.ស.។

តួនាទីថ្នាក់ក្រោមជាតិ

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធានានូវការអនុវត្តកិច្ចការចំនួនពីរគឺ ១) ផ្តល់ធាតុចូលដល់សាលារៀន ពិសេសលើគ្រូបង្រៀននិងនាយកសាលា និង ២) សម្របសម្រួលកសាងសមត្ថភាពសាលារៀន។

*សម្រាប់សាលារៀនដែលទើបអនុវត្តកម្មវិធីយុទ្ធសាស្ត្រសហគមន៍សាលារៀន*

ក្រសួងអប់រំ យុវជន និងកីឡា ផ្តល់ថវិកាដល់ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដើម្បីអនុវត្តការពិនិត្យតាមដាន និងផ្តល់ការគាំទ្រដល់សាលារៀន ទៅតាមអ្វីដែលសាលារៀនត្រូវការ។ ដូច្នេះការិយាល័យ និងមន្ទីរ ត្រូវរៀបចំកម្មវិធីចុះពិនិត្យតាមដាន ដោយមានការព្រមព្រៀងជាមួយសាលារៀនមុននឹងចុះពិនិត្យតាមដាន និងផ្តល់ការគាំទ្រទាំងផ្នែកដឹកនាំ គ្រប់គ្រង បច្ចេកទេស និងពេលវេលា។

កម្មវិធីពិនិត្យតាមដានត្រូវមានខ្លឹមសារដូចតទៅ៖ វត្ថុបំណង តារាងពេលវេលាពិនិត្យតាមដានដោយមានបញ្ជាក់ពីប្រធានបទត្រូវពិភាក្សា ឬ មើលថ្នាក់រៀន មានអ្នកទទួលខុសត្រូវច្បាស់លាស់តាមកម្មវិធី ឬខ្លឹមសារនីមួយៗ

មានបញ្ជាក់ឈ្មោះអ្នកចុះពិនិត្យតាមដាន និងត្រូវបញ្ចប់ការពិនិត្យតាមដានដោយមានការបង្ហាញច្បាស់លាស់ថាបានរកឃើញអ្វី និងមានការព្រមព្រៀងនូវសកម្មភាពអ្វីដែលត្រូវធ្វើក្រោយការពិនិត្យតាមដាន ធ្វើដោយអ្នកណា និងត្រូវបញ្ចប់នៅពេលណា។

គ្រប់ការចុះពិនិត្យតាមដាន មន្ត្រីការិយាល័យ និងមន្ទីរ ត្រូវធ្វើរបាយការណ៍ពិនិត្យតាមដានឱ្យបានច្បាស់លាស់ដែលបញ្ជាក់នូវខ្លឹមសារទាំងអស់ដែលបានលើកឡើងខាងលើ។ ចំនួនដងនៃការចុះពិនិត្យតាមដានត្រូវស៊ីគ្នានឹងចំនួនដង ដែលមានចែងនៅក្នុងផែនការកែលម្អសាលារៀនប្រចាំឆ្នាំ។

*សម្រាប់សាលារៀនដែលបានបំពេញនូវស្តង់ដាសហគមន៍សាលារៀន*

ថ្នាក់ក្រោមជាតិ អាចចុះទស្សនកិច្ចនៅសាលារៀនដែលបានបំពេញបានស្តង់ដា សហគមន៍សាលារៀនសម្រាប់ជាការរៀនសូត្រ ហើយគប្បីផ្តោតលើការចុះជួយសាលារៀនថ្មីដែលចាប់ផ្តើមអនុវត្តកម្មវិធីកំណែទម្រង់។ គោលបំណងនៃការចុះទស្សនកិច្ចត្រូវផ្តោតលើការពិភាក្សា និងការព្រមព្រៀងគ្នារវាងថ្នាក់ក្រោមជាតិ ជាមួយសាលារៀនមានស្តង់ដា ថានឹងត្រូវជួយសាលារៀនណាដែលនៅខ្សោយ។

## តួនាទីថ្នាក់ជាតិ

ក្រុមការងារអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀនថ្នាក់ជាតិត្រូវបានបែងចែកជាបីប្រភេទ ឬ ក្រុមគឺ ១) នាយកសាលា និងគ្រូបង្រៀនដែលបានបរិញ្ញាបត្រជាន់ខ្ពស់ពីកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន ឬគ្រូបង្រៀន និងជាគ្រូបង្រៀននៅមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ឬ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូជាតំណាងថ្នាក់ជាតិឈរជើងនៅតាមសាលារៀន ២)ក្រុមការងារតំបន់របស់ក្រសួង ជាអ្នកមានបរិញ្ញាបត្រជាន់ខ្ពស់ពីមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ឬគ្រឹះស្ថានបណ្តុះបណ្តាលគ្រូក្នុងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន ឬគ្រូបង្រៀន ឬអ្នកមានពិសោធន៍ដឹកនាំ ឬបង្រៀននៅសាលារៀនច្រើនឆ្នាំ ជាតំណាងក្រសួង និង ៣) មន្ត្រីដឹកនាំ ឬគ្រប់គ្រងថ្នាក់ក្រសួង ឬ មហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ឬគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន និងគណៈគ្រប់គ្រងផ្សេងទៀត។

ក្រុមទី១៖ នាយកសាលា ឬ គ្រូបង្រៀនដែលជាគ្រូបង្រៀន/គ្រូឧទ្ទេសនៅមហាវិទ្យាល័យអប់រំ ឬ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន មានកម្មវិធីបង្វឹកជាក់លាក់ ជាមួយនាយកសាលាឬគ្រូបង្រៀន នៅពេលនាយកសាលា ឬគ្រូបង្រៀនមករៀននៅក្នុងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន ឬគ្រូបង្រៀន។ ការចុះបេសកកម្មរបស់នាយកសាលា ឬ គ្រូបង្រៀន គឺ ភាគច្រើនជាការបង្វឹកនាយកសាលា ឬគ្រូបង្រៀនដែលកំពុងបន្តការសិក្សាឱ្យអាចបំពេញបាននូវកិច្ចការដែលបានទទួលពីគ្រឹះស្ថានបណ្តុះបណ្តាល និងពិសេសដើម្បីបំពេញគ្រប់លក្ខខណ្ឌបញ្ចប់វគ្គសិក្សា។ នៅពេលដែលនាយកសាលា ឬ គ្រូបង្រៀនបានបញ្ចប់ការសិក្សាពីវគ្គលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលា និងគ្រូបង្រៀននោះ ការបង្វឹកនាយកសាលានិងគ្រូបង្រៀន ក្លាយជាការចុះពិនិត្យតាមដាន ការគាំទ្រ និងធ្វើបច្ចុប្បន្នកម្មចំណេះដឹង រហូតដល់សាលារៀនអាចស្វ័យដំណើរការ និងបំពេញបាននូវស្តង់ដាសហគមន៍សាលារៀន។

ក្រុមទី២៖ ក្រុមការងារតំបន់ ចុះពិនិត្យតាមដាន ផ្តល់ការគាំទ្រ ហើយត្រូវបំពេញបាននូវការគាំទ្រដែលជាការធានានូវការផ្តល់ធាតុចូល និងកសាងសមត្ថភាពសាលារៀន។ ការគាំទ្រអាចជាការសម្របសម្រួល ឬជាការជួយពង្រឹង

សមត្ថភាពបច្ចេកទេសដល់នាយកសាលានិងគ្រូបង្រៀន។ ការចុះពិនិត្យតាមដានគប្បីផ្តោតលើសាលារៀនដែលនៅមិនទាន់បំពេញបាននូវស្តង់ដាសហគមន៍សាលារៀន។ ការចុះពិនិត្យតាមដានត្រូវមានរបាយការណ៍ជាក់លាក់ពីលទ្ធផលនៃការចុះពិនិត្យតាមដាន។ លំនាំរបាយការណ៍គឺដូចគ្នានឹងរបាយការណ៍ថ្នាក់ក្រោមជាតិ។ (ឧបសម្ព័ន្ធ.......)

ក្រុមទី៣៖ មន្ត្រីដឹកនាំ ឬ គ្រប់គ្រងថ្នាក់ក្រសួង ឬ មហាវិទ្យាល័យអប់រំ ឬ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ អាចចុះពិនិត្យតាមដានក្នុងបរិបទអនុវិស័យ ឬ ចម្រុះអនុវិស័យដែលមានអនុវិស័យអប់រំកុមារតូច អប់រំបឋមសិក្សា និងអប់រំមធ្យមសិក្សាចំណេះទូទៅ។ ការចុះពិនិត្យតាមដាន ផ្តល់ការគាំទ្រនៃក្រុមទីបី គឺ ជាការចុះពិនិត្យវឌ្ឍនភាព ឬ ឧបសគ្គ ឬ ការរាំងស្ទះនៃដំណើរការប្រព័ន្ធទាំងបីថ្នាក់ នៃរាជធានី ខេត្ត ថ្នាក់ ក្រុង ស្រុក ខណ្ឌ និងសាលារៀន។ វត្ថុបំណងនៃការចុះរួមមាន ការសិក្សារៀនសូត្រពីភាពជោគជ័យឬបរាជ័យ ការកំណត់អនុសាសន៍ផ្តល់ការគាំទ្រ និងអនុសាសន៍ដែលថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលារៀនត្រូវអនុវត្តបន្ទាប់ពីពិនិត្យតាមដានរួច។ ម្យ៉ាងវិញទៀតការចុះពិនិត្យតាមដាននេះ គឺដើម្បីសិក្សាពីប្រសិទ្ធភាពនៃការជួយរបស់សាលាមានស្តង់ដាទៅសាលាដែលនៅពុំទាន់មានស្តង់ដា ជាមួយគ្នានឹងភាពប្រទាក់ប្រទងគ្នានៃកិច្ចសហការរវាងសាលាមត្តេយ្យសិក្សា ជាមួយនឹងសាលាបឋមសិក្សា និងសាលាមធ្យមសិក្សា។ ការចុះពិនិត្យតាមដានត្រូវមានរបាយការណ៍ជាក់លាក់ពីលទ្ធផលនៃការចុះពិនិត្យតាមដាន។ របាយករណ៍ត្រូវផ្តោតលើ វត្ថុបំណងនៃការពិត្យតាមដាន និងអនុសាសន៍ដែលមានការព្រមព្រៀងគ្នារវាងថ្នាក់ក្រោមជាតិ និងសាលារៀន។ (ឧបសម្ព័ន្ធ.......)

## ៤ ស្តង់ដាសហគមន៍សាលារៀន និងការវាយតម្លៃ

ការផ្តល់ពិន្ទុនិងការកំណត់ស្តង់ដាអប្បបរមា

- សាលាមួយអាចចាត់ទុកថាបំពេញបាននូវស្តង់ដាអប្បបរមា លុះណាសាលានោះមានពិន្ទុសរុបយ៉ាងតិច ២១០ ពិន្ទុ ហើយស្តង់ដានីមួយៗត្រូវបំពេញបាននូវពិន្ទុអប្បបរមារបស់ខ្លួនដូចតារាងខាងក្រោម។ បើទោះជាសាលាមានពិន្ទុសរុប២១០ ឬ លើសក៏ដោយ តែបើស្តង់ដាណាមួយមិនមានពិន្ទុអប្បបរមាទេ នោះមិនអាចចាត់ទុកថាជាសាលាមានស្តង់ដាអប្បបរមានោះទេ។

| | ស្តង់ដាទី១ | ស្តង់ដាទី២ | ស្តង់ដាទី៣ | ស្តង់ដាទី៤ | ស្តង់ដាទី៥ | សរុបពិន្ទុ |
|---|---|---|---|---|---|---|
| ពិន្ទុអប្បបរមា | ៣៩ | ៤៨ | ៤៨ | ៤៨ | ២៧ | ២១០ |

### ស្តង់ដាសហគមន៍សាលារៀន

| ល.រ. | ស្តង់ដានិងសូចនាករ | ពិន្ទុ១ | ពិន្ទុ២ | ពិន្ទុ៣ | ពិន្ទុ៤ |
|---|---|---|---|---|---|
| ស្តង់ដាទី១៖ សាលារៀនមានដំណើរការសម្រេចផលសម្រេចការអប់រំនិងការសិក្សារៀនសូត្ររបស់សិស្ស (ទិន្នន័យយេនឌ័រនៅគ្រប់សូចនាករ) | | | | | |
| ១ | ចំនួននិងភាគរយសិស្សចូលរៀន | >៩០% | >៩៥% | >៩៧% | >៩៩% |
| ២ | ចំនួននិងភាគរយសិស្សបោះបង់ការសិក្សា | >៣% | ៣% | ១-២% | <១% |

| | | | | | |
|---|---|---|---|---|---|
| ៣ | ចំនួននិងភាគរយសិស្សឡើងថ្នាក់ | <៩៥% | <៩៦% | =<៩៨% | >៩៨% |
| ៤ | ចំនួននិងភាគរយសិស្សមាននិទ្ទេស A និង B មុខវិជ្ជាភាសាខ្មែរ | =<១៩% | ២០%-២៩% | ៣០%-៣៩% | ៤០%-៥០% (២០និង៣០) |
| ៥ | ចំនួននិងភាគរយសិស្សមាននិទ្ទេស A និង B មុខវិជ្ជាគណិតវិទ្យា | =<១៩% | ២០%-២៩% | ៣០%-៣៩% | ៤០%-៥០% (២០និង៣០) |
| ៦ | ចំនួននិងភាគរយសិស្សមាននិទ្ទេសចាប់ពីមធ្យមឡើងមុខវិជ្ជារូបវិទ្យា (A, B, C) | <១៩% | ២០%-៣៩% | ៤០%-៥៩% | ៦០%-៨០% (20/30/30) |
| ៧ | ចំនួននិងភាគរយសិស្សមាននិទ្ទេសចាប់មធ្យមឡើងមុខវិជ្ជាគីមីវិទ្យា (A, B, C) | <១៩% | ២០%-៣៩% | ៤០%-៥៩% | ៦០%-៨០% (20/30/30) |
| ៨ | ចំនួននិងភាគរយសិស្សមាននិទ្ទេសចាប់ពីមធ្យមឡើងមុខវិជ្ជាជីវវិទ្យា (A, B, C) | <១៩% | ២០%-៣៩% | ៤០%-៥៩% | ៦០%-៨០% (20/30/30) |
| ៩ | ចំនួននិងភាគរយសិស្សមាននិទ្ទេសចាប់ពីមធ្យមឡើងមុខវិជ្ជាប្រវត្តិវិទ្យា(A, B, C) | <១៩% | ២០%-៣៩% | ៤០%-៥៩% | ៦០%-៨០% ( 20/30/30 ) |
| ១០ | ចំនួននិងភាគរយសិស្សថ្នាក់ទី៧មានសមត្ថភាពអានតាមស្តង់ដា (១០០ទៅ១២០ពាក្យក្នុងមួយនាទី) | >៤៥% | >៦០% | >៧៥% | >៨០% |
| ១១ | ចំនួននិងភាគរយសិស្សថ្នាក់ទី៩មានសមត្ថភាពអានតាមស្តង់ដា(២០០ទៅ២៥០ពាក្យក្នុងមួយនាទី) | >៤៥% | >៦០% | >៧៥% | >៨០% |
| ១២ | ចំនួននិងភាគរយសិស្សប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ | >60% | >70% | >80% | >90% |
| ១៣ | ចំនួននិងភាគរយសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ | >60% | >70% | >80% | >90% |
| | ***សរុបពិន្ទុស្តង់ដាទី១*** | ***១៣*** | ***២៦*** | ***៣៩*** | ***៥២*** |
| **ស្តង់ដាទី២៖ ថ្នាក់រៀនដំណើរការសម្រាប់ការបង្រៀន និងការសិក្សារៀនសូត្ររបស់សិស្សម្នាក់ៗ** | | | | | |
| ១ | ចំនួនថ្នាក់រៀនមានផែនការបង្រៀនបីឆ្នាំតាមមុខវិជ្ជា | >៨៥% | >៩០% | >៩៥% | =/<១០០% |
| ២ | ចំនួនថ្នាក់រៀនមានផែនការបង្រៀនប្រចាំឆ្នាំតាមមុខវិជ្ជា | >៨៥% | >៩០% | >៩៥% | =/<១០០% |
| ៣ | ចំនួនមុខវិជ្ជាមានបំណែងចែកកម្មវិធី | =/<៦ | ៧-៨ | ៩-១០ | ១១-១២ |

| | | | | | |
|---|---|---|---|---|---|
| | សិក្សាបង្រៀនប្រចាំសប្តាហ៍ និងកាលវិភាគបង្រៀនលម្អិតតាមមេរៀន | | | | |
| ៤ | ចំនួនមុខវិជ្ជាថ្នាក់ទី៧ ដល់ទី១២ មានប្លង់មេរៀនគ្រប់មេរៀន | ៦ | ៧-៨ | ៩-១០ | ១១-១២ |
| ៥ | ចំនួនថ្នាក់រៀនមានផែនការបង្រៀនបីខែ | >៨៥% | >៩០% | >៩៥% | =/<១០០% |
| ៦ | ចំនួនថ្នាក់រៀនមានការប្រជុំពិនិត្យតាមដានប្រចាំខែទៀងទាត់លើការរៀនសូត្រ | >៨៥% | >៩០% | >៩៥% | ១០០% |
| ៧ | ចំនួននិងភាគរយសិស្សមានផែនការសិក្សារៀនសូត្រប្រចាំឆ្នាំនិងបានអនុវត្តការតាមដានផែនការនេះប្រចាំឆ្នាំសិក្សា | >៨៥% | >៩០% | >៩៥% | ១០០% |
| ៨ | ចំនួននិងភាគរយសិស្សរៀនសូត្របំណិនរកចំណូលផ្នែកកសិកម្មនិងបច្ចេកទេស | >៥០% | >៦០% | >៧០% | =/>៨០% |
| ៩ | ចំនួនសិស្សបានធ្វើកិច្ចការគម្រោងទាំងអស់ (ត្រូវមានរៀបចំកញ្ចប់កិច្ចការ) | >៨៥% | >៩០% | >៩៥% | =/<១០០% |
| ១០ | ចំនួនដងនៃការប្រកួតប្រជែងអំណានប្រចាំឆ្នាំសិក្សា | =/<៦ | ៦-៧ | ៨-៩ | >១០ |
| ១១ | ចំនួនដងនៃការប្រកួតប្រជែងលើមុខវិជ្ជាគណិតវិទ្យាប្រចាំឆ្នាំសិក្សា | =/<៦ | ៦-៧ | ៨-៩ | >១០ |
| ១២ | ចំនួននិងភាគរយសិស្សអវត្តមានលើស៤ដងក្នុងមួយឆ្នាំសិក្សា | ២% | ១,៥% | ១,០% | ០,៥% |
| ១៣ | ចំនួនដងគ្រូអវត្តមានមិនមានគ្រូជំនួសប្រចាំឆ្នាំសិក្សា | <២០ | <១៥ | <១០ | <៥ |
| ១៤ | ចំនួនថ្ងៃសាលាបិទទ្វារមិនតាមការឈប់សម្រាកប្រចាំឆ្នាំរបស់រដ្ឋ | ៥ | ៣-៤ | ២ | ១ |
| ១៥ | ចំនួននិងភាគរយសិស្សទទួលរងចរិយាហិង្សាពីគ្រូថយចុះរហូតដល់គ្មាននៅឆ្នាំទី១ | ១,៥% | ១,០% | ០,៥% | ០% |
| ១៦ | ចំនួននិងភាគរយសិស្សបានសន្សំប្រាក់និង/ឬសម្រេចចិត្តទៅរៀនឧត្តមសិក្សាតាមបំណងប្រាថ្នា | >៣០% | >៤០% | >៥០% | >៦០% |
| | ***សរុបពិន្ទុស្តង់ដាទី២*** | ***១៦*** | ***៣២*** | ***៤៨*** | ***៦៤*** |
| **ស្តង់ដាទី៣៖ ភាពជាម្ចាស់នៃសហគមន៍សាលារៀន** | | | | | |
| ១ | ចំនួននិងភាគរយគ្រួសារមានហិង្សា | >១,៥% | >១,០% | >០,៥% | ០% |

| | | | | | |
|---|---|---|---|---|---|
| ២ | ចំនួនសមាសភាពគណៈកម្មការគ្រប់គ្រងសាលារៀន ឬ ក.ប.ស. | <៧ | ៧-៨ | ៩-១០ | >១០ |
| ៣ | ការប្រជុំប្រចាំត្រីមាស ឆមាស និងឆ្នាំដែលដឹកនាំដោយ គ.គ.ស. ឬ ក.ប.ស. | ប្រចាំត្រីមាសម្តងម្កាល | ប្រចាំត្រីមាសទៀងទាត់ | ប្រចាំឆ្នាំទៀងទាត់ | ទាំងអស់ |
| ៤ | ចំនួនគ្រូបង្រៀនបានទទួលការសម្រេចចិត្តពីគ.គ.ស.ឬក.ប.ស.លើការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ | <៨0% | <៨៥% | <៩0% | =>៩0% |
| ៥ | ចំនួននាយកនិងនាយករងបានទទួលការសម្រេចចិត្តពីគ.គ.ស.ឬក.ប.ស.លើការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ | 0 | ១ | ២-៣ | ទាំងអស់ |
| ៦ | ចំនួនសិស្សធ្លាក់ត្រៀមនឹងបោះបង់ ឬបោះបង់បានមករៀនវិញទៀងទាត់ | >៩0% | >៩៤% | >៩៩% | ទាំងអស់ |
| ៧ | បរិមាណចំណូលមូលនិធិគាំទ្រពីសហគមន៍ដល់សាលារៀនប្រចាំឆ្នាំ | ២០ 000 ដុល្លារ | កើន២ទៅ៣ដង | កើន៤ដល់៦ដង | កើនលើស១០ដង |
| ៨ | ទិន្នន័យតេស្តវាយតម្លៃស្តង់ដាលើសមត្ថភាពសិស្សត្រូវបានអនុម័តនិងបិទផ្សាយ | តេស្តប្រចាំខែ | បូកប្រចាំត្រីមាស | បូកប្រចាំឆមាស | ទាំងអស់ |
| ៩ | ផែនការសកម្មភាពអនុវត្តសូចនាករគន្លឹះបានអនុម័តដោយ គ.គ.ស.ឬ ក.ប.ស. | ផលិត | អនុម័តសម្រាប់តែឆ្នាំទី១ | អនុម័តសម្រាប់២ឆ្នាំ | អនុម័តសម្រាប់៣ឆ្នាំឡើង |
| ១០ | ផែនការកែលម្អសាលារៀននិងថវិកាប្រចាំឆ្នាំបានអនុម័តដោយគ.គ.ស.ឬក.ប.ស. | ផលិត | អនុម័តសម្រាប់តែឆ្នាំទី១ | អនុម័តសម្រាប់២ឆ្នាំ | អនុម័តសម្រាប់៣ឆ្នាំឡើង |
| *១១* | *របាយការណ៍វាយតម្លៃស្តង់ដាសាលារៀនត្រូវបានអនុម័តប្រចាំឆ្នាំដោយ គ.គ.ស.ឬក.ប.ស.* | *ផលិត* | *អនុវត្តឆ្នាំទី១* | *អនុវត្តឆ្នាំទី២* | *អនុវត្តឆ្នាំទី៣* |
| *១២* | *របាយការណ៍ប្រចាំឆ្នាំត្រូវបានអនុម័តដោយគ.គ.ស.ឬ ក.ប.ស* | *ផលិត* | *អនុវត្តឆ្នាំទី១* | *អនុវត្តឆ្នាំទី២* | *អនុវត្តឆ្នាំទី៣* |
| *១៣* | *ទិន្នន័យបិទផ្សាយជាសាធារណៈត្រូវបានអនុម័តដោយគ.គ.ស. ឬ ក.ប.ស. និងបិទផ្សាយ* | *ផលិត* | *អនុវត្តឆ្នាំទី១* | *អនុវត្តឆ្នាំទី២* | *អនុវត្តឆ្នាំទី៣* |
| *១៤* | *មានបរិស្ថានបៃតង អនាម័យ អគារសិក្សា សម្ភារៈ និងបរិក្ខារសិក្សាបាន* | *គ្រោង* | *តាមផែនការឆ្នាំទី១* | *តាមផែនការឆ្នាំទី២* | *តាមផែនការឆ្នាំទី៣* |

| | | | | | |
|---|---|---|---|---|---|
| | ថៃរក្សា | | | | |
| ១៥ | មានកម្មវិធីបំណិនរកចំណូលតាមស្តង់ដា | គ្រោង | សម្រេចតាមផែនការឆ្នាំទី១ | សម្រេចតាមផែនការឆ្នាំទី២ | សម្រេចតាមផែនការឆ្នាំទី៣ |
| ១៦ | មានកម្មវិធីធានារ៉ាប់រងសង្គមនិងអភិវឌ្ឍសមត្ថភាព | | គ្រោង | សម្រេចតាមផែនការឆ្នាំទី១ | សម្រេចតាមផែនការឆ្នាំទី២ |
| | **សរុបពិន្ទុស្តង់ដាទី៣** | **១៦** | **៣២** | **៤៨** | **៦៤** |

**ស្តង់ដាទី៤ ៖ ដំណើរប្រតិបត្តិការ និងរដ្ឋបាលសាលារៀន**

| | | | | | |
|---|---|---|---|---|---|
| ១ | ផែនការសកម្មភាពអនុវត្តសូចនាករគន្លឹះរយៈពេលមធ្យមបានរៀបចំតាមការណែនាំ | រៀបចំឆ្នាំទី១ | រៀបចំឆ្នាំទី២ | រៀបចំឆ្នាំទី៣ | រៀបចំឆ្នាំទី៤ |
| ២ | ផលសម្រេចរយៈពេល៣ឆ្នាំ និងផែនការបង្រៀនរយៈពេល៣ឆ្នាំបានរៀបចំតាមការណែនាំ | រៀបចំឆ្នាំទី១ | រៀបចំឆ្នាំទី២ | រៀបចំឆ្នាំទី៣ | រៀបចំឆ្នាំទី៤ |
| ៣ | ផែនការកែលម្អសាលារៀនបានរៀបចំតាមការណែនាំ | រៀបចំឆ្នាំទី១ | រៀបចំឆ្នាំទី២ | រៀបចំឆ្នាំទី៣ | រៀបចំឆ្នាំទី៤ |
| ៤ | ការធ្វើតេស្តស្តង់ដាប្រចាំខែ និងប្រចាំត្រីមាសបានរៀបចំទៀងទាត់ | តេស្តខែ | បូកត្រីមាស | បូកត្រីមាស | បូកត្រីមាស |
| ៥ | លទ្ធផលតេស្តស្តង់ដាប្រចាំខែត្រូវបានយកប្រើប្រាស់ជួយដល់ការសិក្សារៀនសូត្ររបស់សិស្សរៀនយឺត | ទៀងទាត់ឆ្នាំទី១ | ទៀងទាត់ឆ្នាំទី២ | ទៀងទាត់ឆ្នាំទី៣ | ទៀងទាត់ឆ្នាំទី៤ |
| ៦ | លទ្ធផលតេស្តចុងត្រីមាសបានយកប្រើប្រាស់ក្នុងការរៀបចំផែនការបង្រៀន៣ខែតាមថ្នាក់រៀន | ទៀងទាត់ឆ្នាំទី១ | ទៀងទាត់ឆ្នាំទី២ | ទៀងទាត់ឆ្នាំទី៣ | ទៀងទាត់ឆ្នាំទី៤ |
| ៧ | ការប្រជុំប្រចាំខែ ត្រីមាស និងឆមាសបានប្រជុំតាមការណែនាំ | ប្រចាំខែ | បូកសរុបប្រចាំត្រីមាស | បូកសរុបប្រចាំឆមាស | បូកសរុបប្រចាំឆ្នាំ |
| ៨ | ចំនួនដងអធិការកិច្ចផ្ទៃក្នុង និងការប្រជុំបច្ចេកទេសបានអនុវត្តតាមផែនការ | <៧/៧ | <៩/៩ | <១២/១២ | =>១៤/១៤ |
| ៩ | ចំនួនគ្រូបង្រៀនបានចូលរៀនវគ្គអភិវឌ្ឍសមត្ថភាពជាប្រចាំ | គ្រោង | តាមគ្រោងឆ្នាំទី១ | តាមគ្រោងឆ្នាំទី២ | តាមគ្រោងឆ្នាំទី៣ |
| ១០ | ចំនួនគ្រូបង្រៀនបានចូលរួមអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់គ្រូបង្រៀន | <៨០% | <៨៥% | <៩០% | =>៩០% |

| | | | | | |
|---|---|---|---|---|---|
| ១១ | ចំនួននាយកសាលានិងនាយករងបានចូលរួមអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់នាយកសាលា | 0 | ១ | ២-៣ | ទាំងអស់ |
| *១២* | *ស្វ័យវាយតម្លៃសាលារៀនទៅចុងឆ្នាំសិក្សាបានអនុវត្ត និងរបាយការណ៍ហិរញ្ញវត្ថុបានផលិតតាមការណែនាំ* | *អនុវត្ត ឆ្នាំទី១* | *អនុវត្ត ឆ្នាំទី២* | *អនុវត្ត ឆ្នាំទី៣* | *អនុវត្ត ឆ្នាំទី៤* |
| *១៣* | *ចំនួនដងប្រកួតប្រជែងអំណានភាសាខ្មែរ និងគណិតវិទ្យាជាមួយសាលាផ្សេងបានរៀបចំតាមការគ្រោង* | *គ្រោង* | *អនុវត្តឆ្នាំទី១* | *អនុវត្តឆ្នាំទី២* | *អនុវត្តឆ្នាំទី៣* |
| *១៤* | *ទិន្នន័យជឿជាក់បានត្រូវបានផលិត ចងក្រង ប្រើប្រាស់ និងបិទផ្សាយជាសាធារណៈតាមការណែនាំ* | *ចងក្រង ទិន្នន័យ* | *អនុវត្តឆ្នាំទី១* | *អនុវត្តឆ្នាំទី២* | *អនុវត្តឆ្នាំទី៣* |
| *១៥* | *កម្មវិធីអប់រំមាតាបិតា និងគ្រូបង្រៀនទប់ស្កាត់អំពើហិង្សានៅផ្ទះនិងសាលារៀនបានរៀបចំតាមការណែនាំ* | *ប្រមូល ទិន្នន័យ* | *អនុវត្តឆ្នាំទី១* | *អនុវត្តឆ្នាំទី២* | *អនុវត្តឆ្នាំទី៣* |
| *១៦* | *ការពិនិត្យស្វែងរកសិស្សខ្សោយគំហើញ និងស្តាប់បានអនុវត្តទៀងទាត់រាល់ដើមឆ្នាំសិក្សា* | *គ្រោង* | *អនុវត្តឆ្នាំទី១* | *អនុវត្តឆ្នាំទី២* | *អនុវត្តឆ្នាំទី៣* |
| | ***ពិន្ទុសរុបស្តង់ដាទី៤*** | ***១៦*** | ***៣២*** | ***៤៨*** | ***៦៤*** |
| **ស្តង់ដាទី៥៖ គណនេយ្យភាពថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ** | | | | | |
| ១ | ចំនួនដងនាយកនិងនាយករង បានទទួលការហ្វឹកហាត់អនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀនពីគ្រឹះស្ថានបណ្តុះបណ្តាលប្រចាំឆ្នាំ | ១-២ | ៣-៤ | ៥-៦ | ៧-៨ |
| *២* | *ចំនួនដងគ្រូបង្រៀនបានទទួលការហ្វឹកហាត់ការបង្រៀនចម្រុះមុខវិជ្ជាតាមផែនការ* | *គ្រោង* | *តាមគ្រោង ឆ្នាំទី១* | *តាមគ្រោង ឆ្នាំទី២* | *តាមគ្រោង ឆ្នាំទី៣* |
| ៣ | ចំនួនដងទស្សនកិច្ចផ្តល់ការគាំទ្រពីក្រុមការងារតំបន់បានអនុវត្តតាមផែនការប្រចាំឆ្នាំ | ១-២ | ៣-៤ | ៥-៦ | ៧-៨ |
| ៤ | ចំនួនដងទស្សនកិច្ចផ្តល់ការគាំទ្រពីមន្ទីរអ.យ.ក. បានអនុវត្តតាមផែនការប្រចាំឆ្នាំ | ១-២ | ៣-៤ | ៥-៦ | ៧-៨ |
| ៥ | ចំនួនដងទស្សនកិច្ចផ្តល់ការគាំទ្រពីការិយាល័យអ.យ.ក. នៃរដ្ឋបាលក្រុង | ១-២ | ៣-៤ | ៥-៦ | ៧-៨ |

| | | | | | |
|---|---|---|---|---|---|
| | ស្រុក ខណ្ឌ បានអនុវត្តតាមផែនការប្រចាំឆ្នាំ | | | | |
| ៦ | *ការបង្រៀនបំណិនកសិកម្ម និងបច្ចេកទេសបានអនុវត្តតាមផែនការ* | *គ្រោង* | *អនុវត្តតាមគ្រោងឆ្នាំទី១* | *អនុវត្តតាមគ្រោងឆ្នាំទី២* | *អនុវត្តតាមគ្រោងឆ្នាំទី៣* |
| ៧ | ចំនួនគ្រូបង្រៀនខ្វះតាមមុខវិជ្ជាឯកទេសថយចុះតាមផែនការ | =>១០ | ៦-៩ | ២-៥ | ០ |
| ៨ | ចំនួននាយកនិងនាយករងបានតែងតាំងត្រឹមត្រូវតាមនិយាម | ខ្វះ៣ | ខ្វះ២ | ខ្វះ១ | ត្រឹមត្រូវតាមនិយាម |
| ៩ | *កាតរបាយការណ៍សាលារៀនបានផលិត និងបិទផ្សាយជាសាធារណៈ* | *គ្រោង* | *ផលិតនិងបិទផ្សាយឆ្នាំទី១* | *ផលិតនិងបិទផ្សាយឆ្នាំទី២* | *ផលិតនិងបិទផ្សាយឆ្នាំទី៣* |
| ***ពិន្ទុសរុបស្តង់ដាទី៥*** | | ***៩*** | ***១៨*** | ***២៧*** | ***៣៦*** |
| **ពិន្ទុសរុបស្តង់ដាសហគមន៍សាលារៀន** | | **៧០** | **១៤០** | **២១០** | **២៨០** |

## ៥ ការគ្រប់គ្រងហិរញ្ញវត្ថុ និងលទ្ធកម្ម (ត្រូវបញ្ចូលខ្លឹមបន្ថែមពីក្រុមការងារហិរញ្ញវត្ថុ)

*ការគ្រប់គ្រងចំណូលនិងចំណាយ*

- ការចំណាយឧបត្ថម្ភសិស្សដែលសហការជាមួយមិត្តភក្តិនៅកសិដ្ឋានរបស់សិស្សគឺ បានមកពីការចំណេញពីកសិដ្ឋានសិស្ស
- សិស្សដែលអនុវត្តបំណិននៅតាមផ្ទះរបស់ខ្លួនអាចខ្ចីប្រាក់ឥណទានពីសាលាជាដើមទុន ប្រសិនបើសាលាមានកម្មវិធីឥណទាន
- សាលាត្រូវផ្តោតពីឆ្នាំដំបូងនូវការបង្កើនដើមទុន ដោយអនុវត្តបំណិនដែលនាំមកនូវចំណូលច្រើន ដូចជាការចិញ្ចឹមកន្លាយឬអណ្តើក ត្រីសាច់ និងបន្លែមានតម្លៃថ្លៃៗ
| សូចនាករទី១១ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។<br>សូចនាករទី១២ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។<br>សូចនាករទី១៣ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។<br>**សកម្មភាពៈ**<br>១ នាយកសាលាជាអ្នកសម្របសម្រួលរៀបចំនូវការប្រជុំ និងដាក់ស្នើសំណុំឯកសារទាំងអស់ខាងលើមក គ.គ.ស. ឬ ក.ប.ស. ដើម្បីពិនិត្យ និងអនុម័ត។<br>២ នាយកសាលាធានានូវការបិទផ្សាយគ្រប់ទិន្នន័យ និងព័ត៌មានខាងលើជាសាធារណៈ ឱ្យបានទៀងទាត់តាមការកំណត់។ | | | | | |
| ១៤ | មានបរិស្ថានបៃតង អនាម័យ អគារសសិក្សា សង្ហារឹម និងបរិក្ខាសិក្សាបានថែរក្សា | គ្រោង | តាមផែនការឆ្នាំទី១ | តាមផែនការឆ្នាំទី២ | តាមផែនការឆ្នាំទី៣ |
| សូចនាករទី១៤ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។<br>សកម្មភាពៈ<br>១ សិស្សនិងយុវជនមានតួនាទីសំខាន់ក្នុងកិច្ចការនេះ។ នាយកសាលាត្រូវមានផែនការរយៈពេល៣ឆ្នាំដាំដើមឈើតាមចំនួនដែលធ្វើទីធ្លាសាលារៀនគ្របដណ្ដប់ដោយម្លប់ កិច្ចសហការជាមួយក្រសួង មន្ទីរពាក់ព័ន្ធធានាមានកូនឈើមកដាំជាការសំខាន់ ចៀសវាងប្រើលុយសាលារៀនទិញកូនឈើបើអាចទៅរួច។ នាយកសាលាពិភាក្សាជាមួយសិស្ស និងព្រមព្រៀងគ្នាថា សិស្សត្រូវដាំដើមឈើនៅផ្ទះរបស់ខ្លួនប៉ុន្មានដើម ធានាថាផ្ទះសិស្សមានម្លប់គ្រប់គ្រាន់។ នាយកសាលាត្រូវយកទិធ្លាសាលារៀនដាំដំណាំជាបន្លែ គ្រប់ប្រភេទ ធ្វើឱ្យធ្លាសាលារៀនមានពណ៌បៃតង និងអាចយកផលិតផលធ្វើជាអាហារសម្រាប់សិស្សក្រីក្រហូបនៅសាលារៀន ជាជាងដាំផ្កាដែលពុំមានប្រយោជន៍ដល់ការហូបចុក។<br>២ សាលារៀនគប្បីមិនមានធុងសំរាម និងសំរាមនៅក្នុងសាលារៀនឬថ្នាក់រៀនឡើយ។ នាយកសាលាពិភាក្សាជាមួយសិស្សថាមិនត្រូវមានសំរាមនៅផ្ទះ ឬក្នុងភូមិឡើយ។ សិស្សរួមថ្នាក់ណាដែលឃើញថាមានសំរាមនៅផ្ទះនៃសិស្សនៅក្បែរខាង និងត្រូវមានការណែនាំគ្នា ឬមួយយកមកពិភាក្សានៅក្នុងថ្នាក់រៀនដើម្បីដោះស្រាយបញ្ហា។<br>៣ នាយកសាលាដាក់កិច្ចការឱ្យគ្រូទទួលបន្ទុកថ្នាក់ និងក្រុមប្រឹក្សាកុមារ យុវជនតាមថ្នាក់ថែរក្សានូវ សួនបន្លែ អគារសិក្សា សង្ហារឹមតាមថ្នាក់ខ្លួន និងថែរក្សាសម្ភារៈបរិក្ខារវិទ្យាសាស្ត្រតាមកាលវិភាគប្រចាំសប្ដាហ៍។ | | | | | |
| ១៥ | មានកម្មវិធីបំណិនរកចំណូលតាមស្តង់ដា | គ្រោង | សម្រេចតាមផែនការឆ្នាំទី១ | សម្រេចតាមផែនការឆ្នាំទី២ | សម្រេចតាមផែនការឆ្នាំទី៣ |
| ១៦ | មានកម្មវិធីធានារ៉ាប់រងសង្គមនិងអភិវឌ្ឍសមត្ថភាព | | គ្រោង | សម្រេចតាមផែនការឆ្នាំទី១ | សម្រេចតាមផែនការឆ្នាំទី២ |

សូចនាករទី១៥ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ  XX។

សូចនាករទី១៦ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ  XX។

**សកម្មភាព៖**

១ សកម្មភាពរៀបចំកម្មវិធីមាននៅក្នុងស្តង់ដាទី២រួចហើយ តែខ្លឹមសារនៅក្នុងនេះជាការធានានូវការអនុវត្តជាប់ជាប្រចាំនូវកម្មវិធីដែលបានគ្រោងទុក។ នាយកសាលាត្រូវទំនាក់ទំនងច្បាស់លាស់ជាមួយសាកលវិទ្យាល័យដៃគូ បុគ្គលិកក្រសួងដែលមានតួនាទីជួយសាលារៀន និងមហាវិទ្យាល័យអប់រំក្នុងការអនុវត្តកម្មវិធីនេះ។ សាកលវិទ្យាល័យធានាផ្តល់ជំនួយបច្ចេកទេសពីការអនុវត្តបំណិន។ បុគ្គលិកក្រសួងធានាផ្តល់ប្រឹក្សាពីការគ្រប់គ្រងកម្មវិធីធានាដល់ដំណើរការមាននិរន្តរភាព។ មហាវិទ្យាល័យអប់រំធានានូវការបង្រៀនចម្រុះមុខវិជ្ជា។

២ នៅឆ្នាំណាមួយក្រោយពីការអនុវត្តកម្មវិធីបំណិនរកចំណូល នាយកសាលានិងគ.គ.ស.ឬក.ប.ស.ពិភាក្សាគ្នាពីរបៀបរៀបចំកម្មវិធីធានារ៉ាប់រងសង្គម និងអភិវឌ្ឍសមត្ថភាពមន្ត្រី។ បុគ្គលិកក្រសួងនិងទីប្រឹក្សាក្រសួងនឹងជួយសាលារៀនក្នុងការរៀបចំកម្មវិធីនេះ។ ការគ្រប់គ្រងនិងអនុវត្តកម្មវិធីនេះត្រូវមានដំណើរការតាមការណែនាំដែលមាននៅក្នុងសៀវភៅនេះ។

| **សរុបពិន្ទុស្តង់ដាទី៣** | **១៥** | **៣២** | **៤៨** | **៦៤** |
|---|---|---|---|---|
| សរុបពិន្ទុជាក់ស្តែងនៅចុងឆ្នាំសិក្សាចំនួន XX (សរុបពិន្ទុពីកូឡោនខាងស្តាំទាំង៤) | | | | |

| **ស្តង់ដាទី៤ ៖ ដំណើរប្រតិបត្តិការ និងរដ្ឋបាលសាលារៀន** | | | | | |
|---|---|---|---|---|---|
| ១ | ផែនការសមិទ្ធកម្មសូចនាករគន្លឹះរយៈពេលមធ្យមបានរៀបចំតាមការណែនាំ | រៀបចំឆ្នាំទី១ | រៀបចំឆ្នាំទី២ | រៀបចំឆ្នាំទី៣ | រៀបចំឆ្នាំទី៤ |
| ២ | ផលសម្រេចរយៈពេល៣ឆ្នាំ និងផែនការបង្រៀនរយៈពេល៣ឆ្នាំបានរៀបចំតាមការណែនាំ | រៀបចំឆ្នាំទី១ | រៀបចំឆ្នាំទី២ | រៀបចំឆ្នាំទី៣ | រៀបចំឆ្នាំទី៤ |
| ៣ | ផែនការកែលម្អសាលារៀនប្រចាំឆ្នាំបានរៀបចំតាមការណែនាំ | រៀបចំឆ្នាំទី១ | រៀបចំឆ្នាំទី២ | រៀបចំឆ្នាំទី៣ | រៀបចំឆ្នាំទី៤ |

សូចនាករទី១ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ  XX។

សូចនាករទី២ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ  XX។

សូចនាករទី៣ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ  XX។

**សកម្មភាព៖**

១ ក្រោយការបញ្ចូលទិន្នន័យជាលទ្ធផលតេស្តស្តង់ដាដើមឆ្នាំសិក្សាចូលក្នុងតារាងហើយ នាយកសាលារៀបចំ ផែនការសមិទ្ធកម្មសូចនាករគន្លឹះរយៈពេលមធ្យម បន្ទាប់មកផលសម្រេចរយៈពេល៣ឆ្នាំ និងផែនការបង្រៀនរយៈពេល៣ឆ្នាំ និងចុងក្រោយផែនការកែលម្អសាលារៀនប្រចាំឆ្នាំតាមលំដាប់លំដោយ។

| | | | | | |
|---|---|---|---|---|---|
| ៤ | ការធ្វើតេស្តស្តង់ដាប្រចាំខែ និងត្រីមាសបានរៀបចំទៀងទាត់ | តេស្តខែ | បូកត្រីមាស | បូកត្រីមាស | បូកត្រីមាស |
| ៥ | លទ្ធផលតេស្តស្តង់ដាប្រចាំខែត្រូវបានយកប្រើ | ទៀងទាត់ឆ្នាំ | ទៀងទាត់ | ទៀងទាត់ | ទៀងទាត់ |

| | | | | | |
|---|---|---|---|---|---|
| | ប្រាស់ជួយដល់ការសិក្សារៀនសូត្ររបស់សិស រៀនយឺត | ទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ |
| ៦ | លទ្ធផលតេស្តចុងត្រីមាសបានយកប្រើប្រាស់ក្នុងការរៀបចំផែនការបង្រៀន៣ខែតាមថ្នាក់រៀន | ទៀងទាត់ឆ្នាំទី១ | ទៀងទាត់ឆ្នាំទី២ | ទៀងទាត់ឆ្នាំទី៣ | ទៀងទាត់ឆ្នាំទី៤ |
| ៧ | ការប្រជុំប្រចាំខែ ត្រីមាស និងឆមាសបានប្រជុំតាមការណែនាំ | ប្រចាំខែ | បូកត្រីមាស | បូកឆមាស | បូកឆមាស |

សូចនាករទី៤ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។
សូចនាករទី៥ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។
សូចនាករទី៦ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។
សូចនាករទី៧ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។

**សកម្មភាព៖**

១ នាយកសាលាជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តតេស្តស្តង់ដាជាប់ជាប្រចាំ និងរក្សាគុណភាពឱ្យបានល្អ។ សំណួរតេស្តនឹងត្រូវបានផ្តល់ឱ្យដោយក្រសួងដើម្បីរក្សាកម្រិតគុណភាពស្តង់ដាតែមួយទូទាំងប្រទេស។

២ គ្រូត្រូវយកលទ្ធផលតេស្តចុងខែនីមួយៗមកប្រើប្រាស់ ដោយពិភាក្សាជាមួយសិស្ស និងជួយណែនាំសិស្សម្នាក់ឱ្យរៀនតាមសមត្ថភាពខ្វះចន្លោះរបស់សិស្សម្នាក់ៗ។

៣ គ្រូទទួលបន្ទុកថ្នាក់ ជាមួយគ្រូមុខវិជ្ជា ត្រូវប្រជុំពិនិត្យលទ្ធផលតេស្តស្តង់ដាប្រចាំត្រីមាស ដោយស្វែងរកនូវសំណុំមេរៀនតាមមុខវិជ្ជាដែលសិស្សភាគច្រើនរៀនមិនចេះ កំណត់មូលហេតុនិងឧបសគ្គរាំងស្ទាត់ការរៀនសូត្រ ដែលអាចមានដូច បណ្តាលមកពីការបង្រៀនមិនច្បាស់ ដោយសារសមត្ថភាពគ្រូឬមួយដោយការមិនទទួលខុសត្រូវរបស់គ្រូ មកពីការមិនសូវខិតខំរបស់សិស្សម្នាក់ៗ ដោយសារមូលហេតុសង្គមនិងសេដ្ឋកិច្ចរបស់សិស្សឬមួយដោយសារសមត្ថភាពបញ្ញាសិស្សទាបពេក (មកពីការអភិវឌ្ឍខួរក្បាលតាំងពីកុមារភាពមានការប៉ះទង្គិច)។

៤ គ្រូទទួលបន្ទុកថ្នាក់ចងក្រងលទ្ធផលពីការប្រជុំ បញ្ជូនទៅនាយកសាលា ហើយនាយកសាលាសរុបព័ត៌មានពីគ្រូទទួលបន្ទុកថ្នាក់ទាំងអស់ ជារបាយការណ៍សម្រាប់ការប្រជុំត្រីមាសជាមួយគ.គ.ស.ឬក.ប.ស. ដើម្បីដោះស្រាយ។

៥ របាយការណ៍នាយកសាលាត្រូវផលិតរួមមាន របាយការណ៍ពីការរីកចម្រើនការអនុវត្តផែនការកែលម្អសាលារៀន និងរបាយការណ៍វិភាគពីការបង្រៀននិងសិក្សារៀនសូត្ររបស់សិស្ស។

| | | | | | |
|---|---|---|---|---|---|
| ៨ | ចំនួនដងអធិការកិច្ចផ្ទៃក្នុង និងការប្រជុំបច្ចេកទេសបានអនុវត្តតាមផែនការ | ៧-៧ | ៨-៨ | ៩-៩ | ១០-១០ |
| ៩ | ចំនួនគ្រូបង្រៀនបានចូលរៀនវគ្គអភិវឌ្ឍសមត្ថភាពជាប្រចាំ | គ្រោង | តាមគ្រោងឆ្នាំទី១ | តាមគ្រោងឆ្នាំទី២ | តាមគ្រោងឆ្នាំទី៣ |
| ១០ | ចំនួនគ្រូបង្រៀនបានចូលរួមអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់គ្រូបង្រៀន | >៨0% | >៨៥% | >៩0% | =>៩៥% |
| ១១ | ចំនួននាយកសាលានិងនាយករងបានចូលរួមអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់នាយកសាលា | 0 | 1 | 2-3 | ទាំងអស់ |

សូចនាករទី៨ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។
សូចនាករទី៩ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។
សូចនាករទី១០ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។
សូចនាករទី១១ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។
សកម្មភាព៖

១ នាយកសាលាពិភាក្សាជាមួយគ្រូបង្រៀនទាំងអស់ និងរៀបចំជាផែនការសម្រាប់គ្រូបង្រៀនចូលរួមរៀនសូត្រវគ្គលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន។

២ គ្រូបង្រៀនចូលរួមរៀនវគ្គលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន អនុវត្តកិច្ចការបានទទួលពីវគ្គ និងធានាសម្រេចបាននូវស្តង់ដាទី២។

៣ គ្រូបង្រៀនរៀបចំកិច្ចសន្យាលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍសមត្ថភាព។ គ្រូបង្រៀនចូលរួមអនុវត្តការវាយតម្លៃពាក់កណ្តាលឆ្នាំនិងចុងឆ្នាំតាមការណែនាំ។

៤ នាយកសាលាអនុវត្តកិច្ចការអធិការកិច្ចផ្ទៃក្នុងទៅតាមការកំណត់ ក្នុងកិច្ចសន្យាលទ្ធផលប្រចាំឆ្នាំរបស់គ្រូបង្រៀន។ ការធ្វើអធិការកិច្ចផ្ទៃក្នុងមានវត្ថុបំណងជួយគ្រូអនុវត្តការងាររបស់ខ្លួន មិនមែនមានបំណងស្វែងរកកំហុសរបស់គ្រូ និងបន្ទោសគ្រូបង្រៀននោះទេ។ ដូចគ្នានឹងការធ្វើអធិការកិច្ចពីថ្នាក់ក្រោមជាតិឬថ្នាក់ជាតិ ដែលមានបំណងជួយដល់ការកសាងសមត្ថភាពនិងលើកទឹកចិត្តគ្រូបង្រៀន ជាជាងការស្វែងរកកំហុសនិងស្តីបន្ទោស។ ប្រសិនបើមានអធិការណាម្នាក់ដែលអនុវត្តអធិការកិច្ចបែបស្វែងរកកំហុស នាយកសាលារៀនមានសិទ្ធិនិយាយជាមួយអធិការនោះថា ការអនុវត្តកិច្ចការនេះខុសវត្ថុបំណងហើយ និងគប្បីកែប្រែ បើមិនដូច្នោះទេ នាយកសាលានិងគ.គ.ស.ឬក.ប.ស.មិនអនុញ្ញាតឱ្យធ្វើបន្តទៀតឡើយ។

| | | | | | |
|---|---|---|---|---|---|
| ១២ | ស្វ័យវាយតម្លៃសាលារៀននៅចុងឆ្នាំសិក្សាបានអនុវត្ត និងរបាយការណ៍ហិរញ្ញវត្ថុបានផលិតតាមការណែនាំ | អនុវត្តឆ្នាំទី១ | អនុវត្តឆ្នាំទី២ | អនុវត្តឆ្នាំទី៣ | អនុវត្តឆ្នាំទី៤ |

សូចនាករទី១២ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។

***សកម្មភាព៖***

១ លទ្ធផលតេស្តស្តង់ដាចុងឆ្នាំត្រូវបូកសរុបចូលក្នុងតារាងកម្រិតសិស្សម្នាក់ៗ ថ្នាក់រៀននីមួយៗ និងសាលារៀនទាំងមូល។ នៅកម្រិតថ្នាក់រៀន គ្រូទទួលបន្ទុកថ្នាក់រៀបចំការប្រជុំកម្រិតថ្នាក់រៀន ពិនិត្យលទ្ធផលសិក្សារបស់សិស្ស និងពិភាក្សារកមូលហេតុដែលនៅសេសសល់ចុងឆ្នាំ។ ការពិនិត្យពិភាក្សាខ្លឹមសារគឺមានខ្លឹមសារ និងលំនាំដូចគ្នានឹងការប្រជុំប្រចាំត្រីមាសដែរ។ គ្រូទទួលបន្ទុកថ្នាក់បញ្ជូនរបាយការណ៍ប្រជុំប្រចាំឆ្នាំមកនាយករងទទួលបន្ទុកបច្ចេកទេស។ នាយករងទទួលបន្ទុកបច្ចេកទេស បូកសរុបលទ្ធផលរបាយការណ៍ពីគ្រូទទួលបន្ទុកថ្នាក់ទាំងអស់ចូលក្នុងរបាយការណ៍សរុបរបស់សាលារៀន និងជូនទៅនាយកសាលា និងគ.គ.ស. ឬក.ប.ស.។

២ នាយកសាលាដឹកនាំការប្រជុំស្វ័យវាយតម្លៃសាលារៀនចុងឆ្នាំ ដោយប្រើប្រាស់របាយការណ៍ពីការរីកចម្រើនការអនុវត្តផែនការកែលម្អសាលារៀន និងរបាយការណ៍វិភាគពីការបង្រៀននិងសិក្សារៀនសូត្ររបស់សិស្ស។ ចុងបញ្ចប់នាយកសាលាបូកសរុបផ្តល់ពិន្ទុដល់ស្តង់ដា និងសូចនាករនីមួយៗ និងសរុបពិន្ទុស្តង់ដាសហគមន៍សាលារៀនសម្រាប់ឆ្នាំ។

| | | | | | |
|---|---|---|---|---|---|
| ១៣ | ចំនួនដងប្រកួតប្រជែងអំណានភាសាខ្មែរ និងលំហាត់គណិតវិទ្យាជាមួយសាលាផ្សេងបានរៀបចំតាមការគ្រោង | គ្រោង | អនុវត្តឆ្នាំទី១ | អនុវត្តឆ្នាំទី២ | អនុវត្តឆ្នាំទី៣ |

សូចនាករទី១៣ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។

**សកម្មភាពៈ**

១ សកម្មភាពសម្រាប់សូចនាករនេះមានរៀបរាប់នៅខាងលើហើយ ដែលជាសកម្មភាពជាប់ជាបន្ត ហើយសកម្មភាពសម្រាប់សូចនាករនេះជាសកម្មភាពដែលត្រូវអនុវត្តនៅថ្ងៃទិវាជាតិអំណាន និងមានលក្ខណៈទ្រង់ទ្រាយធំ ដែលជាការប្រកួតកម្រិតរាជធានីខេត្ត ឬកម្រិតក្រសួង។ សិស្សដែលចូលរួមប្រកួតត្រូវតែជាសិស្សដែលបានជ្រើសរើសតាមការណែនាំពីក្រសួង ចៀសវាងជ្រើសរើសយកតែសិស្សពូកែមកប្រកួត។ ការជ្រើសរើសត្រូវអនុវត្តតាមរបៀបចាប់ឆ្នោត ជ្រើសយកថ្នាក់ទី៧ ឬ ទី៩ជាអាទិភាព យកចំនួនសិស្សតាមការកំណត់របស់ក្រសួង ពោលគឺយ៉ាងច្រើន ៥នាក់ក្នុងមួយកម្រិតថ្នាក់ ឬ ១០នាក់ក្នុងមួយសាលារៀន។ ការអនុវត្តបែបនេះតម្រូវឱ្យសាលារៀននីមួយៗត្រូវប្រឹងប្រែងជួយសិស្សជាប់ជាប្រចាំក្នុងការអាន ដើម្បីធានាថាល្បឿននៃអំណានគឺមានកម្រិតយ៉ាងតិចត្រឹមស្តង់ដាល្បឿនអំណាន ឬអាចអានលឿនជាងស្តង់ដា។

| | | | | | |
|---|---|---|---|---|---|
| ១៤ | ទិន្នន័យជឿជាក់បានត្រូវបានផលិត ចងក្រង ប្រើប្រាស់ និងបិទផ្សាយសាធារណៈតាមការណែនាំ | ចងក្រងទិន្នន័យ | អនុវត្តឆ្នាំទី១ | អនុវត្តឆ្នាំទី២ | អនុវត្តឆ្នាំទី៣ |

សូចនាករទី១៤ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។

**សកម្មភាពៈ**

- សាលារៀនត្រូវណែនាំសិស្សជួយគ្រប់គ្រងទិន្នន័យគ្រប់បែបយ៉ាងកម្រិតថ្នាក់រៀន និងកម្រិតសាលារៀន។
- សាលារៀនគួរមានមន្ត្រីជាប់កិច្ចសន្យាម្នាក់សម្រាប់ជួយបញ្ចូលទិន្នន័យក្នុងប្រព័ន្ធទន់ បូកសរុបទិន្នន័យ និងបញ្ជូនទិន្នន័យមកក្រសួង។
- នាយកសាលានឹងទទួលការបង្រៀនពីការគ្រប់គ្រងទិន្នន័យទាំងអស់ ពីវគ្គបង្កើនគុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន។ នាយកសាលានឹងត្រូវទទួលបាននូវការណែនាំពីការប្រើប្រាស់ទិន្នន័យ ព័ត៌មាន និងចំណេះដឹងជាពិសោធន៍សម្រាប់គ្រប់ប្រភេទអតិថិជន ដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍសាលារៀន និងសហគមន៍។

| | | | | | |
|---|---|---|---|---|---|
| ១៥ | កម្មវិធីអប់រំមាតាបិតា និងគ្រូបង្រៀនទប់អំពើហិង្សានៅផ្ទះនិងសាលារៀនបានរៀបចំតាមការណែនាំ | ប្រមូលទិន្នន័យ | អនុវត្តឆ្នាំទី១ | អនុវត្តឆ្នាំទី២ | អនុវត្តឆ្នាំទី៣ |
| ១៦ | ការពិនិត្យស្វែងរកសិស្សខ្សោយគំហើញ និងស្តាប់បានអនុវត្តទៀងទាត់រាល់ដើមឆ្នាំសិក្សា | គ្រោង | អនុវត្តឆ្នាំទី១ | អនុវត្តឆ្នាំទី២ | អនុវត្តឆ្នាំទី៣ |

សូចនាករទី១៥ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។

សូចនាករទី១៦ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។

**សកម្មភាព៖**

- នាយកសាលារៀបចំការប្រជុំ និងរៀនសូត្រ ដែលជាការអប់រំមាតាបិតាសិស្សពី សមត្ថភាពចិត្តនិងសង្គម និងរបៀបថែទាំកូន។ ខ្លឹមសារនិងរបៀបប្រជុំអប់រំពីការថែទាំកូនមាននៅក្នុងសៀវភៅនេះ ហើយនាយកសាលាត្រូវអនុវត្តតាមការណែនាំនេះ។ បរិស្ថានដែលសិស្សរស់នៅទាំងនៅផ្ទះ និងនៅសាលារៀនត្រូវតែមានសភាពដូចគ្នា នោះទើបអាចជួយសិស្សឱ្យបណ្តុះបាននូវសមត្ថភាពចិត្តនិងសង្គមដែលគេត្រូវការ។
- នាយកសាលា និងគ្រូបង្រៀនអនុវត្តតាមការណែនាំរបស់ក្រសួង ពីការស្វែងរកសិស្សដែលអាចមានភាពខ្សោយគំហើញ និងខ្សោយស្តាប់។ ព្រោះថាបើសិស្សមានបញ្ហាណាមួយនៃបញ្ហាទាំងពីរនេះមិនអាចរៀនបានឡើយ។ ក្រោយពីរកឃើញហើយ គ្រូបង្រៀនត្រូវអញ្ជើញមាតាបិតាសិស្សមកពិភាក្សា ដើម្បីមាតាបិតានាំសិស្សទៅវាស់ភ្នែក និងទិញវ៉ែនតាពាក់ ឬមួយទៅ ពេទ្យភ្នែក ឬ សាលាគ ថ្លង់ ដើម្បីវាស់កម្រិតទម្ងន់នៃការខ្សោយស្តាប់ និងទិញប្រដាប់ជំនួយស្តាប់សម្រាប់សិស្ស។ ប្រសិនបើសិស្សជាកូនអ្នកក្រ សាលារៀនត្រូវជួយផ្នែកហិរញ្ញវត្ថុដល់សិស្ស ដែលជាការចំណាយពីថវិការដ្ឋផ្តល់ឱ្យសាលារៀន។
- នាយកសាលាត្រូវចាត់តំណាងសិស្សចងក្រងព័ត៌មានទាំងនេះ ដើម្បីបញ្ចូលក្នុងរបាយការណ៍ និងប្រើប្រាស់ជាព័ត៌មានផ្សព្វផ្សាយដល់សាធារណៈ ពីសកម្មភាពសង្គមដែលសាលារៀនបានអនុវត្តដើម្បីជាផ្នែកនៃការថែរក្សាគ្នានៅក្នុងសហគមន៍។

| **ពិន្ទុសរុបស្តង់ដាទី៤** | | **១៦** | **៣២** | **៤៨** | **៦៤** |
|---|---|---|---|---|---|
| សរុបពិន្ទុជាក់ស្តែងនៅចុងឆ្នាំសិក្សាចំនួន XX (សរុបពិន្ទុពីកូឡោនខាងស្តាំទាំង៤) | | | | | |
| **ស្តង់ដាទី៥៖ គណនេយ្យភាពថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ** | | | | | |
| ១ | ចំនួនដងនាយកសាលានិងនាយករង បានទទួលការហ្វឹកហាត់អនុវត្តការគ្រប់គ្រងតាមសាលារៀន | ១-២ | ៣-៤ | ៥-៦ | ៧-៨ |
| ២ | ចំនួនដងគ្រូបង្រៀនបានទទួលការហ្វឹកហាត់ការបង្រៀនចម្រុះមុខវិជ្ជាតាមផែនការ | គ្រោង | តាមគ្រោងឆ្នាំទី១ | តាមគ្រោងឆ្នាំទី២ | តាមគ្រោងឆ្នាំទី៣ |

សូចនាករទី១ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។
សូចនាករទី២ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។

**សកម្មភាព៖**

- នៅក្នុងវគ្គលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន នាយកសាលា និងគ្រូបង្រៀនពិភាក្សាជាមួយមហាវិទ្យាល័យអប់រំ ឬគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ពីចំនួនដងដែលត្រូវទទួលការបង្វឹកពីគ្រូបង្រៀននៃមហាវិទ្យាល័យ ឬគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន។ គ្រូបង្រៀនពីមហាវិទ្យាល័យគឺជានាយកសាលា ឬ គ្រូបង្រៀនដែលឈរជើងធ្វើការជានាយកសាលា នៃសាលារៀនមានស្តង់ដាដែលនៅក្នុងក្រុង ស្រុក ខណ្ឌ ឬរាជធានី ខេត្តជាមួយគ្នា។
- ខ្លឹមសារជួយបង្វឹក ត្រូវផ្តោតលើ សមត្ថភាពមុខវិជ្ជា (ចំណេះដឹងនិងបំណិនមុខវិជ្ជា) សមត្ថភាពអនុវត្តមុខវិជ្ជា

<table>
<tr><td></td><td colspan="5">នៅក្នុងជីវិតជាក់ស្តែងនិងការរកចំណូល(ជាការរៀនចម្រុះមុខវិជ្ជា) និងសមត្ថភាពចិត្តនិងសង្គម។ ការបង្វឹកអាចជាការបង្រៀនឱ្យមើលពីគ្រូបង្វឹក ការបង្រៀនឱ្យមើលពីអ្នកត្រូវទទួលការបង្វឹក ការឱ្យរៀបចំសំណួរតេស្តឬការឆ្លើយសំណួរតេស្តដែលមានកម្រិតងាយស្រួល មធ្យម និងលំបាក ល្បិចបង្រៀនភាសាខ្មែរ ឬ គណិតវិទ្យា វិធីសាស្ត្រជួយសិស្សជួបការលំបាកក្នុងការរៀនសូត្រ របៀបគ្រប់គ្រងនិងប្រើប្រាស់ទិន្នន័យ របៀបទំនាក់ទំនង ការធ្វើផែនការ ឬ ការធ្វើតេស្តស្តង់ដា ការសរសេរកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ ។ល។</td></tr>
<tr><td>៣</td><td>ចំនួនដងទស្សនៈកិច្ចផ្តល់ការគាំទ្រពីក្រុមការងារតំបន់បានអនុវត្តតាមផែនការ</td><td>១-២</td><td>៣-៤</td><td>៥-៦</td><td>៧-៨</td></tr>
<tr><td>៤</td><td>ចំនួនដងទស្សនៈកិច្ចផ្តល់ការគាំទ្រពីមន្ទីរអប់រំបានអនុវត្តតាមផែនការ</td><td>១-២</td><td>៣-៤</td><td>៥-៦</td><td>៧-៨</td></tr>
<tr><td>៥</td><td>ចំនួនដងទស្សនៈកិច្ចផ្តល់ការគាំទ្រពីការិយាល័យអប់រំបានអនុវត្តតាមផែនការ</td><td>១-២</td><td>៣-៤</td><td>៥-៦</td><td>៧-៨</td></tr>
<tr><td colspan="6">សូចនាករទី៣ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។<br>សូចនាករទី៤ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។<br>សូចនាករទី៥ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។<br><u>សកម្មភាព៖</u><br>➢ បុគ្គលិកក្រសួងដែលត្រូវបានចាត់មកទទួលខុសត្រូវតាមតំបន់ មន្ទីរអប់រំ និងការិយាល័យអប់រំក្រុង ស្រុក ខណ្ឌ ត្រូវកំណត់នូវការប្តេជ្ញាចិត្តជួយសាលារៀន តាមរយៈការកំណត់ចំនួនដងចុះបេសកកម្មគាំទ្រដល់សាលារៀននៅក្នុងផែនការនេះ។ ចំនួនតួលេខក្រុមគោលដៅជាចំនួនសង់បន្តរាល់ឆ្នាំ ពោលគឺមានន័យថាក្នុងមួយឆ្នាំ ត្រូវមានការចុះជួយចំនួន២ដង។<br>➢ ការចុះបេសកកម្មមានវត្ថុបំណងជួយសាលារៀន មិនមែនស្វែងរកកំហុសទេ។ ការចុះបេសកកម្មត្រូវអនុវត្តតាមការណែនាំមាននៅក្នុងសៀវភៅយុទ្ធសាស្ត្រសាលារៀនសហគមន៍។<br>➢ ក្រសួងនឹងមានការចុះបេសកកម្មជាអនុវិស័យ ឬចម្រុះអនុវិស័យ ដែលអាចមានទាំងអនុវិស័យកុមារតូច បឋមសិក្សា និងមធ្យមសិក្សា។ ការចុះកម្រិតអនុវិស័យជាការចុះស្វែងយល់និងរៀនសូត្រពីថ្នាក់ក្រោមជាតិ និងសហគមន៍សាលារៀន នូវអ្វីដែលរីកចម្រើន អ្វីជាការរាំងស្ទះ ឧបសគ្គនិងការរាំងស្កាត់ ព្រមទាំងដំណោះស្រាយដែលត្រូវធ្វើដោយក្រសួង ថ្នាក់មន្ទីរ ថ្នាក់ក្រុង ស្រុក ខណ្ឌ និងសាលារៀន។ ការរកឃើញទាំងប៉ុន្មានត្រូវរាយការណ៍នៅចុងចប់នៃបេសកកម្មដល់ថ្នាក់ក្រោមជាតិ និងសហគមន៍សាលារៀន។</td></tr>
<tr><td>៦</td><td>ការបង្រៀនបំណិនកសិកម្ម និងបច្ចេកទេសបានអនុវត្តតាមផែនការ</td><td>គ្រោង</td><td>អនុវត្តតាមគ្រោងឆ្នាំទី១</td><td>អនុវត្តតាមគ្រោងឆ្នាំទី២</td><td>អនុវត្តតាមគ្រោងឆ្នាំទី៣</td></tr>
<tr><td colspan="6">សូចនាករទី៦ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។<br><u>សកម្មភាព៖</u></td></tr>
</table>

- សកម្មភាពនៃកម្មវិធីនេះមានរៀបរាប់នៅខាងលើរួចហើយ អ្វីដែលសំខាន់សម្រាប់សូចនាករនេះគឺ ការវាយតម្លៃចុងឆ្នាំថាតើកម្មវិធីបានបំពេញស្តង់ដាកម្មវិធីហើយឬនៅ។
- ការរកឃើញពីការវាយតម្លៃ នាំមកនូវការស្វែងយល់ និងការសម្រេចចិត្តថា ត្រូវពង្រីកកម្មវិធីលើមុខបំណិនណា ការប្រើប្រាស់ចំណូលប៉ុន្មានសម្រាប់ពង្រីកកម្មវិធី ទៅតាមការគណនាមូលនិធិត្រូវឧបត្ថម្ភគ្រូ សិស្ស គណៈគ្រប់គ្រង សាលារៀន គ.គ.ស. ឬ ក.ប.ស. និងមន្ត្រីកម្រិតក្រសួងអប់រំ និង/ឬគ្រូបង្រៀនរបស់មហាវិទ្យាល័យឬគ្រឹះស្ថានបណ្តុះបណ្តាលនៅឆ្នាំក្រោយ និងមូលនិធិប៉ុន្មានសម្រាប់ឧបត្ថម្ភគ្រូ សិស្ស គណៈគ្រប់គ្រងសាលារៀន គ.គ.ស. ឬ ក.ប.ស. និងមន្ត្រីកម្រិតក្រសួង និង ឬគ្រូរបស់មហាវិទ្យាល័យ ឬគ្រឹះស្ថានបណ្តុះបណ្តាលនៅឆ្នាំនេះ
- សកម្មភាពនេះជាការអនុវត្តនូវយុទ្ធសាស្ត្រសហគមន៍សាលារៀន និងជាការអនុវត្តនូវគុណតម្លៃមួយដែលបានព្រមព្រៀងគ្នាក្នុងសហគមន៍។

| | | | | | |
|---|---|---|---|---|---|
| ៧ | ចំនួនគ្រូបង្រៀនខ្វះតាមមុខវិជ្ជាថយចុះតាមផែនការ | =>១០ | ៦-៩ | ២-៥ | ០ |
| ៨ | ចំនួននាយកសាលានិងនាយករងមានតាមបទដ្ឋាន | ខ្វះ២ | ខ្វះ១ | ខ្វះ០ | ខ្វះ០ |
| ៩ | កាតរបាយការណ៍សាលារៀនបានផលិត និងបិទផ្សាយ | គ្រោង | ផលិតនិងបិទផ្សាយឆ្នាំទី១ | ផលិតនិងបិទផ្សាយឆ្នាំទី២ | ផលិតនិងបិទផ្សាយឆ្នាំទី៣ |

សូចនាករទី៧ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។
សូចនាករទី៨ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។
សូចនាករទី៩ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។

**សកម្មភាព៖**

- នាយកសាលានិងគ.គ.ស.ឬក.ប.ស.ប្រើវិធានការបំពេញតម្រូវការខ្វះគ្រូបង្រៀនតាមវិធី៣យ៉ាង៖ ក) សហការជាមួយថ្នាក់ក្រុង ស្រុក ខណ្ឌ និងមានការព្រមព្រៀងពីថ្នាក់រាជធានី ខេត្ត ដើម្បីផ្ទេរគ្រូពីសាលារៀនលើសគ្រូនៅក្បែរមកបង្រៀននៅសាលារៀនខ្វះគ្រូ ខ) នាយកសាលាពិភាក្សាជាមួយមហាវិទ្យាល័យអប់រំក្នុងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនដែលកំពុងបង្រៀនខុសមុខវិជ្ជា ឱ្យយកមុខវិជ្ជាដែលកំពុងបង្រៀនខុសជាមុខវិជ្ជាឯកទេសវិញ និង គ) ពិភាក្សាជាមួយសិស្សដែលមាននិទ្ទេសរៀនសូត្រល្អប្រសើរ និងដែលមានបំណងប្រាថ្នាធ្វើជាគ្រូបង្រៀន បញ្ជូនសិស្សនោះមករៀនធ្វើជាគ្រូបង្រៀននិងទទួលយកគេជាគ្រូកិច្ចសន្យាទៅបង្រៀននៅសាលារៀនដើមរបស់គេវិញ។
- បើរបៀបទាំង៣ខាងលើនេះនៅតែមិនអាចដោះស្រាយបញ្ហាខ្វះគ្រូទៀត នាយកសាលាយកទិន្នន័យទាំងនេះមកចែករំលែកនៅវគ្គលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន និងសិក្ខាសាលាយុទ្ធសាស្ត្រសហគមន៍សាលារៀន ដើម្បីពិភាក្សាដោះស្រាយ។ ដូចគ្នានេះដែរចំពោះកង្វះខាតនាយកសាលាឬនាយករង។
- នាយកសាលរៀនបញ្ជូនព័ត៌មាននៃសូចនាករទាំង៩ មកក្រសួង ហើយក្រសួងនឹងផលិតនូវកាតរបាយការណ៍សាលារៀនដោយមានបញ្ជាក់ស្ថានភាពនៃសូចនាករនីមួយៗ ដោយប្រៀបធៀបរវាងសាលារៀនខ្ញុំ ក្រុង ស្រុក

| | | | | |
|---|---|---|---|---|
| ខណ្ឌខ្ញុំ រាជធានី ខេត្តខ្ញុំ និងប្រទេសខ្ញុំ។ ក្រសួងនឹងបញ្ជូនកាតរបាយការណ៍នេះមកសាលារៀនវិញ ដើម្បីផ្សព្វផ្សាយជាសាធារណៈ។ កាតរបាយការណ៍នេះបង្ហាញនូវគណនេយ្យភាពដែលបានកសាងនៅកម្រិតសហគមន៍សាលារៀន កម្រិតក្រុង ស្រុក ខណ្ឌ កម្រិតរាជធានី ខេត្ត និងកម្រិតក្រសួង។ | | | | |
| **ពិន្ទុសរុបស្តង់ដាទី៥** | **៩** | **១៨** | **២៧** | **៣៦** |
| សរុបពិន្ទុជាក់ស្តែងនៅចុងឆ្នាំសិក្សាចំនួន XX (សរុបពិន្ទុពីកូឡោនខាងស្តាំទាំង៤) | | | | |
| **ពិន្ទុសរុបស្តង់ដាសហគមន៍សាលារៀន** | **៧០** | **១៤០** | **២១០** | **២៨០** |
| *នៅបន្ទាត់ចុងបញ្ចប់នៃតារាងគឺ ជាការបូកសរុបពិន្ទុស្តង់ដាសហគមន៍សាលារៀនទាំង៥ នៅរាល់ចុងឆ្នាំ ហើយពិន្ទុនេះនឹងត្រូវយកទៅប្រើប្រាស់សម្រាប់ធ្វើផែនការឆ្នាំបន្ទាប់* | | | | |

## ឃ ការធ្វើផែនការថ្នាក់ក្រោមជាតិ

### គំរូផែនការសកម្មភាពឆ្នាំរបស់ថ្នាក់រាជធានី ខេត្ត

ឈ្មោះរាជធានី ខេត្ត................................................ ថ្ងៃខែឆ្នាំវាយតម្លៃ..............................................................................

| ការងារ | ពិន្ទុពីសភាពរីកចម្រើន | | | | |
|---|---|---|---|---|---|
| | គ្មាន=១ | ទាប=២ | មធ្យម=៣ | ល្អ=៤ | ល្អប្រសើរ=៥ |
| ១. ការធ្វើផែនការប្រតិបត្តិឆ្នាំ និងការអនុវត្ត | មិនមានផែនការ | មានតែមិនតាមការណែនាំ | មាននិងតាមការណែនាំតែការអនុវត្តតិច | មាននិងតាមការណែនាំនិងអនុវត្តបានពាក់កណ្តាល | មាននិងតាមការណែនាំនិងអនុវត្តបានស្ទើរឬទាំងអស់ |
| | | | | | |
| ២. ការគ្រប់គ្រងបុគ្គលិក | គ្មានតួលេខគ្រូខ្វះឬលើស | មានតួលេខតែគ្មានដំណោះស្រាយ | មានតួលេខ មានដំណោះស្រាយ និង ចាប់ផ្តើមអនុវត្តដំណោះស្រាយ | មានតួលេខ មានដំណោះស្រាយនិងចំនួនគ្រូខ្វះឬគ្រូលើសចាប់ផ្តើមថយចុះ | មានតួលេខ មានដំណោះស្រាយ និងចំនួនគ្រូលើសឬគ្រូខ្វះលែងជាបញ្ហា |
| | | | | | |
| ៣. ការគ្រប់គ្រងសៀវភៅសិក្សាគោល និងបណ្ណាល័យ | គ្មានតួលេខពីតម្រូវការ | មានតួលេខតែគ្មានដំណោះស្រាយ | មានតួលេខ មានដំណោះស្រាយ និង ចាប់ផ្តើមអនុវត្តដំណោះស្រាយ | មានតួលេខ មានដំណោះស្រាយនិងចំនួនខ្វះឬលើសចាប់ ផ្តើមថយចុះ | មានតួលេខ មានដំណោះស្រាយ និងការខ្វះខាតលែងជាបញ្ហា |
| | | | | | |
| ៤. ការសាងសង់ និងការគ្រប់គ្រង | គ្មានតួលេខពីតម្រូវការសាងសង់ | មានតួលេខ តែមិនដឹងថាស៊ីគ្នានឹងផែនការពង្រីកសេវាឬទេ | មានតួលេខ ស៊ីគ្នានឹងផែនការពង្រីកសេវា | មានតួលេខស៊ីគ្នានឹងផែនការពង្រីកសេវានិងសហការជាមួយដៃគូក្នុងការស្វែងរកធនធានសាងសង់ | មានតួលេខស៊ីគ្នានឹងផែនការណ៍ពង្រីកសេវា សហការជាមួយដៃគូក្នុងការស្វែងរកធនធានសាងសង់ និងអគ្រាសិស្ស/ថ្នាក់មានភាពប្រសើរ |
| | | | | | |
| ៥. ការពិនិត្យតាមដាន និងវាយតម្លៃ | គ្មានផែនការពិនិត្យតាមដាន | មានផែនការពិនិត្យតាមដាន និងអនុវត្តការពិនិត្យតាមដានបានតិចតួច | មានផែនការពិនិត្យតាមដាននិងអនុវត្តការពិនិត្យតាមដានបានទៀងទាត់ ចំនួនក្រុង.ស្រុក.ខណ្ឌមានដំណើរការកើនឡើងត្រឹម៣០% | មានផែនការ អនុវត្តការពិនិត្យតាមដានបានទៀងទាត់ ចំនួនក្រុង.ស្រុក.ខណ្ឌមានដំណើរការកើនឡើងដល់៥០ភាគរយ | មានផែនការ អនុវត្តការពិនិត្យតាមដានបានទៀងទាត់ ចំនួនក្រុង.ស្រុក.ខណ្ឌមានដំណើរការកើនឡើង ដល់៨០ភាគរយ |

| | | | | | |
|---|---|---|---|---|---|
| | | | | | |
| **៦. ការគ្រប់គ្រងហិរញ្ញវត្ថុ** | គ្មានថវិកាគ្រោង | ថវិកាបានគ្រោងតាមការណែនាំ | ថវិកាបានគ្រោងតាមការណែនាំ ការបើកនិងប្រើសាច់ប្រាក់បានតិចជាង៥០ភាគរយ | ថវិកាបានគ្រោងតាមការណែនាំការបើកនិងប្រើសាច់ប្រាក់បានត្រឹម៧០ភាគរយ តែរអាក់រអួល | ថវិកាបានគ្រោងតាមការណែនាំ ការបើកនិងប្រើសាច់ប្រាក់បានច្រើនជាង៩០ភាគរយ និងទៀងទាត់តាមត្រីមាស |
| | | | | | |
| **៧. ការពិនិត្យការងាររបស់ការិយាល័យអប់រំក្រុង ស្រុក ខណ្ឌ ពិសេសលើលទ្ធផលសិក្សារបស់សិស្ស** | មិនមានតួលេខពីលទ្ធផលសិក្សារបស់សិស្ស | មានតួលេខ តែមិនដឹងថាមកពីអ្វីបានជាមានឬមិនមានការរីកចម្រើន | មានតួលេខ ដឹងថាមូលហេតុដែលនាំឱ្យរីកចម្រើនឬមិនចម្រើន តែមិនបានផ្សព្វផ្សាយ | មានតួលេខ ដឹងថាមូលហេតុដែលនាំឱ្យរីកចម្រើនឬមិនចម្រើន បានផ្សព្វផ្សាយ តែមិនមានការតាមដានការអុវត្ត | មានតួលេខ ដឹងថាមូលហេតុដែលនាំឱ្យរីកចម្រើនឬមិនចម្រើន បានផ្សព្វផ្សាយ មានការតាមដានការអនុវត្ត ហើយគំរូល្អបានយកទៅអនុវត្តនៅក្រុង ស្រុកផ្សេងទៀត |
| | | | | | |
| **៨. ការប្រើប្រាស់ថវិកាសាលារៀនមាន ប្រសិទ្ធភាព** | គ្មានតួលេខថាសាលារៀនប៉ុន្មានមានផែនការ | មានតួលេខពីចំនួនសាលារៀនមានផែនការ | សាលារៀនទាំងអស់មានផែនការ មានសហគមន៍ចូលរួមធ្វើផែនការនិងសម្រេចចិត្តក្នុងការគ្រោងថវិកា | សាលារៀនទាំងអស់គ្រោងនិងចំណាយថវិកាយ៉ាងតិច៥០% ផ្តោតលើការបង្រៀននិងរៀន និងសាលារៀន៧០ភាគរយបិទផ្សាយការចំណាយជាសាធារណៈ | សាលារៀនទាំងអស់គ្រោងនិងចំណាយថវិកាយ៉ាងតិច៧០% ផ្តោតលើការបង្រៀននិងរៀន និងបិទផ្សាយការចំណាយជាសាធារណៈ |
| | | | | | |
| **ពិន្ទុសរុប** | | | | | |
| **សរុបពិន្ទុការងារ** | 8 | 16 | 24 | 32 | 40 |
| **ពិន្ទុមិនមានដំណើរការពី ៨ ដល់ ២២** | | **ពិន្ទុមានដំណើរការពី ២៣ ដល់ ៣២** | | **ពិន្ទុមានដំណើរការប្រសើរ ៣៣ ដល់ ៤០** | |

# គំរូផែនការសកម្មភាពឆ្នាំរបស់ការិ.អយក ក្រុង ស្រុក ខណ្ឌ

•ឈ្មោះក្រុង ស្រុក ខណ្ឌ………………………………………… ថ្ងៃខែឆ្នាំវាយតម្លៃ……………………………………………………………….

| ការងារ | ពិន្ទុពីសភាពរីកចម្រើន | | | | |
|---|---|---|---|---|---|
| | គ្មាន=១ | ទាប=២ | មធ្យម=៣ | ល្អ=៤ | ល្អប្រសើរ=៥ |
| **១. ការសម្រេចលទ្ធផល សូចនាករស្តង់ដាទី១ របស់សាលារៀន** | មិនមានតួលេខ | មានតួលេខពី ការសិក្សា គ្មានការកើនឡើង ហើយទាបជាងថ្នាក់ជាតិ | មានតួលេខស្តីពីការសិក្សាកើនឡើង តែនៅទាបជាងថ្នាក់ជាតិ | មានតួលេខស្តីពីការសិក្សាកើនឡើងប្រហាក់ប្រហែលថ្នាក់ជាតិ | មានតួលេខស្តីពីការសិក្សាកើននិងលើសថ្នាក់ជាតិ |
| | | | | | |
| **២. ការធ្វើផែនការប្រតិបត្តិប្រចាំឆ្នាំ និងការអនុវត្ត** | មិនមានផែនការ | មានតែមិនតាមការណែនាំ | មាននិងតាមការ ណែនាំ តែការ អនុវត្តតិច | មាននិងតាមការ ណែនាំ និងអនុវត្តបានពាក់កណ្តាល | មាននិងតាមការណែនាំ និងអនុវត្តបានស្ទើរ ឬទាំងអស់ |
| | | | | | |
| **៣. ការគ្រប់គ្រងបុគ្គលិក** | គ្មានតួលេខគ្រូខ្វះឬលើស | មានតួលេខពីចំនួនគ្រូខ្វះឬលើស | មានឯកសារពីការស្នើសុំបំពេញចំនួនខ្វះ ឬបន្ថយចំនួនលើស | មានឯកសារពីការស្នើសុំបំពេញចំនួនខ្វះ ឬបន្ថយចំនួនលើស ហើយបញ្ហា ចាប់ផ្តើមថយចុះ | មានឯកសារពីការស្នើសុំបំពេញចំនួនខ្វះ ឬបន្ថយចំនួនលើស ហើយបញ្ហា ខ្វះឬលើសនៅមាន តិចបំផុត |
| | | | | | |
| **៤. ការគ្រប់គ្រងសៀវភៅសិក្សាគោលនិង បណ្ណាល័យ** | គ្មានតួលេខពីតម្រូវការ | មានតួលេខតែគ្មានដំណោះស្រាយ | មានតួលេខ មានដំណោះស្រាយ និង ចាប់ផ្តើមអនុវត្តដំណោះស្រាយ | មានតួលេខ មានដំណោះស្រាយ និងចំនួនខ្វះឬលើស ចាប់ផ្តើមថយចុះ | មានតួលេខ មានដំណោះស្រាយ និងការខ្វះខាតលែងជាបញ្ហា |

| | | | | | |
|---|---|---|---|---|---|
| | | | | | |
| **៥. ការសាងសង់ និងការគ្រប់គ្រង** | គ្មានតួលេខពីតម្រូវការសាងសង់ | មានតួលេខ តែមិនដឹងថាស៊ីគ្នានឹងផែនការពង្រីកសេវាឬទេ | មានតួលេខ ស៊ីគ្នានឹងផែនការពង្រីកសេវា | មានតួលេខស៊ីគ្នានឹងផែនការពង្រីកសេវានិងសហការជាមួយដៃគូក្នុងការស្វែងរកធនធានសាងសង់ | មានតួលេខស៊ីគ្នានឹងផែនការណ៍ពង្រីកសេវា សហការជាមួយដៃគូក្នុងការស្វែងរកធនធានសាងសង់ និងអត្រាសិស្ស/ថ្នាក់មានភាពប្រសើរ |
| | | | | | |
| **៦. ការគ្រប់គ្រងហិរញ្ញវត្ថុ** | មិនមានការគ្រោងថវិកា ឬមិនដឹងថាមានថវិកា | មានការគ្រោងថវិកាតាមការណែនាំ | មានការគ្រោងថវិកាតាមការណែនាំ ប្រើប្រាស់ថវិកាតាមមុខចំណាយបាន៥០% | មានការគ្រោងថវិកាតាមការណែនាំ ប្រើប្រាស់ថវិកាតាមមុខចំណាយ បានចំនួន៧០% | មានការគ្រោងថវិកាតាមការណែនាំ ប្រើប្រាស់ថវិកាតាមមុខចំណាយនិងមានចំនួន១០០% |
| | | | | | |
| **៧. ការពិនិត្យតាមដាន វាយតម្លៃ និងការគ្រប់គ្រង** | គ្មានផែនការពិនិត្យតាមដាន | មានតួលេខពីសាលារៀនមាន ស្តង់ដានិងមាន ផែនការ ពិនិត្យតាមដាន | មានផែនការ ពិនិត្យតាមដាន បានចុះជួយសាលារៀន ចំនួនសាលារៀនមានស្តង់ដា កើនដល់៣០% | មានផែនការពិនិត្យតាមដានបានចុះជួយសាលារៀន ចំនួនសាលារៀនមានស្តង់ដាកើនដល់៥០% | មានផែនការពិនិត្យតាមដាន បានចុះជួយសាលារៀន ចំនួនសាលារៀនមានស្តង់ដាកើនដល់៨០% |
| | | | | | |
| **៨. ការប្រើប្រាស់ថវិកាសាលារៀនមានប្រសិទ្ធភាព** | គ្មានតួលេខថាសាលារៀនប៉ុន្មានមានផែនការ | មានតួលេខពីចំនួនសាលារៀនមានផែនការ | សាលារៀនទាំងអស់មានផែនការ មានសហគមន៍ចូលរួមធ្វើផែនការនិងសម្រេចចិត្តក្នុងការគ្រោងថវិកា | សាលារៀនទាំងអស់គ្រោងនិងចំណាយថវិកាយ៉ាងតិច៥០% ផ្តោតលើការបង្រៀននិងរៀន និងសាលារៀន៧០ភាគរយបិទផ្សាយការចំណាយជាសាធារណៈ | សាលារៀនទាំងអស់គ្រោងនិងចំណាយថវិកាយ៉ាងតិច៧០% ផ្តោតលើការបង្រៀននិងរៀន និងបិទផ្សាយការចំណាយជាសាធារណៈ |

| | | | | | |
|---|---|---|---|---|---|
| | | | | | |
| **ពិន្ទុសរុប** | | | | | |
| **សរុបពិន្ទុការងារ** | 8 | 16 | 24 | 32 | 40 |
| ពិន្ទុមិនមានដំណើរការពី ៨ ដល់ ២២ | | ពិន្ទុមានដំណើរការពី ២៣ ដល់ ៣២ | | ពិន្ទុមានដំណើរការប្រសើរ ៣៣ ដល់ ៤០ | |

## ខ ការធ្វើផែនការធ្វើឱ្យថ្នាក់រៀនមានដំណើរការសម្រាប់ការសិក្សារបស់សិស្សម្នាក់ៗ

នេះជាជំនាក់ការទី២ក្នុងការធ្វើផែនការ។ កិច្ចការក្នុងជំនាក់ការទី២នេះមានៈ

*ការធ្វើឱ្យថ្នាក់រៀនមានដំណើរការ*

### ១) ការរៀបចំសិស្សតាមកម្រិតសមត្ថភាពសិស្ស និងការរៀបចំគណៈកម្មការគ្រប់គ្រងថ្នាក់រៀន

នៅពេលចាប់អនុវត្តយុទ្ធសាស្ត្រសាលារៀននៅឆ្នាំដំបូង សិស្សភាគច្រើនមិនមានសមត្ថភាពរៀនកម្មវិធីសិក្សានៃថ្នាក់ដែលគេកំពុងរៀននោះឡើយ និងម្យាងវិញទៀត សិស្សមានកម្រិតសមត្ថភាពខុសៗគ្នាតាំងពីកម្រិតល្អប្រសើរហូតដល់ធ្លាក់ ហើយបរិមាណសិស្សធ្លាក់មានច្រើន។ ដូចនេះជាការចាំបាច់ត្រូវរៀបចំសិស្សតាមកម្រិតសមត្ថភាពគេដើម្បីគ្រូបង្រៀនងាយស្រួលបង្រៀន ដោយបង្រៀនចាប់ពីកម្រិតសមត្ថភាបរបស់សិស្ស។

បើសាលារៀនធំ មានកម្រិតថ្នាក់ដូចគ្នាច្រើន ឧទាហរណ៍ ថ្នាក់ទី៧ មាន៣ថ្នាក់ អាចរៀបសិស្សជា៣ ក្រុម។ ១ក្រុមជាសិស្សរៀនពូកែ (A B) ១ក្រុមជាសិស្សរៀនមធ្យម (C D) និង១ក្រុមទៀត ជាសិស្សរៀនយឺត (E F)។ តែបើសាលារៀនតូចមានថ្នាក់ទី៧តែមួយថ្នាក់ សាលារៀនអាចរៀបសិស្សក្នុងថ្នាក់ជាក្រុម តាមកម្រិតសមត្ថភាព។

ចំពោះការរៀបចំគណៈកម្មការគ្រប់គ្រងថ្នាក់រៀន គ្រូទទួលបន្ទុកថ្នាក់រៀបចំការប្រជុំជាមួយ គ្រូបង្រៀន មាតាបិតាសិស្ស និងសិស្សពិភាក្សាពីការបង្កើតគណៈកម្មការគ្រប់គ្រងថ្នាក់រៀន។ របៀបរៀបចំត្រូវធ្វើតាមលំនាំដូចគ្នានឹងការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀនដែរ។ វត្ថុបំណងនៃគណៈកម្មការគ្រប់គ្រងថ្នាក់រៀនគឺ ធានាអនុវត្តនូវផែនការបង្រៀនកម្រិតថ្នាក់រៀន និងការរីកចម្រើនការសិក្សារបស់សិស្សម្នាក់ៗតាមផែនការសិក្សារៀនសូត្ររបស់សិស្សម្នាក់ៗ។

### ២) ការរៀបចំផែនការបង្រៀន៣ឆ្នាំតាមថ្នាក់ (ចំនួននិងភាគរយ)

***ពិន្ទុ និងនិទ្ទេសៈ** F:</=50; E=51-60; D=61-70; C=71-79; B=80-89; A=90-100*

| ឧទាហរណ៍ ថ្នាក់ទី៧ក មានសិស្ស ៥០នាក់ | | | | | |
|---|---|---|---|---|---|
| | | ចំនួនសិស្ស | ក្រុមគោលដៅចុងឆ្នាំទី១ ២០២១ | ក្រុមគោលដៅចុងឆ្នាំទី២ ២០២២ | ក្រុមគោលដៅចុងឆ្នាំទី៣ ២០២៣ |
| ១ | ២ | ៣ | ៤ | ៦ | ៧ |
| ភាសាខ្មែរ | | | | | |
| | A | | 2% | 4% | 8% |
| | B | | 5% | 6% | 15% |
| | C | | 10% | 14% | 17% |
| | D | | 10% | 20% | 30% |
| | E | | 23% | 26% | 20% |
| | F | | 50% | 25% | 10% |
| គណិតវិទ្យា | | | | | |
| | A | | 2% | 4% | 8% |
| | B | | 5% | 6% | 15% |

| | | | | | |
|---|---|---|---|---|---|
| | C | | 10% | 14% | 17% |
| | D | | 10% | 20% | 30% |
| | E | | 23% | 26% | 20% |
| | F | | 50% | 25% | 10% |
| រូបវិទ្យា | | | | | |
| | A | | 2% | 4% | 8% |
| | B | | 5% | 6% | 15% |
| | C | | 10% | 14% | 17% |
| | D | | 10% | 20% | 30% |
| | E | | 23% | 26% | 20% |
| | F | | 50% | 25% | 10% |
| គីមីវិទ្យា | | | | | |
| | A | | 2% | 4% | 8% |
| | B | | 5% | 6% | 15% |
| | C | | 10% | 14% | 17% |
| | D | | 10% | 20% | 30% |
| | E | | 23% | 26% | 20% |
| | F | | 50% | 25% | 10% |
| ជីវវិទ្យា | | | | | |
| | A | | 2% | 4% | 8% |
| | B | | 5% | 6% | 15% |
| | C | | 10% | 14% | 17% |
| | D | | 10% | 20% | 30% |
| | E | | 23% | 26% | 20% |
| | F | | 50% | 25% | 10% |
| ប្រវត្តិវិទ្យា | | | | | |
| | A | | 2% | 4% | 8% |
| | B | | 5% | 6% | 15% |
| | C | | 10% | 14% | 17% |
| | D | | 10% | 20% | 30% |
| | E | | 23% | 26% | 20% |
| | F | | 50% | 25% | 10% |
| ភាសាអង់គ្លេស | | | | | |
| | A | | 2% | 4% | 8% |

| | | | | | |
|---|---|---|---|---|---|
| | B | | 5% | 6% | 15% |
| | C | | 10% | 14% | 17% |
| | D | | 10% | 20% | 30% |
| | E | | 23% | 26% | 20% |
| | F | | 50% | 25% | 10% |
| ព័ត៌មានវិទ្យា | | | | | |
| | A | | 2% | 4% | 8% |
| | B | | 5% | 6% | 15% |
| | C | | 10% | 14% | 17% |
| | D | | 10% | 20% | 30% |
| | E | | 23% | 26% | 20% |
| | F | | 50% | 25% | 10% |
| សីលធម៌ពលរដ្ឋ | | | | | |
| | A | | 2% | 4% | 8% |
| | B | | 5% | 6% | 15% |
| | C | | 10% | 14% | 17% |
| | D | | 10% | 20% | 30% |
| | E | | 23% | 26% | 20% |
| | F | | 50% | 25% | 10% |
| ផែនដីនិងបរិស្ថានវិទ្យា | | | | | |
| | A | | 2% | 4% | 8% |
| | B | | 5% | 6% | 15% |
| | C | | 10% | 14% | 17% |
| | D | | 10% | 20% | 30% |
| | E | | 23% | 26% | 20% |
| | F | | 50% | 25% | 10% |
| ភូមិវិទ្យា | | | | | |
| | A | | 2% | 4% | 8% |
| | B | | 5% | 6% | 15% |
| | C | | 10% | 14% | 17% |
| | D | | 10% | 20% | 30% |
| | E | | 23% | 26% | 20% |
| | F | | 50% | 25% | 10% |
| គេហវិទ្យា | | | | | |

| | | | | | |
|---|---|---|---|---|---|
| | A | | 2% | 4% | 8% |
| | B | | 5% | 6% | 15% |
| | C | | 10% | 14% | 17% |
| | D | | 10% | 20% | 30% |
| | E | | 23% | 26% | 20% |
| | F | | 50% | 25% | 10% |
| អប់រំកាយ កីឡា និងសុខភាព | | | | | |
| | A | | 2% | 4% | 8% |
| | B | | 5% | 6% | 15% |
| | C | | 10% | 14% | 17% |
| | D | | 10% | 20% | 30% |
| | E | | 23% | 26% | 20% |
| | F | | 50% | 25% | 10% |
| អប់រំបំណិនជីវិតមូលដ្ឋាន ឬអប់រំវិជ្ជាជីវៈជម្រើស | | | | | |
| | A | | 2% | 4% | 8% |
| | B | | 5% | 6% | 15% |
| | C | | 10% | 14% | 17% |
| | D | | 10% | 20% | 30% |
| | E | | 23% | 26% | 20% |
| | F | | 50% | 25% | 10% |

*សម្គាល់៖ បញ្ចូលចំនួនសិស្សនៅក្នុងកូនឡោនទី៣, ៤, ៥, និង៦។ សម្រាប់សិស្សថ្នាក់ទី៧ ត្រូវយកចំនួនសិស្សតាមនិទ្ទេសនៃពិន្ទុតេស្តដើមឆ្នាំ តែសម្រាប់សិស្សពីថ្នាក់ទី៨ ឡើង គឺយកចំនួនសិស្សតាមនិទ្ទេសនៃពិន្ទុចុងឆ្នាំមុន។ ត្រូវបញ្ចូលទាំងចំនួនសិស្ស និងភាគរយនៅកូឡោនទី៣។ សម្រាប់កូឡោនទី៤ ដល់៦ ត្រូវបញ្ចូលចំនួនសិស្សទៅតាមចំនួនភាគរយកំណត់ក្នុងកូឡោន។ ឧទាហរណ៍ ៥ (ស្មើ១០%) ពោលគឺសរសេរទាំងចំនួន ហើយភាគរយត្រូវដាក់ក្នុងវង្វង់ក្រចក។*

ផ្អែកតាមពិសោធន៍ពីគម្រោងកែលម្អគុណភាពមធ្យមសិក្សា ការធ្វើឱ្យថ្នាក់រៀនមានដំណើរការ គឺអាចឈានទៅសម្រេចចំនួនភាគរយដែលបានកំណត់ក្នុងតារាងខាងលើ។ គ្រូទទួលបន្ទុកថ្នាក់ និងគ្រូបង្រៀនមុខវិជ្ជាតាមថ្នាក់ ត្រូវពិភាក្សាជាមួយសិស្ស និងកំណត់ថាសិស្សណាដែលត្រូវរៀនដំឡើងនិទ្ទេសរបស់ខ្លួននៅក្នុងឆ្នាំសិក្សា។ ពោលគឺសម្រាប់និទ្ទេស A B និងC សិស្សចំនួន១ ទៅ ៤នាក់ អាចគ្រោងរៀនឡើងសម្រាប់និទ្ទេសនីមួយៗក្នុងមួយឆ្នាំសិក្សា។ សម្រាប់និទ្ទេស F ត្រូវបន្ថយឱ្យបាន៧ ទៅ១០ នាក់ក្នុងមួយឆ្នាំ។ ក្រៅពីនោះគឺនិទ្ទេស D និង E ដែលនិទ្ទសទាំងពីរនេះគឺត្រូវបន្ថយឱ្យស្មើរតែអស់នៅឆ្នាំទី៤ និងទី៥។

៣) ការរៀបចំផែនការបង្រៀន៣ខែ

វត្ថុបំណងនៃផែនការបង្រៀន៣ខែ គឺ សម្រាប់ផ្តល់ការជួយគាំទ្រដល់សិស្សរៀនទាន់ពេលនិងទទួលបាននិទ្ទេសកើនឡើងតាមការគ្រោងក្នុងឆ្នាំ។ មានន័យថាបើសិស្សមាននិទ្ទេស E នៅដើមឆ្នាំសិក្សា នោះសិស្សត្រូវរៀនឱ្យបាននិទ្ទេស D នៅចុងត្រីមាសទី១ឬទី២ ឬយឺតណាស់នៅចុងត្រីមាសទី៣។

**គំរូផែនការបង្រៀន៣ខែ ថ្នាក់ទី៧ សិស្ស៥០នាក់ ខែមករាដល់មីនា ឆ្នាំ២០២១**

***ពិន្ទុ និងនិទ្ទេស៖ F:</=50; E=51-60; D=61-70; C=71-79; B=80-89; A=90-100***

| មុខវិជ្ជា | ចំនួន និង % ភាសាខ្មែរ | | | | ចំនួន/% | ចំនួន និង % គណិតវិទ្យា | | | | ចំនួន/% |
|---|---|---|---|---|---|---|---|---|---|---|
| | ទិន្នន័យ មូលដ្ឋាន | ចុងខែ មករា | ចុងខែ កុម្ភៈ | ចុងខែ មីនា | ចុងឆ្នាំ សិក្សា | ទិន្នន័យ មូលដ្ឋាន | ចុងខែ មករា | ចុងខែ កុម្ភៈ | ចុងខែ មីនា | ចុងឆ្នាំ សិក្សា |
| និទ្ទេស A | | | | | 2% | | | | | 2% |
| និទ្ទេស B | | | | | 5% | | | | | 5% |
| និទ្ទេស C | | | | | 10% | | | | | 10% |
| និទ្ទេស D | | | | | 10% | | | | | 10% |
| និទ្ទេសE | | | | | 23% | | | | | 23% |
| និទ្ទេសF | | | | | 50% | | | | | 50% |
| សរុប | 50/100% | | | | | 50/100% | | | | 50/100% |
| មុខវិជ្ជា | ចំនួន និង % រូបវិទ្យា | | | | ចំនួន/% | ចំនួន និង % គីមីវិទ្យា | | | | ចំនួន/% |
| | ទិន្នន័យ មូលដ្ឋាន | ចុងខែ មករា | ចុងខែ កុម្ភៈ | ចុងខែ មីនា | ចុងឆ្នាំ សិក្សា | ទិន្នន័យ មូលដ្ឋាន | ចុងខែ មករា | ចុងខែ កុម្ភៈ | ចុងខែ មីនា | ចុងឆ្នាំ សិក្សា |
| និទ្ទេស A | | | | | 2% | | | | | 2% |
| និទ្ទេស B | | | | | 5% | | | | | 5% |
| និទ្ទេស C | | | | | 10% | | | | | 10% |
| និទ្ទេស D | | | | | 10% | | | | | 10% |
| និទ្ទេសE | | | | | 23% | | | | | 23% |
| និទ្ទេសF | | | | | 50% | | | | | 50% |
| សរុប | | | | | | | | | | |
| មុខវិជ្ជា | ចំនួន និង % ជីវវិទ្យា | | | | ចំនួន/% | ចំនួន និង % ប្រវត្តិវិទ្យា | | | | ចំនួន/% |
| | ទិន្នន័យ មូលដ្ឋាន | ចុងខែ មករា | ចុងខែ កុម្ភៈ | ចុងខែ មីនា | ចុងឆ្នាំ សិក្សា | ទិន្នន័យ មូលដ្ឋាន | ចុងខែ មករា | ចុងខែ កុម្ភៈ | ចុងខែ មីនា | ចុងឆ្នាំ សិក្សា |
| និទ្ទេស A | | | | | 2% | | | | | 2% |
| និទ្ទេស B | | | | | 5% | | | | | 5% |
| និទ្ទេស C | | | | | 10% | | | | | 10% |
| និទ្ទេស D | | | | | 10% | | | | | 10% |
| និទ្ទេសE | | | | | 23% | | | | | 23% |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| និទ្ទេសF | | | | | 50% | | | | | 50% |
| សរុប | | | | | | | | | | |
| មុខវិជ្ជា | ចំនួន និង % អង់គ្លេស | | | | ចំនួន/% ចុងឆ្នាំសិក្សា | ចំនួន និង % ភូមិវិទ្យា | | | | ចំនួន/% ចុងឆ្នាំសិក្សា |
| | ទិន្នន័យ មូលដ្ឋាន | ចុងខែ មករា | ចុងខែ កុម្ភៈ | ចុងខែ មីនា | | ទិន្នន័យ មូលដ្ឋាន | ចុងខែ មករា | ចុងខែ កុម្ភៈ | ចុងខែ មីនា | |
| និទ្ទេស A | | | | | 2% | | | | | 2% |
| និទ្ទេស B | | | | | 5% | | | | | 5% |
| និទ្ទេស C | | | | | 10% | | | | | 10% |
| និទ្ទេស D | | | | | 10% | | | | | 10% |
| និទ្ទេសE | | | | | 23% | | | | | 23% |
| និទ្ទេសF | | | | | 50% | | | | | 50% |
| សរុប | | | | | | | | | | |
| មុខវិជ្ជា | ចំនួន និង % សីលធម៌ពលរដ្ឋ | | | | ចំនួន/% ចុងឆ្នាំសិក្សា | ចំនួន និង % ផែនដីនិងបរិស្ថានវិទ្យា | | | | ចំនួន/% ចុងឆ្នាំសិក្សា |
| | ទិន្នន័យ មូលដ្ឋាន | ចុងខែ មករា | ចុងខែ កុម្ភៈ | ចុងខែ មីនា | | ទិន្នន័យ មូលដ្ឋាន | ចុងខែ មករា | ចុងខែ កុម្ភៈ | ចុងខែ មីនា | |
| និទ្ទេស A | | | | | 2% | | | | | 2% |
| និទ្ទេស B | | | | | 5% | | | | | 5% |
| និទ្ទេស C | | | | | 10% | | | | | 10% |
| និទ្ទេស D | | | | | 10% | | | | | 10% |
| និទ្ទេសE | | | | | 23% | | | | | 23% |
| និទ្ទេសF | | | | | 50% | | | | | 50% |
| សរុប | | | | | | | | | | |
| មុខវិជ្ជា | ចំនួន និង % ភូមិវិទ្យា | | | | ចំនួន/% ចុងឆ្នាំសិក្សា | ចំនួន និង % គេហវិទ្យា | | | | ចំនួន/% ចុងឆ្នាំសិក្សា |
| | ទិន្នន័យ មូលដ្ឋាន | ចុងខែ មករា | ចុងខែ កុម្ភៈ | ចុងខែ មីនា | | ទិន្នន័យ មូលដ្ឋាន | ចុងខែ មករា | ចុងខែ កុម្ភៈ | ចុងខែ មីនា | |
| និទ្ទេស A | | | | | 2% | | | | | 2% |
| និទ្ទេស B | | | | | 5% | | | | | 5% |
| និទ្ទេស C | | | | | 10% | | | | | 10% |
| និទ្ទេស D | | | | | 10% | | | | | 10% |
| និទ្ទេសE | | | | | 23% | | | | | 23% |
| និទ្ទេសF | | | | | 50% | | | | | 50% |
| សរុប | | | | | | | | | | |
| មុខវិជ្ជា | ចំនួន និង % អប់រំកាយ កីឡានិងសុខភាព | | | | ចំនួន/% ចុងឆ្នាំសិក្សា | ចំនួន និង % អប់រំបំណិនជីវិតមូលដ្ឋាន ឬ អប់រំវិជ្ជាជីវៈជម្រើស | | | | ចំនួន/% ចុងឆ្នាំសិក្សា |
| | ទិន្នន័យ មូលដ្ឋាន | ចុងខែ មករា | ចុងខែ កុម្ភៈ | ចុងខែ មីនា | | ទិន្នន័យ មូលដ្ឋាន | ចុងខែ មករា | ចុងខែ កុម្ភៈ | ចុងខែ មីនា | |
| និទ្ទេស A | | | | | 2% | | | | | 2% |
| និទ្ទេស B | | | | | 5% | | | | | 5% |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| និទ្ទេស C | | | | | 10% | | | | | 10% |
| និទ្ទេស D | | | | | 10% | | | | | 10% |
| និទ្ទេសE | | | | | 23% | | | | | 23% |
| និទ្ទេសF | | | | | 50% | | | | | 50% |
| **សរុប** | | | | | | | | | | |

*សម្គាល់៖ គ្រូទទួលបន្ទុកថ្នាក់ ជាមួយគ្រូមុខវិជ្ជាត្រូវតែពិភាក្សាជាមួយសិស្សម្នាក់ៗពីការគ្រោងផែនការ៣ខែនេះ។ ពោលគឺ កំណត់ថាសិស្សឈ្មោះអ្វីត្រូវឡើងពីនិទ្ទេសណាទៅនិទ្ទេសណានៅក្នុងខែមករា ឬ កុម្ភៈ ឬ មីនា នៃផែនការបង្រៀន៣ខែនេះ។ រួចហើយត្រូវបង្កើតតារាងឈ្មោះសិស្សដែលរៀនឡើងពីនិទ្ទេសណាទៅនិទ្ទេសណាតាមខែនីមួយៗ ដោយមានបញ្ជាក់និទ្ទេសជាមូលដ្ឋានផងដែរ។*

## ច ការធ្វើឱ្យសិស្សម្នាក់ៗរៀនសូត្រ

**គំរូតារាងឈ្មោះសិស្សរៀនឡើងនិទ្ទេសប្រចាំខែ**

| | ឈ្មោះសិស្ស (ឧទាហរណ៍) | មុខវិជ្ជា | និទ្ទេសខែមករា | | និទ្ទេសខែកុម្ភៈ | | និទ្ទេសខែមីនា | |
|---|---|---|---|---|---|---|---|---|
| | | | ដើមខែ | ចុងខែ | ដើមខែ | ចុងខែ | ដើមខែ | ចុងខែ |
| ១ | សុរិយា | ភាសាខ្មែរ | C | B | B | B | B | A |
| | | គណិតវិទ្យា | C | C | C | B | B | B |
| ២ | ភក្ត្រា | រូបវិទ្យា | E | E | E | D | D | D |
| | | គណិត វិទ្យា | C | C | C | B | B | B |
| | | | | | | | | |
| | | | | | | | | |

*សម្គាល់៖ ជាការកម្រដែលសិស្សម្នាក់អាចមាននិទ្ទេសល្អប្រសើរលើគ្រប់មុខវិជ្ជា។ ដូចនេះនៅចុងរយៈពេល៦ឆ្នាំ ដោយរាប់ចាប់តាំងពីឆ្នាំដំបូងនៃការអនុវត្តយុទ្ធសាស្ត្រសាលារៀន សម្រាប់មុខវិជ្ជានីមួយៗ ប្រសិនបើមានសិស្សនិទ្ទេសល្អប្រសើរសរុបចំនួន ៣០% និងនិទ្ទេសល្អចំនួន ៥០% នោះជាការប្រសើរហើយ។ នៅក្នុងតារាងខាងលើគប្បីផ្តោតតែលើមុខវិជ្ជាគោល ដែលសិស្សត្រូវរៀនឱ្យបាននិទ្ទេសល្អប្រសើរឬល្អលើមុខវិជ្ជាដែលស៊ីគ្នាជាមួយមុខវិជ្ជាជំនាញដែលត្រូវទៅរៀននៅមហាវិទ្យាល័យបានហើយ។*

ដើម្បីសម្រេចគោលបំណងរៀនសូត្របង្កើននិទ្ទេសនេះបាន គ្រូមុខវិជ្ជានិងសិស្សម្នាក់ៗត្រូវផ្តោតការបង្រៀននិងរៀនឱ្យបានហ្មត់ចត់ ពិសេសការបង្រៀនត្រូវចាប់ផ្តើមពីកម្រិតសមត្ថភាពសិស្សបច្ចុប្បន្នលើមុខវិជ្ជានីមួយៗ។ ឧទាហរណ៍ សិស្សថ្នាក់ទី៧ មានសមត្ថភាពភាសាខ្មែរត្រឹមថ្នាក់ទី៣ និទ្ទេសE នោះត្រូវបង្រៀនចាប់ពីកម្រិតថ្នាក់និងនិទ្ទេសនេះឡើងទៅ។ សម្រាប់សាលារៀនដែលទើបនឹងអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀននេះ បើទោះជាសិស្សថ្នាក់ទី៨ ដល់១២ក៏ដោយ បើសិស្សណាមិនចេះអានភាសាខ្មែរ ឬមិនចេះគិតលេខ នោះមិនមានប្រយោជន៍ដែលត្រូវចាប់ផ្តើមបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រនោះទេ។ គ្រូបង្រៀនទាំងអស់ត្រូវផ្តោតការបង្រៀនមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យាកម្រិតបឋមសិក្សាសិន ដល់ពេលសិស្សចេះអាចនិងគិតលេខហើយ សឹមចាប់ផ្តើមបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ។ ម៉្យាង

វិញទៀតកិច្ចការនេះតម្រូវឱ្យមានការងាររដ្ឋបាលថ្នាក់រៀនច្រើន ដែលគ្រូតាមមុខវិជ្ជានិងសិស្សម្នាក់ៗត្រូវជួយគ្រូក្នុងការងាររដ្ឋបាលថ្នាក់រៀននេះ។ បន្ថែមពីលើការផ្តោតការរៀននិងបង្រៀន សិស្សម្នាក់ៗត្រូវរៀបចំផែនការរៀនសូត្ររបស់ខ្លួនតាមគំរូនៅខាងក្រោម៖

**<u>ការរៀបចំផែនការរៀនសូត្រប្រចាំឆ្នាំរបស់សិស្សម្នាក់ៗ</u>**

**សិស្សឈ្មោះ ពេជ្រ ចរណៃ ថ្នាក់ទី៧ក ឆ្នាំសិក្សា២០២១**

**ពិន្ទុ និងនិទ្ទេស៖** F:</=50; E=51-60; D=61-70; C=71-79; B=80-89; A=90-100

| កម្រិតសិក្សាភាសាខ្មែរដើមឆ្នាំសិក្សា | | | | | | | កម្រិតសិក្សាចុងត្រីមាសទី១ | កម្រិតសិក្សាចុងត្រីមាសទី២ | កម្រិតសិក្សាចុងឆ្នាំ |
|---|---|---|---|---|---|---|---|---|---|
| កម្រិតថ្នាក់ | ១. ស្គាល់ព្យញ្ជនៈនិងស្រៈ | ២. ស្គាល់សំឡេង | ៣. ស្គាល់ពាក្យ | ៤. អានស្ទាត់ | ៥. អានយល់ | កម្រិតសិក្សាដើមឆ្នាំ | | | |
| ទី៨ | | | | | | | | | |
| ទី៧ | | | | F | F | F | F | E | E |
| ទី៥ | | | | F | | | E | D | D |
| ទី៥ | | | E | | | | D | C | B |
| ទី៤ | | E | | | | | C | B | B |
| ទី៣ | C | | | | | | B | B | B |

| កម្រិតថ្នាក់ | កម្រិតសិក្សាគណិតវិទ្យាដើមឆ្នាំសិក្សា | | | | | | កម្រិតសិក្សាចុងត្រីមាសទី១ | កម្រិតសិក្សាចុងត្រីមាសទី២ | កម្រិតសិក្សាចុងឆ្នាំ |
|---|---|---|---|---|---|---|---|---|---|
| | □ | □ | □ | □ | □ | □ | | | |
| ទី៨ | | | | | | | | | |
| ទី៧ | | | | | | F | F | E | E |
| ទី៦ | | | | | | F | F | F | D |
| ទី៥ | | | | | E | | E | D | C |
| ទី៤ | | | | D | | | D | C | B |
| ទី៣ | | | C | | | | C | B | B |
| | | | | | | | | | |

| មុខវិជ្ជា | ពិន្ទុនិងនិទ្ទេសដើមឆ្នាំ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | ចុងឆ្នាំសិក្សា |
| រូបវិទ្យា | | | | | | | | | | | |
| គីមីវិទ្យា | | | | | | | | | | | |
| ជីវវិទ្យា | | | | | | | | | | | |
| ប្រវត្តិវិទ្យា | | | | | | | | | | | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| អង់គ្លេស | | | | | | | | | | | |
| ព័ត៌មានវិទ្យា | | | | | | | | | | | |
| សីលធម៌ ពលរដ្ឋ | | | | | | | | | | | |
| ឡូមិវិទ្យា | | | | | | | | | | | |
| គេហវិទ្យា | | | | | | | | | | | |
| អប់រំកាយ សុខភាព កីឡា | | | | | | | | | | | |
| បំណិនជីវិត វិជ្ជាជីវៈ | | | | | | | | | | | |
| | | | | | | | | | | | |

*សម្គាល់៖ សិស្សត្រូវគ្រោងនិទ្ទេសសិក្សានៅចុងត្រីមាសនីមួយៗ ពោលគឺនៅចុងខែមីនា មិថុនា កញ្ញា និងចុងឆ្នាំសិក្សា។ រួចហើយត្រូវគ្រោងប្រចាំខែចាប់ពីខែមករាទៅរហូតដល់ចុងឆ្នាំសិក្សា។ គ្រូមុខវិជ្ជានីមួយត្រូវរាប់ចំនួនសិស្សានុសិស្ស តាមនិទ្ទេស និងត្រូវធានាថាមានចំនួនស្សិដែលមាននិទ្ទេសទៅតាមចំនួនគ្រោងនៃផែនការថ្នាក់រៀន ហើយគ្រូទទួលបន្ទុកថ្នាក់ត្រូវរាប់និងធានាថាចំនួនសិស្សតាមនិទ្ទេស និងតាមមុខវិជ្ជាប្រាកដជាត្រូវនឹងចំនួនសិស្សនិងភាគរយតាមនិទ្ទេសនៃផែនការរបស់សាលារៀន។*

## ឆ. ដំណាក់កាលបញ្ចប់នៃការធ្វើផែនការសាលារៀន ចងក្រងលទ្ធផលពិភាក្សាចូលទៅក្នុងផែនការកែលម្អសាលារៀន

គ្រូទទួលបន្ទុកថ្នាក់បញ្ជូនផែនការបង្រៀនប្រចាំឆ្នាំ ផែនការបង្រៀន៣ខែ និងផែនការរៀនសូត្ររបស់សិស្សម្នាក់ៗទៅនាយកសាលា។ នាយកសាលារៀបចំប្រមូល និងពិនិត្យទិន្នន័យនៅក្នុងផែនការកម្រិតថ្នាក់រៀនទាំងអស់បូកសរុប និងពិនិត្យភាពស៊ីគ្នានៃទិន្នន័យគ្រោងតាមកម្រិតថ្នាក់រៀនជាមួយទិន្នន័យគ្រោងរបស់សាលារៀន។ ប្រសិនបើទិន្នន័យមានភាពស៊ីគ្នា នាយកសាលាអាចចាត់ទុកថាការគ្រោងតាមថ្នាក់រៀនមានភាពត្រឹមត្រូវ តែបើថ្នាក់រៀនណាមួយឬមុខវិជ្ជានៃថ្នាក់រៀនណាមួយមានទិន្នន័យគ្រោងមិនត្រឹមត្រូវ នាយកសាលាអាចស្នើឱ្យគ្រូទទួលបន្ទុកថ្នាក់រៀននោះ ធ្វើកិច្ចការជាមួយគ្រូមុខវិជ្ជានោះ កែសម្រួលទិន្នន័យគ្រោងឱ្យបានត្រឹមត្រូវ។

នាយកសាលាអាចអញ្ជើញសហគមន៍ មាតាបិតាសិស្ស សិស្ស និងគ្រូបង្រៀនទាំងអស់មកចូលរួមប្រជុំបូកសរុបលទ្ធផលនៃការធ្វើផែនការកែលម្អសាលារៀនប្រចាំឆ្នាំ។ នាយកសាលាបង្ហាញដល់អង្គប្រជុំនូវផែនការកែលម្អសាលារៀនប្រចាំឆ្នាំ និងបង្ហាញជាគំរូនូវផែនការបង្រៀនកម្រិតថ្នាក់រៀនប្រចាំឆ្នាំ ផែនការបង្រៀន៣ខែ និងផែនការរៀនត្ររបស់សិស្សម្នាក់ៗ។ រួចហើយសួរអង្គប្រជុំថា មានអ្វីដែលត្រូវកែសម្រួល បន្ថែម និងបន្ថយទេ។ បើមាន នាយកសាលាត្រូវកែសម្រួលតាមមតិអង្គប្រជុំ។ នាយកសាលាជម្រាបអង្គប្រជុំថា សាលារៀននឹងយកផែនការទាំងនេះ ទៅពិភាក្សាតាមភូមិជាមួយសមាជិកសហគមន៍ដែលមិនបានមកចូលរួមអង្គប្រជុំ បន្ទាប់សាលារៀននឹងកែសម្រួលផែនការកែលម្អសាលារៀន ហើយចុងបញ្ចប់នឹងបិទផ្សាយជាសាធារណៈនូវផែនការកែលម្អសាលារៀននៅក្នុងទីតាំងសាលារៀន ឬតាមកន្លែងសាធារណៈផ្សេងៗទៀត។

## ៤ ការសាងសង់ការទាមទារដើម្បីកសាងកិច្ចសន្យាសង្គម

ផែនការខាងលើទាំងកម្រិតសាលារៀន កម្រិតថ្នាក់រៀន និងកម្រិតសិស្សម្នាក់ៗទាំងអស់ជាការសន្យារវាងសាលារៀននិងសហគមន៍ហើយ។ ដូចនេះជាការចាប់ផ្តើមអនុវត្តនូវផែនការទាំងនេះ ជាការចាំបាច់ ក្រសួងបញ្ចូលនូវវិធីសាស្ត្របង្រៀនខាងក្រោមជាគោលសម្រាប់អនុវត្ត។ ការអនុវត្តជាប់លាប់នូវការបង្រៀនដែលជួយឱ្យសិស្សរៀនសូត្រ និងទទួលបាននូវលទ្ធផលតាមការគ្រោងនឹងបង្កើតឡើងនូវកិច្ចសន្យាសង្គមមួយដែលសហគមន៍ មាតាបិតាសិស្ស និងសិស្សមានការទុកចិត្តដល់គ្រូបង្រៀន និងសាលារៀន។

វិធីសាស្ត្រទាំងនេះមាននូវ ក) សិក្សាពីការរៀនសូត្រតាមបែបសម្របសម្រួលជាមួយសមត្ថភាពសិស្ស ខ) វិធីសាស្ត្របង្រៀនភាសាខ្មែរ និង គ) វិធីសាស្ត្របង្រៀនគណិតវិទ្យា។ ខ្លឹមសារទាំងនេះគ្រាន់តែជាគោលប៉ុណ្ណោះ តែការអនុវត្តជាក់ស្តែងអាចមានភាពប្រែប្រួលទៅតាមពិសោធន៍ជាក់ស្តែងនៅក្នុងថ្នាក់រៀននិងសាលារៀន។

### ក សិក្សាពីការរៀនសូត្រតាមបែបសម្របសម្រួលជាមួយសមត្ថភាពសិស្ស

តើអ្វីទៅជា *ប្រព័ន្ធរៀនសូត្រតាមបែបសម្របសម្រួលជាមួយសមត្ថភាពសិស្ស* ប្រព័ន្ធត្រូវបានរៀបចំឡើងសម្រាប់ជួយសិស្សទទួលបាននូវផលសម្រេចសិក្សានៅពេលប្រឡង សមត្ថភាពមុខវិជ្ជា និងសមត្ថភាពអនុវត្តនូវមុខវិជ្ជាស្ទែម (STEM) ពេលធ្វើតេស្ត។ ប្រព័ន្ធនេះតាមដានតម្រូវការសិក្សារបស់សិស្សម្នាក់ៗ ជួយសិស្សរៀនដោះស្រាយបញ្ហា ផ្តល់លទ្ធភាពដល់គ្រូបងប្រៀនប្រើបច្ចេកវិទ្យាជួយសិស្សដែលរៀនជួបការលំបាក ហើយទីបញ្ចប់សិស្សអាចរៀនបានពេញលេញនូវសមត្ថភាពមុខវិជ្ជា និងសមត្ថភាពអនុវត្តការងារ (competencies standards និង performance standards) ។

តើប្រព័ន្ធនេះមានដំណើរការយ៉ាងដូចម្តេច វាប្រែក្លាយពីការបង្រៀននិងរៀនបែបរឹងកំព្រឹសមកជាបែបសម្របឬ បត់បែនវិញ។ វាប្រែក្លាយប្លង់មេរៀន ពីមានតែមួយ មកជាប្លង់មេរៀនមានច្រើន ការបង្ហាញពីមានតែមួយសម្រាប់មួយថ្នាក់ មកជា មានច្រើនតម្រូវតាមសិស្សម្នាក់ៗ និងប្រែក្លាយខ្លឹមសារសម្រាប់ថ្នាក់ទាំងមូល មកជា ខ្លឹមសារសម្រាប់សិស្សម្នាក់ៗ។ ក្រសួង និងមហាវិទ្យាល័យអប់រំ នឹងបង្កើតមេរៀន និងប្លង់មេរៀនតាមបែបសម្របសម្រួលនេះ ដោយប្រើ Google Form នៅជំហានដំបូងឆ្នាំ២០២១ និងបន្ទាប់ប្រើជា Application។ នៅក្នុង Application មានគ្រប់មេរៀនដែលចងក្រងក្រងជាបណ្តាញចំណេះដឹង សម្រាប់គ្រូបង្រៀនប្រើជាប្លង់មេរៀន និងសម្រាប់សិស្សម្នាក់ៗរៀនសម្រាប់បុគ្គលខ្លួនឯង។ បណ្តាញចំណេះដឹងមាន បណ្ណាល័យមេរៀនតាមមុខវិជ្ជា។ ក្នុងមុខវិជ្ជានីមួយៗមានមេរៀនសព្វគ្រប់ និងតាមលំដាប់លំដោយ ដូចជាសម្រាប់មុខវិជ្ជាគណិតវិទ្យាមាន មូលដ្ឋានគណិតវិទ្យា, ពេជគណិត និងប្រមាណវិធី (Basic math, Algebra និង Calculus) ។ នៅក្នុងមេរៀននីមួយៗមាន វត្ថុបំណង សំណុំនៃប្រភេទសំណួរតេស្ត និងសំណុំខ្លឹមសារត្រូវបង្រៀន។

**បណ្តាញចំណេះដឹងគណិតវិទ្យា**



តើប្រព័ន្ធនេះជួយសិស្សដូចម្ដេច? ប្រព័ន្ធជួយកត់ត្រានូវចំណេះដឹងដែលសិស្សរៀនមុនចូលថ្នាក់រៀន រៀននៅកន្លែងណាក៏បាន (សម្របតាមសិស្សនៅមុនពេលចូលរៀនក្នុងថ្នាក់រៀន) សិស្សទទួលបាននូវការយល់និងចងចាំមេរៀន ឆ្លើយតបទៅនឹងតម្រូវការរៀនសូត្ររបស់សិស្សម្នាក់ៗ ហើយវាបានបន្ថយគម្លាតចំណេះដឹងរបស់សិស្ស (ពេលរៀនសកម្មនៅក្នុងថ្នាក់រៀន) ដូចនេះសិស្សអាចមានសមត្ថភាពអនុវត្ត វិភាគ វាយតម្លៃ និងបង្កើតបាន។

តើប្រព័ន្ធនេះជួយគ្រូបង្រៀនដូចម្ដេច? វាជួយឱ្យគ្រូដឹងថាសិស្សត្រូវការអ្វី វាវាយតម្លៃការរៀនសូត្ររបស់សិស្សធៀបជាមួយកម្មវិធីសិក្សា ហើយវាធ្វើឱ្យការបង្រៀនមានល្បឿនលឿន។ តើវិធីសាស្ត្រគរុកោសល្យមានដំណើរការយ៉ាងណា គឺវាមានប្រព័ន្ធជាលក្ខណៈសម្របសម្រួល និងសកម្ម។ ប្រព័ន្ធសម្របសម្រួល គឺ ជួយឱ្យសិស្សរៀនជាមុនតាមរយៈការធ្វើកិច្ចការជាក់លាក់ដូចជា ការអានសៀវភៅសិក្សាគោល មើលវីដេអូ ឬ ឆ្លើយសំណួរតេស្តក្នុងទូរស័ព្ទ ឬកុំព្យូទ័រដើម្បីទទួលបានព័ត៌មាន និងអនុវត្តកិច្ចការដែលបញ្ជាក់ថាមានការយល់ដឹងតាមរយៈ ការដោះស្រាយលំហាត់ ឬ លេងតេស្តជាល្បែងមុនពេលចូលរៀនក្នុងថ្នាក់រៀន។ ប្រព័ន្ធសកម្មគឺ សិស្សចូលរួមធ្វើកិច្ចការជាក់លាក់ដូចជា ដោះស្រាយឬធ្វើលំហាត់ (ករណីសិក្សា) ជាមួយសិស្សរួមថ្នាក់ និងបង្ហាញថាគេប្រាកដជាចេះមេរៀនតាមរយៈការធ្វើលំហាត់ ជាការសរសេរអត្ថបទ ដោះស្រាយបញ្ហា ឆ្លើយសំណួរតេស្ត។ នៅក្នុងប្រព័ន្ធសិក្សាសកម្ម សិស្សនឹងទទួលបាននូវការចូលចិត្តសិក្សា តាមរយៈការរៀនសូត្របែបចម្រុះមុខវិជ្ជានៅកសិដ្ឋានកសិកម្ម ឬរៀនជាងបច្ចេកទេស និងរៀនសរសេរជាអត្ថបទសិក្សាស្រាវជ្រាវ។

តើប្រព័ន្ធសម្របជាមួយសិស្សដូចម្ដេចទៅ? ជាប្រព័ន្ធនាំសិស្សរៀនតាមលំដាប់បណ្ដាញចំណេះដឹង និងតាមជម្រើសមេរៀនត្រូវរៀន។ ឧទាហរណ៍ សិស្សចូលរៀនថ្នាក់ទី៧ នៅដើមឆ្នាំសិក្សា អាចមិនចេះភាសាខ្មែរ ឬគណិតវិទ្យាតាំងពីថ្នាក់ទី៣ ឬ ទី៤ ។ ដូចនេះការបង្រៀននិងរៀនត្រូវសម្របតាមសមត្ថភាពសិស្ស មានន័យថាគ្រូត្រូវចាប់ផ្ដើមបង្រៀនពីកម្រិតសមត្ថភាពសិស្សកំពុងមាន ពោលគឺបង្រៀនភាសាខ្មែរ ឬគណិតវិទ្យាតាំងពីថ្នាក់ទី៣ ឬទី៤មក។ ម្យ៉ាងវិញទៀតការបង្រៀននិងរៀនសូត្រត្រូវចាប់ផ្ដើមពីកម្រិតសមត្ថភាពលើមុខវិជ្ជានីមួយៗ ប្រសិនបើសិស្សរៀនបានកម្រិត E មុខវិជ្ជាភាសាខ្មែរថ្នាក់ទី៣ នៅត្រូវបង្រៀនចាប់ពីកម្រិត E មក។

តើអ្វីដែលណែនាំឱ្យមាននូវការសម្របសម្រួល ពេលចូលរៀនដំបូងនៅឆ្នាំសិក្សាថ្មី សាលារៀនត្រូវធ្វើ តេស្តស្តង់ដាវាស់សមត្ថភាព ហើយប្រើលទ្ធផលតេស្តសម្រាប់ធ្វើផែនការបង្រៀនរបស់គ្រូបង្រៀន និងផែនការរៀនសូត្ររបស់សិស្ស។ សំណួរតេស្តស្តង់ដាកម្រិតថ្នាក់មួយត្រូវមានសំណុំសំណួរនៃកម្រិតថ្នាក់មុនៗ បី ឬ បួនថ្នាក់។ ឧទាហរណ៍ តេស្តស្ដង់ដាភាសាខ្មែរថ្នាក់ទី៧ ត្រូវមានសំណួរតេស្តភាសាខ្មែរតាំងពីថ្នាក់ទី៣មក។ គ្រូបង្រៀនត្រូវមានម៉ាទ្រិកប្លង់មេរៀនលម្អិតតាមមុខវិជ្ជា ដើម្បីធានានូវភាពសកម្មនៃការរៀនសូត្ររបស់សិស្ស និងធ្វើឱ្យការបង្រៀនអាចជួយសិស្សតាមទាន់កម្មវិធីសិក្សានៃថ្នាក់ដែលកំពុងរៀន។ ការធ្វើតេស្តតាមមេរៀននីមួយៗជាការសំខាន់ណាស់ ដើម្បីធានាថាសិស្សម្នាក់ៗរៀនចេះប្រាកដនូវមេរៀននីមួយៗ មុនបន្តទៅរៀនមេរៀនបន្ទាប់។













*វិធីសាស្ត្របង្រៀននិងរៀនទាំងមូលដែលប្រទេសហ្វាំងឡង់ បែបប្រទេសខ្មែរ*

យោងតាមពិសោធន៍ប្រទេសហ្វាំងឡង់ សមត្ថភាពគោលរបស់សិស្សប្រទេសកម្ពុជាអាចមានដូចខាងក្រោម ហើយមហាវិទ្យាអប់រំអាចយកជាគោលក្នុងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន៖

១) ការគិត និងការរៀនសូត្រពីរបៀបរៀនសូត្រ

២) អក្ខរកម្មវប្បធម៌ និងសុជីវធម៌ ទំនាក់ទំនង និងការថែទាំកុមារ

៣) ការគ្រប់គ្រងជីវិតប្រចាំថ្ងៃ ការថែទាំខ្លួន និងការរស់មានសុខមាលភាព

៤) អក្ខរកម្មមុខវិជ្ជាចម្រុះ

៥) ភាសាបរទេស និងបំណិនព័ត៌មានវិទ្យា

៦) បំណិនមុខរបរ និងការងារ

៧) ការចូលរួម និងកសាងការទទួលខុសត្រូវសង្គមសម្រាប់អនាគតមាននិរន្តរភាព

## ខ -យុទ្ធសាស្រ្តបង្រៀនភាសាខ្មែរ

### ការជួយសិស្សទាំងអស់ឱ្យអាននិងសរសេរភាសាខ្មែរ

ជារួមបើសិស្សមានសមត្ថភាពភាសាខ្មែរនិងគណិតវិទ្យាបានត្រឹមត្រូវ នោះសិស្សអាចរៀនគ្រប់មុខវិជ្ជាបាន។ ចំណុចពិសេសមួយទៀតគឺ បើសិស្សមានសមត្ថភាពភាសាខ្មែរ នោះសិស្សនឹងអាចរៀនគណិតវិទ្យាបាន។ ពោលគឺ បើសិស្សមានសមត្ថភាពភាសាខ្មែរ នោះសិស្សនឹងអាចរៀនគ្រប់មុខវិជ្ជាបាន។ ដើម្បីដឹងថាសិស្សមានសមត្ថភាពភាសាខ្មែរ នោះសូចនាករសំខាន់នៃសមត្ថភាពភាសាខ្មែរគឺ សិស្សអាចអានបានតាមស្តង់ដាចំនួនពាក្យក្នុងមួយនាទីនិងអានពាក្យនីមួយៗបានត្រឹមត្រូវ។ ស្តង់ដាចំនួនពាក្យក្នុងមួយនាទីសម្រាប់សិស្សថ្នាក់ទី៣គឺ ៤៥ ទៅ ៦០ពាក្យ សិស្សថ្នាក់ទី ៦ ឬ ទី៧គឺ ១០០ ទៅ ១២០ពាក្យ និងសិស្សថ្នាក់ទី៩ គឺ ២០០ ទៅ២៥០ពាក្យ។ ប្រសិនបើសិស្សអានពាក្យនីមួយៗត្រូវ និងអានបានតាមចំនួនពាក្យទាំងនេះ នោះសិស្សនឹងអាចយល់ខ្លឹមសារនៃឃ្លានិងកថាខណ្ឌដែលបានអាន។ បើសិស្សអានកថាខណ្ឌនីមួយៗយល់បាន នោះសិស្សក៏នឹងអាចយល់អត្ថបទបានដែរ។ ការដែលមានសមត្ថភាពអានអត្ថបទច្រើនជាមួយនឹងការយល់ដឹងពីអត្ថបទ នាំឱ្យសិស្សអាចគិតនិងពិចារណាពីខ្លឹមសារអត្ថបទហើយសិស្សនឹងចង់អានសៀវភៅកាន់តែច្រើន និងនៅទីបញ្ចប់សិស្សនឹងឈានដល់ការអានសៀវភៅច្រើនបាន។ ពេលសិស្សអានសៀវភៅបានច្រើន នោះសិស្សអាចចាប់ផ្តើមចេះសរសេរអត្ថបទបាន។

តែដំណាក់កាលដំបូងដើម្បីចេះអាន សិស្សត្រូវចាប់ផ្តើមរៀនអក្សរតាមដំណាក់កាល៥ដូចខាងក្រោម៖

ភាសាខ្មែរជាភាសាដែលត្រូវរៀនតាមរបៀបប្រកបអក្សរ ដោយការភ្ជាប់ព្យញ្ជនៈនិងស្រៈបង្កើតបានជាពាក្យ។ មិនមែនដូចភាសាចិន ឬ អង់គ្លេសដែលអាចពាក្យមួយៗតែម្តងដោយមិនបាច់ប្រកបនោះទេ។

១) **ស្គាល់ព្យញ្ជនៈនិងស្រៈ** នេះជាដំណាក់ដំបូងដែលសិស្សត្រូវស្គាល់ ដើម្បីអាចឈានទៅប្រកបបង្កើតបានជាសំឡេងនៃពាក្យមួយៗ។

២) **ស្គាល់សំឡេងជាមួយពាក្យ** នេះជាដំណាក់ដែលសិស្សរៀនប្រកបពាក្យ ដោយការផ្គុំព្យញ្ជនៈនិងស្រៈ និងចាប់ផ្តើមស្គាល់សំឡេងជាពាក្យ។

៣) **អានភាសា** នេះជាដំណាក់ចាប់ផ្តើមផ្គុំពាក្យច្រើននិងអានជាពាក្យ ជាឃ្លា។ នេះជាសមត្ថភាពសំខាន់ណាស់នៅពេលដំបូង បើសិស្គាល់ពាក្យច្រើន នោះសិស្សអាចអានឃ្លាបានច្រើន។

៤) **អានស្ទាត់** នេះជាដំណាក់កាលដែលសិស្សអានពាក្យច្រើនសម្បូបែបបានត្រឹមត្រូវ ពង្រីកចំណុះខួរក្បាលដោយការចាំពាក្យច្រើន ដែលគ្រាន់តែក្រឡេកភ្លាមស្គាល់ពាក្យភ្លាម ការបំពេញពេលវេលាក្នុងការអានសៀវភៅបានឆាប់និងកាន់តែច្រើន និងអានច្រើនពេលណាការយល់ដឹងនឹងកាន់តែកើនពេលនោះ ហើយល្បឿនអានកាន់តែកើន។

៥) **អានយល់** អ្នកអានពូកែ គឺ មានចំណាប់អារម្មណ៍ណាស់ទៅលើរឿងដែលគេអាន។ ពេលអាន គេពុនូវទំនាក់ទំនងគ្នានៃមនុស្សនៅក្នុងខួរក្បាលគេ គេមើលឃើញនូវចរិយានៃមនុស្សទាំងនោះ យល់ដឹងខ្លឹមសារស៊ីជម្រៅ ដែលវាច្រើនជាងឃ្លានៅក្នុងទំព័រសៀវភៅ។ អ្នកអានបែបនេះគិតស្រមៃនូវអ្វីដែលកំពុងកើតឡើងនៅក្នុងរឿង ហើយរំលែកជាមួយមនុស្សជុំវិញនូវចិត្តអារម្មណ៍ដែលកើតឡើងពីរឿងកំពុងអាន។

ដូចនេះគ្រូបង្រៀនត្រូវតែចាប់បង្រៀនសិស្សពីកម្រិតសមត្ថភាពភាសាដែលសិស្សកំពុងមាន ថាតើសិស្សម្នាក់ៗកំពុងស្ថិតនៅចន្លោះកម្រិតណា ពីកម្រិតទី១ ដល់ទី៥។ គ្រូបង្រៀនត្រូវជួយសិស្សតាមគ្រប់វិធីនិងគ្រប់សកម្មភាពដែលសិស្សធ្វើជាប្រចាំថ្ងៃ។ រៀនរួចរកព្យញ្ជនៈនិងស្រៈ រៀនរួចរកពាក្យ រៀនរួចរកពាក្យនិងភ្ជាប់ពាក្យជាឃ្លា រៀនអាននិងភ្ជាប់

ឃ្លាច្រើនចូលគ្នា រៀនអានកថាខណ្ឌ រៀនអានអត្ថបទ រៀនអានបង្កើនល្បឿនអំណាន រៀនអានមេរៀនមួយ រៀនអានសៀវភៅ។ល។ សកម្មភាពរៀនអានរៀនដោយសិស្សម្នាក់ៗនៅក្នុងថ្នាក់ ពេលសម្រាកក្នុងសាលារៀន ពេលនៅផ្ទះ ឬរៀនជាក្រុម ឬរៀនជាការប្រកួតប្រជែង ជាការប្រជែងអំណាន ឬការសរសេរអត្ថបទ ឬ កំណាព្យ។ សម្ភារៈអានមានដូចជាសៀវភៅសិក្សាគោលទាំងអស់ គ្រប់សៀវភៅនិងឯកសារទាំងអស់ដែលសិស្សមាននៅផ្ទះសិស្ស ឬផ្ទះមិត្តភក្តិសិស្ស ឬមាននៅបណ្ណាល័យសាលារៀន ។ល។

- *កម្រិតថ្នាក់រៀន សិស្សម្នាក់ៗ និងសាលារៀន*

អនុវត្តដូចនៅឆ្នាំទី១ដែរ តែត្រូវសង់បន្តទាំង លទ្ធផលសិក្សា ពិន្ទុស្តង់ដាសហគមន៍សាលារៀន និងការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន។

### ខ. ពិនិត្យទិន្នន័យជឿជាក់បានសម្រាប់សូចនាករពឹងកសារសម្អាងនិងម្ចាស់ទិន្នន័យ

- *ពិនិត្យទិន្នន័យតេស្តវាយតម្លៃសមត្ថភាពសិស្ស*

នាយកសាលាត្រូវបន្តការអនុវត្តតេស្តស្តង់ដាឱ្យបានហ្មត់ចត់តាមការណែនាំ ទាំងលើការប្រើសំណួរ តេស្តដែលក្រសួងផ្តល់ឱ្យ និងលើរដ្ឋបាលគ្រប់គ្រងការអនុវត្តតេស្ត។ ទិន្នន័យតេស្តអាចយកជាការបាន ឬអាចជឿជាក់បាន លុះណាការធ្វើតេស្តត្រូវបានអនុវត្តតាមការណែនាំ។ ដូចនេះក្រសួងត្រូវធានាថានៅពេលចុះបេសកកម្មផ្តល់ការគាំទ្រ ត្រូវពិនិត្យគុណភាពទិន្នន័យតេស្ត ទាំងលើសំណួរតេស្ត និងរដ្ឋបាលគ្រប់គ្រងការអនុវត្តតេស្ត ដោយសម្អាងលើភស្តុតាងដែលមាន។

- *ទិន្នន័យការរីកចម្រើនការអនុវត្តផែនការកែលម្អសាលារៀន*

ដូចគ្នានឹងការពិនិត្យគុណភាពទិន្នន័យតេស្ត ភស្តុតាងទាំងអស់ត្រូវតែមាន។ នាយកសាលាទទួលខុសត្រូវលើការរក្សាភស្តុតាងទាំងនេះ។ ដោយឡែកក្រៅពីទិន្នន័យតេស្ត (ស្តង់ដាទី១) ភស្តុតាងទាក់ទងគ្រប់សូចនាករនៃស្តង់ដាទី២ ទី៣ ទី៤ និងទី៥ត្រូវមានគ្រប់ទាំងអស់។ បើសូចនាករណាមានភស្តុតាង ហើយដែលបំពេញបានលក្ខខណ្ឌក្នុងការផ្តល់ពិន្ទុ នោះពិន្ទុដែលបានផ្តល់ឱ្យដោយសាលារៀននឹងត្រូវបានទទួលស្គាល់។

### គ. អនុវត្តស្វ័យវាយតម្លៃសាលារៀននិងការរាយការណ៍នៅចុងឆ្នាំ

- *ពិនិត្យឡើងវិញកម្រិតថ្នាក់រៀនលើការអនុវត្តផែនការកែលម្អសាលារៀន*

អនុវត្តដូចឆ្នាំទី១ដែរ ការពិនិត្យនេះមានទាំងកម្រិតសិស្សម្នាក់ៗនិងកម្រិតថ្នាក់រៀន ដោយប្រើតារាង ដូចគ្នា និងត្រូវប្រៀបធៀបការសម្រេចលទ្ធផលធៀបជាមួយក្រុមគោលដៅគ្រោងចុងឆ្នាំ។ បើសម្រេចមិនបាន ចំនួនដែលខ្វះ ត្រូវយកទៅសង់បន្ថែមជាមួយក្រុមគោលដៅឆ្នាំបន្ទាប់។ តែត្រូវចៀសវាងទំហំនៃការសម្រេចមិនបានដែលនាំទៅដល់ភាពបរាជ័យនៃការសម្រេចក្រុមគោលដៅចុងឆ្នាំទី៣។

- *ពិនិត្យឡើងវិញកម្រិតសាលារៀនលើការអនុវត្តផែនការកែលម្អសាលារៀន*

អនុវត្តដូចឆ្នាំទី១ដែរ ដោយប្រើតារាងដូចគ្នា។ ផ្តោតលើកិច្ចការនៃសូចនាករណាដែលនៅតែមានឧបសគ្គនិងការរាំងស្ទាត់ ពិសេសបរិមាណគ្រូនិងនាយកសាលាដែលខ្វះ បន្ទប់ថ្នាក់រៀនខ្វះ ជាមួយនឹងការចុះបេសកកម្មគាំទ្រពីថ្នាក់ក្រោមជាតិនិងថ្នាក់ជាតិ។

- *ដាក់ពិន្ទុវាយតម្លៃការរីកចម្រើនស្តង់ដាសាលារៀនដើម្បីកំណត់តួលេខមូលដ្ឋានសម្រាប់ធ្វើផែនការឆ្នាំបន្ទាប់*

នាយកសាលាជាអ្នកទទួលខុសត្រូវលើការវាយតម្លៃស្តង់ដាសហគមន៍សាលារៀននេះ។ នៅពេលពិនិត្យ ឡើងវិញនូវការអនុវត្តផែនការកែលម្អសាលារៀន នាយកសាលានិងនាយករង គ្រូទទួលបន្ទុកថ្នាក់ និងតំណាងសិស្សត្រូវពិនិត្យភស្តុតាងទាក់ទងនឹងសូចនាករនីមួយៗ និងកំណត់នូវភាពជោគជ័យ និងមិនជោគជ័យ រួចហើយសម្រេចផ្តល់ពិន្ទុដល់សូចនាករនីមួយៗ និងសរុបពិន្ទុតាមស្តង់ដានីមួយៗ ហើយទីបំផុតសរុបពិន្ទុសរុបសម្រាប់សាលារៀនទាំងមូល។ ពិន្ទុបានផ្តល់នឹងត្រូវយកទៅប្រើសម្រាប់ជាពិន្ទុមូលដ្ឋានក្នុងការធ្វើផែនការកែលម្អសាលារៀននៅឆ្នាំបន្ទាប់។

➢ *ការវាយតម្លៃនិងរាយការពីការអនុវត្តយុទ្ធសាស្ត្រសាលារៀន*

អនុវត្តដូចគ្នានឹងឆ្នាំទី១ ក្នុងការឆ្លើយនឹងសំណួរដឹកនាំទាំងប្រាំបី។

### *ឃ. តួនាទីសិស្សនិងក្រុមប្រឹក្សាយុវជនក្នុងការអនុវត្តរបស់សាលារៀន*

➢ *ការអប់រំនិងការអនុវត្ត*

នៅឆ្នាំទី២ នាយកសាលាគប្បីរៀបចំការប្រជុំនៅដើមឆ្នាំដើម្បីរៀបចំការបោះឆ្នោតជ្រើសរើសតំណាងសិស្សឬយុវជនឱ្យជួយដល់ការងាររបស់សាលារៀន ពិសេសចូលរួមក្នុងសូចនាករស្តង់ដាទី៤ និងស្តង់ដាទី៥។ ការចូលរួមនេះមានប្រយោជន៍ សម្រាប់កសាងសមត្ថភាពដឹកនាំនិងគ្រប់គ្រងរបស់យុវជនខ្លួនឯង ជួយដល់សាលារៀនក្នុងការផ្តល់ព័ត៌មានពិត និងទាន់ពេលដល់នាយកសាលានិងគគែឬក.ប.ស.ដើម្បីដោះស្រាយបញ្ហាទាន់ពេលវេលា និងពិសេសទៅទៀតកិច្ចការនេះជាបំណែកសំខាន់ក្នុងការកសាងតម្លាភាពនិងគណនេយ្យភាពសាលារៀន។

➢ *កម្មវិធីពិភាក្សាទៀងទាត់ជាមួយមាតាបិតានិងសិស្សពីចិត្តសង្គមនិងការថែកូន*

វត្ថុបំណងនៃកិច្ចការនេះគឺ ១) កសាងសមត្ថភាពមាតាបិតាពីការថែទាំងកូន និងធ្វើឱ្យបរិយាកាសគ្រួសារសិស្សមានភាពល្អដូចគ្នានៅសាលារៀន និង ២) កសាងសមត្ថភាពយុវជនឱ្យក្លាយទៅជាមនុស្សល្អ ដែលអនាគតគេអាចថែរក្សាកូនរបស់គេបានល្អ។

នាយកសាលានឹងទទួលបាននូវចំណេះដឹងនេះនៅក្នុងវគ្គលើកកម្ពស់គុណវុឌ្ឍិនាយកសាលា ហើយដូចគ្នានឹងគ្រូបង្រៀនដែរ នឹងទទួលបាននូវការថែរក្សាសិស្សឱ្យគេមានសមត្ថភាពពេញលេញក្នុងការសិក្សារៀនសូត្រ។ សកម្មភាពអប់រំមាតាបិតានឹងត្រូវបញ្ចូលទៅក្នុងផែនការកែលម្អសាលរៀនប្រចាំឆ្នាំ។

## *៥- រំលែកព័ត៌មានពីលទ្ធផលសម្រេចបានសម្រាប់កសាងគណនេយ្យភាព*

### *ក ផ្សព្វផ្សាយសាធារណៈនូវទិន្នន័យត្រូវការ*

➢ *ប្រមូល ដាក់ស្នើ និងផ្សព្វផ្សាយទិន្នន័យដល់សាធារណៈ*

អនុវត្តដូចឆ្នាំទី១ដែរ ប្រភេទទិន្នន័យមាន លទ្ធផលប្រឡងស្តង់ដាចុងឆ្នាំ ផលសម្រេចអប់រំនិងការសិក្សារៀនសូត្រ៣ឆ្នាំ ការរីកចម្រើនការអនុវត្តផែនការកែលម្អសាលារៀនប្រចាំឆ្នាំដោយមានពិន្ទុពីការរីកចម្រើនស្តង់ដាសហគមន៍សាលារៀន ចំណូលនិងចំណាយ និងកាតរបាយការណ៍ប្រៀបធៀបសូចនការសំខាន់ៗប្រចាំឆ្នាំ។

# ឆ្នាំទី៣ ឆ្ពោះទៅរកការរក្សានិរន្តរភាពសាលារៀនជាមួយកម្មវិធីបំណិនរកចំណូល

## ១ វត្ថុបំណង

វត្ថុបំណងយុទ្ធសាស្ត្រសហគមន៍សាលារៀនឆ្នាំទី៣នេះគឺ ការធានបំពេញបាននូវការសម្រេចក្រុមគោលផលសម្រេចអប់រំនិងការសិក្សារៀនសូត្ររបស់សិស្សឆ្នាំទី៣ ការសម្រេចបាននូវស្តង់ដាសហគមន៍សាលារៀន និងការចាប់ផ្តើមនូវការថែរក្សាគ្រូបង្រៀន នាយកសាលា សិស្ស និងសហគមន៍ទាំងមូល។

ឆ្នាំទី៣ជាឆ្នាំដែលត្រូវបន្តអនុវត្តសកម្មភាពពីឆ្នាំទី១ និងទី២ និងបន្ថែមកម្មវិធីបំណិនរកចំណូល និងកម្មវិធីធានារ៉ាប់រងសង្គមនិងអភិវឌ្ឍសមត្ថភាព។ ខ្លឹមសារធំៗមានដូចខាងក្រោម៖

១) ការកំណត់ក្រុមគោលដៅឆ្នាំទី៣ដើម្បីធានាសម្រេចបាននូវក្រុមគោលដៅគ្រោងឆ្នាំទី៣
២) ការធ្វើផែនការបំពេញស្តង់ដាសហគមន៍សាលារៀន
៣) កម្មវិធីបំណិនរកចំណូល
៤) ការអនុវត្តការទទួលខុសត្រូវសង្គមដោយការជួយសាលារៀនផ្សេងទៀតក្នុងសហគមន៍
៥) ការពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើទិន្នន័យជឿជាក់បាន

## ២ ការកំណត់ក្រុមគោលដៅឆ្នាំទី៣បំពេញបាននូវក្រុមគោលដៅគ្រោងឆ្នាំទី៣

### ក- កែសម្រួលក្រុមគោលដៅផលសម្រេចនិងការសិក្សារៀនឆ្នាំទី៣

ពិនិត្យ និងបញ្ចូលទិន្នន័យទៅក្នុងតារាងខាងក្រោម ហើយអនុវត្តការពិភាក្សាដីចខាងក្រោម៖

**ផែនការសមិទ្ធកម្មសូចនាករគន្លឹះ ឆ្នាំ២០២២ ដល់ ២០២៦ សម្រាប់ឆ្នាំ២០២៣**

ចំពោះក្រុមគោលដៅសូចនាករផលសម្រេច៖ ករណីសូចនាករណាមួយមិនបានសម្រេចតាមក្រុមគោលដៅឆ្នាំ ២០២២ ឧទាហរណ៍ សូចនាករទី៣ មានក្រុមគោលដៅចំនួន ២៧ តែសម្រេចបានត្រឹម ២៤ ដូចនេះសាលារៀនត្រូវដឹងថា មានកង្វះចំនួន៣ និងតើមានចំនួនកង្វះប៉ុន្មានតាមកម្រិត A, B និង C ។ រួចហើយត្រូវយកចំនួនខ្វះ៣នេះទៅបូកបន្ថែមលើក្រុមគោលដៅឆ្នាំ២០២៣ និងទៅតាមកម្រិតសិក្សានីមួយៗ។ សូមមើលឧទាហរណ៍ខាងក្រោម ដែលដូចគ្នានឹងការបំពេញនៅឆ្នាំទី២ដែរ។

| សមិទ្ធកម្មគន្លឹះ | ឆ្នាំមូលដ្ឋាន 2021 | 2021 | 2022 | 2023 | 2024 | 2025 | 2026 |
|---|---|---|---|---|---|---|---|
| **សូចនាករផលសម្រេច** | | | | | | | |
| ១. ភាគរយចូលរៀនថ្នាក់ទី៧នៃសិស្សថ្នាក់ទី៦ | TBP | 94 | 95 | 96 | 97 | 98 | 99 |
| ២. ភាគរយបោះបង់ការសិក្សា | TBP | 1 | 1 | 1 | 0.5 | 0 | 0 |
| ៣. ភាគរយសិស្សភាសាខ្មែរ និទ្ទេស A, B និង C | TBP | 14/17 (2/2, 4/5, 8/10) | 24/27 (4/6/11/14/16) | 40+3 (8/15+1/17+2) | 62 (12/20/20) | 66 (16/25/25) | 80 (20/30/30) |
| ៤. ភាគរយសិស្សគណិតវិទ្យានិទ្ទេស A, B និង C | TBP | 17 (2/5/10) | 24 (4/6/14) | 40 (8/15/17) | 52 (12/20/20) | 66 (16/25/25) | 80 (20/30/30) |
| ៥. ភាគរយសិស្សរូបវិទ្យា និទ្ទេស A, B និង C | TBP | 17 (2/5/10) | 24 (4/6/14) | 40 (8/15/17) | 52 (12/20/20) | 66 (16/25/25) | 80 (20/30/30) |
| ៦. ភាគរយសិស្សគីមីវិទ្យា និទ្ទេស A, B និង C | TBP | 17 (2/5/10) | 24 (4/6/14) | 40 (8/15/17) | 52 (12/20/20) | 66 (16/25/25) | 80 (20/30/30) |
| ៧. ភាគរយសិស្សជីវវិទ្យា | TBP | 17 | 24 | 40 | 52 | 66 | 80 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| និទ្ទេស A, B និង C | | (2/5/10) | (4/6/14) | (8/15/17) | (12/20/20) | (16/25/25) | (20/30/30) |
| ៨. ភាគរយសិស្សប្រវត្តិវិទ្យា និទ្ទេស A, B និង C | TBP | 17 (2/5/10) | 24 (4/6/14) | 40 (8/15/17) | 52 (12/20/20) | 66 (16/25/25) | 80 (20/30/30) |
| ៩. ភាគរយសិស្សភាសាអង់គ្លេសនិទ្ទេស A, B និង C | TBP | 17 (2/5/10) | 24 (4/6/14) | 40 (8/15/17) | 52 (12/20/20) | 66 (16/25/25) | 80 (20/30/30) |
| ១០. ភាគរយសិស្សព័ត៌មានវិទ្យានិទ្ទេស A, B និង C | TBP | 17 (2/5/10) | 24 (4/6/14) | 40 (8/15/17) | 52 (12/20/20) | 66 (16/25/25) | 80 (20/30/30) |
| ១១. ភាគរយសិស្សសីលធម៌ពលរដ្ឋនិទ្ទេស A, B និង C | TBP | 17 (2/5/10) | 24 (4/6/14) | 40 (8/15/17) | 52 (12/20/20) | 66 (16/25/25) | 80 (20/30/30) |
| ១២. ភាគរយសិស្សផែនដី និងបរិស្ថានវិទ្យានិទ្ទេស A, B និង C | TBP | 17 (2/5/10) | 24 (4/6/14) | 40 (8/15/17) | 52 (12/20/20) | 66 (16/25/25) | 80 (20/30/30) |
| ១៣. ភាគរយសិស្សភូមិវិទ្យា និទ្ទេស A, B និង C | TBP | 17 (2/5/10) | 24 (4/6/14) | 40 (8/15/17) | 52 (12/20/20) | 66 (16/25/25) | 80 (20/30/30) |
| ១៤. ភាគរយសិស្សគេហវិទ្យានិទ្ទេស A, B និង C | TBP | 17 (2/5/10) | 24 (4/6/14) | 40 (8/15/17) | 52 (12/20/20) | 66 (16/25/25) | 80 (20/30/30) |
| ១៥. ភាគរយសិស្សអប់រំកាយ កីឡា និងសុខភាពនិទ្ទេស A, B និង C | TBP | 17 (2/5/10) | 24 (4/6/14) | 40 (8/15/17) | 52 (12/20/20) | 66 (16/25/25) | 80 (20/30/30) |
| ១៦. ភាគរយសិស្សអប់រំបំណិនជីវិតមូលដ្ឋាន ឬអប់រំវិជ្ជាជីវៈជម្រើស និទ្ទេស A, B និង C | TBP | 17 (2/5/10) | 24 (4/6/14) | 40 (8/15/17) | 52 (12/20/20) | 66 (16/25/25) | 80 (20/30/30) |

ចំពោះសូចនាករនាំឱ្យសម្រេចផលសម្រេច គឺ ធ្វើដូចគ្នានឹងសូចនាករផលសម្រេចដែរសម្រាប់សូចនាករណាដែលមានក្រុមគោលដៅជាតួលេខ។ តែសម្រាប់សូចនាករផ្សេងទៀតដែលក្រុមគោលដៅមិនមែនជាតួលេខ ត្រូវសរសេរពណ៌បៃតងសម្រាប់សូចនាករសម្រេចបាន និងពណ៌ក្រហមលើសូចនាករសម្គាល់មិនបានពីឆ្នាំ២០២២។

| **សូចនាករនាំឱ្យសម្រេចផលសម្រេច** | **ឆ្នាំមូលដ្ឋាន** 2021 | **2021** | **2022** | **2023** | **2024** | **2025** | **2026** |
|---|---|---|---|---|---|---|---|
| ១. ផលសម្រេចនិងក្រុមគោលដៅសិក្សា៣ឆ្នាំបានផលិត | ទេ | មាន | មាន | មាន | មាន | មាន | មាន |
| ២. ផែនការបង្រៀន៣ឆ្នាំតាមកម្រិតថ្នាក់និងមុខវិជ្ជាបានផលិត | ទេ | មាន | មាន | មាន | មាន | មាន | មាន |
| ៣. ផែនការកែលម្អសាលារៀនបានផលិតនិងបិទផ្សាយសាធារណៈ | ទេ | មាន | មាន | មាន | មាន | មាន | មាន |
| ៤. សាលាមានស្តង់ដាយុទ្ធសាស្ត្រសហគមន៍សាលារៀន | ទេ | ពុំទាន់ | ពុំទាន់ | ពុំទាន់ | មាន | មាន | មាន |
| ៥. សាលារៀនមានកម្មវិធីបំណិនរកចំណូលដែលមានស្តង់ដាតាមកម្មវិធី | ទេ | ពុំទាន់ | ពុំទាន់ | មាន | មាន | មាន | មាន |
| ៦. ភាគរយគ្រូបង្រៀនចូលរៀននៅកម្មវិធីលើកកម្ពស់គ្រូបង្រៀន | ទេ | 30 | 35 | 45 | 60 | 75 | 90 |
| ៧. ភាគរយនាយកសាលាបានចូលរួមកម្មវិធីលើកកម្ពស់គុណវុឌ្ឍិនាយកសាលា | ទេ | 1 | 2 | 2 | 3 | 4 | All |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៨. សាលារៀនមានកម្មវិធីធានារ៉ាប់រងសង្គមនិងអភិវឌ្ឍសមត្ថភាពមន្ត្រី | ទេ | ពុំទាន់ | ពុំទាន់ | ពុំទាន់ | មាន | មាន | មាន |
| ៩. ភាគរយសិស្សទទួលរងហិង្សានៅផ្ទះ និងសាលារៀន | TBP | 0.5 | 0 | 0 | 0 | 0 | 0 |
| ១០. ភាគរយសិស្សអនុវត្តបំណិនកសិកម្មឬបច្ចេកទេស និងមានសន្សំលុយ | ទេ | >50% | >55% | >60% | >70% | >80% | >98% |
| ១១. គ្រប់ថ្នាក់រៀនប្រើបច្ចេកវិទ្យាសម្រាប់បង្រៀននិងរៀន | ទេ | >10% | >20 | >30 | >50% | >70% | >80% |
| ១២. ភាគរយសិស្សថ្នាក់ទី៩ជាប់ល្បឿនអំណានក្នុងមួយនាទី | TBP | >45% | >50% | >60% | >75% | >80% | >90% |
| ១៣. ភាគរយសិស្សថ្នាក់ទី៩ប្រឡងថ្នាក់ជាតិទី៩ (កម្រិតសំណួរ PISA) | TBP | >60% | >65% | >70% | >80% | >90% | >90% |
| ១៤. ភាគរយសិស្សថ្នាក់ទី១២ប្រឡងជាប់ថ្នាក់ជាតិ | TBP | >60% | >65% | >70% | >80% | >90% | >90% |

*សម្គាល់៖ ចំពោះកូឡោនទី២ដែលមានអក្សរ **TBP** គឺត្រូវមានសរសេរបញ្ចូលនូវទិន្នន័យមូលដ្ឋាន។ ក្រុមគោលដៅរៀនសូត្រសម្រាប់ឆ្នាំ២០៣០គឺ **30%A + 50%B + 20%C = 100%***

បន្ទាប់ពីបំពេញទិន្នន័យក្នុងតារាងខាងលើ នាយកសាលាសហការណ៍ជាមួយ នាយករងសាលារៀន គ្រូទទួលបន្ទុកថ្នាក់ និងតំណាងយុវជនអនុវត្តកិច្ចការនេះ។ ក្នុងករណីការសម្រេចក្រុមគោលដៅឆ្នាំទី៣តាមបរិមាណដែលបានគ្រោង នោះជាការប្រសើរបំផុត។ តែបើក្នុងករណីមានសូចនាករណាដែលក្រុមគោលដៅឆ្នាំទី៣មិនបានសម្រេច នោះជាការសំខាន់ដែលត្រូវវិភាគរកមូលហេតុ។ ការវិភាគមូលហេតុមានដូចខាងក្រោម។ នាយកសាលាត្រូវមានភាពហ្មត់ចត់ក្នុងការដឹកនាំការប្រជុំនេះ បើពុំនោះទេភាពរាជ័យនេះនឹងបន្តរីករាលដាល ដែលអាចនឹងនាំសាលារៀនទាំងមូលឈានទៅរកសមភាពដើមនៃអតីតកាលវិញ។

មូលហេតុអាចមានមកពី៖

១) ស្វែងរកថាតើអ្នកណា (ឈ្មោះអ្វីនិងឋានៈអ្វី) ជាម្ចាស់នៃសូចនាករនេះ

២) ឧបសគ្គ និងការរាំងស្កាត់នាំមិនអាចសម្រេចបាននូវក្រុកមគោលដៅ

៣) ពិនិត្យមើលថាតើ ឧបសគ្គ និងការរាំងស្កាត់ទាំងនេះត្រូវបានរកឃើញទេការពី៣ឆ្នាំកន្លង

៤) បើបានរកឃើញ សួរថា តើមកពីអ្វីបានជាមិនអាចដោះស្រាយបាន និងបណ្តោយឱ្យនៅមានក្នុងឆ្នាំទី៣

៥) តើកត្តាអ្វីខ្លះជាហេតុ (ការមិនទទួលខុសត្រូវ ខ្វះសមត្ថភាព សុំជួយហើយតែមិនមានការជួយ ខ្វះថវិកា)

៦) តើអ្នកណាជាអ្នកទទួលខុសត្រូវលើកត្តាដែលបានរកឃើញ

៧) បន្តសួរថា ហេតុអ្វីបានជាសាមីខ្លួនមិនទទួលខុសត្រូវ ឬ អ្នកទទួលខុសត្រូវមិនបានអនុវត្តវា(កត្តាដែលបានរកឃើញ)

៨) នាយកសាលាពិភាក្សាជាមួយនាយករក គ្រូទទួលបន្ទុកថ្នាក់ និងតំណាងយុវជននូវដំណោះស្រាយដែលល្អបំផុត សម្រាប់ដោះស្រាយកត្តាដែលបានរកឃើញ

៩) នាយកសាលាត្រូវយកលទ្ធផលពីការវិភាគនេះទោះពិភាក្សាជាមួយគ.គ.ស.ឬក.ប.ស. និងកំណត់នីវការសម្រេចចិត្តសម្រាប់ដោះស្រាយ។

កំណត់ហេតុប្រជុំត្រូវមានខ្លឹមសារតាមប្រធានបទខាងលើ។ ការសរសេរខ្លឹមសារត្រូវផ្តោត និងខ្លី ជាការពិតដែលបានកើតឡើង។ ចៀសវាងការសរសេរឱ្យតែពិរោះ ក្លែងបន្លំ ចៀសវាងការពិត។

## ខ កែសម្រួលផលសម្រេចនិងក្រុមគោលដៅរំកិល៣ឆ្នាំកម្រិតសាលារៀន

*ផលសម្រេចអប់រំ និងក្រុមគោលដៅសិក្សាមុននស្តូត្រ៣ឆ្នាំ ឆ្នាំ២០២៣*

ការបំពេញទិន្នន័យគឺដូចគ្នានឹងតារាងខាងលើ។ បំពេញទិន្នន័យសម្រេចបាននៅក្នុងកូឡោនទី៨ ពណ៌បៃតងត្រូវប្រើសម្រាប់ក្រុមគោលដៅសម្រេចបាន និងក្រហមសម្រេចមិនបាន។ ចំពោះកូឡោនទី៩ ត្រូវបញ្ចូលបន្ថែមនូវក្រុមគោលដៅសម្រេចមិនបានជាពណ៌ក្រហមពីលើក្រុមគោលដៅឆ្នាំ២០២៣។ ត្រូវយកទិន្នន័យពីផែនការសមិទ្ធកម្មសូចនាករគន្លឹះសម្រាប់ឆ្នាំទី៣ មកប្រើ។ សម្រាប់សូចនាករដែលបានសម្រេចក្រុមគោលដៅ គឺរក្សាក្រុមគោលដៅដដែលដូចបានគ្រោងដៅដើមឆ្នាំទី១។

| លេខ | សូចនាករ | | ឆ្នាំ0 ២០២១ លេខមូលដ្ឋាន<br>ចំនួន និង % | ឆ្នាំទី១ ២០២២ គោលដៅ<br>ចំនួន និង % | សម្រេចបាន ឆ្នាំទី១ ២០២២<br>ចំនួន និង % | ឆ្នាំទី២ ២០២៣ គោលដៅ<br>ចំនួន និង % | សម្រេចបាន ឆ្នាំទី២ ២០២៣<br>ចំនួន និង % | ឆ្នាំទី៣ ២០២៤ គោលដៅ<br>ចំនួន និង % |
|---|---|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 |
| 1 | ចូលរៀន ត្រួតថ្នាក់ បោះបង់ និងឡើងថ្នាក់ (ចំនួនសិស្សតាម%កំណត់) | *ចូលរៀន* | TBP | =/>95% | | =/>95% | | =/>95% |
| | | *ត្រួតថ្នាក់* | TBP | 0% | | 0% | | 0% |
| | | *បោះបង់* | TBP | /3% | | /2% | | /1% |
| | | *ឡើងថ្នាក់* | TBP | /100% | | /100% | | /100% |
| 2 | ចំនួនសិស្ស (តាម%កំណត់) សម្រេចផលសិក្សាចុងឆ្នាំ និទ្ទេស A, B និង C | *ភាសាខ្មែរ* | 17 (2/5/10) | 24 (4/6/14) | | 40 (8/15/17) | | 52 (12/20/20) |
| | | *គណិតវិទ្យា* | 17 (2/5/10) | 24 (4/6/14) | | 40 (8/15/17) | | 52 (12/20/20) |
| 3 | ចំនួនសិស្ស (តាម%កំណត់) សម្រេចផលសិក្សាចុងឆ្នាំមុខវិជ្ជាវិទ្យាសាស្ត្រ និទ្ទេស A, B និង C | *រូបវិទ្យា* | 17 (2/5/10) | 24 (4/6/14) | | 40 (8/15/17) | | 52 (12/20/20) |
| | | *គីមីវិទ្យា* | 17 (2/5/10) | 24 (4/6/14) | | 40 (8/15/17) | | 52 (12/20/20) |
| | | *ជីវវិទ្យា* | 17 (2/5/10) | 24 (4/6/14) | | 40 (8/15/17) | | 52 (12/20/20) |
| | | *ប្រវត្តិវិទ្យា* | 17 (2/5/10) | 24 (4/6/14) | | 40 (8/15/17) | | 52 (12/20/20) |
| 4 | ចំនួនសិស្ស (តាម%កំណត់) សម្រេចផលសិក្សាចុងឆ្នាំមុខវិជ្ជាវិទ្យាសាស្ត្រសង្គម និទ្ទេស A, B និង C | ភាសាអង់គ្លេស | 17 (2/5/10) | 24 (4/6/14) | | 40 (8/15/17) | | 52 (12/20/20) |
| | | ព័ត៌មានវិទ្យា | 17 (2/5/10) | 24 (4/6/14) | | 40 (8/15/17) | | 52 (12/20/20) |
| | | សីលធម៌ ពលរដ្ឋ | 17 (2/5/10) | 24 (4/6/14) | | 40 (8/15/17) | | 52 (12/20/20) |
| | | ផែនដីនិងបរិស្ថានវិទ្យា | 17 (2/5/10) | 24 (4/6/14) | | 40 (8/15/17) | | 52 (12/20/20) |
| | | ភូមិវិទ្យា | 17 | 24 (4/6/14) | | 40 (8/15/17) | | 52 (12/20/20) |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | (2/5/10) | | | | | |
| | | គេហវិទ្យា | 17 (2/5/10) | 24 (4/6/14) | | 40 (8/15/17) | | 52 (12/20/20) |
| | | អប់រំកាយ កីឡា និង សុខភាព | 17 (2/5/10) | 24 (4/6/14) | | 40 (8/15/17) | | 52 (12/20/20) |
| | | អប់រំបំណិនជីវិតមូលដ្ឋាន ឬអប់រំវិជ្ជាជីវៈជម្រើស | 17 (2/5/10) | 24 (4/6/14) | | 40 (8/15/17) | | 52 (12/20/20) |
| 5 | ភាគរយសិស្សថ្នាក់ទី៩ជាប់ស្តង់ដាអំណានជាពាក្យមួយនាទី ១០០ទៅ១២០ពាក្យ | | TBP | >45% | | >60% | | >75% |
| 6 | ភាគរយសិស្សថ្នាក់ទី៩ជាប់ការប្រឡងថ្នាក់ជាតិ | | TBP | >60% | | >70% | | >80% |
| 7 | ភាគរយសិស្សថ្នាក់ទី១២ជាប់ការប្រឡងថ្នាក់ជាតិ | | TBP | >60% | | >70% | | >80% |

*សម្គាល់៖ ក្រុមគោលដៅឆ្នាំនឹងត្រូវយកទៅប្រើប្រាស់សម្រាប់ធ្វើផែនការកែលម្អសាលារៀនប្រចាំឆ្នាំ ហើយវាជាទិសដៅកំណត់សម្រាប់ថ្នាក់រៀននីមួយៗយកទៅធ្វើផែនការថ្នាក់រៀន។ បញ្ចូលទិន្នន័យទៅក្នុងកូឡោនទី៥ នូវផលសម្រេចចុងឆ្នាំតាមគ្រប់សូចនាករ។*

## គ រៀបចំផែនការបង្រៀនរំកិល៣ឆ្នាំតាមមុខវិជ្ជាតាមថ្នាក់រៀន

ការរីកចម្រើនការអនុវត្តផែនការបង្រៀន៣ឆ្នាំតាមថ្នាក់ ២០២ឆ្នាំ (ចំនួននិងភាគរយ)៣

***ពិន្ទុ និងនិទ្ទេស៖** F:</=50; E=51-60; D=61-70; C=71-79; B=80-89; A=90-100*

នៅឆ្នាំទី៣ សិស្ស ត្រូវឡើងថ្នាក់មកដល់ថ្នាក់ទី៩ហើយ។ ដូចនេះ នេះជាតារាងសិស្សថ្នាក់ទី៩ក។ ឧទាហរណ៍ពីការបំពេញតារាង។ មុខវិជ្ជាភាសាខ្មែរ សិស្សថ្នាក់ទី៩ក មាននិទ្ទេស A តែ៦%នៅចុងឆ្នាំ២០២២ នេះមានន័យថាសម្រេចហើយ ហើយគឺដូចគ្នាសម្រាប់សិស្សនិទ្ទេស D E និងF។ តែសិស្សមាននិទ្ទេស B មានតែ៩% ដូចនេះជំពាក់១% ដែលនឹងត្រូវយកទៅបំពេញជំនួសនៅឆ្នាំ២០២៣។ ដូចគ្នានឹងនិទ្ទេស Cដែរ។ នេះ ត្រូវយក ១% ជំពាក់បូកជាមួយក្រុមគោលដៅឆ្នាំ២០២២ ចំនួន ៥% គឺ 6%=1%+5%។ តែបើឆ្នាំ២០២១បានសម្រេចក្រុមគោលដៅនោះ សរសេរភាគជាពណ៌ខៀវ ហើយក្រុមគោលដៅឆ្នាំ២០២២ទុកនៅដដែល។

| ថ្នាក់ទី៩ក សិស្ស៥០នាក់ | | | | | | | |
|---|---|---|---|---|---|---|---|
| មុខវិជ្ជា | និទ្ទេស | ចំនួនសិស្ស | ក្រុមគោលដៅចុងឆ្នាំទី១ ២០២១ | ផលសម្រេចចុងឆ្នាំទី១ | ក្រុមគោលដៅចុងឆ្នាំទី២ ២០២២ | ផលសម្រេចចុងឆ្នាំទី២ | ក្រុមគោលដៅចុងឆ្នាំទី៣ ២០២៣ |
| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ |
| ភាសាខ្មែរ | | | | | | | |
| | A | | 2% | 1% | 5=1+4% | 6 | 8% |
| | B | | 5% | 5% | 6% | 9 | 1+15% |
| | C | | 10% | | 14% | 12 | 2+17% |
| | D | | 10% | | 20% | 2□ | 30% |
| | E | | 23% | | 26% | 26 | 20% |
| | F | | 50% | | 25% | 25 | 10% |
| គណិតវិទ្យា | | | | | | | |
| | A | | 2% | | 4% | | 8% |
| | B | | 5% | | 6% | | 15% |
| | C | | 10% | | 14% | | 17% |
| | D | | 10% | | 20% | | 30% |
| | E | | 23% | | 26% | | 20% |
| | F | | 50% | | 30% | | 10% |
| រូបវិទ្យា | | | | | | | |
| | A | | 2% | | 4% | | 8% |
| | B | | 5% | | 6% | | 15% |
| | C | | 10% | | 14% | | 17% |
| | D | | 10% | | 20% | | 30% |
| | E | | 23% | | 26% | | 20% |
| | F | | 50% | | 30% | | 10% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គីមីវិទ្យា | | | | | | | |
| | A | | 2% | | 4% | | 8% |
| | B | | 5% | | 6% | | 15% |
| | C | | 10% | | 14% | | 17% |
| | D | | 10% | | 20% | | 30% |
| | E | | 23% | | 26% | | 20% |
| | F | | 50% | | 30% | | 10% |
| ជីវវិទ្យា | | | | | | | |
| | A | | 2% | | 4% | | 8% |
| | B | | 5% | | 6% | | 15% |
| | C | | 10% | | 14% | | 17% |
| | D | | 10% | | 20% | | 30% |
| | E | | 23% | | 26% | | 20% |
| | F | | 50% | | 30% | | 10% |
| ប្រវត្តិវិទ្យា | | | | | | | |
| | A | | 2% | | 4% | | 8% |
| | B | | 5% | | 6% | | 15% |
| | C | | 10% | | 14% | | 17% |
| | D | | 10% | | 20% | | 30% |
| | E | | 23% | | 26% | | 20% |
| | F | | 50% | | 30% | | 10% |
| ភាសា<br>អង់គ្លេស | | | | | | | |
| | A | | 2% | | 4% | | 8% |
| | B | | 5% | | 6% | | 15% |
| | C | | 10% | | 14% | | 17% |
| | D | | 10% | | 20% | | 30% |
| | E | | 23% | | 26% | | 20% |
| | F | | 50% | | 30% | | 10% |
| ព័ត៌មានវិទ្យា | | | | | | | |
| | A | | 2% | | 4% | | 8% |
| | B | | 5% | | 6% | | 15% |
| | C | | 10% | | 14% | | 17% |
| | D | | 10% | | 20% | | 30% |
| | E | | 23% | | 26% | | 20% |
| | F | | 50% | | 30% | | 10% |
| សីលធម៌<br>ពលរដ្ឋ | | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | A | | 2% | | 4% | | 8% |
| | B | | 5% | | 6% | | 15% |
| | C | | 10% | | 14% | | 17% |
| | D | | 10% | | 20% | | 30% |
| | E | | 23% | | 26% | | 20% |
| | F | | 50% | | 30% | | 10% |
| ផែនដី និងបរិស្ថានវិទ្យា | | | | | | | |
| | A | | 2% | | 4% | | 8% |
| | B | | 5% | | 6% | | 15% |
| | C | | 10% | | 14% | | 17% |
| | D | | 10% | | 20% | | 30% |
| | E | | 23% | | 26% | | 20% |
| | F | | 50% | | 30% | | 10% |
| ភូមិវិទ្យា | | | | | | | |
| | A | | 2% | | 4% | | 8% |
| | B | | 5% | | 6% | | 15% |
| | C | | 10% | | 14% | | 17% |
| | D | | 10% | | 20% | | 30% |
| | E | | 23% | | 26% | | 20% |
| | F | | 50% | | 30% | | 10% |
| គេហវិទ្យា | | | | | | | |
| | A | | 2% | | 4% | | 8% |
| | B | | 5% | | 6% | | 15% |
| | C | | 10% | | 14% | | 17% |
| | D | | 10% | | 20% | | 30% |
| | E | | 23% | | 26% | | 20% |
| | F | | 50% | | 30% | | 10% |
| អប់រំកាយ កីឡា និង សុខភាព | | | | | | | |
| | A | | 2% | | 4% | | 8% |
| | B | | 5% | | 6% | | 15% |
| | C | | 10% | | 14% | | 17% |
| | D | | 10% | | 20% | | 30% |
| | E | | 23% | | 26% | | 20% |
| | F | | 50% | | 30% | | 10% |
| អប់រំបំណិន | | | | | | | |

| ជីវិតមូលដ្ឋាន ឬអប់រំវិជ្ជាជីវៈ ជម្រើស | | | | | | | |
|---|---|---|---|---|---|---|---|
| | A | | 2% | | 4% | | 8% |
| | B | | 5% | | 6% | | 15% |
| | C | | 10% | | 14% | | 17% |
| | D | | 10% | | 20% | | 30% |
| | E | | 23% | | 26% | | 20% |
| | F | | 50% | | 30% | | 10% |

*សម្គាល់៖ បញ្ចូលទិន្នន័យប្រឡងចុងឆ្នាំក្នុងកូឡោនទី៥។ រួចហើយផ្ទៀបទិន្នន័យជាផលមស្រេចស្រេចបាន ណាមួយនឹងក្រុមគោលដៅឆ្នាំ។ បន្ទាប់ត្រូវបូកសរុបព័ត៌មានពីគ្រប់គ្រទទួលបន្ទុកថ្នាក់ចូលទៅក្នុងតារាងខាងក្រោម។*

## *៣- ការធ្វើផែនការបំពេញស្តង់ដាសាលារៀនមានប្រសិទ្ធភាព*

## ក. កែសម្រួលអាទិភាពសកម្មភាពក្នុងផែនការកែលម្អសាលារៀនដើម្បីសម្រេចក្រុមគោលដៅឆ្នាំទី៣

### ផែនការកែលម្អសាលារៀន និងថវិកា ឆ្នាំ២០២៣

ឈ្មោះសាលារៀន៖ កូដ៖

ឈ្មោះនាយកសាលារៀន៖ លេខទូរស័ព្ទ៖

ភូមិ៖ ឃុំ៖ ស្រុក៖ ខេត្ត៖

តារាងពិន្ទុស្តង់ដាសហគមន៍សាលារៀន តាមស្តង់ដានីមួយៗ និងស្តង់ដាសរុបឆ្នាំ២០២៣

*ប្រើពណ៌ខៀវសម្រាប់សូចនាករសម្រេចបាន និងពណ៌ក្រហមសម្រាប់សូចនាករសម្រេចមិនបាន។ ការបំពេញបននូវពិន្ទុស្តង់ដាអប្បបរមា ២១០ គប្បីអនុវត្តឱ្យបាននៅឆ្នាំទី៣ ឬឆ្នាំទី៤យ៉ាហយូរ។*

| ពិន្ទុអប្បបរមា | ស្តង់ដាទី១ ៣៩ | | ស្តង់ដាទី២ ៤២ | | ស្តង់ដាទី៣ ៤៨ | | ស្តង់ដាទី៤ ៤៨ | | ស្តង់ដាទី៥ ២៧ | | សរុបពិន្ទុ២១០ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដើមឆ្នាំ | ចុងឆ្នាំ | ដើមឆ្នាំ | ចុងឆ្នាំ | ដើមឆ្នាំ | ចុងឆ្នាំ | ដើមឆ្នាំ | ចុងឆ្នាំ | ដើមឆ្នាំ | ចុងឆ្នាំ | ដើមឆ្នាំ | ចុងឆ្នាំ |
| ពិន្ទុ២០២១ | 0 | 10/13 | 0 | 10/14 | 0 | 16/16 | 0 | 12/16 | 0 | 7/9 | 0 | 55/70 |
| ពិន្ទុ២០២២ | 10 | 24/26 | 10 | 28/28 | 16 | 30/32 | 12 | 32/32 | 7 | 18/18 | 55 | 132/140 |
| ពិន្ទុ២០២៣ | | 2+39 | 28 | 42 | | 2+48 | 32 | 48 | 18 | 27 | 132 | 8+210 |
| ពិន្ទុ២០២៤ | | 52 | | 56 | | 64 | | 64 | | 36 | | 280 |
| ពិន្ទុ២០២៥ | | | | | | | | | | | | |
| ពិន្ទុ២០២៦ | | | | | | | | | | | | |

| បន្តសកម្មភាពឆ្នាំទី២ និងផ្តោតសកម្មភាព លើសូចនាករដែលមិនបានសម្រេចនៅឆ្នាំទី២ | | | | |
|---|---|---|---|---|
| សូចនាករសម្រេចបាន និងមិនបាន | សកម្មភាពបានអនុវត្តនិងមិនបានអនុវត្តក្នុងខែ | ឧបសគ្គ | ការរាំងស្ទាត់ | មិនមានសកម្មភាពជាដំណោះស្រាយ |
| ១ | ២ | ៣ | ៤ | ៥ |
| ស្តង់ដាទី១៖ សាលារៀនមានដំណើរការសម្រេចផលសម្រេចអប់រំនិងការសិសក្សារបស់សិស្ស | | | | |
| ១ | សម្រេចបាន | មិនមាន | មិនមាន | ពិន្ទុ៣ |
| ២ | សម្រេចមិនបាន | ? | ? | ពិន្ទុ៣ |
| ៣ | សម្រេចមិនបាន | ? | ? | ពិន្ទុ១? |
| ស្តង់ដាទី២៖ ថ្នាក់រៀនមានដំណើរការសម្រាប់ការបង្រៀននិងការសិក្សារបស់សិស្សម្នាក់ៗ | | | | |
| | | | | |
| ស្តង់ដាទី៣៖ ភាពជាម្ចាស់របស់សហគមន៍សាលារៀន | | | | |
| | | | | |
| ស្តង់ដាទី៤៖ ដំណើរការប្រតិបត្តិនិងរដ្ឋបាលសាលារៀន | | | | |
| | | | | |
| ស្តង់ដាទី៥៖ គណនេយ្យភាពថ្នាក់ជាតិនិងក្រោមជាតិ | | | | |
| | | | | |

## ខ រៀបចំផែនការបង្រៀន៣ខែផ្អែកលើផែនការបង្រៀន៣ខែនៃឆ្នាំទី២ដើម្បីសម្រេចក្រុមគោលដៅឆ្នាំទី៣

- *រៀបចំផែនការបង្រៀន៣ខែសង់បន្តពីឆ្នាំទី២*

**ផែនការបង្រៀន៣ខែ**

**ថ្នាក់ទី៩ក សិស្ស៥០នាក់ ខែមករាដល់មីនា ឆ្នាំ២០២៣**

***ពិន្ទុ និងនិទ្ទេស៖*** *F:</=50; E=51-60; D=61-70; C=71-79; B=80-89; A=90-100*

បញ្ចូលតួលេខជាទិន្នន័យមូលដ្ឋានចូលក្នុងកូឡោនទិន្នន័យមូលដ្ឋាន។ រួចហើយកំណត់ក្រុមគោលដៅនៅក្នុងកូឡោនខែ ចុងខែមករា ចុងខែកុម្ភៈ និងខុងខែមីនា សម្រាប់គ្រប់មុខវិជ្ជា។ ធ្វើសម្រាប់គ្រប់ថ្នាក់ និងគ្រប់កម្រិតពីថ្នាក់ទី៧ដល់ទី១២។ យកតួលេខប្រឡងស្តង់ដាចុងឆ្នាំទី២មកប្រើប្រាស់ សម្រាប់សិស្សថ្នាក់ទី៨ដល់១២។ អនុវត្តតេស្តយស្តង់ដាដើមឆ្នាំដដែលសម្រាប់សិស្សថ្នាក់ទី៧ចូលថ្មី ដោយប្រើតារាងឆ្នាំទី១។

| មុខវិជ្ជា | ចំនួន និង % ភាសាខ្មែរ | | | | ចំនួន/% ចុងឆ្នាំសិក្សា | ចំនួន និង % គណិតវិទ្យា | | | | ចំនួន/% ចុងឆ្នាំសិក្សា |
|---|---|---|---|---|---|---|---|---|---|---|
| | ទិន្នន័យមូលដ្ឋាន | ចុងខែមករា | ចុងខែកុម្ភៈ | ចុងខែមីនា | | ទិន្នន័យមូលដ្ឋាន | ចុងខែមករា | ចុងខែកុម្ភៈ | ចុងខែមីនា | |
| និទ្ទេស A | | | | | **8%** | | | | | **8%** |
| និទ្ទេស B | | | | | **15%** | | | | | **15%** |
| និទ្ទេស C | | | | | **17%** | | | | | **17%** |
| និទ្ទេស D | | | | | **30%** | | | | | **30%** |
| និទ្ទេស E | | | | | **20%** | | | | | **20%** |
| និទ្ទេស F | | | | | **10%** | | | | | **10%** |
| **សរុប** | 50/100% | | | | 50/100% | 50/100% | | | | 50/100% |

| មុខវិជ្ជា | ចំនួន និង % រូបវិទ្យា | | | | ចំនួន/% ចុងឆ្នាំសិក្សា | ចំនួន និង % គីមីវិទ្យា | | | | ចំនួន/% ចុងឆ្នាំសិក្សា |
|---|---|---|---|---|---|---|---|---|---|---|
| | ទិន្នន័យមូលដ្ឋាន | ចុងខែមករា | ចុងខែកុម្ភៈ | ចុងខែមីនា | | ទិន្នន័យមូលដ្ឋាន | ចុងខែមករា | ចុងខែកុម្ភៈ | ចុងខែមីនា | |
| និទ្ទេស A | | | | | **8%** | | | | | **8%** |
| និទ្ទេស B | | | | | **15%** | | | | | **15%** |
| និទ្ទេស C | | | | | **17%** | | | | | **17%** |
| និទ្ទេស D | | | | | **30%** | | | | | **30%** |
| និទ្ទេស E | | | | | **20%** | | | | | **20%** |
| និទ្ទេស F | | | | | **10%** | | | | | **10%** |
| **សរុប** | 50/100% | | | | 50/100% | 50/100% | | | | 50/100% |

| មុខវិជ្ជា | ចំនួន និង % ជីវវិទ្យា | | | | ចំនួន/% ចុងឆ្នាំសិក្សា | ចំនួន និង % ប្រវត្តិវិទ្យា | | | | ចំនួន/% ចុងឆ្នាំសិក្សា |
|---|---|---|---|---|---|---|---|---|---|---|
| | ទិន្នន័យមូលដ្ឋាន | ចុងខែមករា | ចុងខែកុម្ភៈ | ចុងខែមីនា | | ទិន្នន័យមូលដ្ឋាន | ចុងខែមករា | ចុងខែកុម្ភៈ | ចុងខែមីនា | |
| និទ្ទេស A | | | | | **8%** | | | | | **8%** |
| និទ្ទេស B | | | | | **15%** | | | | | **15%** |
| និទ្ទេស C | | | | | **17%** | | | | | **17%** |
| និទ្ទេស D | | | | | **30%** | | | | | **30%** |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| និទ្ទេស E | | | | | **20%** | | | | | **20%** |
| និទ្ទេស F | | | | | **10%** | | | | | **10%** |
| **សរុប** | 50/100% | | | | 50/100% | 50/100% | | | | 50/100% |
| **មុខវិជ្ជា** | **ចំនួន និង % អង់គ្លេស** | | | | **ចំនួន/%** ចុងឆ្នាំ សិក្សា | **ចំនួន និង % ភូមិវិទ្យា** | | | | **ចំនួន/%** ចុងឆ្នាំ សិក្សា |
| | **ទិន្នន័យ មូលដ្ឋាន** | **ចុងខែ មករា** | **ចុងខែ កុម្ភៈ** | **ចុងខែ មីនា** | | **ទិន្នន័យ មូលដ្ឋាន** | **ចុងខែ មករា** | **ចុងខែ កុម្ភៈ** | **ចុងខែ មីនា** | |
| និទ្ទេស A | | | | | **8%** | | | | | **8%** |
| និទ្ទេស B | | | | | **15%** | | | | | **15%** |
| និទ្ទេស C | | | | | **17%** | | | | | **17%** |
| និទ្ទេស D | | | | | **30%** | | | | | **30%** |
| និទ្ទេស E | | | | | **20%** | | | | | **20%** |
| និទ្ទេស F | | | | | **10%** | | | | | **10%** |
| **សរុប** | 50/100% | | | | 50/100% | 50/100% | | | | 50/100% |
| **មុខវិជ្ជា** | **ចំនួន និង % សីលធម៌ពលរដ្ឋ** | | | | **ចំនួន/%** ចុងឆ្នាំ សិក្សា | **ចំនួន និង % ផែនដីនិងបរិស្ថានវិទ្យា** | | | | **ចំនួន/%** ចុងឆ្នាំ សិក្សា |
| | **ទិន្នន័យ មូលដ្ឋាន** | **ចុងខែ មករា** | **ចុងខែ កុម្ភៈ** | **ចុងខែ មីនា** | | **ទិន្នន័យ មូលដ្ឋាន** | **ចុងខែ មករា** | **ចុងខែ កុម្ភៈ** | **ចុងខែ មីនា** | |
| និទ្ទេស A | | | | | **8%** | | | | | **8%** |
| និទ្ទេស B | | | | | **15%** | | | | | **15%** |
| និទ្ទេស C | | | | | **17%** | | | | | **17%** |
| និទ្ទេស D | | | | | **30%** | | | | | **30%** |
| និទ្ទេស E | | | | | **20%** | | | | | **20%** |
| និទ្ទេស F | | | | | **10%** | | | | | **10%** |
| **សរុប** | 50/100% | | | | 50/100% | 50/100% | | | | 50/100% |
| **មុខវិជ្ជា** | **ចំនួន និង % ភូមិវិទ្យា** | | | | **ចំនួន/%** ចុងឆ្នាំ សិក្សា | **ចំនួន និង % គេហវិទ្យា** | | | | **ចំនួន/%** ចុងឆ្នាំ សិក្សា |
| | **ទិន្នន័យ មូលដ្ឋាន** | **ចុងខែ មករា** | **ចុងខែ កុម្ភៈ** | **ចុងខែ មីនា** | | **ទិន្នន័យ មូលដ្ឋាន** | **ចុងខែ មករា** | **ចុងខែ កុម្ភៈ** | **ចុងខែ មីនា** | |
| និទ្ទេស A | | | | | **8%** | | | | | **8%** |
| និទ្ទេស B | | | | | **15%** | | | | | **15%** |
| និទ្ទេស C | | | | | **17%** | | | | | **17%** |
| និទ្ទេស D | | | | | **30%** | | | | | **30%** |
| និទ្ទេស E | | | | | **20%** | | | | | **20%** |
| និទ្ទេស F | | | | | **10%** | | | | | **10%** |
| **សរុប** | 50/100% | | | | 50/100% | 50/100% | | | | 50/100% |
| **មុខវិជ្ជា** | **ចំនួន និង % អប់រំកាយ កីឡានិងសុខភាព** | | | | **ចំនួន/%** ចុងឆ្នាំ សិក្សា | **ចំនួន និង %** អប់រំបំណិនជីវិតមូលដ្ឋាន ឬ អប់រំវិជ្ជាជីវៈជម្រើស | | | | **ចំនួន/%** ចុងឆ្នាំ សិក្សា |
| | **ទិន្នន័យ មូលដ្ឋាន** | **ចុងខែ មករា** | **ចុងខែ កុម្ភៈ** | **ចុងខែ មីនា** | | **ទិន្នន័យ មូលដ្ឋាន** | **ចុងខែ មករា** | **ចុងខែ កុម្ភៈ** | **ចុងខែ មីនា** | |
| និទ្ទេស A | | | | | **8%** | | | | | **8%** |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| និទ្ទេស B | | | | | **15%** | | | | | **15%** |
| និទ្ទេស C | | | | | **17%** | | | | | **17%** |
| និទ្ទេស D | | | | | **30%** | | | | | **30%** |
| និទ្ទេស E | | | | | **20%** | | | | | **20%** |
| និទ្ទេស F | | | | | **10%** | | | | | **10%** |
| **សរុប** | 50/100% | | | | 50/100% | 50/100% | | | | 50/100% |

*សម្គាល់៖ គ្រូទទួលបន្ទុកថ្នាក់ គ្រូបង្រៀនតាមមុខវិជ្ជា និងសិស្សត្រូវសហការណ៍គ្នាក្នុងការបញ្ចូលទិន្នន័យក្នុងតារាងនេះ។ បន្ទាប់ពីបំពេញតួរលេខក្នុងតារាងនេះហើយ គ្រូបង្រៀននិងសិស្សត្រូវកំណត់ថា តើភាគរយនីមួយៗមានតម្លៃស្មើនឹងចំនួនសិស្សប៉ុន្មាននាក់ បន្ទាប់ត្រូវកំណត់ថា តើសិស្សមានឈ្មោះណាខ្លះដែលតាងឱ្យចំនួនណាមួយ តាមមុខវិជ្ជានីមួយៗ។ រួចហើយ សិស្សម្នាក់ៗត្រូវរៀបចំផែនការសិក្សារៀនសូត្ររបស់ខ្លួនតាមតារាងខាងក្រោម។*

## គ កែសម្រួលផែនការសិក្សារៀនសូត្រសិស្សម្នាក់ៗ

សិស្ស ចរណៃ ត្រូវប្រើទិន្នន័យប្រឡងចុងឆ្នាំមុនសម្រាប់កំណត់ក្រុមគោលដៅចុងឆ្នាំ២០២២។ ឧទាហរណ៍ជាក្រុមគោលដៅចុងឆ្នាំ២០២២មាននៅក្នុងតារាងខាងក្រោម៖

*ផែនការសិក្សារៀនសូត្រសិស្សម្នាក់ៗឆ្នាំ២០២៣*

**សិស្សឈ្មោះ ពេជ្រ ចរណៃ ថ្នាក់ទី៩ក ឆ្នាំសិក្សា២០២៣**

***ពិន្ទុ និងនិទ្ទេស៖** F:</=50; E=51-60; D=61-70; C=71-79; B=80-89; A=90-100*

*ប្រសិនបើ សិស្សសម្រេចបាននិទ្ទេស A សម្រាប់ថ្នាក់ទី ៣ ដល់ទី៥ ហើយនោះ សិស្ស **ពេជ្រ ចរណៃ** មិនចាំបាច់តាមដានទៀតទេ។ ត្រូវបញ្ចូលបន្ទាត់សម្រាប់ថ្នាក់ទី៩នៅខាងលើ។ ការតាមដានការសិក្សាតាមមុខវិជ្ជារបស់សិស្សម្នាក់ៗនឹងត្រូវធ្វើរហូតដល់ថ្នាក់ទី១២។*

| កម្រិតសិក្សាភាសាខ្មែរដើមឆ្នាំសិក្សា | | | | | | | | | កម្រិតសិក្សាចុងឆ្នាំ |
|---|---|---|---|---|---|---|---|---|---|
| កម្រិតថ្នាក់ | ១ ស្គាល់ព្យញ្ជនៈនិងស្រៈ | ២ ស្គាល់សំឡេង | ៣ ស្គាល់ពាក្យ | ៤. អានស្ទាត់ | ៥ អានយល់ | កម្រិតសិក្សាដើមឆ្នាំ | កម្រិតសិក្សាចុងត្រីមាសទី១ | កម្រិតសិក្សាចុងត្រីមាសទី២ | |
| ទី៩ | | | | | | | | | B |
| ទី៨ | | | | | | D | D | C | C/C |
| ទី៧ | | | | | | C | C | B | A/B |
| ទី៥ | | | | | | C | B | B | A/B |
| ទី៥ | | | | | | B | A | A | A |
| ទី៤ | | | | | | B | A | A | A |
| ទី៣ | | | | | | B | A | A | A |

| កម្រិតថ្នាក់ | កម្រិតសិក្សាគណិតវិទ្យាដើមឆ្នាំសិក្សា | | | | | | កម្រិតសិក្សាចុងត្រីមាសទី១ | កម្រិតសិក្សាចុងត្រីមាសទី២ | កម្រិតសិក្សាចុងឆ្នាំ៣ |
|---|---|---|---|---|---|---|---|---|---|
| | □ | □ | □ | □ | □ | □ | | | |
| ទី៩ | | | | | | | C | C | B |
| ទី៨ | | | | | | | C | C | B |
| ទី៧ | | | | | | | B | B | A |
| ទី៦ | | | | | | | B | B | A |
| ទី៥ | | B | | | | | A | A | A |
| ទី៤ | | B | | | | | A | A | A |
| ទី៣ | | B | | | | | A | A | A |

| មុខវិជ្ជា | ពិន្ទុនិងនិទ្ទេសដើមឆ្នាំ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | ចុងឆ្នាំសិក្សា |
| រូបវិទ្យា | | | | | | | | | | | |
| គីមីវិទ្យា | | | | | | | | | | | |
| ជីវវិទ្យា | | | | | | | | | | | |
| ប្រវត្តិវិទ្យា | | | | | | | | | | | |
| អង់គ្លេស | | | | | | | | | | | |
| ព័ត៌មានវិទ្យា | | | | | | | | | | | |
| សីលធម៌ពលរដ្ឋ | | | | | | | | | | | |
| ឡូមិវិទ្យា | | | | | | | | | | | |
| គេហវិទ្យា | | | | | | | | | | | |
| អប់រំកាយសុខភាពកីឡា | | | | | | | | | | | |
| បំណិនជីវិតវិជ្ជាជិវៈ | | | | | | | | | | | |

## ឃ បន្តអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងារគ្រូបង្រៀននិងនាយកសាលា

នៅឆ្នាំទី៣ ការរៀបចំកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំត្រូវមានភាពស៊ីគ្នាជាមួយនឹងការរីកចម្រើននៃសូចនាករនៃស្តង់ដាទី១ ទៅតាមមុខវិជ្ជារបស់គ្រូបង្រៀន និងសូចនាករស្តង់ដាទី២។ សម្រាប់នាយកសាលាគឺ ដូចគ្នាដែរ លើការរីកចម្រើនសូចនាករស្តង់ដាទី១ទាក់ទងនឹងនាយកសាលា និងស្តង់ដាទី៣ និងទី៤។

## ៤ អនុវត្តកម្មវិធីបំណិនរកចំណូលនៅសាលារៀន

ឆ្នាំទី៣ ជាពេលវេលាដែលត្រូវអនុវត្តនូវគុណតម្លៃសហគមន៍សាលារៀន ដែលបញ្ជាក់ពីការថែរក្សាគ្នាទៅវិញទៅមក និងការបន្តរៀនសូត្រដើម្បីអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ។

### ៤-១ ការគ្រោងកម្មវិធីបំណិនរកចំណូលរយៈពេល៣ឆ្នាំ (គំរូ)

#### ក- សារចារ

សហគមន៍ និងសាលាមធ្យមសិក្សា (ឈ្មោះ) មានបំណងធ្វើទំនើបកម្មនិងប្រតិបត្តិការអង្គភាពរបស់ខ្លួនឱ្យឆ្លើយតបទៅនឹងការកំណត់ទិសដៅរបស់រដ្ឋាភិបាល ដោយប្រែក្លាយប្រទេសឱ្យក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ ដើម្បីសម្រេចបាននូវបំណងប្រាថ្នានេះ សាលានឹងត្រូវអនុវត្តការបង្រៀនតាមរបៀបថ្មី ដែលជាការបង្រៀនចម្រុះមុខវិជ្ជា ទាំងលើទ្រឹស្តីនិងការអនុវត្តជាក់ស្តែងសម្រាប់ជីវិតនិងការងារ។ សិស្សនឹងរៀននូវចំណេះបញ្ញា បំណិនចិត្តសង្គម និងបំណិនបច្ចេកទេសលើវិស័យកសិកម្ម និងបច្ចេកទេសការងារ។ ការសិក្សាបែបនេះនឹងត្រូវអនុវត្តនៅក្នុងកម្មវិធីបំណិនរកចំណូលនៅសាលារៀន។ សិស្សនឹងអាចមានសមត្ថភាពរកចំណូលដើម្បីទប់ទល់នឹងភាពខ្វះខាតក្នុងការរស់នៅ និងអាចសន្សំប្រាក់សម្រាប់ចូលរៀននៅមហាវិទ្យាដែលមានកម្មវិធីបរិញ្ញាបត្រមានស្តង់ដា។ សាលារៀន នឹងសហគមន៍អនុវត្តកិច្ចសហប្រតិបត្តិការជាមួយអ្នកជំនាញក្រសួង អ្នកជំនាញសាកលវិទ្យាល័យ និងអាជ្ញាធរមូលដ្ឋានក្នុងការអនុវត្តកម្មវិធីនេះ។ តាមរយៈកម្មវិធីបំណិនរកចំណូលនេះ សាលារៀននិងសហគមន៍មានជំនឿថា អាចផ្គត់ផ្គង់តម្រូវការបន្លែនិងត្រីសាច់ក្នុងភូមិ ស្រុក ហើយសិស្សនឹងបានចូលរៀនច្រើននៅមធ្យមសិក្សា និងឧត្តមសិក្សា។

***តារាងបែងចែកតំបន់សម្រាប់សាកលវិទ្យាល័យបង្រៀនបំណិន***

*តារាងនេះនឹងត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ដោយផ្អែកទៅលើការអនុវត្តជាក់ស្តែងនៃសាកលវិទ្យាល័យនីមួយៗ ការបន្ថែមសាលារៀនគោលដៅថ្មី និងភាពចាំបាច់ដែលសាលារៀនថ្មី អាចរៀនបន្តពីសាលារៀនដែលមានពិសោធន៍ ដោយមិនបាច់រៀនសូត្រពីសាកលវិទ្យាល័យ។ សម្រាប់កូឡោនទី៣ នឹងបញ្ចូលនូវចំនួនសាលាមធ្យមសិក្សាទៅតាមចំនួនសាលាមធ្យមសិក្សាគោលដៅនៃគម្រោងថ្មី។*

| សាលវិទ្យាល័យនិងតំបន់ទទួលខុសត្រូវ | ឈ្មោះខេត្ត | ចំនួនសាលាមធ្យម |
|---|---|---|
| តំបន់បាត់ដំបង៖ សាកលវិទ្យាល័យជាតិបាត់ដំបង | បាត់ដំបង ប៉ៃលិន ពោធិ៍សាត់ បន្ទាយមានជ័យ សៀមរាប ព្រះវិហារ ឧត្តរមានជ័យ | |
| តំបន់ស្វាយរៀង៖ សាកលវិទ្យាល័យស្វាយរៀង | ស្វាយរៀង ព្រៃវែង រតនគីរី កណ្តាល | |
| តំបន់កណ្តាល៖ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | ភ្នំពេញ តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង កំពត សីហនុ កែប កោះកុង មណ្ឌលគិរី | |
| តំបន់ត្បូងឃ្មុំ៖ សាកលវិទ្យាល័យហេងសំរិន ត្បូងឃ្មុំ | ត្បូងឃ្មុំ កំពង់ចាម ក្រចេះ កំពង់ធំ កំចាយមារ ក្នុងព្រៃវែង ស្ទឹងត្រែង | |
| វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | តំបន់ស្វាយរៀង និងត្បូងឃ្មុំ និងតំបន់ទាំងអស់សម្រាប់បំណិន បច្ចេកទេស | |

ទំនាក់ទំនងបំណិនមួយឬគំនិតមួយជាមួយខ្សែច្រវ៉ាក់ផលិតកម្ម

**ខ្សែ ច្រវ៉ាក់ ផលិតកម្ម**

- អនុវត្តបំណិនមួយ ផលិតផលិតផលគំរូ ឬ ពូជ ឬ ហូប
- ពង្រីកបរិមាណផលិតសម្រាប់លក់ទីផ្សារ
- ដឹកជញ្ជូនលក់នៅទីផ្សារ
- បញ្ជាទិញ គ្រោងផលិត និងលក់តាមវែប
- ផ្តល់សេវា ដំឡើង និងថែទាំ

## ជ្រើសរើសមុខបំណិនចង់រៀន

តារាងជ្រើសរើសបំណិនរៀនសូត្រគឺមាននៅក្នុងការអនុវត្តសម្រាប់ឆ្នាំទី២ហើយ។




| បំណិនកសិកម្ម | បំណិនបច្ចេកទេស |
|---|---|

| | | |
|---|---|---|
| បន្លែ | ផ្នែកអគ្គិសនី | បច្ចេកទេសផ្សារ |
| មណ្ឌា | ការតភ្លើងក្នុងអគារ | ការដំឡើងនិងជួសជុលម៉ាស៊ីនត្រជាក់ |
| កន្ទាយ/អណ្ដើក/កង្កែប | ការតភ្លើងក្នុងសហគ្រាស | ផ្នែកព័ត៌មានវិទ្យា |
| ជ្រូកព្រៃ/ជ្រូកស្រុក | ការរៀបចំប្រព័ន្ធពន្លត់អគ្គីភ័យ | ចំណេះដឹងកុំព្យូទ័រ |
| គោ/ចៀម/ពពែ | ការដំឡើងប្រព័ន្ធកាមេរ៉ាសុវត្ថិភាព | ការប្រើប្រាស់ម៉ាយក្រូស័ហ្វ |
| បក្សីៈ មាន់/ទា/ក្ងាន | Programmable logic control | ការថតនិងកាត់តវីដេអូ |
| ក្រួច/លលក/ចង្រិត | Stនិង alone system និង energy back up system | ការបង្កើតទំព័រពាណិជ្ជកម្ម |
| ឈើហូបផ្លែ | ផ្នែកចំណីអាហារ | |
| រុក្ខជាតិលម្អ/ឃ្មុំ | កែច្នៃនិងថែរក្សាចំណីអាហារ | |
| កែច្នៃអាហារ | | |

## ខ- វត្ថុបំណងកម្មវិធី

១) សិស្សសាលាមធ្យមសិក្សាមានសមត្ថភាពចំណេះដឹងល្អនិងល្អប្រសើរ ពិសេសមុខវិជ្ជា សំខាន់ៗដែលត្រូវចូលរៀនកម្រិតបរិញ្ញាបត្រនៅមហាវិទ្យាល័យ ។

២) សិស្សសាលាមធ្យមសិក្សាមានសមត្ថភាពបញ្ញា ចិត្តសង្គម និងសមត្ថភាពរកចំណូល។

## គ- សូចនាករនិងក្រុមគោលដៅផលសម្រេច

១) សាលារៀនអនុវត្តបំណិនកសិកម្មចំនួន XX មុខ និងបំណិនការងារចំនួន XX មុខ

២) សិស្សចំនួន XX និងចូលរួមសិក្សានៅក្នុងកម្មវិធីបំណិនរកចំណូល (៨០%)

៣) សិស្សចំនួន XX និងបន្តចូលរៀននៅមហាវិទ្យាល័យតាមឧបនិស្ស័យរបស់ខ្លួន (%) ថ្នាក់ទី១០ យក ៨០% ថ្នាក់ទី១១ យក២០% និងថ្នាក់ទី១២យក ១២% រកឃើញ ចំនួនសិស្សទាំង៣ថ្នាក់ហើយ បូកយកលេខសរុបហើយសរសេរបញ្ចូល

៤) សាលារៀនមានកម្មវិធីបំណិនរកចំណូលមានស្តង់ដានៅឆ្នាំ២០២៣ (២០២៣?)

## ឃ ក្របខណ្ឌលទ្ធផលពាំ

| ក្របខណ្ឌលទ្ធផល | មូលដ្ឋាន ២០២០ | ក្រុមគោលដៅ ២០២១ | ក្រុមគោល ដៅ ២០២២ | ក្រុមគោលដៅ ២០២៣ |
|---|---|---|---|---|
| **សូចនាករផលសម្រេច** | | | | |
| ក) សិស្សសាលាមធ្យមសិក្សាមានសមត្ថភាពចំណេះដឹងល្អនិងល្អប្រសើរស្រប តាមឧប្បនិស្ស័យកើនជាងមុន (ត្រូវយកលេខសិស្សសរុបនៅដើមឆ្នាំ ២០២១) | 0+3= 3% | ៣+6=9% | 6+15=21% | 10+20= 30% (2023) 20+30 = 50% (2026) |
| ខ) សិស្សសាលាមធ្យមសិក្សាមានសមត្ថភាពសមត្ថភាពបញ្ញានិងចិត្តសង្គម និងសមត្ថភាពរកចំណូល (បន្តរៀន-រៀនចេះ) | 0 | 30% | 50% | 70% |
| **សូចនាករទិន្នផល** | | | | |
| ១. ចំនួនមុខបំណិនកសិកម្ម (រាប់មុខបំណិនដែលបានអនុវត្ត) | 0 | | | |
| ២. ចំនួនសិស្សចូលរួមសិក្សានៅក្នុងកម្មវិធីបំណិនរកចំណូល | 0 | ៤0% | ៦0% | ៨0% |
| ៣. ចំនួនសិស្សចូលរៀននៅមហាវិទ្យាល័យតាមឧបនិស្ស័យរបស់ខ្លួន (ផ្អែកទិន្នន័យសិស្សដើមឆ្នាំ ២០១៩-២០២០ចុះឈ្មោះចូលរៀននៅមហាវិទ្យាល័យ) | 0 | ១២%នៃសិស្សថ្នាក់ទី ១២ | ២០%នៃសិស្សថ្នាក់ទី ១១ | ៤០%នៃសិស្សថ្នាក់ទី១០ |
| ៤. សាលារៀនមានកម្មវិធីបំណិនរកចំណូលមានស្តង់ដានៅឆ្នាំ២០២២ | ទេ | | | មាន ស្តង់ដា |

## ខ- ផែនការសកម្មភាព

| សកម្មភាព | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|
| សូចនាករផលសម្រេច | | |
| ក. សិស្សសាលាមធ្យមសិក្សាមានសមត្ថភាពចំណេះដឹងល្អនិងល្អប្រសើរស្របតាមឧបនិស្ស័យកើនជាងមុន | | |
| សិស្សទទួលបានការជួយទាន់ពេលលើមុខវិជ្ជាស្របតាមឧប្បនិស្ស័យ | ចុងត្រីមាស | គ្រូតាមមុខវិជ្ជា |
| សិស្សអនុវត្តនិងសរសេរកិច្ចការជាគម្រោងពីបំណិនរកចំណូល | ចុងឆមាសទី១ | គ្រូតាមមុខវិជ្ជា |

| | | |
|---|---|---|
| គ្រូបង្រៀនអនុវត្តហ្មត់ចត់នូវផែនការបង្រៀន ៣ខែជួយសិស្សទាន់ពេល (វត្ត នាយកទាំងពីរជំនាន់) | ចុងត្រីមាស | គ្រូតាមមុខវិជ្ជា |
| ចុះជួយគ្រូពីការបង្រៀនចម្រុះមុខវិជ្ជានិងជួយសិស្សរៀនបានល្អប្រសើរនិងល្អ (ពី គ្រប់សាកលវិទ្យាល័យ អនុវត្តដោយមន) | ៤ដង | សាកលវិទ្យាល័យ |
| **ខ. សិស្សសាលាមធ្យមសិក្សាមានសមត្ថភាពសមត្ថភាពបញ្ញា និងចិត្តសង្គម និងសមត្ថភាពរកចំណូល** | | |
| ប្រមូលទិន្នន័យសិស្សទទួលរងហិង្សានៅសាលានិងផ្ទះ | ខែមករា | នាយកសាលា |
| រៀបចំការប្រឹក្សានិងការអប់រំពីហិង្សានិងការថែកូនជាមួយមាតាបិតា | ២ដង/ឆ្នាំ | នាយកសាលា |
| សិស្សអនុវត្តបំណិនរកចំណូលនៅតាមផ្ទះរបស់ខ្លួនឬសាលារៀនឬក្រុមហ៊ុនឬ សហគ្រាស (គ្រូត្រូវចុះទៅតាមផែនការគ្រោង និងអនុវត្តបំណិន) | ផែនការអនុវត្តបំណិ ននៅផ្ទះរបស់សិស្ស | គ្រូតាមមុខវិជ្ជា |
| សិស្សអនុវត្តបំណិនរកចំណូលនៅកសិដ្ឋានមិត្តភក្តិ (ផែនការអនុវត្តបំណិន ជាក្រុមរបស់សិស្ស) ផែនការត្រូវគិតដល់ការអនុវត្តទ្រឹស្តី និងការអនុវត្តផ្ទាល់ | ផែនការអនុវត្តបំណិ នកសិដ្ឋាន | នាយកសាលា |
| **១) សាលារៀនអនុវត្តបំណិនកសិកម្មចំនួន □□ មុខ និងបំណិនការងារចំនួន □□ មុខ** | | |
| សិក្សាទីផ្សារពីបរិមាណតម្រូវការផលិតផល ឬ សេវាសម្រាប់ធ្វើផែនការផលិត | កញ្ញា ២០២០ | នាយកសាលា |
| ពិភាក្សាជាមួយសាលាជ្រើសនិងកំណត់យកបំណិនត្រូវបង្រៀន | ចន្លោះ ខែកញ្ញា-ធ្នូ ២០២០ | សាកលវិទ្យាល័យ |
| ពិភាក្សាកំណត់យកទីតាំង និងទំហំដីសម្រាប់បង្កើតកសិដ្ឋាន ឬរោងជាង | ចន្លោះ ខែកញ្ញា-ធ្នូ ២០២០ | សាកលវិទ្យាល័យ |
| ទិញឧបករណ៍ និងសម្ភារៈត្រូវការ | ចន្លោះ ខែកញ្ញ ២០២០ -មិថុនា ២០២១ | សាកលវិទ្យាល័យ |
| សាងសង់កសិដ្ឋាន ឬ រោងជាង និងបំពាក់ឧបករណ៍និងសម្ភារៈ | ចន្លោះ ខែកញ្ញ ២០២០ -មិថុនា ២០២១ | សាកលវិទ្យាល័យ |
| **២) សិស្សចំនួន □□ និងចូលរួមសិក្សានៅក្នុងកម្មវិធីបំណិនរកចំណូល** | | |
| ពិភាក្សាជាមួយសិស្សពីបំណិនចង់រៀនដែលត្រូវនឹងឧបនិស្ស័យ | ចន្លោះ ខែកញ្ញា-ធ្នូ ២០២០ | សាកលវិទ្យាល័យ |
| កត់ឈ្មោះសិស្សតាមថ្នាក់និងតាមមុខបំណិនមួយៗ (កសិកម្មនិងឬការងារ) | ចន្លោះ ខែកញ្ញា-ធ្នូ ២០២០ | នាយកសាលា |
| បង្រៀនសាលាពីការរៀបចំកម្មវិធីឥណទាន | ២០២១ | ក្រសួង (SEIP) |
| រៀបចំកម្មវិធីឥណទានជួយសិស្ស គ្រូបង្រៀន និងមន្ត្រី | ២០២១-២០២២ | ក្រសួង (SEIP) |
| **៣) សិស្សចំនួន □□ និងបន្តចូលរៀននៅមហាវិទ្យាល័យតាមឧបនិស្ស័យរបស់ខ្លួន** | | |
| កត់ឈ្មោះសិស្ស និងកម្មវិធីបរិញ្ញាបត្រនៅមហាវិទ្យាល័យចង់សិក្សា | កញ្ញា-ធ្នូ ២០២០ | សាកលវិទ្យាល័យ |
| អនុវត្តការបង្រៀនបំណិនដល់គ្រូបង្រៀន | ២០២១ (មករា-មិថុនា) | សាកលវិទ្យាល័យ |
| អនុវត្តការបង្រៀនបំណិនដល់សិស្ស រួមជាមួយការអនុវត្តបំណិន | ២០២១ | សាកលវិទ្យាល័យ |
| ជួយសិស្សអនុវត្តបំណិននៅកសិដ្ឋានតាមផ្ទះ | ២០២១ | គ្រូតាមមុខវិជ្ជា |

| | | |
|---|---|---|
| ចុះជួយពិនិត្យតាមដានពីសាលានៅតាមផ្ទះ | ២០២១ | គ្រូតាមមុខវិជ្ជា |
| ចុះជួយណែនាំសាលាពីដំណើរការប្រតិបត្តិកម្មវិធីបំណិនរកចំណូល | ២០២១ | ក្រសួង |
| បង្រៀនសាលាពីការរាយការណ៍ និងការគ្រប់គ្រងចំណូលចំណាយ | ២០២១ | ក្រសួង |
| បង្រៀនសិស្សពីការគ្រប់គ្រងមុខរបរ និងជំនួញ | ២០២១ | ក្រសួង |
| **៤) សាលារៀនមានកម្មវិធីបំណិនរកចំណូលមានស្តង់ដានៅឆ្នាំ២០២២** | | |
| **អនុវត្តការប្រជុំប្រចាំខែ ត្រីមាស និងឆ្នាំទៀងទាត់** | **ខែ ត្រីមាស ២០២១** | **ក្រសួង-នាយក** |
| អនុវត្តការវាយតម្លៃកម្មវិធីធៀបជាមួយស្តង់ដានៅចុងឆ្នាំ | ធ្នូ ២០២១ | ក្រសួង |
| កែសម្រួលសកម្មភាពផែនការរៀងរាល់ចុងឆ្នាំក្រោយការវាយតម្លៃ | ធ្នូ ២០២១ | ក្រសួង |

## ៤-២ ស្តង់ដាកម្មវិធី និងការវាយតម្លៃ

| ក្របខណ្ឌលទ្ធផល | ពិន្ទុ០ | ពិន្ទុ១ | ពិន្ទុ២ | ពិន្ទុ៣ |
|---|---|---|---|---|
| **សូចនាករផលមស្រេច** | | | | |
| ១. សិស្សសាលាមធ្យមសិក្សាមានសមត្ថភាពចំណេះដឹងល្អនិងល្អប្រសើរស្របតាមឧប្បនិស្ស័យកើនជាងមុន | មិនមាន | តិចជាងផែនការ | តាមផែនការ | លើសផែនការ |
| ២. សិស្សសាលាមធ្យមសិក្សាមានសមត្ថភាពសមត្ថភាពបញ្ញានិងចិត្តសង្គម និងសមត្ថភាពរកចំណូល | មិនមាន | តិចជាងផែនការ | តាមផែនការ | លើសផែនការ |
| **សូចនាករទិន្នផល** | | | | |
| ៣. ចំនួនមុខបំណិនកសិកម្ម | មិនមាន | តិចជាង | គ្រប់មុខ | លើសចំនួន |
| ៤. ចំនួនមុខបំណិនការងារ | មិនមាន | តិចជាង | គ្រប់មុខ | លើសចំនួន |
| ៥. ចំនួនសិស្សចូលរួមសិក្សានៅក្នុងកម្មវិធីបំណិនរកចំណូល | មិនមាន | តិចជាងផែនការ | តាមផែនការ | លើសផែនការ |
| ៦. ចំនួនសិស្សចូលរៀននៅមហាវិទ្យាល័យតាមឧប្បនិស្ស័យរបស់ខ្លួន | មិនមាន | តិចជាងផែនការ | តាមផែនការ | លើសផែនការ |
| ៧. សាលារៀនមានកម្មវិធីបំណិនរកចំណូលមានស្តង់ដានៅឆ្នាំ២០២២ | មិនមាន | ទាប | អប្បបរមា | ពេញលេញ |
| | ០ | ៦ (៧) | **១២** (១៤) | ១៨ (២១) |

## ៤-៣ ការធ្វើផែនការឆ្នាំ និងការពង្រីកកម្មវិធី

បំណិនកសិម្ម បរិមាណផលិត និងចំណូល

| បំណិន | បរិមាណ ផលិត | ចំណូល ២០២១ | ចំណូល ២០២២ | ចំណូល ២០២៣ |
|---|---|---|---|---|
| ១. បន្លែ | គីឡូ (មុខ?) | គីឡូ | គីឡូ | គីឡូ |
| ២. មណ្ឌា | (មុខ?) | គីឡូ | គីឡូ | គីឡូ |
| ៣. កន្ទាយ/អណ្តើក/កង្កែប | (មុខ?) | ក្បាល | ក្បាល | ក្បាល |
| ៤. ជ្រូកព្រៃ/ជ្រូកស្រុក | (មុខ?) | ក្បាល | ក្បាល | ក្បាល |
| ៥. គោ/ចៀម/ពពែ | (មុខ?) | ក្បាល | ក្បាល | ក្បាល |
| ៦. បក្សីៈ មាន់/ទា/ក្ងាន | (មុខ?) | គីឡូ | គីឡូ | គីឡូ |
| ៧. ក្រួច/លលក/ចង្រិត | (មុខ?) | គីឡូ | គីឡូ | គីឡូ |
| ៨. ឈើហូបផ្លែ | (មុខ?) | គីឡូ | គីឡូ | គីឡូ |
| ៩. រុក្ខជាតិលម្អ/ឃ្មុំ | (មុខ?) | | | |
| ១០. កែឆ្នៃអាហារ | (មុខ) | គីឡូ | គីឡូ | គីឡូ |
| សរុប | | | | |

## ៤-៤ ការពិនិត្យតាមដាន វាយតម្លៃ និងការរាយការណ៍

### ក-ការពិនិត្យតាមដាន និងវាយតម្លៃ

- ការពិនិត្យតាមដានគឺផ្តោតលើក្រុមគោលដៅដែលកំណត់នៅក្នុងក្របខណ្ឌលទ្ធផលរយៈពេល៣ឆ្នាំ
- ការពិនិត្យតាមដានជាប់ជាប្រចាំគឺ ផ្តោតលើការសិក្សារបស់សិស្សប្រចាំថ្ងៃ។ អ្នកទទួលខុសត្រូវសកម្មភាពនីមួយៗនៅក្នុងតារាងផែនការសកម្មភាពត្រូវទទួលខុសត្រូវលើសកម្មភាពនីមួយៗ
- ការពិនិត្យតាមដានលើកម្មវិធីបំណិនរកចំណូលត្រូវបញ្ចូលចាប្រធានបទមួយនៅក្នុងការប្រជុំប្រចាំខែ ត្រីមាស និងឆ្នាំរបស់សាលារៀន
- ការវាយតម្លៃឆ្នាំលើកម្មវិធីជាកិច្ចការមួយបន្ថែមលើការវាយតម្លៃឆ្នាំរបស់សាលាទាំងមូល។

### ខ-ការរាយការណ៍

- ការរាយការណ៍ប្រចាំខែៈ រាយការណ៍ពីការអនុវត្តសកម្មភាពបានគ្រោងប្រចាំខែ (បានធ្វើឬមិនបានធ្វើ បើមិនបានធ្វើមូលហេតុអ្វី ដោះស្រាយដោយសកម្មភាពអ្វី អ្នកណាអនុវត្ត និងអនុវត្តពេលណា)
- ការរាយការណ៍ប្រចាំត្រីមាសនិងឆមាសៈ រាយការណ៍ពីការសម្រេចបាន ឬសក្តានុពលនៃការសម្រេចបានក្រុមគោលដៅតាមសូចនាករនៅចុងឆ្នាំ
- ការរាយការណ៍ប្រចាំឆ្នាំៈ រាយការណ៍ពីការសម្រេចបាននូវក្រុមគោលដៅគ្រោងតាមគ្រប់សូចនាករ ឧបសគ្គនិងការរាំងស្ទាត់ សកម្មភាពជាដំណោះស្រាយ ស្ថានភាពហិរញ្ញវត្ថុ (ចំណូល ចំណាយ និងមូលធនមាន) និងផែនការពង្រីកចំនួននិងវិសាលភាពមុខបំណិន។

- ❑ ការវាយតម្លៃពីផលប៉ះពាល់៖ មហាវិទ្យាល័យអប់រំ និងសាកលវិទ្យាល័យជាអ្នកទទួលខុសត្រូវអនុវត្តកិច្ចការនេះ។

## ៤-៥ ការគ្រប់គ្រងចំណូល និងចំណាយ

សាលាត្រូវផ្តោតពីឆ្នាំដំបូងនូវការបង្កើនដើមទុន ដោយអនុវត្តបំណិនដែលនាំមកនូវចំណូលច្រើន ដូចជា ការចិញ្ចឹមកន្ទាយ ឬ អណ្តើក ត្រីសាច់ និងបន្លែមានតម្លៃថ្លៃៗ។ ដោយមានជួយពីសាកលវិទ្យាល័យ សាលាត្រូវរៀបចំសិស្សជាក្រុមអនុវត្តការសិក្សាពីតម្រូវការទីផ្សារទៅតាមមុខផលិតផលនីមួយៗ ជាមួយគ្នានឹងការពិភាក្សាបង្កើតកិច្ចសន្យា កុំម្ម៉ង់ទិញពីអ្នកលក់នៅតាមទីផ្សារ។ កិច្ចសន្យាទិញអាចជាខែ ឬ បីខែ ឬឆ្នាំនៅពេលណាអ្នកទិញទុកចិត្តជាមួយការផ្តល់ផលិតផលមានគុណភាពនិងទាន់ពេលវេលា។ ស្របពេលជាមួយគ្នា សាលារៀនត្រូវកសាងផែនការអនុវត្តលើគ្រប់មុខបំណិនដែលសិស្សមានបំណងប្រាថ្នាចង់រៀន មានបំណងអនុវត្តនៅសាលារៀន តាមផ្ទះរបស់ខ្លួន ឬតាមផ្ទះមិត្តភក្តិ។

**ចំណូលដែលបានមកត្រូវបែងចែកសម្រាប់៖** ១) ទុកជាដើមទុនពង្រីកវិសាលភាពបំណិនឬបង្កើនចំនួនបំណិន ២) ឧបត្ថម្ភដល់គ្រូ អ្នកគ្រប់គ្រងសាលា ៣) ឧបត្ថម្ភដល់អ្នកជំនាញមកពីសាកលវិទ្យាល័យនិងក្រសួង និង ៤) ឧបត្ថម្ភដល់សិស្សដែលចាំថែទាំកសិដ្ឋានសាលា ឬ ផ្តល់សេវាបច្ចេកទេសតាមគ្រួសារ (ដូចជាការជួសជុលទូរទឹកកក ម៉ាស៊ីនត្រជាក់ តភ្លើង...)។ សាលាគប្បីបង្កើនបរិមាណនៃការឧបត្ថម្ភគ្រូបង្រៀន និងនាយកសាលាដែលចាប់ផ្តើមពី ១០០ដុល្លារក្នុង១ខែ នឹងឈានឆ្ពោះដល់ ៥០០ដុល្លារក្នុង១ខែ ឬច្រើនជាងនេះ។

**ការកំណត់ភាគរយនៃប្រាក់ចំណូលក្នុងមួយឆ្នាំ**

ព្រំដែនបរិមាណផ្តល់ឱ្យគឺអាចធានាបាននូវការរស់នៅសមរម្យតាមតម្រូវការទីផ្សារ។ ជាការល្អ ការឧបត្ថម្ភអាចគ្រោងចាប់ពី៥០ដុល្លាក្នុងមួយខែ និងដំឡើងរហូតដល់៥០០ដុល្លារក្នុង១ខែ សម្រាប់គ្រូបង្រៀន ឬនាយកសាលា។ បរិមាណឧបត្ថម្ភសម្រាប់សិស្សគឺ អាចឱ្យសិស្សជួយបំពេញបាននូវតម្រូវការអាហារនិងការស់នៅ ព្រមទាំងមានលុយអាចសន្សំសម្រាប់ទៅរៀននៅមហាវិទ្យាល័យ។ ការឧបត្ថម្ភសម្រាប់គណៈកម្មការគ្រប់គ្រងសាលារៀនគឺ តម្រូវទៅតាមសមាជិកម្នាក់ៗ ដែលត្រូវការសម្រាប់ការរស់នៅ តែបើសមាជិកណាជាអ្នកមានដែលមិនត្រូវការការឧបត្ថម្ភ នោះមិនចាំបាច់ចំណាយទេ តែត្រូវមានកំណត់ហេតុច្បាស់លាសថាមិនទទួលនូវការឧបត្ថម្ភទេ។ ការឧបត្ថម្ភសម្រាប់មន្ត្រីក្រសួងឬមហាវិទ្យាល័យគឺ ដើម្បីរក្សានូវនិរន្តរភាពនៃការជួយឱ្យកម្មវិធីមានដំណើរការទៅបាន និងជួយបំពេញនូវតម្រូវការសម្រាប់រស់នៅ។ បរិមាណសរុបសម្រាប់ឧបត្ថម្ភគឺ ត្រូវដកចេញនៅថ្លៃដើមសម្រាប់អនុវត្តកម្មវិធីគ្រោងចុងឆ្នាំ។ នៅពេលណាដែលសាលារៀនមានសល់ទឹកប្រាក់ ដែលនៅសល់ក្រោយពីការដកបរិមាណប្រាក់ឧបត្ថម្ភ និងថ្លៃដើមហើយនោះ នាយកសាលាអាចពិភាក្សាជាមួយ គ.គ.ស. ឬក.ប.ស. ពី ការបង្កើតកម្មវិធីធានារ៉ាប់រង និងអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ។

| បរិមាណចំណូលជារៀល | % និងបរិមាណសាច់ប្រាក់ឧបត្ថម្ភ | | | | |
|---|---|---|---|---|---|
| | គ្រូបង្រៀនជួយសិស្សអនុវត្ត | សិស្សចាំកសិដ្ឋានសាលា | គណៈគ្រប់គ្រងសាលា | គណៈកម្មការគ្រប់គ្រងសាលា | មន្ត្រីក្រសួងឬសាកលវិទ្យា |

| | គម្រោង | | | រៀន | ល័យ |
|---|---|---|---|---|---|
| | ៥០% | ៣០% | ១០% | ៧% | ៣% |
| | | | | | |
| | | | | | |

ដោយឡែកសម្រាប់សិស្សអនុវត្តបំណិននៅតាមផ្ទះ គ្រូបង្រៀនត្រូវជួយសិស្សគ្រោងផែនការបំណិនប្រចាំឆ្នាំ និងតាមជួយសិស្សអនុវត្តបំណិននៅតាមផ្ទះ។ សាច់ប្រាក់ចំណូលគឺ មានការវិភាគនៅក្នុងកម្មវិធីរៀនបំណិនរបស់សិស្សម្នាក់ៗហើយ។ ដូចគ្នានឹងសិស្សដែលមិនដីសម្រាប់កសិដ្ឋាន ហើយមានបំណងអនុវត្តបំណិននៅកសិដ្ឋានមិត្តភក្តិ នោះបរិមាណចំណូល និងចំណាយគឺមានការវិភាគនៅក្នុងគម្រោងបំណិនរកចំណូលហើយ។

សាលាត្រូវជួយសិស្សក្នុងការគ្រប់គ្រងចំណូលនិងចំណាយ ដោយការសន្សំប្រាក់សម្រាប់ចូលរៀនមហាវិទ្យាល័យ។ ចាប់ពីរៀនថ្នាក់ទី ៧រហូតដល់ថ្នាក់ទី១២ សិស្សមួយនាក់គប្បីអាចសន្សំប្រាក់យ៉ាងតិចចំនួនពី១ ទៅ២ពាន់ដុល្លារ ដើម្បីបង់ថ្លៃសិក្សា១២០០ដុល្លារក្នុង១ឆ្នាំសម្រាប់ឆ្នាំទី១នៅមហាវិទ្យាល័យ។ នៅឆ្នាំសិក្សានៃឆ្នាំទី១ សិស្សអាចរៀនផង និងរកចំណូលសម្រាប់បង់ថ្លៃសិក្សានៅឆ្នាំពីឆ្នាំទី២ រហូតដល់ឆ្នាំទី៤ ឬ ឆ្នាំបញ្ចប់ការសិក្សាបាន។

នៅឆ្នាំទី៤ ពេលដែលសាលារៀនមានសុខភាពហិរញ្ញវត្ថុ មានន័យថានៅមានបរិមាណជាសាច់ប្រាក់នៅសល់ បូកជាមួយការចូលភាគហ៊ុនពីគ្រូបង្រៀន សិស្សនិងសហគមន៍ សាលាត្រូវពិភាក្សាជាមួយសហគមន៍បង្កើតកម្មវិធីធានារ៉ាប់រងសង្គម និងអភិវឌ្ឍសមត្ថភាពគ្រូបង្រៀននិងនាយកសាលា។ ក្រៅពីការរៀនបំណិន កសិកម្ម និងបច្ចេកទេស ឬការងារ សាលាត្រូវរៀបចំថ្នាក់ភាសាអង់គ្លេស និង ព័ត៌មាន-បច្ចេកវិទ្យា ដែលមានគុណភាពខ្ពស់ ហើយពិភាក្សាជាមួយមាតាបិតានិងសិស្សពីការបង់ប្រាក់បង្កើតថ្នាក់រៀន ទិញឧបករណ៍ និងឧបត្ថម្ភគ្រូ។ សិស្សត្រូវការការសិក្សាបានទូលាយនៅមហាវិទ្យាល័យ ដូចនេះសមត្ថភាពភាសាអង់គ្លេសនិងICT ជាសមត្ថភាពដែលត្រូវមាននិងមិនអាចខ្វះបាន។ ក្រសួងមិនអាចមានឱកាសសម្រាប់តម្រូវការនេះទេ។ ក្រសួងនឹងចាប់ផ្តើមអនុវត្តសាកល្បងការប្រើ EdTech ក្នុងការបង្រៀនគណិតវិទ្យាពីឆ្នាំ២០២២ទៅ។

## ៤-៦ រៀបចំសាលារៀនត្រៀមទៅបំពេញបាន នូវស្តង់ដាសាលារៀននៅប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់

ការអភិវឌ្ឍសាលារៀនត្រូវមានទិសដៅដែលកំណត់ដោយរដ្ឋាភិបាល ក្នុងការប្រែក្លាយប្រទេសឈានទៅរកប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ ដូចនេះជាការប្រសើរ ប្រសិនបើសាលារៀនដែលបំពេញបាននូវស្តង់ដាសហគមន៍សាលារៀនហើយ ចាប់ផ្តើមនូវការគ្រោងផែនការសមិទ្ធកម្មរបស់ខ្លួន ដើម្បីបំពេញនូវលក្ខខណ្ឌចាំបាច់ដែលអាចឈានទៅអភិវឌ្ឍសាលារៀនខ្លួន ក្លាយជាសាលារៀនដែលមានស្តង់ដាដូចសាលារៀននៅប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ដែរ។

### លក្ខខណ្ឌចាំបាច់ដែលត្រូវបំពេញមាន

១) មានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុពេញលេញ

២) មានសុខភាពហិរញ្ញវត្ថុដែលអាចគាំទ្រគម្រោងវិនិយោគ

៣) មានសមត្ថភាពគ្រោងគម្រោងវិនិយោគ សម្រាប់ដាក់ស្នើសុំថវិកាពីរដ្ឋ

៤) បង្រៀនភាសាអង់គ្លេស និងព័ត៌មានវិទ្យា និងមានឧបករណ៍ព័ត៌មានវិទ្យានិងបច្ចេកវិទ្យាដែលអាចឱ្យសិស្សរៀនបាននូវចំណេះដឹងសាកលលោក

៥) មានគ្រូបង្រៀនកម្រិតបរិញ្ញាបត្រ៨០% និងអនុបណ្ឌិត២០% ដែលមានការទទួលស្គាល់ពីក្រសួង

## ៥- កសាងទំនួលខុសត្រូវសង្គមរបស់សាលារៀនក្នុងសហគមន៍

### ក. ជួយសិស្សនិងគ្រួសារសិស្សក្រីក្រនិងយ៉ាប់យ៉ឺន

នេះជាកិច្ចការមួយនៃការអនុវត្តគុណតម្លៃដែលសាលារៀនត្រូវតែអនុវត្ត។ សិស្សក្រីក្រនិងយ៉ាប់យឺនត្រូវការនូវការជួយបន្ទាន់លើ ការរៀនយឺតយ៉ាវ ការខ្វះសម្ភារៈរៀនសូត្រ ការខ្វះខាតចំណីអាហារ សុខភាពមិនល្អឬមានជំងឺ និងការទទួលរងហិង្សា ឬ ការទុកចោលដោយគ្មានការថែរក្សានៅផ្ទះ។

ការជួយសិស្សក្រីក្រនិងយ៉ាប់យឺនអាចជួយ តាមរបៀប២យ៉ាង គឺ ១) ជួយផ្តល់បន្ទាន់នូវអ្វីដែលត្រូវការ សម្រាប់ការរៀនសូត្រ ការហូបចុក និងការព្យាបាលជំងឺ និង ២) ការជួយសិស្សរៀនបំណិនរកចំណូល រួមជាមួយនឹងការជួយសិស្សលប់បំបាត់ការទទួលរងនូវភាពហិង្សាក្នុងគ្រួសារ ដែលជាការជួយមានរយៈពេលមធ្យម និងវែងសម្រាប់ជាការកសាងអនាគតរបស់គេ។ ជាការល្អបើការជួយនេះអាចធ្វើបានចាប់ពីឆ្នាំទី១ និងការជួយដល់ឆ្នាំទី៣នេះ ជាការជួយដល់សិស្សក្រីក្រនិងយ៉ាប់យឺនទាំងអស់នៅក្នុងសាលារៀន និងសហគមន៍។

### ខ. ជួយដល់សាលាបឋមសិក្សានិងមធ្យមសិក្សានៅក្បែរ

នេះជាសកម្មភាពបញ្ជាក់នូវកិច្ចសន្យាសង្គមសម្រាប់សហគមន៍ និងក៏ជាការជួយដល់សាលារៀនរបស់ខ្លួនក្នុងការរក្សាបាននូវគុណភាពអប់រំ។ មានន័យថា ប្រសិនបើសាលារៀនមួយបំពេញបាននូវស្តង់ដាសហគមន៍សាលារៀនហើយតែមិនបានជួយដល់សាលារៀននៅក្បែរខាង នោះមាតាបិតានៃសិស្សនៅរៀនសាលារៀនក្បែរខាង នឹងបញ្ជូនកូនទាំងអស់មករៀននៅសាលារៀនមានស្តង់ដា។ បែបនេះនាំឱ្យសាលារៀនមានស្តង់ដាមិនអាចមានសមត្ថភាពទទួលយកនូវចំនួនសិស្សដែលកើនឡើងសន្ទឹកសន្ទាប់នេះបានទេ ហើយនៅទីបញ្ចប់គុណភាពបង្រៀន និងរៀនត្រូវធ្លាក់ចុះវិញ។ តែបើសាលារៀនមានស្តង់ដាអាចជួយដល់សាលារៀននៅក្បែរខាងបាន នោះសហគមន៍របស់ខ្លួននឹងផ្តល់តម្លៃដល់សាលារៀនមានស្តង់ដា ហើយសហគមន៍នឹងមានសង្ឃឹមថាអាចជួយសាលារៀននេះឈានទៅរកស្តង់ដាសាលារៀននៃប្រទេសជឿនលឿនបាន។ របៀបអនុវត្តកិច្ចការនេះគឺ មាននៅក្នុងគំរូផែនការកែលម្អសាលារៀនប្រចាំឆ្នាំហើយ។

សាលារៀនដែលជឿនលឿនគប្បីផ្តួចផ្តើមការរៀបចំផែនការកែលម្អសាលារៀនប្រចាំឆ្នាំដោយអញ្ជើញសាលារៀនក្បែរខាង ទាំងសាលាបឋមសិក្សា និងមធ្យមសិក្សា មកធ្វើផែនការជាមួយគ្នា។

### គ. សាលារៀនអនុវត្តការងារឆ្ពោះទៅរកស្វ័យភាពពេញលើរដ្ឋបាលនិងហិរញ្ញវត្ថុ

កត្តាដែលអាចនាំទៅរកស្វ័យភាពពេញលេញលើរដ្ឋបាលនិងហិរញ្ញវត្ថុបានមាន

១) ការសម្រេចលទ្ធផលជាផលសម្រេចអប់រំ និងការសិក្សារៀនសូត្រតាមផែនការសមិទ្ធកម្ម ព្រោះថានេះជាបំណែកសំខាន់មួយក្នុងការកសាងជំនឿទុកចិត្តពីសហគមន៍ និងមាតាបិតាសិស្សចំពោះគ្រូបង្រៀននិងសាលារៀន

២) ការរក្សាតម្លាភាពទាំងលើ ចំណូលនិងចំណាយ ទិន្នន័យរីកចម្រើនពីការបង្រៀននិងរៀន ទិន្នន័យពីការបំពេញបាននូវស្តង់ដាសហគមន៍សាលារៀន តាមរយៈការផ្សព្វផ្សាយទិន្នន័យទាំងនេះជាសាធារណៈ
៣) សុខភាពហិរញ្ញវត្ថុរបស់សាលារៀន ដែលបានចំណូលពីកម្មវិធីបំណិនរកចំណូល កម្មវិធីធានារ៉ាប់រងសង្គម និងអភិវឌ្ឍសមត្ថភាព និងការចូលរួមជាជំនួយមនុស្សធម៌ពីអ្នកមាន រួមជាមួយថវិកាជាតិ សម្រាប់អនុវត្តកម្មវិធីវិនិយោគរបស់សាលារៀន

## ឃ. ការផ្លាស់ប្តូរអាណត្តិនាយកសាលា និង គ.គ.ស. ឬ ក.ប.ស.

**ចំពោះការផ្លាស់ប្តូរអាណត្តិនាយកសាលា**

ការផ្លាស់ប្តូរអាណត្តិរបស់នាយកសាលាជាបំណែកមួយនៃស្វ័យភាពរដ្ឋបាលនៅសាលារៀន។ ការផ្លាស់ប្តូរអាណត្តិនេះគប្បីត្រូវផ្អែកលើ ១) គណនេយ្យភាពការងាររបស់នាយកសាលាដែលបញ្ជាក់នូវការទទួលខុសត្រូវក្នុងបំពេញភារៈកិច្ច ២) ការកសាងសមត្ថភាពជាប់ជាប្រចាំ ៣) កោសល្យជាអ្នកដឹកនាំនិងគ្រប់គ្រង និង ៤) នីតិវិធីរបស់រដ្ឋពីការបង្កើនឋានន្តរសក្តិ។

ជារៀងរាល់ឆ្នាំ ការអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់មន្ត្រីជាកិច្ចការសំខាន់ដែលជាយានន្តនាំមកនូវការវិនិច្ឆ័យលើការផ្លាស់ប្តូរអាណត្តិនេះ។ នាយករង ឬ គ្រូបង្រៀនដែលមានកោសល្យជាអ្នកដឹកនាំឬអ្នកគ្រប់គ្រង និងសមត្ថភាពមូលដ្ឋាន រួមមានពិសោធន៍ និងគុណវុឌ្ឍិដែលទទួលស្គាល់ដោយក្រសួង ត្រូវបានសង្កេតជាប់ជាប្រចាំ។ នៅពេលដែលនាយកសាលាបច្ចុប្បន្នមិនអាចបំពេញបាននូវតួនាទីរបស់ខ្លួន ដែលមានភស្តុតាងពីការវាយតម្លៃប្រចាំឆ្នាំចំនួន២ឆ្នាំ នោះគ.គ.ស.ឬក.ប.ស.ត្រូវតែរៀបចំដំណើរការផ្លាស់ប្តូរអាណត្តិហើយ។ ២ឆ្នាំនៃការមិនបំពេញការងារជានាយកសាលា ជារយៈពេលយូរពេកហើយ ព្រោះថាសាលារៀនត្រូវបំពេញស្តង់ដាសហគមន៍សាលារៀននៅឆ្នាំទី៣ និងយ៉ាងយូរបំផុតនៅឆ្នាំទី៥ ដោយសារបានខកខានរយៈពេល២ឆ្នាំ នៃការមិនមានគណនេយ្យភាពរបស់នាយកសាលារៀន។

សម្រាប់នាយករង ឬ គ្រូបង្រៀនដែលមានកោសល្យ និងសក្តានុពល ត្រូវមានកាតវាយតម្លៃពីគ.គ.ស.ឬ ក.ប.ស ឯកភាពជាមួយក្រុង ស្រុក ខណ្ឌ និងត្រូវបញ្ជូនបេក្ខជនមករៀនបង្កើនគុណវុឌ្ឍិជានាយកសាលានៅមហាវិទ្យាល័យអប់រំ ឬ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន។ ក្រោយរៀនចប់ ត្រូវទទួលបាននូវការចាត់តាំងពេញសិទ្ធិជានាយកសាលា។

**ចំពោះការផ្លាស់ប្តូរអាណត្តិគ.គ.ស. ឬ ក.ប.ស.**

ដូចគ្នានឹងនាយកសាលាដែរ ប្រសិនបើ គ.គ.ស. ឬ ក.ប.ស. មិនមានដំណើរការរយៈពេល១ឆ្នាំ នោះត្រូវរៀបចំធ្វើការបោះឆ្នោតជ្រើសរើសសារជាថ្មី។ ភស្តុតាងនៃភាពមិនមានដំណើរការគឺ បង្ហាញដោយស្តង់ដាទី៣ នៃស្តង់ដាសហគមន៍សាលារៀន។ តែប្រសិនបើមានសមាជិកណាម្នាក់មិនអនុវត្តនូវកិច្ចការរបស់ខ្លួន គ.គ.ស. ឬ ក.ប.ស. ត្រូវពិភាក្សាជាមួយនាយកសាលា និងមានការព្រមព្រៀងពីថ្នាក់ក្រុង ស្រុក ខណ្ឌ និងពីសាមីជន ក្នុងការបញ្ឈប់ពីកិច្ចការក្នុងគ.គ.ស.ឬក.ប.ស.។ ភស្តុតាងនៃការមិនអនុវត្តកិច្ចការ គឺ ត្រូវបង្ហាញនូវភាពមិនប្រក្រតី នៃការអនុវត្តតួនាទីដែលសមាជិកបានព្រមព្រៀងទទួលនៅពេលជ្រើសរើសគ.គ.ស.ឬក.ប.ស.។

## ៦- ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តរបស់សាលារៀនផ្អែកលើទិន្នន័យជឿជាក់បាន

### *ក) ពិនិត្យតាមដានប្រចាំខែ និងពិនិត្យឡើងវិញប្រចាំត្រីមាស និងការរាយការណ៍*

ការអនុវត្តកិច្ចការនេះគឺមានលំនាំដូចគ្នា របៀបអនុវត្តដូចគ្នា និងប្រើឧបករណ៍ដូចគ្នានឹងឆ្នាំទី២ដែរ។

### *ខ) ពិនិត្យទិន្នន័យជឿជាក់បានទាក់ទងនឹងសូចនាករពឹងកសាសម្លាងនិងម្ចាស់ទិន្នន័យ*

ទិន្នន័យដែលជឿជាក់បានលុះណាមានលក្ខខណ្ឌដូចតទៅ ១) មានភស្តុតាងដែលផលិតតាមការណែនាំរបស់ក្រសួង ២) ភស្តុតាងដែលប្រាកដជាមានម្ចាស់ និងមិនមែនជាភស្តុតាង ដែលកែច្នៃដោយអ្នកណាម្នាក់ដែលមិនមែនជាម្ចាស់សូចនាករ ៣) មានប្បុប្បន្នភាព មិនមែនយកភស្តុតាងពីឆ្នាំមុនៗមកប្រើទេ ៤) បង្ហាញទំនោរនៃការរីកចម្រើនដែលមានភាពសមហេតុសមផល ដោយមិនលោតផ្លោះដែលមិនមានមូលដ្ឋានសម្រាប់ពិចារណានោះទេ និង ៥) មានភាពប្រទាក់ប្រទងគ្នា និងស៊ីគ្នាសមហេតុសមផល ដូចជា ស្តង់ដាទី១បំពេញបាននូវពិន្ទុអប្បរមា តែស្តង់ដាទី២មិនអាចបំពេញបានស្តង់ដាអប្បបរមា។ ពោលគឺ ការពិនិត្យតាមដានដោយផ្អែកលើ តួលេខ ភាពជាម្ចាស់នៃតួលេខ និងពេលវេលាត្រូវសម្រេចតួលេខ។

### *គ) ស្វ័យវាយតម្លៃសាលារៀន និងរាយការណ៍*

ដំណើរការអនុវត្ត របៀបអនុវត្ត និងការប្រើប្រាស់ឧបករណ៍ គឺដូចគ្នានឹងឆ្នាំទី២ដែរ។ នាយកសាលាដឹកនាំកិច្ចការនេះដោយភាពហ្មត់ចត់ និងត្រឹមត្រូវ។

### *ឃ) តួនាទីសិស្សនិងយុវជននៅក្នុងការគ្រប់គ្រងសាលារៀន*

ជាការចាំបាច់នៅឆ្នាំទី៣នេះ តំណាងយុវជនតាមថ្នាក់រៀនអាចបោះឆ្នោតរងតំណាងយុវជនសាលារៀនទាំងមូល ហើយការបោះឆ្នោតត្រូវធ្វើដោយមានតម្លាភាព និងតាមលំដាប់លំដោយ ដូចជាការបោះឆ្នោតជ្រើសរើសគ.គ.ស.ឬក.ប.ស.ដែរ។ តំណាងយុវជនដែលបានជ្រើសរើសនឹងត្រូវឈរជាសមាជិកម្នាក់នៅក្នុងគ.គ.ស. ឬក.ប.ស. ហើយតួនាទីគឺត្រូវបានកំណត់នៅពេលត្រូវបានជ្រើសរើសជាតំណាង និងមានការព្រមព្រៀងពីនាយកសាលានិងគ.គ.ស .ឬក.ប.ស.។ ថាមពលនៃតំណាងយុវជននៅក្នុងគ.គ.ស.ឬក.ប.ស.មានសារៈប្រយោជន៍ធំណាស់ដល់សាលារៀនការសម្រេចបាននូវផលសម្រេចអប់រំ និងការរក្សាបាននូវគុណភាពនៃការបង្រៀននិងរៀន។ កត្តានាំមកនូវការសម្រេចបាននេះ ព្រោះថាសម្លេងសិស្សទាំងអស់ក្នុងមួយសាលារៀននឹងត្រូវបានពាំនាំមកជាមួយតំណាងរបស់គេសម្រាប់ធ្វើការកែលម្អសេវាអប់រំ និងការបង្រៀននិងរៀន។

## ឆ្នាំទី៤៖ សាលារៀនមានដំណើរការប្រកបដោយនិរន្តរភាព និងច្រើនជាងនេះ

### ១. ខត្តុបំណាច

ឆ្នាំទី៤ជាឆ្នាំដែលត្រូវផលិត ផែនការ៣ឆ្នាំ លើកទីពីរ។ ផែនការ៣ឆ្នាំលើកទីពីរ ជាផែនការចុងក្រោយ ដែលសហគមន៍សាលារៀនត្រូវប្តេជ្ញាចិត្តសម្រេចឱ្យបាននូវក្រុមគោលដៅឆ្នាំទី៦ នៃផែនការសមិទ្ធកម្ម៦ឆ្នាំ ២០២១ដល់ ២០២៦។ សាលារៀនមិនអាចប្តូរក្រុមគោលដៅឆ្នាំទី៦បានទេ តែត្រូវកែសម្រួលក្រុមដៅឆ្នាំ ២០២៤ និង២០២៥ ដែលមានទំនោរទៅសម្រេចបានក្រុមគោលដៅឆ្នាំ២០២៦។

### ២. ធ្វើផែនការសាលារៀនបំពេញខ្ទានខុខស្តង់ដាសាលារៀនមានប្រសិទ្ធភាព និងលើសពីនេះ (ឆ្ពោះទៅស្តង់ដាសាលារៀននៃប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់)

លំនាំនៃការធ្វើផែនការកែលម្អឆ្នាំ គឺ ដូចគ្នានឹងឆ្នាំទី៣ដែរ។ នាយកសាលាត្រូវអញ្ជើញសាលារៀន និងសហគមន៍នៃសាលារៀននៅក្នុងសហគមន៍មកចូលរួមធ្វើផែនការជាមួយគ្នា។

**ខ្លឹមសារលម្អិតនៃលក្ខខណ្ឌចាំបាច់ដែលត្រូវបំពេញមាន**

១. មានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុពេញលេញ
- មានសិទ្ធិជ្រើសរើស និងធ្វើកិច្ចសន្យាជាមួយគ្រូបង្រៀន និងមន្ត្រីជាប់កិច្ចសន្យា។
- មានសិទ្ធិស្នើសុំចាត់តាំងជាផ្លូវការនូវគ្រូបង្រៀន និងនាយកសាលាពេញសិទ្ធ និងមាន ក្របខណ្ឌ។
- មានសិទ្ធិចាត់ចែងនិងការគ្រប់គ្រងចំណូលនិងចំណាយសាលារៀន។

២. មានសុខភាពហិរញ្ញវត្ថុដែលអាចគាំទ្រគម្រោងវិនិយោគ
- មានសិទ្ធិរកចំណូល និងធនធានត្រូវការសម្រាប់អភិវឌ្ឍសាលារៀន។
- មានសិទ្ធិចំណាយសម្រាប់អនុវត្តកម្មវិធីវិនិយោគសហគមន៍សាលារៀន។

៣. មានសមត្ថភាពគ្រោងគម្រោងវិនិយោគ សម្រាប់ដាក់ស្នើសុំថវិកាពីរដ្ឋ
- មានសិទ្ធិគ្រោងគម្រោងវិនិយោគ និងដាក់ស្នើជាផ្លូវលារដល់ថ្នាក់លើដើម្បីស្នើសុំថវិកា។

៤. បង្រៀនភាសាអង់គ្លេស និងព័ត៌មានវិទ្យា និងមានឧបករណ៍ព័ត៌មានវិទ្យានិងបច្ចេកវិទ្យាដែលអាចឱ្យសិស្សរៀនបាននូវចំណេះដឹងសាកលលោក
- មានសិទ្ធិបញ្ជាទិញនូវសម្ភារៈ និងឧបករណ៍ដែលសាលារៀនត្រូវការសម្រាប់អភិវឌ្ឍសាលារៀន ការបង្រៀននិងរៀនសូត្រ។

៥. មានគ្រូបង្រៀនកម្រិតបរិញ្ញាបត្រ៨០% និងអនុបណ្ឌិត២០% ដែលមានការទទួលស្គាល់ពីក្រសួង
- មានសិទ្ធិបញ្ជូនគ្រូបង្រៀន និងនាយកសាលាចូលរៀនកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀននិងនាយកសាលា

៦. មានបណ្តាញសហគមន៍សាលារៀនដែលមានដំណើរការ
- មានសិទ្ធិផ្តល់ជំនួយបច្ចេកទេស ដល់សាលារៀនផ្សេងទៀតក្នុងសហគមន៍ដើម្បីជួយលើកកម្ពស់គុណភាពអប់រំ។

## ក-បន្តប្រព័ន្ធការគ្រប់គ្រងសាលារៀនវដ្តទី២ (២០២៤ ដល់ ២០២៦)

ឆ្នាំទី៤ សហគមន៍សាលារៀនគប្បីឈានដល់ដំណាក់កាលកសាងបាននូវលក្ខខណ្ឌចាំបាច់សម្រាប់ធានានិរន្តរភាព និងអភិវឌ្ឍសហគមន៍សាលារៀន ឈានឆ្ពោះទៅមានស្តង់ដាដូចសាលារៀន នៃប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់។ សកម្មភាពទាំងអស់ដែលបានអនុវត្តពីឆ្នាំទី១ ដល់ទី ៣ ត្រូវបានអនុវត្តបន្តជាប់ជាប្រចាំ។

## ខ-ការរក្សានិរន្តរភាពដំណើរការសាលារៀន

*ក. បន្តអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់គ្រូបង្រៀននិងនាយកសាលា និងការដំឡើងឋានៈ*

នាយកសាលានិងគ.គ.ស.ឬក.ប.ស.ត្រូវបន្តអនុវត្តប្រព័ន្ធនេះដោយហ្មត់ចត់ និងបញ្ជូនព័ត៌មានទៅថ្នាក់ជាតិជាប់ជាប្រចាំសម្រាប់ថ្នាក់ជាតិបូកសរុបលទ្ធផល និងដាក់ស្នើទៅរដ្ឋមន្ត្រីដើម្បីដំឡើងឋានៈ។

*ខ. ការផ្លាស់ប្តូរតួនាទីនិងរចនាសម្ព័ន្ធគ្រប់គ្រងនិងអភិបាលកិច្ចសាលារៀន*

នៅពេលដែលសហគមន៍សាលារៀនបំពេញបាននូវលក្ខខណ្ឌមានស្វ័យភាពពេញលេញហើយ និងមានអ្នកមាននៅក្នុងសហគមន៍មានបំណង និងប្តេជ្ញាជួយសហគមន៍សាលារៀន នោះនាយកសាលា និង គ.គ.ស.ត្រូវប្រជុំដើម្បីរៀបចំក.ប.ស.។ ជាការពិតដែលសហគមន៍សាលារៀនឈានមកដល់កម្រិតអភិវឌ្ឍនេះគឺ គ.គ.ស. មានដំណើរការល្អ និងមានប្រសិទ្ធភាព ដែលបញ្ជាក់ដោយការបំពេញបាននូវស្តង់ដាទី៣ នោះការរៀបចំក.ប.ស គឺ គ.គ.ស.គ្រាន់តែបន្ថែមឈ្មោះសមាជិកថ្មីទៅក្នុងក្រុម និងពិភាក្សាពីតួនាទីដែលសមាជិកម្នាក់ៗត្រូវទទួលខុសត្រូវ។

*គ. តួនាទីសិស្សនៅក្នុង ក.ប.ស.*

តំណាងយុវជនដែលជាសមាជិកគ.គ.ស.អាចបន្តកិច្ចការជាសមាជិកក.ប.ស.។ តែប្រសិនបើយុវជនជាសមាជិកមិនមានភាពសកម្មជាសមាជិកទេ គ.គ.ស.អាចស្នើដល់នាយកសាលាអនុវត្តការជ្រើសរើសតំណាងយុវជនថ្មីសម្រាប់ចូលជាសាមជិកក.ប.ស.។

*ឃ. សុខភាពហិរញ្ញវត្ថុសាលារៀន*

សហគមន៍សាលារៀន គប្បីត្រូវមានមូលនិធិគ្រប់គ្រាន់សម្រាប់ចំណាយលើអាទិភាពរបស់សាលារៀនដែលបានកំណត់នៅក្នុងកម្មវិធីវិនិយោគ និងផែនការសមិទ្ធកម្ម៦ឆ្នាំ របស់សហគមន៍សាលារៀន។ ប្រភពមូលនិធិអាចមានមកពីថវិការដ្ឋ ថវិកាចំណូលពីកម្មវិធីបំណិនរកចំណូល កម្មវិធីធានារ៉ាប់រងសង្គមនិងអភិវឌ្ឍន៍សមត្ថភាពមូលនិធិមនុស្សធម៌ពីសហគមន៍ និងអ្នកមាននៅក្នុងសហគមន៍ឬពីខាងក្រៅ។

*ង. គម្រោងវិនិយោគរបស់សាលារៀន*

សហគមន៍សាលារៀនប្រើគំរូ នៃគម្រោងវិនិយោគសាធារណៈរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការរៀបចំគម្រោងវិនិយោគសហគមន៍សាលារៀន។ កិច្ចការនេះគប្បីចាប់ផ្តើមអនុវត្តនៅឆ្នាំទី៤ ឬទី៥នៃការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន។ ដំណើរនៃការរៀបចំក៏ត្រូវអនុវត្តតាមសេចក្តីណែនាំប្រតិបត្តិរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែរ។

*ច. កម្មវិធីធានារ៉ាប់រងនិងអភិវឌ្ឍសមត្ថភាពសាលារៀន*

គ.គ.ស.ឬក.ប.ស.គប្បីចាប់ផ្ដើមកម្មវិធីនេះ យ៉ាងយឺតណាស់នៅឆ្នាំទី៤។ មូលនិធិដើមទុនសម្រាប់រៀបចំកម្មវិធីនេះគឺបានមកពី កម្មវិធីបំណិនរកចំណូល និងការចូលភាគហ៊ុនពីសិស្ស គ្រូបង្រៀន នាយកសាលា និងសហគមន៍។ បរិមាណការប្រាក់គឺត្រូវពិភាក្សាអនុម័តជាមួយសហគមន៍ និងសមាជិក។ ការចំណាយគឺមានរៀបរាប់ពីខាងដើមហើយ។

## ៣. ការបន្តការសិក្សានៅមុខទៀតរបស់សិស្ស

*ក. ធ្វើការជាមួយសាកលវិទ្យាល័យលើផែនការផលសម្រេច៣ឆ្នាំ និងផែនការបង្រៀនវគ្គប្រចាំឆ្នាំ*

កិច្ចសហការណ៍ជាមួយសាកលវិទ្យាគឺត្រូវបានអនុវត្តនៅឆ្នាំទី៣។ ការវាយតម្លៃចុងឆ្នាំត្រូវផ្ដោតលើការសម្រេចក្រុមគោលដៅលទ្ធផលចុងឆ្នាំ ដូចមានការណែនាំអនុវត្ត និងគំរូនៅឆ្នាំទី៣ស្រាប់។ នាយកសាលាគប្បីពិភាក្សាជាមួយសាកលវិទ្យាល័យ បង្កើតកិច្ចសហការណ៍រវាងនិស្សិតមហាវិទ្យាល័យ និងសិស្សសាលាមធ្យមសិក្សាក្នុងការរៀបចំផែនការឆ្នាំសម្រាប់សិក្សារៀនសូត្របំណិននេះ។ សមត្ថភាពនិស្សិតក្នុង វិស័យកសិកម្មអាចជួយដោះស្រាយបញ្ហាដែលសិស្សសាលាមធ្យមសិក្សាបានជួបប្រទះ ក្នុងការអនុវត្តបំណិនកសិកម្មរបស់ខ្លួន និងធានាថាការអនុវត្តគឺបានជោគជ័យ។ ការជួយរបស់និស្សិតមហាវិទ្យាដល់សិស្សសាលមធ្យមសិក្សាគឺ ជាផ្នែកមួយនៃការអនុវត្តកិច្ចសន្យាសង្គមរបស់និស្សិតមហាវិទ្យាល័យផងដែរ។

*ខ. ផ្សារភ្ជាប់ដំណើរការសាលារៀនជាមួយយុទ្ធសាស្ត្រអនុវិស័យមធ្យមសិក្សា មហាវិទ្យាល័យអប់រំ និងសាកលវិទ្យាល័យ*

ចំណុចផ្សារភ្ជាប់គ្នានៃយុទ្ធសាស្ត្រសហគមន៍សាលារៀនជាមួយយុទ្ធសាស្ត្រអនុវិស័យមធ្យមសិក្សាមាន៖

ក) ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន និងនាយកសាលា

ខ) ការផ្សារភ្ជាប់រវាងអនុវិស័យមធ្យមសិក្សាជាមួយឧត្ដមសិក្សា ធានាការផ្ដល់សមត្ថភាពបំណិនរកចំណូលលើផ្នែកកសិកម្មនិងបច្ចេកទេស

គ) ការធ្វើបេសកកម្មគាំទ្រពីថ្នាក់ជាតិនិងក្រោមជាតិជួយសាលារៀន

ឃ) ការគ្រោងនិងអនុវត្តកម្មវិធីវិនិយោគថ្នាក់ជាតិ ជួយដល់ការពង្រីកវិសាលភាពអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន

ង) ការដំឡើងឋានៈនៃគ្រូបង្រៀននិងមន្ត្រីរាជការ

ច) ការបង្កលក្ខណៈឱ្យគ្រូបង្រៀន និងនាយកសាលាពូកែ ក្លាយជាគ្រូបង្រៀននៅមហាវិទ្យាល័យឬគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ និងឈរជើងនៅតាមសាលារៀនដើម្បីជួយដល់សាលារៀនផ្សេងទៀតនៅក្នុងក្រុងស្រុក ឬខណ្ឌ និងរាជធានី ខេត្ត។

*គ. ពិនិត្យឡើងវិញការរីកចម្រើនការចូលរៀនរបស់សិស្សនៅមហាវិទ្យាល័យ និងការចូលរួមក្នុងទីផ្សារការងារក្រោយពីរៀនចប់សាលាមធ្យមសិក្សា*

នាយកសាលាត្រូវមានការសម្របសម្រួលក្នុងការចងក្រង ឬ បង្កើតនូវ លេខទូរស័ព្ទ និងអ៊ីមែលសិស្ស និងត្រូវមានមន្ត្រីរដ្ឋបាលសម្រាប់តាមយកព័ត៌មានពីសិស្ស នៅពេលគេចេញទៅបន្តការសិក្សានៅមហាវិទ្យាល័យ ឬបន្តមុខរបរជាកសិករ ឬអ្នកផ្ដល់សេវាបច្ចេកទេស។ នាយកសាលាគប្បីមានការណែនាំដល់សិស្សទាំងអស់ឱ្យរក្សាការផ្ដល់ព័ត៌មានមកសាលារៀននៅរាល់ចុងឆ្នាំនីមួយៗ។ ព័ត៌មានទាំងនេះអាចមាន ១) កំពុងបន្តការសិក្សា ឬ រកចំណូល ២) មុខជំនាញសិក្សានៅមហាវិទ្យាល័យ ឬ រកស៊ី ៣) ការបញ្ចប់ការសិក្សាបរិញ្ញាបត្រ

និង ៤) បរិមាណចំណូលក្នុង១ឆ្នាំ ។ល។ ទិន្នន័យនេះមានប្រយោជន៍ណាស់សម្រាប់សហគមន៍សាលារៀន ដើម្បីយកទៅប្រើក្នុងការកែលម្អគុណភាពបង្រៀននិងរៀន និងគុណភាពដឹកនាំនិងគ្រប់គ្រងសាលារៀន។

## ៤. ការកសាងធនធានមនុស្ស

វត្ថុបំណងនៃការកសាងធនធានមនុស្សមាន ១) ដោះស្រាយការខ្វះធនធានមនុស្ស និង ២) អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ និងឋានៈរបស់គ្រូបង្រៀន និងនាយកសាលា។

**សម្រាប់ដោះស្រាយបញ្ហាខ្វះធនធានមនុស្សតែមានដូចខាងក្រោម៖**

ដំណោះស្រាយខ្វះគ្រូបង្រៀន៖ ក) សហការណ៍ជាមួយថ្នាក់ក្រោមជាតិផ្ទេរគ្រូពីសាលារៀនលើសគ្រូបង្រៀនមកបង្រៀននៅសាលារៀនខ្វះគ្រូបង្រៀនដែលនៅក្បែរ ខ) លើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនដែលកំពុងបង្រៀនខុសមុខវិជ្ជានៅមហាវិទ្យាល័យ អប់រំឬគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន គ) បញ្ជូនសិស្សមធ្យមសិក្សាពូកែតាមមុខវិជ្ជាមករៀនយកបរិញ្ញាបត្រគ្រូបង្រៀននៅមហាវិទ្យាល័យ ហើយរើសគេមកធ្វើជាគ្រូបង្រៀន និង ឃ) បើនៅតែខ្វះត្រូវបញ្ជូនទិន្នន័យមកក្រសួងដោះស្រាយ។

**សម្រាប់ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ និងឋានៈរបស់គ្រូបង្រៀន និងនាយកសាលា៖**

១) គ្រូបង្រៀន និងនាយកសាលាចូលរួមកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន និងនាយកសាលា កម្រិតបរិញ្ញាបត្រ និងអនុបណ្ឌិត
២) គ្រូបង្រៀននិងនាយកសាលាត្រូវធ្វើឱ្យមានការរីកចម្រើននៅថ្នាក់រៀននិងសាលារៀន បំពេញស្តង់ដាយុទ្ធសាស្ត្រសហគមន៍សាលារៀនរបស់ខ្លួន
៣) គ្រូបង្រៀននិងនាយកសាលា ត្រូវជួយសាលារៀនផ្សេងទៀត នៅក្នុងក្រុង ស្រុក ខណ្ឌ និង ខេត្តនិងរាជធានីរបស់ខ្លួនឱ្យបំពេញបាននូវស្តង់ដាយុទ្ធសាស្ត្រសហគមន៍សាលារៀនដូចខ្លួនដែរ
៤) ការគ្រប់គ្រងទិន្នន័យនិងព័ត៌មាន
ទិន្នន័យមានតួនាទីសំខាន់ណាស់សម្រាប់ការអភិវឌ្ឍសាលារៀន ការបង្រៀននិងរៀន។ ការផ្តុំទិន្នន័យច្រើចូលគ្នាបង្កើតបានជាព័ត៌មាន។ ការផ្តុំព័ត៌មានច្រើនចូលគ្នាបង្កើតបានជាចំណេះដឹង។

**ប្រភេទទិន្ន័យដែលសហគមន៍សាលារៀនត្រូវចងក្រងមានដូចខាងក្រោម៖**

១) គុណភាពទិន្នន័យ៖ មានភស្តុតាងបញ្ជាក់ថាកិច្ចការបានអនុវត្តតាមវិជ្ជាជីវៈ មានបច្ចុប្បន្នភាព បញ្ជាក់ការពិត មានម្ចាស់ពិតប្រាកដ
២) ទិន្នន័យដែលប្រទាក់ប្រទងគ្នា៖ គ្រប់ទិន្នន័យបានផលិត បានយកទៅប្រើប្រាស់ បង្ហាញពីភាពប្រទាក់និងផ្សារភ្ជាប់គ្នា ហើយដែលអាចទទួលយកបាន
៣) ទិន្នន័យបង្ហាញពីការផ្លាស់ប្តូរកម្រិតអភិបាលកិច្ច៖ ផលសម្រេចអប់រំ និងផលសម្រេចការសិក្សារបស់សិស្ស និងព័ត៌មានបញ្ជាក់ពីហេតុនិងផលនាំមកនូវការផ្លាស់ប្តូរ ឬមួយមិនមានការផ្លាស់ប្តូរ
៤) ទិន្នន័យបង្ហាញពីការផ្លាស់ប្តូរមានប្រសិទ្ធភាព៖ ការបង្រៀននិងរៀន ការដឹកនាំនិងការគ្រប់គ្រង
៥) ទិន្ន័យពីការចូលចិត្តរបស់អតិថិជន ពីចំណូលនិងការគាំទ្រ
៦) ទិន្នន័យនិងព័ត៌មានពី របៀបឬជម្រើសថ្មីៗដែលនាំឱ្យការអនុវត្តការងារកាន់តែប្រសើរ ព័ត៌មានដែលបញ្ជាក់ថាជម្រើសណាដែលល្អបំផុត
៧) ទិន្នន័យនិងព័ត៌មានពីការរៀនសូត្រ បញ្ជាក់ពីហេតុនិងផល នាំមកនូវការបណ្តុះគំនិតថ្មីៗ ដែលនឹងនាំមកនូវការរីកចម្រើនប្រសិនបើអនុវត្តវា

## ៥. និរន្តរភាពសហគមន៍សាលារៀន

កត្តាដែលនាំសហគមន៍សាលារៀនមាននិរន្តរភាពមាន ចរិយាដឹកនាំផ្តោតលើលទ្ធផលផ្អែកលើវប្បធម៌ និងគុណតម្លៃអង្គភាពសមត្ថភាពស្ថាប័ន និងសមត្ថភាពទាំង៤ដែលនាំ សមត្ថភាពមន្ត្រី សមត្ថភាពហិរញ្ញវត្ថុ និង ការអនុវត្តវប្បធម៌និងគុណតម្លៃអង្គភាព។ ។ ខ្លឹមសារខាងក្រោមនឹងរៀបរាប់ពី ចរិយាដឹកនាំ និង ព័ត៌មានត្រូវការសម្រាប់ឆ្លើយសំណួរដឹកនាំ៨ ដែលបញ្ជាក់នូវសមត្ថភាពទាំង៤ខាងខាលើ។

## ក- ចរិយាដឹកនាំផ្តោតលើលទ្ធផលផ្អែកលើវប្បធម៌ និងគុណតម្លៃអង្គភាព

អ្នកដឹកនាំត្រូវតែជាមនុស្សពូកែស្តាប់។ បើអ្នកអាចស្តាប់ អ្នកអាចសម្របសម្រួលមន្ត្រីពិភាក្សាគ្នាបាន។ បើអាចសម្របសម្រួលការពិភាក្សា អ្នកអាចសម្របសម្រួលឱ្យមនុស្សធ្វើការជាមួយគ្នាបាន។ បើអ្នកអាចសម្របសម្រួលឱ្យមនុស្សធ្វើការជាមួយគ្នាបាន អ្នកអាចដឹកនាំបាន។ បើអ្នកអាចបង្រៀនមន្ត្រីបាន អ្នកអាចដឹកនាំបានហើយ។ តែភាគច្រើនជាបញ្ហាគឺ អ្នកមិនស្តាប់តែម្តង។

អ្នកដឹកនាំជាមនុស្ស ដូចនេះអ្នកធ្វើតែអ្វីដែលអាចធ្វើបានតែប៉ុណ្ណោះ។ គ្រប់ការផ្លាស់ប្តូរគឺ ចាប់ផ្តើមពីមួយ មិនអាចលោភបានទេ។ ការផ្លាស់ប្តូរមួយនាំឱ្យមនុស្សចូលរួមកាន់តែច្រើន។ តែមនុស្សមានចិត្តបិសាច (Evil or Darkness) ឬគិតអវិជ្ជមានរហូតនៅតែមិនចូលរួម។ តែបើអ្នកអាចជួយមនុស្សមានចិត្តបិសាចម្នាក់បាន អ្នកអាចជួយមនុស្សគ្រប់ប្រភេទបាន។ ជួយមនុស្សបិសាចបានលុះណា អ្នកប្រាកដថាមានការអត់ធ្មត់ មានពេលវេលាគ្រប់គ្រាន់ និងរៀនដោះស្រាយបញ្ហាដោយឆ្លាតវៃបំផុត។

### ១០យុទ្ធសាស្ត្រក្លាយជាអ្នកដឹកនាំដែលសម្រេចលទ្ធផល

១០ យុទ្ធសាស្ត្រនេះបានសម្របពីទ្រឹស្តីនៃសៀវភៅ ការដឹកនាំមានមូលដ្ឋានលើលទ្ធផល របស់សាកលវិទ្យាល័យហាវ៉ាដ (Harvard Business School Press, Boston, www.hbsp.harvard.edu)។

ខាងក្រោមនេះជា១០យុទ្ធសាស្ត្រ៖

**១) ផ្តោតលើលទ្ធផលចង់បាន**

លទ្ធផលត្រូវចាត់ទុកជាអាទិភាពលើអ្វីទាំងអស់ លើកលែងតែកក្តីភាពចំពោះអង្គភាព និងសុជីវធម៌ និងគុណតម្លៃបុគ្គល។ ដូចនេះលទ្ធផលត្រូវតែបានកំណត់ន័យឱ្យច្បាស់ និងត្រូវបានយល់ដឹងដូចគ្នានៃគ្រប់មន្ត្រីម្នាក់ៗនៅក្នុងអង្គភាព។ អ្នកដឹកនាំអង្គភាព និងអ្នកគ្រប់គ្រងថ្នាក់ខ្ពស់មិនអាចកែប្រែក្រុមគោលដៅលទ្ធផលជាប់រហូតនៅពេលណាដែលលទ្ធផលនៅទ្រឹង ឬ ជិតសម្រេចនោះទេ។

**២) ជាអ្នកដឹកនាំ អ្នកត្រូវទទួលខុសត្រូវទាំងស្រុងចំពោះលទ្ធផល**

បរាជ័យក្នុងការទទួលខុសត្រូវនេះ នាំឱ្យមានភាពខ្សោយនៃសីលធម៌ និងបាត់បង់នូវឱកាសសម្រាប់ការផ្លាស់ប្តូរ និងកែលម្អឱ្យមានការរីកចម្រើន។ អ្នកដឹកនាំដែលបរាជ័យក្នុងការទទួលខុសត្រូវ ឬអន់ជាងនេះទៅទៀតគឺបោះមន្ត្រីចោលចូលក្រោមឡានក្រុង នឹងមិននៅជាអ្នកដឹកនាំសម្រាប់រយៈពេលយូរអង្វែងទេ។ នេះមិនមែនជាការដឹកនាំទេ តែជាលទ្ធិផ្តាច់ការនិយមហើយ។

**៣) ត្រូវមានទំនាក់ទំនងច្បាស់លាស់នូវលទ្ធផលរំពឹងទុក និងក្រុមគោលដៅទៅអ្នកគ្រប់គ្រង និងមន្ត្រី**

ការផ្តោតលើលទ្ធផលចង់បានគឺ ត្រូវកំណត់បានដោយ គោលបំណង និងក្រុមគោលដៅច្បាស់លាស់ ដល់គ្រប់មន្ត្រី ដូចនេះអាទិភាពត្រូវបានលាតត្រដាងច្បាស់លាស់ ហើយមន្ត្រីគ្រប់រូបអាចធ្វើការងារឆ្ពោះទៅទីចុងបញ្ចប់ដែលចង់បាន។ តើប៉ុន្មានដងហើយដែលអ្នកធ្វើកិច្ចការគម្រោង និងបានធ្វើឱ្យមានការរីកចម្រើននៅតែលើអ្វីដែលបានដឹងថាអ្នកដឹកនាំចង់បានអ្វីដែលផ្សេងពីនេះ? អ្នកដែលធ្វើឱ្យពេលវេលាខាតបង់ត្រូវបានបំផ្លាញនូវសីលធម៌ហើយ។ ជានិច្ចកាល ជានិច្ចកាល អ្នកត្រូវតែច្បាស់ថា អ្វីប្រាកដដែលជាសេចក្តីសង្ឃឹម ឬ លទ្ធផលចង់បាន។

**៤) កំណត់នូវកិច្ចការដែលអ្នកត្រូវធ្វើដោយបុគ្គលខ្លួនឯងដើម្បីសម្រេចលទ្ធផល**

ភាពជោគជ័យរបស់អ្នកនឹងត្រូវផ្អែកលើ តើអ្នកអនុវត្តកិច្ចការទាំងនេះដូចម្តេច បើទោះបីជាដំណើរអនុវត្តការងារឬការសម្រេចចិត្តរបស់មន្ត្រីផ្សេងនាំរំខានដល់កិច្ចការក៏ដោយ។ ការប្តេជ្ញាចិត្តរបស់អ្នកដើម្បីកែលម្អខ្លួននឹងកែលម្អស្មារតីរបស់មន្ត្រីអ្នក និងធ្វើឱ្យទំនាក់ទំនងទៅខាងលើ បង្ហាញថាអ្នកជាអ្នកដឹកនាំតាមរយៈ ធ្វើជាគំរូដល់មន្ត្រី។ ការដឹកនាំមិនជាអ្វីដែលត្រូវត្រួតត្រាអ្នកដទៃនោះទេ តែជាអ្វីដែលអ្នកត្រូវធ្វើគឺត្រួតត្រាខ្លួនអ្នក។

**៥) ចូលរួមក្នុងសកម្មភាពដែលនឹងជួយអ្នកផលិតលទ្ធផលបានប្រសើរ**

ភាពបន្ទាន់ជាវិធានការដំបូងត្រូវប្រើសម្រាប់សកម្មភាពអភិវឌ្ឍបុគ្គល ឬ អ្វីទាំងអស់។ វិធីគិតគឺ ខ្ញុំនឹងធ្វើកិច្ចការនេះ _______ ដូចនេះលទ្ធផលនេះ _______ នឹងត្រូវសម្រេច។ អនុវត្តតែកិច្ចការណាដែល ផលិតនូវផលសម្រេចដែលចង់បាន ផលសម្រេចដែលអាចវាស់វែងបាន បានហើយ។ អនុវត្តសកម្មភាពផ្សេងទៀតជាការនាំឱ្យខាតបង់ពេលវេលាហើយ ហើយវានឹងមិននាំឱ្យអ្នកសម្រេចបាននូវគោលបំណង និងវត្ថុបំណងគោលយោបាយបានឡើយ។

**៦) យល់ដឹង និងប្រើសមត្ថភាពអង្គភាពអ្នក**

អ្នកដឹកនាំសម្រេចលទ្ធផលត្រូវតែដឹងភាពខ្លាំង និងខ្សោយនៃមន្ត្រីគ្រប់រូប នៅក្នុងអង្គភាព ដែលនាំឱ្យអាចយកចំណេញពីអ្វីដែលកំពុងមាន និង លុបចោលនូវអ្វីខ្សោយ។ នេះមានរួមបញ្ចូលដែរនូវ អ្នកលក់ អ្នកផ្តល់សេវា និងអ្នកទិញសេវា។ អ្នកត្រូវតែដឹង ដឹងនូវអ្វីដែលកំពុងកើតមាន លើទិដ្ឋភាពមានជីវិតនៃមុខជំនួញ និងការងាររបស់អ្នក។

**៧) វាស់វែងឱ្យត្រូវ និងញឹកញាប់**

សារស្នូលនៃសៀវភៅ៖ ផលសម្រេចគឺសំខាន់ ហើយអ្នកត្រូវវាស់វែងវា។ ប៉ុន្តែមុននឹងវាស់វែងវា អ្នកត្រូវតែយល់ថាអ្វីដែលអ្នកត្រូវវាស់វែង និងវិធីប្រសើរបំផុតអ្វីដែលត្រូវអនុវត្តសម្រាប់វាស់វែង។ ប្រព័ន្ធគ្រប់គ្រងព័ត៌មានអាចឱ្យអ្នកសរសេររបាយការណ៍ តែវាមិនមានន័យថា វាមានតម្លៃច្រើនជាងអ្វីដែលជាក្រដាសបោះពុម្ពនោះទេ។ របាយការណ៍មិននាំឱ្យអ្នកក្លាយជាអ្នកដឹកនាំល្អនោះទេ។ តែអ្វីដែលអ្នកធ្វើ ជាមួយនឹងព័ត៌មានដែលនឹងជួយអ្នកដឹកនាំក្រុមរបស់អ្នកបាន ដើម្បីផលិតផលសម្រេចដែលចង់បាន នោះទើបអ្នកជាអ្នកដឹកនាំដែលល្អ ដែលផលិតនូវរបាយការណ៍ជួយអ្នកឱ្យដឹកនាំបាន។

**៨). ត្រូវធ្វើសកម្មភាពជាប់ជាបន្ត**

អ្នកដឹកនាំសម្រេចលទ្ធផលត្រូវតែ រៀបចំចាត់ចែង ទំនាក់ទំនង និងផ្តោតលើឱកាស ជាប់ជាប្រចាំ លើអ្វីដែលអង្គភាពត្រូវធ្វើ ជាជាងលើអ្វីដែលធ្វើមិនបាន។ អ្នកត្រូវលើកទឹកចិត្តមន្ត្រីផលិតលទ្ធផលតាមរបៀបនេះ។ បណ្តុះការចូលចិត្តសម្រាប់អនុវត្តសកម្មភាព។ អ្នកត្រូវតែជាអ្នកដែលបានទទួលស្គាល់ថាជាមនុស្ស ដែលនាំការងារសម្រេចបាន ការងារដែលត្រូវធ្វើ និងធ្វើតាមរៀបដែលត្រូវ។

**៩). ស្វែងរកព័ត៌មានត្រឡប់**

គេថាព័ត៌មានត្រឡប់ជា អាហារពេលព្រឹករបស់អ្នកពូកែ។ សាកសួរអ្នកគ្រប់គ្រង និងមន្ត្រីពីអ្វីដែលអ្នកកំពុងធ្វើ។ តើអ្វីដែលគេចង់បានដែលមិនត្រូវបានផ្តល់ឱ្យ? តើការផ្លាស់ប្តូរអ្វីដែលគេចង់ឃើញ? តើអ្វីដែលអ្នកកំពុងធ្វើមានដំណើរការល្អនៅក្នុងក្រសែភ្នែករបស់គេ? តើឧបករណ៍អ្វីដែលមន្ត្រីត្រូវការដើម្បីសម្រេចបាននូវលទ្ធផលចង់បាន? អ្នកដឹកនាំមានប្រសិទ្ធភាព ចង់បានព័ត៌មានពិតនិងត្រង់ ហើយយកព័ត៌មាននេះប្រើសម្រាប់កែលម្អការងារ។

**១០) ចៀសវាងទស្សនៈថាមានប្រយោជន៍សម្រាប់បុគ្គល**

សំណួរត្រូវសួរ៖ តើអ្វីជាកេរ្តិ៍ដំណែលរបស់ខ្ញុំសម្រាប់អង្គភាព? អ្វីទាំងអស់កំពុងធ្វើ ត្រូវបានមើលឃើញថាមានប្រយោជន៍អ្វីសម្រាប់អង្គភាព ហើយមិនមែនជាប្រយោជន៍របស់អ្នក។ មានប្រយោជន៍សម្រាប់បុគ្គល គឺ អ្នកប្រើទ្រព្យសម្បត្តិ ឬ ឧបករណ៍របស់អង្គភាពសម្រាប់ប្រយោជន៍បុគ្គលខ្លួន។

ការដឹកនាំវាច្រើនជាងបញ្ជីនៃអត្តចរិត។ វាច្រើនជាងការដឹងពីរបៀបប្រឈមជាមួយមនុស្ស។ វាច្រើនជាងការដឹងពីទស្សនៈវិស័យរបស់អង្គភាព។ វាច្រើនជាងទំនាក់ទំនងដែលប្រសើរ ការគ្រប់គ្រងការផ្លាស់ប្តូរ ការបណ្តុះនូវសុច្ចរិតភាព ធ្វើឱ្យអ្នកដទៃមានសមត្ថភាពនិងអំណាច កសាងក្រុមការងារ ការពង្រីកជម្រើសច្រើនមុខ ការពង្រីកការប្រើបច្ចេកវិទ្យា ឬមានភាពអត់ធ្មត់លើកិច្ចការនៅនឹងដៃ។ ការដឹកនាំដែលពិត ការដឹកនាំដែលមានប្រសិទ្ធភាព ព្រោះគឺជា ការផ្សារភ្ជាប់គ្នានូវអត្តចរិតទាំងអស់នេះ (និងអ្វីជាច្រើនផ្សេងទៀត) សម្រាប់សម្រេចបាននូវលទ្ធផលដែលប៉ងប្រាថ្នា។ អ្នកដឹកនាំធ្វើឱ្យកិច្ចការត្រូវធ្វើត្រូវបានអនុវត្ត។

តើអ្នកទាំងអស់គ្នាចង់ក្លាយជាមនុស្សថ្មីឬទេ? បើចង់ត្រូវ អនុវត្តកិច្ចការមួយបរាជ័យលើកទី១ មិនមែនជាបញ្ហាទេ តែត្រូវរៀនសូត្រពីវា។ ហើយដាច់ខាតមិនត្រូវធ្វើកិច្ចការដដែលខុសជាលើកទីពីរនោះទេ។ កិច្ចការមួយបរាជ័យ គឺ ដោយសារវាមិនបានបម្រើប្រយោជន៍ដល់សិស្សនិងប្រជាជនដូចនេះត្រូវស្តាប់សិស្សនិងប្រជាជន ព្រោះសិស្សនិងប្រជាជនជាអ្នកដឹងពីអ្វីដែលគេត្រូវការ ហើយគេអាចប្រាប់យើងពីរឿងនេះ។

## ខ- សមត្ថភាពធានានិរន្តរភាព និងច្បាយការណ៍រីកចម្រើនការអនុវត្តយុទ្ធសាស្ត្រ សហគមន៍សាលារៀន

ព័ត៌មានត្រូវការអាចឆ្លើយសំណួរដឹកនាំទាំង៨នៅខាងក្រោម ដែលជាព័ត៌មាន ឬ ភស្តុតាងសំខាន់បញ្ជាក់ពីសមត្ថភាពស្ថាប័ន សមត្ថភាពមន្ត្រី មត្ថភាបហិរញ្ញវត្ថុ និង ការអនុវត្បុជីវធម៌។

១) ស្ថាប័ន៖ យន្តការអង្គភាព និង យន្តការប្រតិបត្តិមានដំណើរការឥតខ្ចោះ ក្នុងការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន។ យុទ្ធសាស្ត្រមានការពិនិត្យនិងកែសម្រួលឡើងវិញទៀងទាត់។

២) សមត្ថភាពមន្ត្រី៖ មន្ត្រីមានចំណេះដឹងនិងបំណិនសព្វគ្រប់ បំពេញការងាររបស់ខ្លួន និងបង្ហាញគណនេយ្យភាពក្នុងការសម្រេចលទ្ធផល។

៣) ហិរញ្ញវត្ថុ៖ គ្រប់គ្រាន់សម្រាប់ជ្រើសរើសនិងថែរក្សាមន្ត្រីមានសមត្ថភាពឱ្យនៅធ្វើការងារពេញពេល និងសម្រាប់ការពង្រីកវិសាលភាពសេវាគ្របដណ្តប់ដែលអាចឆ្លើយតបនឹងតម្រូវការប្រទេសជាតិ។

៤) សុជីវធម៌៖ រក្សាខ្ជាប់ខ្ជួននូវការគោរពនិងអនុវត្ត វប្បធម៌ និងគុណតម្លៃរបស់ស្ថាប័ន ដើម្បីកសាងកេរ្តិ៍ឈ្មោះសាលារៀន និងគ្រូបង្រៀន។

## សរុបរបាយការណ៍ពីការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន

## ប្រចាំឆ្នាំ២០២១

**១) ភាពរីកចម្រើនការអនុវត្តចក្ខុវិស័យសហគមន៍សាលារៀន**

វត្ថុបំណងនៃការរីកចម្រើនការអនុវត្តចក្ខុវិស័យសហគមន៍សាលារៀន គឺ សិក្សាពីសំណួរថា តើសកម្មភាពដែលត្រូវអនុវត្តបានអនុវត្តដែរឬទេ។ សកម្មភាពដែលត្រូវអនុវត្តមាន បេសកកម្ម និងគោលបំណង យុទ្ធសាស្ត្រនិងការផ្លាស់ប្តូរ និង វប្បធម៌ និងគុណតម្លៃសហគមន៍សាលារៀន។

ក) តើអ្វីដែលត្រូវធ្វើបានធ្វើដែរឬទេ ហើយតើអ្វីដែលត្រូវធ្វើតែមិនបានធ្វើ

ខ) បង្ហាញពីការផ្លាស់ប្តូរដែលទទួលបានទាក់ទងនឹងបេសកកម្មនិងគោលបំណង យុទ្ធសាស្ត្រនិងការផ្លាស់ប្តូរ និង វប្បធម៌ និងគុណតម្លៃសហគមន៍សាលារៀន

**២) ភាពរីកចម្រើនការអនុវត្តស្តង់ដាសហគមន៍សាលារៀន**

វត្ថុបំណងនៃការអនុវត្តស្តង់ដាសហគមន៍សាលារៀនគឺ សិក្សាពីសំណួរថា តើអ្វីដែលបានធ្វើ តើធ្វើបានត្រឹមត្រូវដែរឬទេ។ ភាពត្រូវនៃការអនុវត្តគឺ ត្រូវស្តែងចេញថាមានប្រសិទ្ធភាព (បំពេញបាននូវស្តង់ដាសហគមន៍សាលារៀន) ថាមានប្រសិទ្ធផល (ការជួយដល់សហគមន៍សាលារៀនដ៏ទៃទៀត) និង ការចូលចិត្តរបស់អតិថិជនគ្រប់ប្រភេទ។

ក) ការបំពេញបាននូវក្រុមគោលដៅស្តង់ដា និងសូចនាករសហគមន៍សាលារៀន

ខ) បរិមាណ និងគុណភាពនៃការជួយដល់សហគមន៍សាលារៀនផ្សេងទៀត ទាំងសាលាមធ្យមសិក្សា បឋមសិក្សា និងមត្តេយ្យសិក្សា

គ) ការចូលចិត្តរបស់អតិថិជន មានសិស្សនិងមាតាបិតាសិស្ស សហគមន៍ គ.គ.ស. ឬ ក.ប.ស. គ្រូបង្រៀន នាយកនិងនាយករងសាលារៀន វិស័យបាក់ព័ន្ធ

**៣) មេរៀនពិសោធន៍ពីការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន**

វត្ថុបំណងនៃការស្វែងរកមេរៀនពិសោធន៍ពីការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន គឺ ការសិក្សាពីសំណួរថា តើមានអ្វីផ្សេងទៀតជាជម្រើសក្រៅពីកិច្ចការដែលត្រូវធ្វើទាំងនេះឬទេ ហើយតើមានជម្រើសណាមួយដែលល្អប្រសើរបំផុតនោះ និងថាតើមានអ្វីដែលប្រាកដនាំទៅរកនិរន្តភាពសហគមន៍សាលារៀនឬទេ។

គ) តើមានអ្វីផ្សេងទៀតជាជម្រើសក្រៅពីកិច្ចការដែលត្រូវធ្វើទាំងនេះឬទេ

ខ) ហើយតើមានជម្រើសណាមួយដែលល្អប្រសើរបំផុតនោះ

គ) ថាតើមានអ្វីដែលប្រាកដនាំទៅរកនិរន្តភាពសហគមន៍សាលារៀនឬទេ។

**៤) ចំណោទ និងសកម្មភាពដោះស្រាយ**

វត្ថុបំណងនៃការស្វែងរកចំណោទគឺ ការសិក្សាពីសំណួរដែលថា តើនៅមានឧបសគ្គនិងការរាំងស្ទាក់អ្វីទៀតដែលនាំមិនឱ្យសម្រេចបាននូវផលសម្រេចគ្រោងទុក ហើយតើមានអ្វីជាពិសេសដោះស្រាយនូវការរាំងស្ទាក់ទាំងនេះ និងថាតើអាទិភាពសកម្មភាពអ្វីដែលត្រូវផ្តោតសម្រាប់បញ្ចូលក្នុងផែនការកែលម្អសាលារៀននៅឆ្នាំបន្ទាប់។

ក) តើនៅមានឧបសគ្គ និងការរាំងស្ទាក់អ្វីទៀត ដែលនាំមិនឱ្យសម្រេចបាននូវផលសម្រេចគ្រោងទុក

ខ) ហើយតើមានអ្វីជាពិសេសដោះស្រាយនូវការរាំងស្ទាក់ទាំងនេះ

គ) ថាតើអាទិភាពសកម្មភាពអ្វី ឬកម្មវិធីវិនិយោគអ្វីដែលត្រូវផ្តោតសម្រាប់បញ្ចូលក្នុងផែនការកែលម្អសាលារៀននៅឆ្នាំបន្ទាប់។

## ឧបសម្ព័ន្ធ

**១ ស្តង់ដាគ្រូបង្រៀន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

# ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន

**នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ**

**ឆ្នាំ ២០០៩**

## មាតិការឿង

| លរ | ខ្លឹមសារ | ទំព័រ |
|---|---|---|
| ១- | សេចក្តីផ្តើម ...................................................... | ១-៤ |
| ២- | *រចនាសម្ព័ន្ធស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន* .................. | ៥ |
| ៣- | ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនជាអ្វី? ......................... | ៦ |
| ៤- | គោលបំណង .................................................... | ៦ |
| ៥- | ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនមានផលប្រយោជន៍អ្វីខ្លះ? | ៧ |
| ៦- | ចំណេះដឹងវិជ្ជាជីវៈ............................................. | ៨-១០ |
| ៧- | ការប្រតិបត្តិវិជ្ជាជីវៈ.......................................... | ១១-១៥ |
| ៨- | ការសិក្សាវិជ្ជាជីវៈ............................................. | ១៦-១៨ |
| ៩- | សីលធម៌វិជ្ជាជីវៈ ............................................. | ១៩-២១ |

សេចក្តីផ្តើម

ការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពសម្រាប់បម្រើប្រទេសជាតិមិនអាច កាត់ផ្តាច់ចេញពីការអប់រំបានឡើយ ។ វិស័យអប់រំរីកចម្រើន និងមានប្រសិទ្ធភាពទាមទារជាចាំ បាច់នូវកម្រិតសមត្ថភាពរបស់គ្រូបង្រៀនដែលក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងយក ចិត្តទុកដាក់ថៃបំប៉នជាប្រចាំ ។

ជាការពិត ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ វិស័យអប់រំ ក៏ដូចជាវិស័យ ផ្សេងទៀត ដែរត្រូវបានបំផ្លិចបំផ្លាញដល់កម្រិតសូន្យ ទាំងធនធាន មនុស្សទាំងមូលដ្ឋានសម្ភារបរិក្ខារ។

នៅថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៨០ ក្រសួងអប់រំ យុវជន និងកីឡាត្រូវ បានបង្កើតឡើងវិញ សាលារៀនគ្រប់កម្រិតសិក្សាក្នុងទូទាំងប្រទេសត្រូវបាន បើកទ្វារ ទទួលសិស្សានុសិស្ស ។ ទន្ទឹមនឹងនេះ ការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន ត្រូវបានចាប់ផ្តើមជាបន្ទាន់ដោយ មាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការជា អ្នកទទួលខុសត្រូវ ។

ក្នុងស្ថានភាពដ៏លំបាកនេះ ការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន ត្រូវបានចាប់ ផ្តើមពីការប្រមូលអតីតគ្រូបង្រៀន សិស្ស និស្សិត និងអ្នកមាន កម្រិតវប្បធម៌មួយចំនួន ដែលនៅ សេសសល់ពីការកាប់សម្លាប់មកបំប៉ន ចិត្ត-គរុកោសល្យ និងវិធីសាស្រ្តបង្រៀនរយៈពេលខ្លីនៅ តាមសាលាគរុកោសល្យ និង វិក្រឹតការរាជធានី-ខេត្តទាំង១៨ រួចបញ្ជូនទៅកាន់សាលារៀនចំណោះ ទូទៅក្នុងទូទាំង ប្រទេស។ ជាមួយគ្នានេះដែរ ការបំប៉នមន្ត្រីគ្រប់គ្រងអប់រំក៏ត្រូវបានចាប់ផ្តើម ផងដែរ តាមរយៈការបើកវគ្គបំប៉នប្រមូលផ្តុំ នៅសាលាជាន់ខ្ពស់កម្មាភិបាលគ្រប់គ្រង អប់រំដែល "បច្ចុប្បន្នជាវិទ្យាស្ថានជាតិអប់រំ "។

ចាប់ពីឆ្នាំ ១៩៨៣ ក្រសួងបានសម្រេចឱ្យសាលាគរុកោសល្យ និងវិក្រឹតការ រាជធានី ខេត្តទាំង ១៨ និងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម បណ្តុះបណ្តាលគ្រូបង្រៀន បឋមសិក្សា និងមត្តេយ្យសិក្សារយៈពេលវែងដោយ ចាប់ផ្តើមពីរូបមន្ត 7 +1 រហូតដល់ 12 +2 សម្រាប់ខេត្តវាលរាប ។ ដោយឡែកសម្រាប់ខេត្តភូមិភាគឦសាន កោះកុង និងតំបន់ដាច់ ស្រយាលមួយចំនួន ការបណ្តុះបណ្តាលគ្រូបឋមសិក្សាត្រូវបានចាប់ផ្តើមពីរូបមន្ត 3 +1 និងបច្ចុប្បន្ន 9 +2 និង 12 +2 ។

នៅឆ្នាំ ១៩៨៤ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន៦ ត្រូវបានបង្កើតឡើងសម្រាប់ បណ្តុះបណ្តាលគ្រូមធ្យមសិក្សា បឋមភូមិដោយផ្តើមពី រូមមន្ត 7+3 រហូតបច្ចុប្បន្ន 12 +2 ។

ដោយឡែកចំពោះការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម បានចាប់ផ្តើម ពីឆ្នាំសិក្សា 1980-1981 នៅសាលាគរុវិជ្ជាជាន់ខ្ពស់ ប៉ច្ចុប្បន្នជាសាកលវិទ្យាល័យ ភ្នំពេញ ដោយចាប់ផ្តើម ពីការបណ្តុះបណ្តាលរយៈពេលខ្លី 4 ខែ 7 ខែ 10 + 3 10 + 4 និងបរិញ្ញា +1 ដែលកំពុងបន្ត នៅវិទ្យាស្ថានជាតិអប់រំរហូតដល់បច្ចុប្បន្ន។

ក្នុងស្ថានភាពបែបនេះ យើងឃើញថាគុណភាពនៃការអប់រំមានការប្រែប្រួល មួយកម្រិត គួរឱ្យកត់សម្គាល់ ប៉ុន្តែវានៅមានលក្ខណៈដោយឡែកពុំអាចកំណត់នូវ កម្រិគុណភាពមួយបាន សមស្របនៅឡើយ ពោលគឺសមត្ថភាពរបស់គ្រូបង្រៀន ពុំស្មើគ្នា ។ ផ្តើមចេញពីនេះដើម្បីឱ្យ ការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន មានកម្មវិធី និងទិសដៅច្បាស់លាស់ដោយធានា បាននូវគុណភាពសមស្រប ទើបក្រសួងបានកសាងស្តង់ដារនេះឡើង ក្នុងគោលបំណងធ្វើឱ្យគ្រូ បង្រៀនយើងមាន សមត្ថភាពដល់ស្តង់ដារមួយសមស្របប្រហាក់ប្រហែលនឹងគ្រូបង្រៀនក្នុង
តំបន់។

**តើស្តង់ដារជាអ្វី** ?

ពិតហើយថា ការកំណត់កម្រិតបរិមាណ និងគុណភាពផលិតផលមួយ វាអាស្រ័យមួយ ផ្នែកធំទៅលើបុគ្គល ឬមនុស្សមួយក្រុមដែលគេសន្មតថា "ស្តង់ដារ "។ អ្នកខ្លះប្រើពាក្យស្តង់ដារ សម្រាប់កំណត់បរិមាណ។ ឧទាហរណ៍ៈ ធ្វើការ ៧ម៉ោង ក្នុងមួយថ្ងៃ ជាស្តង់ដារមួយ ។ ឯអ្នកខ្លះទៀតប្រេបីពាក្យស្តង់ដារ សម្រាប់កំណត់ គុណភាព។ឧទាហរណ៍ៈ គ្រូបង្រៀនមានគុណភាព លុះត្រាតែមានចំណេះដឹងលើមុខវិជ្ជា ឯកទេសមានទេពកោសល្យក្នុងការបង្រៀន។ ប៉ុន្តែស្តង់ដារ គុណភាពពិបាកនឹងកំណត់ ណាស់ ពោលគឺវាប្រែប្រួលទៅតាមអាជីពប្រភេទផលិតផល និងប្រទេសនីមួយៗ ។

ដូច្នេះពាក្យស្តង់ដារត្រូវបានប្រើប្រាស់សម្រាប់កំណត់គុណភាព និងបរិមាណ របស់វត្ថុ ឬ សមត្ថភាពរបស់មនុស្សទៅតាមមុខរបរ ឬអាជីពផ្សេងៗគ្នា ។

ការកំណត់ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនពីប្រទេសមួយទៅប្រទេសមួយ ផ្អែកលើ កត្តាច្រើន ដូចជា កត្តាបច្ចេកវិទ្យា សេដ្ឋកិច្ច សង្គម និងវប្បធម៌។ ដោយឡែក ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន នៅកម្ពុជាយើងបានកំណត់ជាបួនសមាសភាគគឺ ចំណេះដឹងវិជ្ជាជីវៈ ការប្រតិបត្តិវិជ្ជាជីវៈ ការសិក្សាវិជ្ជាជីវៈ និងសីលធម៌វិជ្ជាជីវៈ។ សមាសភាគនីមួយៗ មានអនុសមាសភាគជាច្រើន និងនៅក្នុងអនុសមាសភាគ នីមួយៗមានសេចក្តីពណ៌នាស្តង់ដារជាច្រើនបន្តទៀត ហើយនៅក្នុង សេចក្តីពណ៌នា ស្តង់ដារនីមួយៗមានបញ្ជក្នាំពីសមត្ថភាពលម្អិតតូចៗសម្រាប់ផ្ទៀងផ្ទាត់សមត្ថភាព ស្តែងឡើង។

ទោះបីស្តង់ដារបានលើកឡើងពីសមត្ថភាពសំខាន់ៗជាច្រើន តែយើងនឹង ជ្រើសរើសយក តែសមត្ថភាពមួយចំនួនដែល យើងចាត់ទុកថា ជាសមត្ថភាព អប្បបរមាប៉ុណ្ណោះ ឯសមត្ថភាព ផ្សេងទៀត នឹងត្រូវលើកយកមក បង្ហាញនាពេលអនាគត ។ ជាមួយគ្នានេះ យើងក៏មានជំនឿ ជាក់ផងដែរថា គ្រូបង្រៀនទាំងអស់មានសមត្ថភាពដល់ស្តង់ដារអប្បបរមាហើយ ។ ឧទាហរណ៍ៈ ការបង្ហាញពីការប្តេជ្ញាចិត្តនិងការចូលរួមចំណែកក្នុងវិជ្ជាជីវៈគ្រូបង្រៀន។ ឯស្តង់ដារផ្សេងទៀត យើងដឹងថាគ្រូប្រង្រៀនភាគច្រើនកំពុងធ្វើ។ ឧទាហរណ៍ ៈ ផ្តល់ បរិស្ថានសិក្សាដែល មានសុវត្ថិភាព និងធ្វើឱ្យសិស្សរៀនអស់ពីសមត្ថភាព។ ឯស្តង់ដារខ្លះទៀតមានតែគ្រូមួយចំនួន តូចទេ ដែលអាចធ្វើបាន ។ ឧទាហរណ៍ ៖ ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ និង ធនធានក្នុងបណ្ណាល័យ ដើម្បីធ្វើឱ្យ ការបង្រៀនមានប្រសិទ្ធភាព។

១- ចំណេះដឹងវិជ្ជាជីវៈ

គ្រូបង្រៀនមានចំណេះដឹងវិជ្ជាជីវសៈម្បូបែប ។ គាត់ត្រូវតែដឹងច្បាស់ពីតម្រូវការ សិក្សា សមត្ថភាពសិក្សា ប្រវត្តិសិក្សាច្បាស់លាស់ និងឥរិយាបថរបស់សិស្សម្នាក់ៗហើយក៏ យល់ដឹងផង ដែរពីប្រភេទគ្រួសារ និងកត្តាផ្សេងៗដែលមានឥទ្ធិពលដល់ការសិក្សារបស់ សិស្ស (យេនឌ័រ ពិការភាព និងក្រុមជនជាតិ ភាគតិច...)ព្រមទាំងយល់ដឹងពីវិធីដោះស្រាយ កត្តាទាំងនេះ។គ្រូបង្រៀនត្រូវមានការយល់ដឹងពីគោលនយោបាយអប់រំ ជាពិសេសគោលដៅ អប់រំជាតិ និងគោលបំណងអប់រំចំណេះទុទៅហើយពេញចិត្តក្នុងការអនុវត្តនៅសាលារៀន។ គ្រូ បង្រៀនយល់ ពីទ្រឹស្តីក្នុងការរៀបចំកិច្ចតែងការបង្រៀន ដូចជា វត្ថុបំណង វិធីសាស្ត្របង្រៀន និងអាច ជ្រើសរើសវិធីវាយតម្លៃលទ្ធផលសិក្សាបានសមស្រប។ គ្រូបង្រៀនយល់ពីខ្លឹមសារ កម្មវិធីសិក្សា ហើយមានសមត្ថភាពពន្យល់មេរៀនបានច្បាស់លាស់ និងយល់ពីរបៀបបញ្ជ្រាប ខ្លឹមសារពីមុខ វិជ្ជាមួយទៅមុខវិជ្ជាមួយផ្សេងទៀត ក្នុងន័យឱ្យសិស្សទទួលបានបំណិនជាច្រើន និងមានចិត្ត កាន់តែចង់រៀន។

គ្រូបង្រៀនត្រូវយល់ពីបរិស្ថានអប់រំក្នុងថ្នាក់រៀន និងក្នុងសហគមន៍ ពិសេសយល់ពី របៀបរៀនរបស់សិស្ស ភាពខុសគ្នារវាងទេពកោសល្យ ល្បឿន និងរបៀបសិក្សា ដែលមាន ឥទ្ធិពលដល់ការសិក្សារបស់សិស្ស។

| | | |
|---|---|---|
| សិក្សារបស់សិស្ស) | | |
| • ពណ៌នាបានពីតម្រូវការសិក្សារបស់សិស្ស<br>• ពណ៌នាបានពីសមត្ថភាពសិក្សារបស់សិស្ស<br>• ពណ៌នាបានពីប្រវត្តិសិក្សារបស់សិស្ស<br>• ពណ៌នាបានពីឥរិយាបថសិក្សារបស់សិស្ស។ | • ពិភាក្សានិងដាក់សកម្មភាពរៀនក្រៅថ្នាក់<br>• លទ្ធផលតេស្ត<br>• តេស្តឆ្នាំមុនៗ<br>• ភាពទៀងទាត់នៃការធ្វើកិច្ចការនិងការសិក្សា | • កញ្ចប់កិច្ចការក្រៅថ្នាក់<br>• សំណួរតេស្ត<br>• សៀវភៅតាមដាន<br>• លំហាត់ដាក់ឱ្យសិស្ស |
| ១.២ ដឹងច្បាស់ពីប្រភេទគ្រួសារ និងកត្តាផ្សេងៗ (ឧ.យេនឌ័រ សាវតារសង្គម សេដ្ឋកិច្ច ពិការភាព និង ក្រុមជនជាតិភាគតិច...) ដែលមានឥទ្ធិពល ដល់ការសិក្សា របស់សិស្ស និងដឹងពីរបៀបដោះស្រាយកត្តាទាំងនោះ | | |
| • ពណ៌នាបានពី យេនឌ័រ ដែលមានឥទ្ធិពលដល់ការសិក្សារបស់សិស្ស<br>• ពណ៌នាបានពីកត្តាសង្គម សេដ្ឋកិច្ច ដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស<br>• ពណ៌នាបានពីក្រុមជនជាតិ និងពិការភាព ដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស<br>• ពណ៌នាបានពីរបៀបដោះស្រាយកត្តាទាំងនោះ។ | ន័យដដែល<br><br>• ដោះស្រាយបញ្ហាតាមលទ្ធភាពជាក់ស្តែងនៃគ្រួសារ សាលា និងឃុំ | • ឧបករណ៍ដាក់ពាក្យសុំអាហារូបករណ៍ការប្រជុំជាមួយមាតា នាយកសាលា និង មេភូមិនិងមេឃុំ |

| | | | |
|---|---|---|---|
| ចំណេះដឹងអំពីខ្លឹមសារមេរៀន | ១.៣ យល់ដឹងពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះទូទៅ | | |
| | • ពណ៌នាបានពី គោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ និង គោលបំណងអប់រំចំណេះទូទៅ<br>• ពណ៌នាបានពី វិធីដែលធ្វើឱ្យបានសម្រេច គោលនយោបាយ អប់រំជាតិ គោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះទូទៅ ។ | ន័យដដែល | • ផែនការយុទ្ធសាស្ត្រ អប់រំ ស្តង់ដាវិជ្ជា ជីវៈគ្រូនិងនាយក<br>• ផែនការសកម្មភាព គោលនយោបាយគ្រូបង្រៀន និងគោលនយោបាយអភិវឌ្ឍវិជ្ជាជីវៈ |
| | ១.៤ យល់ដឹងពីទ្រឹស្តីនៃការសរសេរកិច្ចតែងការបង្រៀន | | |
| | • ពណ៌នាបានពីវត្ថុបំណង និងធាតុរបស់វាបានត្រឹមត្រូវ<br>• ពណ៌នាបានពីចំណុចសំខាន់ៗនៃគោលវិធីសិស្សមជ្ឈមណ្ឌល<br>• ពណ៌នាបានពីយុទ្ធវិធីវាយតម្លៃលទ្ធផលសិក្សារបស់សិស្សបាន សមស្រប<br>• ពណ៌នាបានពី សម្ភារបង្រៀន និងរៀនបានសមស្រប សម្រាប់ប្រើប្រាស់ ក្នុងការបង្រៀនមេរៀន។ | ន័យដដែល | • គំរូកិច្ចតែងការបង្រៀន<br>• កិច្ចតែងការបង្រៀនជាក់ស្តែងគ្រូបានរៀបចំ<br>• ស្តង់ដាឧបករណ៍វិទ្យាសាស្ត្រ |
| | ១.៥ យល់ដឹងពីខ្លឹមសារកម្មវិធីសិក្សា ហើយមានសមត្ថភាព ពន្យល់ និងបង្រៀនខ្លឹមសារមុខវិជ្ជាដែលមានក្នុងកម្មវិធីសិក្សាបានល្អ | | |
| | • គូសបញ្ជាក់ពីខ្លឹមសារសំខាន់ៗ នៃកម្មវិធីសិក្សាដែលត្រូវបង្រៀនបានច្បាស់លាស់<br>• បង្រៀនដើម្បីបង្ហាញពីការយល់ខ្លឹមសារច្បាស់លាស់។ | ន័យដដែល | • កម្មវិធីសិក្សា<br>• កិច្ចតែងការបង្រៀន<br>• មេរៀនសង្ខេប |
| | ១.៦ យល់ដឹងពីរបៀបបញ្ជ្រាបខ្លឹមសារ ពីមុខវិជ្ជាមួយទៅមុខវិជ្ជាផ្សេងទៀតក្នុងន័យឱ្យសិស្សទទួលបានបំណិនជាច្រើន និងមានចិត្តកាន់តែចង់រៀន | | |
| | • ពណ៌នាបានពីវិធីបញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅក្នុងមុខវិជ្ជាផ្សេងទៀត ដែលអាចជួយឱ្យសិស្ស រៀនកាន់តែប្រសើរឡើង និងចូលចិត្តរៀន។ | ន័យដដែល | • កម្មវិធីសិក្សាថ្មី<br>• បញ្ជីឈ្មោះកិច្ចការជាគម្រោង<br>• សេចក្តីណែនាំពីការបង្រៀនដោយមានការបញ្ជ្រៀបឆ្លងមុខវិជ្ជា |

<table>
<tr><td rowspan="6">ចំណេះដឹងពីរបៀបរៀនរបស់សិស្ស</td><td colspan="3">១.៧ យល់ដឹងពីបរិស្ថានសិក្សាក្នុងថ្នាក់រៀន និងសហគមន៍</td></tr>
<tr><td>• ពណ៌នាបានពី វិធីដែលធ្វើឱ្យប្រសើរឡើងនូវបរិស្ថានសិក្សា ក្នុងថ្នាក់រៀន ដើម្បីជួយឱ្យសិស្សរៀនកាន់តែពូកែ<br>• ពណ៌នាបានពី វិធីដែលធ្វើឱ្យសហគមន៍សាលារៀន ចូលរួមជួយសិស្សឱ្យរៀនកាន់តែពូកែ។</td><td>• ពណ៌នាបានពីស្តង់ដា សាលារៀនមានប្រសិទ្ធភាព</td><td>• ស្តង់ដាសាលារៀនមានប្រសិទ្ធភាព</td></tr>
<tr><td colspan="3">១.៨ យល់ដឹងពីរបៀបរៀនរបស់សិស្ស</td></tr>
<tr><td>ពណ៌នាបានពីទ្រឹស្តីមួយ ឬច្រើននៃរបៀបរៀនរបស់សិស្ស<br>ប្រាប់បានពីរបៀបរៀនផ្សេងៗគ្នារបស់សិស្ស ។</td><td>ពណ៌នាបាននូវអន្តរកម្មក្នុងថ្នាក់ ក្រៅថ្នាក់ ថ្នាក់រៀនបន្ថែម</td><td>ការងារក្រុម ក្លឹបសិក្សា លំហាត់ កិច្ចការផ្ទះ កិច្ចការគម្រោង ទស្សនៈកិច្ចសិក្សា ។ល។</td></tr>
<tr><td colspan="3">១.៩ យល់ដឹងពីភាពខុសគ្នានៃសម្បទា ល្បឿន និងរបៀបសិក្សារបស់សិស្ស</td></tr>
<tr><td>• ពន្យល់ពី ភាពខុសគ្នានៃសម្បទាសិក្សារបស់សិស្ស<br>• ពន្យល់ពីភាពខុសគ្នានៃល្បឿនសិក្សារបស់សិស្ស<br>• ពន្យល់ពីភាពខុសគ្នានៃរបៀបសិក្សារបស់សិស្ស។</td><td>ពណ៌នាបានពី កម្រិតនៃការចងចាំ ការយល់ ការអនុវត្ត ការវិភាគ ការវាយតម្លៃ និងការបង្កើត</td><td>Bloom Taxoទៃmy<br>ការសង្កេតសកម្មភាពសិស្សក្នុងថ្នាក់ ឬក្រៅថ្នាក់</td></tr>
</table>

២- ការប្រតិបត្តិវិជ្ជាជីវៈ

គ្រូបង្រៀនត្រូវរៀបចំកិច្ចតែងការបង្រៀនឱ្យបានច្បាស់លាស់ប្រកបដោយប្រសិទ្ធភាព ស្របតាមកម្មវិធីសិក្សាដោយផ្អែកលើ សៀវភៅសិស្ស សៀវភៅគ្រូ និងសម្ភារសិក្សាផ្សេងៗ ទៀត ដែលអាចរកបាន។ ដើម្បីគាំទ្រដល់កិច្ចតែងការបង្រៀន គ្រូបង្រៀនត្រូវរៀបចំសម្ភារ បង្រៀន និងរៀន ដើម្បីរិះរកមធ្យោបាយសម្រេចការសិក្សារបស់សិស្សប្រកបដោយប្រសិទ្ធ- ភាព ។ គ្រូបង្រៀនក៏ប្រើប្រាស់វិធីវាយតម្លៃលទ្ធផលសិក្សាផ្សេងៗគ្នា ដែលស្របទៅតាម តម្រូវការ និងទេពកោសល្យរបស់សិស្ស ។ គ្រូបង្រៀនត្រូវបញ្ជូនព័ត៌មានត្រឡប់ទៅ សិស្ស មាតាបិតា ឬអាណាព្យាបាល អំពីការអភិវឌ្ឍចំណេះដឹង បំណិន និងឥរិយាបថរបស់សិស្ស។

គ្រូបង្រៀនផ្តល់ឱ្យសិស្សគ្រប់រូប នូវបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព និងធ្វើឱ្យ មានការប្រឹងប្រែងអស់ពីសមត្ថភាព ហើយលើកទឹកចិត្តសិស្សឱ្យកាន់តែមានការទទួលខុសត្រូវ ចំពោះការសិក្សារបស់ខ្លួន។ គ្រូបង្រៀនត្រូវចូលរួមក្នុងការអភិវឌ្ឍសាលារៀន ដើម្បីគាំទ្រការ សិក្សា និងសុខុមាលភាពរបស់សិស្ស និងគ្រូបង្រៀនឯទៀត។

គ្រូបង្រៀនត្រូវចេះប្រើប្រាស់វិធីបង្រៀនឱ្យសម្បូរបែបដើម្បីសម្រួលដល់ការសិក្សា របស់សិស្ស និងសម្រេចបានវត្ថុបំណងមេរៀន ។ ម៉្យាងទៀតគ្រូបង្រៀនគួរមានសមត្ថភាព ផ្តល់ជាមធ្យោបាយឱ្យស្របទៅតាមរបៀបសិក្សា និងតម្រូវការផ្សេងៗគ្នារបស់សិស្សតាមរយៈ ការអនុវត្តវិធីបង្រៀនសមស្របសម្បូរបែប ដោយបង្កឱកាសឱ្យសិស្សចូលរួមគិតបានល្អិតល្អន់ និងដោយច្នៃប្រឌិត។ លើសពីនេះទៀត គ្រូបង្រៀនត្រូវចេះប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ និងធនធានក្នុងបណ្ណាល័យបើមានលទ្ធភាព ដើម្បីធ្វើឱ្យការបង្រៀន និងរៀនកាន់ តែមានប្រសិទ្ធភាព។

| ការធ្វើផែនការ និងការពិនិត្យតាមដាន វាយតម្លៃលទ្ធផលសិក្សា | ២.១ រៀបចំកិច្ចតែងការបង្រៀន កម្មវិធីបង្រៀន និងការវាយតម្លៃ<br>លទ្ធផលសិក្សាបានត្រឹមត្រូវ ហើយមានប្រសិទ្ធភាព | **និយមន័យ** | **ឧបករណ៍** |
|---|---|---|---|
| | • កិច្ចតែងការបង្រៀនមានសេចក្តីពណ៌នាបញ្ជាក់ ពីវត្ថុបំណងមេរៀនច្បាស់លាស់<br>• កិច្ចតែងការបង្រៀនមានសេចក្តីពណ៌នាបញ្ជាក់ពីរបៀបវាយតម្លៃ លទ្ធផលសិក្សាបានច្បាស់លាស់<br>• កិច្ចតែងការបង្រៀនមានសេចក្តីពណ៌នាបញ្ជាក់ពីសកម្មភាពគ្រូ<br>សិស្ស និងខ្លឹមសារមេរៀន ដើម្បីគាំទ្រវត្ថុបំណងមេរៀនបានច្បាស់លាស់<br>និងត្រឹមត្រូវតាមគោលការណ៍។ | ខ្លឹមសារកិច្ចតែងការបង្រៀន កម្មវិធីបង្រៀន និង<br>ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស | កម្មវិធីបង្រៀន កិច្ចតែងការបង្រៀន ការវាយតម្លៃលទ្ធផលសិក្សា |
| | ២.២ រៀបចំសម្ភារបង្រៀន និងរៀន ដើម្បីធ្វើឱ្យការសិក្សាសម្រេចបានលទ្ធផលល្អ | | |
| | • រៀបចំសម្ភាររៀនប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចបានលទ្ធផលសិក្សា ល្អរបស់សិស្ស<br>• រៀបចំសម្ភារបង្រៀនប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចបានលទ្ធផលសិក្សា ល្អរបស់សិស្ស។ | ប្រភេទសម្ភារៈរៀន និងបង្រៀន | សម្ភារៈរៀននិងបង្រៀន |
| | ២.៣ ប្រើប្រាស់វិធីសមស្របសម្បូរបែប សម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស | | |
| | • កសាងសំណួរតែស ដោយមានទម្រង់ និងរយៈពេលសមស្របសម្រាប់ សិស្សឆ្លើយ<br>• ជ្រើសរើសអាយតឹមតែស (Item Test)ពីសៀវភៅផ្សេងៗ ដែលមាន ទម្រង់សំណួរ និងរយៈពេលសមស្របសម្រាប់សិស្សឆ្លើយ<br>• បង្ហាញប្រាប់ពីអត្រាកំណែតែស និងការកែចម្លើយរបស់សិស្សបានត្រឹមត្រូវ<br>• កំណត់បានយ៉ាងច្បាស់ពី លទ្ធផលតែស ដើម្បីបង្ហាញពីប្រសិទ្ធភាពនៃ ការសិក្សារបស់សិស្ស។ | Bloom Taxoទemy | សំណួរតែស អាយតឹមតែស កំណែតែស និង លទ្ធផលតែស |

| | |
|---|---|
| | ២.៤ តាមដានការចូលរួម និងថែរក្សាកំណត់ត្រានៃភាពរីកចម្រើនរបស់សិស្ស |

| | | | |
|---|---|---|---|
| | • តាមដានការចូលរួមរបស់សិស្ស តាមរយៈការសង្កេត និងធ្វើកំណត់ត្រា<br>• ថែរក្សាកំណត់ត្រា ស្ដីពីការចូលរួមរបស់សិស្សក្នុងសកម្មភាពសិក្សា។ | ពណ៌នាបានពីសិស្សអសកម្ម និងកំណត់ត្រាត្រូវការ | សៀវភៅពិន្ទុសិស្ស និងថ្នាក់ បញ្ជីវត្តមាន |
| | ២.៥ ផ្ដល់ព័ត៌មានត្រឡប់ទៅសិស្ស មាតាបិតា ឬអាណាព្យាបាលសិស្សអំពីការអភិវឌ្ឍចំណេះដឹង បំណិន និងឥរិយាបថរបស់សិស្ស | | |
| | • ផ្ដល់ព័ត៌មានត្រឡប់ទៅសិស្ស តាមរយៈការនិយាយដោយផ្ទាល់ និង ដាក់មូលវិចារណ៍សមស្របជា លាយលក្ខណ៍អក្សរ នៅលើសន្លឹកកិច្ចការរបស់សិស្ស ពិសេសលើសៀវភៅទំនាក់ទំនង<br>• ផ្ដល់ព័ត៌មានត្រឡប់ទៅមាតាបិតាឬអាណាព្យាបាលសិស្សតាមរយៈ របាយការណ៍ ប្រចាំខែនិងទៅជួបផ្ទាល់ បើចាំបាច់។ | ពណ៌នាបានពីព័ត៌មានត្រឡប់ដែលត្រូវផ្ដល់ | សៀវភៅតាមដានការសិក្សា ការប្រជុំជាមួយមាតាបិតាសិស្ស |
| ការគ្រប់គ្រងបរិស្ថានសិក្សា | ២.៦ ផ្ដល់បរិស្ថានសិក្សាដែលមានសុវត្ថិភាព និងធ្វើឱ្យសិស្សទាំងអស់ខិតខំរៀនអស់ពីលទ្ធភាព | | |
| | • បង្ហាញឱ្យឃើញពីការគ្រប់គ្រងថ្នាក់រៀនមានប្រសិទ្ធភាព<br>• ជួយសិស្សឱ្យមានអន្តរកម្មវិជ្ជមានជាមួយសិស្សដទៃទៀត<br>• ផ្ដល់បរិស្ថានសិក្សាដែលធ្វើឱ្យសិស្សពង្រីកការសិក្សាបានច្រើន។ | ពណ៌នាពីការគ្រប់គ្រងថ្នាក់ របៀបរៀនជាបុគ្គល ដៃគូ ឬជាក្រុម | សេចក្ដីណែនាំពីការគ្រប់គ្រងថ្នាក់រៀន កិច្ចតែងការបង្រៀន ការសង្កេតថ្នាក់ |
| | ២.៧ ជួយសិស្សឱ្យបង្កើនការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួន | | |
| | • បង្ហាញពីវិធីដែលអាចជួយសិស្សឱ្យមានការទទួលខុសត្រូវចំពោះការសិក្សា របស់ខ្លួនកាន់តែខ្លាំង<br>• បង្ហាញកិច្ចការសិស្សជាឧទាហរណ៍ ដែលចង្អុលបង្ហាញការរៀនដោយខ្លួនឯង ( កិច្ចការសិស្ស គម្រោងតូចៗ របាយការណ៍ក្រុម។ល។ )។ | ន័យដដែល | កិច្ចការសិស្ស គម្រោង របាយការណ៍ក្រុម ឬ ក្លឹប |
| | ២.៨ ចូលរួមអភិវឌ្ឍន៍សាលារៀន ដើម្បីទ្រទ្រង់ការសិក្សា និងសុខុមាលភាពរបស់សិស្ស ព្រមទាំងសហសេវិក/មិត្តរួមអាជីព | | |
| | • ពណ៌នាបានពីសកម្មភាពអភិវឌ្ឍសាលារៀនដែលគាត់បានចូលរួម<br>• លើកជាសំណូមពរពីសកម្មភាពអភិវឌ្ឍន៍សាលារៀន។ | ខ្លឹមសារផែនការកែលម្អសាលារៀន | ផែនការកែលម្អសាលារៀន |

| | | | |
|---|---|---|---|
| វិធីបង្រៀន | ២.៩ ប្រើវិធីបង្រៀនផ្សេងៗ ដើម្បីជួយសម្រួលការសិក្សារបស់សិស្ស និងសម្រេចឱ្យបានតាមស្តង់ដារកម្មវិធីសិក្សារបស់ក្រសួង | | |
| | • បង្ហាញពីវិធីបង្រៀនផ្សេងៗ ដូចជាអនុមានរួម អនុមានញែក ការងារក្រុម  ពន្យល់បង្ហាញ ពីដំណោះស្រាយបញ្ហា។ល។<br>• ពណ៌នាបានពី វិធីបង្រៀនដែលមានប្រសិទ្ធភាពចំពោះមេរៀននីមួយៗ ដែលបានប្រើពិសេសអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបានត្រឹមត្រូវ<br>• ពន្យល់បានពីមូលហេតុដែលប្រើវិធីបង្រៀនទាំងនោះ។ | ន័យដដែល | សៀវភៅគ្រូ<br>កិច្ចតែងការបង្រៀន<br>ការបង្ហាញវិធីបង្រៀន<br>ថ្នាក់និទស្ស |
| | ២.១០ ផ្តល់មធ្យោបាយឱ្យស្របទៅតាមរបៀបសិក្សា  និងត្រូវការផ្សេងៗគ្នារបស់សិស្សតាមរយៈការអនុវត្ត វិធីបង្រៀនសមស្រប និងសម្បូរបែប | | |
| | • បង្ហាញពីវិធីបង្រៀនផ្សេងៗដែលផ្តល់ជាមធ្យោបាយឱ្យត្រូវទៅតាមរបៀបសិក្សា របស់សិស្សផ្សេងៗគ្នា (ឧ.ពូកែខាង ភាសា គណិត ចក្ខុ ចលនារាងកាយ តន្ត្រី ទាក់ទងរវាងបុគ្គល និងបុគ្គល។ល។)ពន្យល់បានពី វិធីបង្រៀនដែលផ្តល់ជាមធ្យោបាយ ឱ្យត្រូវទៅតាមរបៀបសិក្សា ខុសៗ គ្នារបស់សិស្ស។ | យុទ្ធវិធីបង្រៀន ទៅតាមរបៀបសិក្សាខុសៗគ្នារបស់សិស្ស | យុទ្ធវិធីបង្រៀន |
| | ២.១១ រៀបចំ និងផ្តល់ឱ្យសិស្ស នូវឱកាសសិក្សាពី ដំណោះស្រាយបញ្ហាដើម្បីចូលរួមគិតឱ្យបានល្អិតល្អន់ និងដោយច្នៃប្រឌិត | | |
| | • ជួយសិស្សឱ្យប្រើការគិតល្អិតល្អន់ ដើម្បីវិភាគចំណោទបញ្ហា<br>• ពណ៌នាបានពីរបៀប ដែលគាត់ប្រើការគិតដោយច្នៃប្រឌិត ដើម្បីដោះស្រាយ បញ្ហា។ | ន័យដដែល | លំហាត់អនុវត្ត<br>គម្រោងដើម្បីដោះស្រាយបញ្ហាក្នុងសហគមន៍ |
| | ២.១២ ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ បើមានលទ្ធភាព  ដើម្បីធ្វើឱ្យការបង្រៀន និងរៀនកាន់តែមាន ប្រសិទ្ធភាព | | |
| | • ពណ៌នាបានពីរបៀបប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ដើម្បីជួយ ឱ្យសិស្សមានចិត្តចង់រៀន<br>• ពណ៌នាបានពីរបៀបដែលគាត់ប្រើប្រាស់ចំណេះដឹង និងបំណិនបច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ ដើម្បីឱ្យសិស្សរៀនកាន់តែមានប្រសិទ្ធភាព។ | ន័យដដែល | មេរៀនក្នុងYou Tube<br>បន្ទប់កុំព្យូទ័រមានភ្ជាប់អ៊ិនធឺណែត |

### ៣- ការសិក្សាវិជ្ជាជីវៈ

យើងបានដឹងហើយថាគ្រូបង្រៀនគឺជាអ្នកលើកទឹកចិត្ត និងជាអ្នកធានាឱ្យសិស្សទទួល បានជោគជ័យក្នុងការសិក្សា ។ ដូច្នេះគាត់ត្រូវតែស្វ័យសិក្សា វាយតម្លៃការបង្រៀន ដើម្បី អភិវឌ្ឍខ្លួនឯង និងប្រើប្រាស់ផែនការសម្រាប់ដឹកនាំស្វ័យសិក្សាមុខវិជ្ជាជីវៈជាប្រចាំស្របតាម ជីវភាពរស់នៅជាក់ស្តែង ។ គ្រូបង្រៀនត្រូវអភិវឌ្ឍផ្នែកបច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ និងបំណិនផ្សេងៗសម្រាប់អនុវត្តក្នុងការប្រង្រៀន ហើយធ្វើឱ្យប្រសើរឡើងនូវបំណិនទំនាក់ ទំនងជាមួយ សិស្ស មាតាបិតា មិត្តរួមអាជីព និងជាមួយអ្នកផ្សេងៗទៀត នៅក្នុងសហគមន៍។ គ្រូបង្រៀនត្រូវលើកកម្ពស់កម្រិតសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនតាមរយៈការអាន និងស្រាវជ្រាវ ប្រភពឯកសារផ្សេងៗ ដើម្បីពង្រីកចំណេះដឹងឱ្យបានទូលំទូលាយក្នុងន័យកែលំអការបង្រៀន និងរៀន ហើយត្រូវមានទំនាក់ទំនងល្អជាមួយគ្រូដទៃទៀតក្នុងការសិក្សាវិជ្ជាជីវៈ។

| | | | |
|---|---|---|---|
| ស្វ័យសិក្សា | ៣-១ វាយតម្លៃការបង្រៀន ការអភិវឌ្ឍខ្លួន និងការប្រើប្រាស់ផែនការ សម្រាប់ដឹកនាំស្វ័យសិក្សាវិជ្ជាជីវៈបានទៀងទាត់ | និយមន័យ | ឧបករណ៍ |
| | • កំណត់បានពីចំណុចខ្លាំង ចំណុចដែលត្រូវកែលំអ និងតម្រូវការក្នុងមុខវិជ្ជាជីវៈ ផ្ទាល់ខ្លួន<br>• រៀបចំផែនការអភិវឌ្ឍន៍វិជ្ជាជីវៈផ្ទាល់ខ្លួនប្រកបដោយប្រសិទ្ធភាព<br>• ស្វែងយល់ពីការប្រើប្រាស់សៀវភៅកំណត់ត្រាប្រចាំថ្ងៃ ដើម្បីឆ្លុះបញ្ចាំងការងារ របស់ខ្លួន។ | ការគ្រប់គ្រងការអនុវត្តការងាររបស់មន្ត្រី | ស្វ័យវាយតម្លៃ<br>កិច្ចសន្យាលទ្ធផលប្រចាំឆ្នាំ<br>ផែនការអភិវឌ្ឍវិជ្ជាជីវៈ |
| | ៣-២ អភិវឌ្ឍចំណេះដឹងបច្ចេកវិទ្យាព័ត៌មាន សារគមនាគមន៍ និងបំណិន សម្រាប់អនុវត្តក្នុងការបង្រៀន និងរៀន | | |
| | • បង្កើនបំណិនដែលទាក់ទងនឹងវិជ្ជាជីវៈរបស់ខ្លួន ដោយបង្ហាញវិញ្ញាបនបត្រ ជាភស្តុតាង<br>• ពណ៌នាបានពីរបៀបប្រើប្រាស់ បច្ចេកវិទ្យាព័ត៌មាន សារគមនាគមន៍ សម្រាប់ ការស្រាវជ្រាវ និងរៀនដោយខ្លួនឯង<br>• មានឆន្ទៈស្វ័យសិក្សាស្រាវជ្រាវបំពេញបន្ថែម ទាំងចំណេះដឹងមូលដ្ឋាន ទាំងបច្ចេកទេសបង្រៀនថ្មីៗ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។ | ន័យដដែល | ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងការបង្រៀននិងការសិក្សា |

| | |
|---|---|
| | ៣-៣ ធ្វើឱ្យប្រសើរឡើង នូវបំណិនទំនក់ទំនង ជាមួយសិស្ស មាតាបិតា មិត្តរួមអាជីព និងសហគមន៍ |

| | | | |
|---|---|---|---|
| | • បង្ហាញពីបំណិនទំនាក់ទំនងជាមួយសិស្ស<br>• បង្ហាញពីបំណិនទំនាក់ទំនងជាមួយសហការី<br>• បង្ហាញពីបំណិនទំនាក់ទំនងជាមួយមាតាបិតា និងសហគមន៍។ | ន័យដដែល | ការប្រជុំជាមួយ<br>មាតាបិតានិងសិស្ស<br>ថ្នាក់និទស្ស |
| ការចូលរួមកែលំអការបង្រៀន | ៣-៤ អានអត្ថបទវិជ្ជាជីវៈគ្រូបង្រៀន និងស្រាវជ្រាវ ដើម្បីពង្រីកចំណេះដឹង ឱ្យបានទូលំទូលាយក្នុងន័យធ្វើឱ្យ ការបង្រៀនកាន់តែប្រសើរឡើង | | |
| | • ពណ៌នាបានពីអត្ថបទដែលគាត់បានអាន និងស្រាវជ្រាវហើយយកបទពិសោធ ក្នុងអត្ថបទនោះមក ជួយកែលំអការបង្រៀន<br>• ធ្វើថ្នាក់និទស្សន៍ដើម្បីបង្ហាញបទពិសោធដែលទទួលបានពីការអាន និងស្រាវជ្រាវ ឯកសារផ្សេងៗ ដល់មិត្តរួមអាជីព ដើម្បីបង្កើនសមត្ថភាព។ | ន័យដដែល | អត្ថបទវិជ្ជាជីវៈបានអាន<br>ថ្នាក់និទស្ស<br>ស្នាដៃគ្រូបង្រៀន |
| | ៣-៥ ធ្វើអន្តរកម្មជាមួយគ្រូដទៃទៀតក្នុងសកម្មភាពសិក្សាវិជ្ជាជីវៈផ្សេងៗ | | |
| | • ធ្វើបញ្ជីឈ្មោះសិក្ខាសាលា ឬវគ្គបំប៉នផ្សេងៗ ដែលបានចូលរួម<br>• ពន្យល់បានពីខ្លឹមសារសិក្ខាសាលា ឬវគ្គបំប៉ន ដែលបានចូលរួម ហើយបានផ្តល់បទ ពិសោធ ល្អៗ ដល់ការបង្រៀន និងរៀន។ | ន័យដដែល | វគ្គបំប៉នឬសិក្ខាសាលា<br>ថ្នាក់និទស្ស<br>ប្រើបច្ចេកវិទ្យាព័ត៌មាន |

៤- សីលធម៌វិជ្ជាជីវៈ

សីលធម៌វិជ្ជាជីវៈ គឺពាក់ព័ន្ធទៅនឹងគ្រប់ទិដ្ឋភាពទាំងអស់ក្នុងវិជ្ជាជីវៈគ្រូបង្រៀនដែល ជារួមមានការប្តេជ្ញាចិត្តបង្រៀនសិស្សប្រើប្រាស់មនសិការវិជ្ជាជីវៈប្រកបដោយគតិបណ្ឌិត និង មនាចំណេះដឹងគ្រប់គ្រាន់តាមក្រមសីលធម៌ វិជ្ជាជីវៈគ្រូបង្រៀន និងច្បាប់ស្តីពីការអប់រំ។

គ្រូបង្រៀនត្រូវគោរពពេលវេលាតាមភារកិច្ច មានវត្តមានជាប្រចាំនៅក្នុងសាលារៀន មានការស្លៀកពាក់សមរម្យ និងមានឥរិយាបថថ្លៃថ្នូរ។ គាត់គួរតែចូលរួមក្នុងគ្រប់សកម្មភាព ទាំងក្នុងនិងក្រៅម៉ោងទាំងអស់របស់សាលារៀនឱ្យបានសមស្របតាមករណីដែលអាចធ្វើបាន។

គ្រូបង្រៀនមានប្រសិទ្ធភាព គឺមិនរើសអើងសិស្ស ទោះនៅក្នុងកាលៈទេសៈណាក៏ដោយ ដូចជាបញ្ហាយេនឌ័រ ជនជាតិភាគតិច ពិការភាព ក្រីក្រ និងត្រូវចេះថែទាំសិស្ស ផ្តល់លទ្ធភាព ឱ្យសិស្សប្រើប្រាស់ធនធានឱ្យអស់ពីលទ្ធភាព ហើយយកចិត្តទុកដាក់ដលសិស្សឱ្យបានស្មើៗគ្នា រួចបង្ហាញពីភាពយុត្តិធម៌ក្នុងការត្រួតពិនិត្យលទ្ធផលសិក្សា។ នៅពេលទាក់ទងជាមួយសិស្ស គ្រូបង្រៀនត្រូវមានការគោរពសិស្សដោយមិននិយាយមើលងាយ ឬដាក់ទណ្ឌកម្មពួកគេតាម របៀបហិង្សាឡើយ។ គ្រូបង្រៀនប្រកាន់ចរិយាសម្បត្តិមានសុជីវធម៌ និងអាកប្បកិរិយាថ្លៃថ្នូរ សម្រាប់ធ្វើការសហការជាមួយសហការី និងមាតបាតិសាស្សិ ដើម្បីផលប្រយោជន៍សិស្សផ្តល់ ជាគំរូដល់សិស្សក្នុងការរស់នៅ និងរៀន

សូត្របានល្អ ពិសេសចេះលើកកម្ពស់ស្មារតីសិស្សឱ្យ រឹងប៉ឹង និងវិជ្ជមានហើយបង្កើតស្មារតីលះបង់ និងការរួមចំណែកចំពោះ សហគមន៍ទាំងមូល។

| *៤.១ បង្ហាញពីការយកចិត្តទុកដាក់ និងថែរក្សាសិស្សហើយជានិច្ចកាលធ្វើការ ដើម្បីប្រយោជន៍សិស្ស និងសង្គម* | **និយមន័យ** | **ឧបករណ៍** |
|---|---|---|
| និយាយទៅកាន់សិស្ស សហការីនិងអ្នកឯទៀតនៅក្នុងសហគមន៍ដោយ មានការគោរព និងលើកទឹកចិត្ត<br>បង្ហាញពីការគោរពសិទ្ធិកុមារមិនត្រូវនិយាយមើលងាយ ឬដាក់ពិន័យ សិស្សតាមរបៀបអំពើហិង្សា<br>ធ្វើការជាមួយសហការី និងសមាជិកសហគមន៍ឯទៀត ដើម្បីប្រយោជន៍ សិស្ស។ | ន័យដដែល | កិច្ចសន្យាលទ្ធផលប្រចាំឆ្នាំ និង ការវាយតម្លៃ<br>អត្ថបទស្មារដៃជួយសិស្ស<br>សិទ្ធិកុមារ<br>ស្តង់ដាទី៥សូចនាករពីភាពមិនប្រក្រតី |
| ៤.២ បង្ហាញពីការប្តេជ្ញាចិត្ត និងចូលរួមចំណែកក្នុងវិជ្ជាជីវៈគ្រូបង្រៀនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ | | |
| ទៅថ្នាក់រៀន និងចូលរួមព្រឹត្តិការណ៍ផ្សេងៗបានទៀងទាត់ និងទាន់ពេលវេលា<br>បង្ហាញពីអាកប្បកិរិយារាក់ទាក់ និងសប្បុរសធម៌<br>បង្ហាញពីការគោរពសិស្ស សហការី និងអ្នកឯទៀតក្នុងសហគមន៍<br>បង្ហាញពីអារម្មណ៍ជក់ចិត្ត និងគំនិតផ្តួចផ្តើមលើគ្រប់ទិដ្ឋភាពនៃសកម្មភាពវិជ្ជាជីវៈ<br>បង្ហាញពីចំណេះដឹងលើក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងច្បាប់ស្តីពីការអប់រំ។ | ន័យដដែល | វត្តមានគ្រូបង្រៀន<br>ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន<br>ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន<br>ច្បាប់ស្តីពីការអប់រំ |
| ៤.៣ បង្ហាញអាកប្បកិរិយាវិជ្ជមានជាគំរូប្រកបដោយសីលធម៌ និងមាន ទំនាក់ទំនង ដោយសុខដុម ជាមួយ សិស្ស និងសហគមន៍ | | |
| ស្លៀកពាក់សមរម្យ<br>បង្ហាញពីអារម្មណ៍វិជ្ជមានចំពោះសិស្ស និងអ្នកឯទៀត<br>បង្ហាញពីសមត្ថភាព ដើម្បីរក្សាទំនាក់ទំនងប្រកបដោយសុខដុម<br>ផ្តល់តម្លៃសីលធម៌ទៅមាតាបិតាសិស្ស និងអ្នកឯទៀត។ | ន័យដដែល | លិខិតជូនដំណឹងលេខ ៣០១<br>ការវាយតម្លៃកិច្ចសន្យាលទ្ធផលប្រចាំឆ្នាំ |

| ៤.៤ ប្រើប្រាស់ភាពយុត្តិធម៌ និងតម្លាភាព ក្នុងការប្រព្រឹត្តជាមួយសិស្ស សហសេវិក និងសមាជិកផ្សេងៗរបស់សហគមន៍ | | |
|---|---|---|
| បង្ហាញពីការស្មោះត្រង់ក្នុងមុខវិជ្ជាជីវៈដោយសំដែងនូវសុភាវធម៌ និងភាពមិនលំអៀង<br>ផ្តល់ឱកាសដល់សិស្សគ្រប់រូបមានលទ្ធភាពទទួលបាននូវពេវេលា និងធនធនាស្មើៗគ្នា ដោយមិនគិតពីភេទ ជនជាតិភាគតិច ឬអ្នកក្រីក្រ និងពិការភាព<br>វាយតម្លៃលទ្ធផលសិក្សាប្រកបដោយយុត្តិធម៌។ | ន័យដដែល | ធ្វើតេស្ត និងវាយតម្លៃលទ្ធផលសិក្សារបស់សិស្សប្រកបដោយយុត្តិធម៌ និងតម្លាភាព<br>សិស្សផ្តល់ចំឡើយតបពីការសិក្សានិងការបង្រៀន |